# មង្គលកថា

## មង្គលទី ១



រៀបរៀងដោយ

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

ព.ស.២៥៥៧

# មង្គលកថា

## មង្គលទី ១



រៀបរៀងដោយ

**ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី**

ព.ស.២៥៥៧

# ពុទ្ធប្បវត្តិសង្ខេប

ព្រះពុទ្ធមានព្រះនាមថាព្រះសទ្ធត្ថជាបុគ្គលប្រសើរបំផុតក្នុងលោក។ បិតាព្រះនាម សុទ្ធោទនៈ, មាតាព្រះនាម សិរិមហាមាយា, ព្រះនគរឈ្មោះ កបិលពស្តុ, សព្វថ្ងៃជាប្រទេសនេប៉ាល បែកចេញពីឥណ្ឌា, ប្រសូតនៅថ្ងៃសុក្រ១៥ កើត ខែវិសាខ ឆ្នាំ ច, ត្រកូលជាក្សត្រ សក្យវង្ស តំណពីព្រះបាទឱក្កាករាជ ប្អូនរួមបិតាព្រះនាម ព្រះនន្ទ មាតាផ្សេងគ្នា ព្រះជន្ម ១៦ ព្រះវស្សា មានអគ្គមហេសី ព្រះនាម ពិម្ពាយសោធរា ព្រះជន្ម ២៩ ព្រះវស្សា រាហុល ជាបុត្រប្រសូត និង ទ្រង់ចេញសាងផ្នួសព្រះជន្ម ២៩ ព្រះវស្សាត្រាស់ជាព្រះពុទ្ធព្រះជន្ម ៣៥ ព្រះវស្សា ព្រះនាមថា សមណៈគោតម ។

## ស្ថានទីគង់ចាំព្រះវស្សា

១-ឥសិបតនមិគទាយវ័ន, ២-៤ វត្តវេឡុវ័ន, ៥-កូដាគារសាលាមហាវ័ន ៦-មកុដបព៌តដែនមគធៈ, ៧-ឋានតាវត្តិង្ស, ៨-ភេសកឡាវ័ន ភគ្គរាជ-ជនបទ, ៩-ឃោសិតារាម, ១០-ព្រៃបាលិលេយ្យ ១១-ដងព្រៃជិតស្រុកសាលាលេយ្យកៈ, ១២-ក្រោមដើមស្ដៅជិតស្រុកវេរញ្ជា, ១៣-ចាលិកបព៌ត, ១៤-វត្តជេតពន ១៥- វត្តនិគ្រោធារាម, ១៦-ស្រុកអាឡវី, ១៧-វត្តវេឡុវ័ន១៨-១៩-ចាលិកបព៌ត ២០- វេឡុវ័ន, ២១-៤៤ វត្តជេតពន, ៤៥- ស្រុកវេឡុវគ្រាម ។

ព្រះជន្ម ៨០ ព្រះវស្សា ដាក់ព្រះជន្មាយុ និងបរិញ្ញានក្នុងនគរកុសិនារា នៅថ្ងៃអង្គារ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ ក្នុងវេលាជិតភ្លឺ ។ ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនា ៥.០០០ ព្រះវស្សា រហូតរៀងមក ។

# ទេវតាមួយម៉ឺនចក្រវាឡ ចុះមកអារាធនាសូមឱ្យព្រះអង្គសម្ដែងមង្គល




រឿងមង្គលនេះ ទេវតាមួយម៉ឺនចក្រវាឡប្រើពេលអស់១២ឆ្នាំរកមង្គល តែរកមិនឃើញលុះដល់ព្រះអង្គបានត្រាស់ដឹងក៏នាំគ្នាចុះមកទូលសួរព្រះអង្គ ។ ព្រះអង្គបានសម្ដែងមង្គលទាំង៣៨ប្រការមានកិរិយាមិនសេពគប់បុគ្គលពាលជាដើមរហូតដល់មានចិត្តក្សេមក្សាន្ត កាលចប់**ទេវតាសម្រេចជាព្រះអរហន្តរាប់សែនកោដិ ។ សម្រេចជាសោតាបត្តិផល សកទាគាមិផល អនាគាមិផល រាប់ប្រមាណមិនបាន ។**

# មង្គលកថា

## មង្គលទី ១

រៀបរៀងដោយ

**ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី**

**វត្តនិគ្រោធវ័ន  គល់ទទឹង**

ព.ស.២៥៥៧

-ឈ្មោះសៀវភៅ **មង្គលកថាមង្គលទី ១**

-រៀបរៀងដោយ **ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី**

-អនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័រដោយ **អគ្គធីរោ គង់ សុមិត្ត**

-**ចេញផ្សាយ** លើកទី ១

-**កាលបរិច្ឆេទ** ព.ស. ២៥៥៧

- **ទីកន្លែងធ្វើ** វត្តនិគ្រោធវ័ន"គល់ទទឹង" ភូមិកោះក្របី

សង្កាត់ព្រែកថ្មី ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

# អារម្ភកថា

មនុស្សនៅលើសកលលោកយើងនេះ សុទ្ធតែជាអ្នកប្រាថ្នានូវសេចក្តីសុខចម្រើន សិរីសួស្តី សុភមង្គល ភាពសុខដុមរមនាគ្រប់គ្នា ៗទាំងអស់ មិនចំពោះថា ជាតិសាសន៍ណាឡើយ មានអ្នកខ្លះព្រោះតែចង់បានសេចក្តីសុខ ចម្រើន សិរីសួស្តី សុភមង្គលដល់ជីវិតខ្លាំងពេកទៅ រហូតដល់ថ្នាក់ បន់ស្រន់បួងសួង អារក្សអ្នកតាទេវតា ព្រៃភ្នំ មន្តអាគមអូមអាមផ្សេង ៗនិងមានអ្នកខ្លះទៀតយល់ថា ទាល់តែមានទ្រព្យ សម្បត្តិស្តុកស្តម្ភ មានយសសក្តិខ្ពង់ខ្ពស់មានគេគោរពលើកតម្កើង បរិវារ ហែហម ចោមរោម ការពារគ្រប់ជំហានជាដើម ទើបជីវិតមាននៅសិរី សួស្តីសុភមង្គល ។ ទង្វើទាំងអស់នេះ វាផ្ទុយស្រឡះអំពីគន្លងនៃព្រះពុទ្ធសាសនាទាំងស្រុង ។

នៅក្នុងព្រះធម៌របស់ព្រះអង្គទាំង ៨៤,០០០ ព្រះធម្មខន្ធដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកទាំង ១១០ ក្បាល ដោយព្រះអង្គសម្តែងអស់រយៈពេល ៤៥ ព្រះវស្សានោះ ទាំងសម្តែងឋានទេវតា ឋានមនុស្សគ្រប់ស្រុកតំបន់ផ្សេង ៗនោះ មានព្រះសូត្រមួយឈ្មោះថា **មង្គលសូត្រ** ដែលជាព្រះសូត្រសម្តែងអំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ឧត្តុង្គឧត្តមនៃជីវិត ។ និងជាព្រះសូត្រ ដែលព្រះអង្គសម្តែងបើកបង្ហាញដល់មនុស្សនិង

ទេវតានាសម័យនោះ ។ ព្រះសូត្រនេះសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលប្រាថ្នានូវសិរីសួស្តីដល់ខ្លួនឯង ក្រុមគ្រួសារ ញាតិមិត្តបងប្អូន និងសង្គមជាតិទាំងមូល ។ ព្រោះព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងចំតែម្តង អំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ឧត្តមនៃជីវិត ។

នៅក្នុងអដ្ឋកថា **មង្គលជាតក** បានពោលអំពីព្រាហ្មណ៍ម្នាក់ អ្នកនៅក្នុងក្រុងនគររាជគ្រឹះ ជាអ្នកប្រកាន់មង្គលភ្ញាក់ផ្អើល មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាបុគ្គលមិច្ឆាទិដ្ឋិ មានភោគសម្បត្តិច្រើន ។

ក្នុងកាលនោះកណ្តុរបានកាត់នូវសម្ពត់សាដកមួយគូរបស់គាត់ ។ ដល់ពេលគាត់ត្រូវការឱ្យគេយកសំពត់នោះមក ទើបដឹងថាត្រូវកណ្តុរកាត់ជាច់ជាអន្ទើ ៗទៅហើយ ។ ព្រាហ្មណ៍គិតថា សំពត់នេះជាអពមង្គល បើទុកនៅទីផ្ទះនាំឱ្យមានការវិនាសយ៉ាងក្រៃលែង គឺវាដូចជាកាឡកណ្ណីមួយអីចឹង ទាំងមិនអាចឱ្យដល់បុត្រធីតា ឬទាសកម្មករផង ព្រោះសេចក្តីវិនាសនឹងកើតដល់អ្នកទទួលសំពត់នោះទៅគ្រប់គ្នា ត្រូវយកទៅចោលក្នុងព្រៃខ្មោចទើបបាន ។

ព្រាហ្មណ៍មិច្ឆាទិដ្ឋិ មិនឱ្យពួកទាសកម្មករយកទៅចោលទេ ដោយខ្លាចពួកទាសកម្មករ នាំយកនូវសំពត់នោះទៅប្រើប្រាស់ បណ្តាលឱ្យវិនាសត ៗគ្នា ។ ទើបព្រាហ្មណ៍ប្រាប់ឱ្យកូនប្រុសរបស់គាត់យកឈើឆ្កឹះទាក់នូវសំពត់នោះ នាំទៅចោលនៅព្រៃខ្មោច ហើយត្រូវងូតទឹកមុជឱ្យលិចក្បាលសឹមត្រឡប់មកផ្ទះវិញ ។

ព្រះបរមសាស្តាសម្មាសម្ពុទ្ធគង់ប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ជ្រាបឧបនិស្ស័យនៃព្រាហ្មណ៍ពីរនាក់ឪពុកនិងកូន ព្រះអង្គបានយាងទៅកាន់ព្រៃខ្មោចនោះ ហើយទ្រង់កាន់យកនូវសំពត់សាដកដែលកូនប្រុសរបស់ព្រាហ្មណ៍បានចោលហើយ ទាំងដែលកូន ប្រុសនោះឃាត់ព្រះអង្គមិនឱ្យចាប់ ដោយអាងថា ជារបស់ចង្រៃ ។ ព្រះបរមសាស្តាទ្រង់កាន់យកនូវសំពត់មួយគូរនោះ វិលត្រឡប់មកកាន់វត្តវេឡុវ័នវិញ ។

កាលដែលកូនប្រុសត្រឡប់មកជម្រាបរឿងរ៉ាវ ដល់ឪពុកហើយ ឪពុកនិងកូនក៏ប្រញាប់នាំគ្នាទៅវត្តវេឡុវ័ន ដើម្បីសូមឱ្យព្រះសម្មាសម្ពុទ្ធចោលនូវសំពត់នោះទៅវិញ ។ ព្រាហ្មណ៍គិតថា បើព្រះសមណគោតម ប្រើសំពត់នេះទៅ វាត្រូវធ្វើឱ្យលំបាកដល់ព្រះអង្គផង ត្រូវវិនាសវត្តវេឡុវ័នផង ម្ល៉ោះហើយគេនិងនិន្ទាស្តីថា

មកដល់យើងជាពិតប្រាដក ដូច្នេះ យើងត្រូវយកសំពត់សាដក ថ្មី ៗទៅថ្វាយដល់ព្រះសមណគោតម ដើម្បីសូមឱ្យព្រះសមណ គោតម បោលនូវសំពត់ចង្រៃនោះ ។

នៅពេលដែលព្រាហ្មណ៍ឪពុកនិងកូនប្រុសបានទៅដល់វត្ត ហើយ ព្រាហ្មណ៍ជាឪពុកបានក្រាបទូលព្រះសម្មាសម្ពុទ្ធដោយ សព្វគ្រប់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួក យើងមានឈ្មោះថាជាបព្វជិតដូច្នេះសំពត់ចាស់ ៗដែលគេបោល នៅព្រៃខ្មោច ឬគំនរសម្រាមជាដើម រមែងសមគួរដល់ពួកយើង ឯចំណែកព្រាហ្មណ៍ឯង មិនមែនទើបតែឥឡូវនេះទេ ពីជាតិមុន មក ក៏ធ្លាប់ប្រកាន់នូវលទ្ធិដូច្នេះដែរ ។

កាលដែលព្រាហ្មណ៍អារាធនាហើយ ព្រះអង្គទ្រង់ត្រាស់ សម្ដែងនូវរឿងរ៉ាវអតីតជាតិ មានសេចក្ដីប្រហែលគ្នានឹងបច្ចុប្បន្ន ដែរគ្រាន់តែកាលណោះ ព្រះបរមពោធិសត្វជាតាបសបានឈាន ហើយប្រោសព្រាហ្មណ៍ ឯព្រាហ្មណ៍ក៏បានយកព្រះបរមពោធិសត្វ ជាសរណៈ ។

នៅក្នុងបិដលេខ ៥៨ ទំព័រ ៣៨ **មង្គលជាតក** ព្រះ បរមសាស្ដាទ្រង់ត្រាស់ថា ៖

មង្គលទាំងឡាយក្តី ឧត្បាតទាំងឡាយក្តី សុបិនទាំងឡាយក្តី លក្ខណៈទាំងឡាយក្តី ដែលបុគ្គលណាបានផ្តាច់បង់ហើយ បុគ្គលនោះឈ្មោះថា អ្នកកន្លងផុតនូវទោសនៃមង្គល ( ភ្ញាក់ផ្អើល ) ។ ជាអ្នកគ្របសង្កត់នូវយុគក្កិលេស ( ក្រោធ ១ ការចងគំនុំ ១ ការមើលគុណ ១ និងការវាយឫកស្មើ ១ ទាំង ៤ នេះ ហៅថា យុគក្កិលេស ) និងយោគក្កិលេស ( កាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ ១ អវិជ្ជាយោគ ១ ) រមែងមិនមកកើតទៀតឡើយ ។

ដោយសេចក្តីថា បុគ្គលណាមិនប្រកាន់មង្គលភ្ញាក់ផ្អើល មិនប្រកាន់ឧត្បាត មិនប្រកាន់ការយល់សប្តិ មិនប្រកាន់លក្ខណៈជោគល្អ ឬជោគអាក្រក់ បុគ្គលនោះឈ្មោះថា ជាអ្នកកន្លងផុតនូវទោសនៃការប្រកាន់មង្គលភ្ញាក់ផ្អើល ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ឱ្យព្រាហ្មណ៍ឪពុក និងកូនបានសម្រេចសោតាបត្តិផល ។

នៅក្នុងអដ្ឋកថា**នក្ខត្តជាតក** បានពោលអំពីត្រកូលមួយនៅក្រៅក្រុងសាវត្ថី បានទៅស្តីដណ្តឹងកុលធីតាម្នាក់នៅក្នុងក្រុងសាវត្ថី ដើម្បីជាប្រយោជន៍ដល់កូនប្រុសរបស់ខ្លួន ។ គេបានសន្យាថ្ងៃកំណត់មកទទួលយកកូនកូនស្រីទៅកាន់ត្រកូលខាងប្រុស ប៉ុន្តែ

លុះដល់ថ្ងៃកំណត់ ត្រកូលខាងប្រុសគេបានសួរអាជីវកម្នាក់ដែលបានចូលទៅកាន់ត្រកូលរបស់ខ្លួនថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើនូវមង្គលមួយ តើនក្ខត្តឫក្សល្អដែរទេ ?

អាជីវកមានការខឹងក្រោធជាខ្លាំង ព្រោះគិតថាពួកអស់នេះមិនសួរយើងពីដំបូង ឥឡូវដល់ថ្ងៃទៅហើយទើបតែសួរ យើងនឹងផ្ដល់មេរៀនឱ្យគេម្ដង ដូច្នេះហើយក៏ពោលថា ថ្ងៃនេះមិនល្អទេ អ្នកទាំងអស់គ្នាកុំធ្វើមង្គលឡើយ បើចចេសចេះតែធ្វើនឹងមានការវិនាសធំ ។ ពួកមនុស្សក្នុងត្រកូលក៏ជឿអាជីវកនោះ ហើយក៏មិនបានទៅទទួលយកកូនស្រីក្នុងថ្ងៃហ្នឹងឡើយ ។

ចំណែកត្រកូលខាងស្រី បានចាត់ការមង្គលរៀបចំទទួលភ្ញៀវខាងប្រុស លុះមិនឃើញពួកគេមកតាមសន្យា ក៏លើកជីតាឱ្យទៅត្រកូលដទៃសម្រេចស្រេចបាច់ក្នុងថ្ងៃនោះដែរទៅ ។

ថ្ងៃស្អែកឡើង ត្រកូលក្រៅក្រុងក៏បាននាំគ្នាមកដល់សូមយកកូនស្រីពួកអ្នកក្នុងក្រុងក៏ពោលតិះដៀលថា ពួកអ្នកឯងសមនឹងឈ្មោះ អ្នកក្រៅក្រុងមែនហើយ ជាមនុស្សខ្វះសម្បត្តិរបស់មនុស្សល្អ ជាមនុស្សអាក្រក់ សន្យាគ្នាហើយ មើលងាយពាក្យសន្យា មិនមកតាមកំណត់ អញ្ជើញទៅតាមផ្លូវដែលអ្នករាល់គ្នា

មកនោះវិញទៅ ពួកយើងលើកកូនស្រីយើងឱ្យអ្នកផ្សេង ៗទៅហើយ ។

ពួកអ្នកក្រៅក្រុង ខំប្រឹងឈ្លោះនឹងអ្នកក្រុងអស់មួយសន្ទុះធំ លុះដឹងប្រាកដថា មិនបានកូនក្រមុំពិតហើយ ក៏នាំគ្នាត្រឡប់ទៅវិញតាមផ្លូវដែលមកនោះឯង ។

រឿងទាំងអស់នេះបានជ្រាបដល់ព្រះមានព្រះភាគ ព្រះអង្គទ្រង់ត្រាស់ព្រះជាតក ពីអាជីវកនោះធ្លាប់បំផ្លាញមង្គលរបស់គេតាំងពីជាតិមុនមកហើយ ។

ក្នុងជាតិមុននោះ អ្នកក្រុងពារាណសី ទៅស្ដីដណ្ដឹងកូនស្រីអ្នកជនបទហើយមិនទៅតាមសន្យា ព្រោះថាជឿតាមពាក្យកុហករបស់អាជីវក ។ រឿងក៏ងមានទំនងដូចគ្នា ខុសត្រង់ថាអ្នកជនបទបានតិះដៀលអ្នកក្រុងពារាណសីថា ពួកអ្នករាល់គ្នាឈ្មោះថាជាអ្នកក្រុង ប៉ុន្តែខ្វះនូវសម្បត្តិរបស់មនុស្សល្អ ព្រោះមិនគោរពពាក្យសន្យា ។ ក្នុងកាលណោះ ព្រះបរមពោធិសត្វជាបណ្ឌិត បានពោលថា ផ្កាយទាំងឡាយនិងមានប្រយោជន៍អ្វី ព្រោះការបានកូនស្រីក្រមុំជាឫក្សល្អស្រេចទៅហើយ មិនមែនទេ ? រួចហើយទើបព្រះបរមពោធិសត្វពោលនូវគាថា ៖

នៅក្នុងបិដកលេខ៥៨ ទំព័រ ២២ **នក្ខត្តជាតក** បណ្ឌិតបុរស ពោធិសត្វពោលថា ៖

**នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា**

**អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកាតិ ។**

ប្រែថា: ប្រយោជន៍រមែងកន្លងបង់នូវមនុស្សល្ងង់ដែលរាប់អាននូវនក្ខត្តឫក្ស ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

បណ្ដាបទទាំងនោះ បទថា **បដិមានេន្តំ** ដោយសេចក្ដីថា អ្នករង់ចាំមើល អធិប្បាយថា រវល់តែរង់ចាំមើល នក្ខត្តឫក្សនឹងមានក្នុងពេលនេះ នឹងមានក្នុងកាលឥឡូវនេះ ។

បទថា អត្ថោពាលំឧបច្ចគា ដោយសេចក្ដីថា ប្រយោជន៍ពោលគឺការបាននូវកូនក្រមុំ កន្លងផុតនូវមនុស្សល្ងង់ដែលជាអ្នកក្រុងពារាណសីនោះ ។

បទថា អត្ថោ អត្ថស្ស នក្ខត្តំ ដោយសេចក្ដីថា បុគ្គលស្វែងរកនូវប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯង ឈ្មោះថាជានក្ខត្តឫក្សរបស់ប្រយោជន៍ ។

បទថា កឹករិស្សន្តិតារកា ដោយសេចក្ដីថា តើដួងផ្កាយ

ទាំងឡាយក្នុងអាកាសក្រៅអំពីនេះ នឹងញុំាងប្រយោជន៍ដូចម្ដេចឱ្យសម្រេចបាន ។

ម្យ៉ាងទៀត នៅក្នុងបិដកលេខ ៤១, ទំព័រ ៤៧៥ ត្រង់ **មង្គលវគ្គ** ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាបុព្វណ្ហសម័យ( ពេលព្រឹក ) សត្វទាំងនោះ ឈ្មោះថា **មានបុព្វណ្ហសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាមជ្ឈន្តិកសម័យ( ពេលថ្ងៃ )សត្វទាំងនោះឈ្មោះថា **មានមជ្ឈន្តិកសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចាប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាសាយណ្ហសម័យ( ពេលល្ងាច )សត្វទាំងនោះឈ្មោះថា សាយណ្ហសម័យដ៏ល្អ ។

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ ។

ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជា) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថា ជាគ្រឿងបូជាល្អ ។

**បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ**

**បទក្ខិណំ មនោកម្មំ បណិធី តេ បទក្ខិណា ។**

(ក្នុងថ្ងៃនោះ) កាយកម្មឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន មនោកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នារបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន ។

**បទក្ខិណានិ កត្វាន លភន្តត្ថេ បទក្ខិណេ ។**

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្មគួរដល់សេចក្តីចម្រើនហើយ រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។

នៅក្នុង**មង្គល**សូត្រនេះ ព្រះអង្គបានសម្តែងមានទាំងអស់ ១០ ព្រះគាថា ។ ក្នុងមួយគាថា មាន ៣ ក៏មាន ៤ ក៏មាន ៥ ក៏មាន ។ ញែកជាមាតិកា មានទាំងអស់ ៣៨ ប្រការ ដែលខាង

ដើម ព្រះអង្គទ្រង់ត្រាស់សម្តែងថា **អាសេវនា ច ពាលានំ** មិនឱ្យសេពគប់បុគ្គលពាល រហូតដល់ខាងចុងថា **ខេមំ** ធ្វើចិត្តឱ្យឃ្លាតចាកអំពីកិលេស ដែលហៅថា **ចិត្តក្សេមក្សាន្ត** ។

**សរុបមក** បើបុគ្គលណាប្រាថ្នានូវសិរីសួស្តី សុភមង្គល ភាពសុខដុមរមនាដល់ខ្លួនដល់ក្រុមគ្រួសារជាដើមនោះត្រូវព្យាយាមបដិបត្តិទៅតាមមង្គលទាំង ៣៨ ប្រការនេះចុះ, ឬថា ត្រូវប្រព្រឹត្តឱ្យល្អទៅតាមផ្លូវកាយ វាចា ចិត្ត ឱ្យបានជានិច្ចចុះ ទុំះសិរីសួស្តី សុភមង្គល សេចក្តីសុខចម្រើន នឹងកើតមានដល់បុគ្គលនោះឯង ។

សៀវភៅ **មង្គលកថា** ដែលនិយាយអំពីមង្គលទាំង ៣៨ ប្រការនេះ ខ្ញុំព្រះករុណាសង្ឃឹមថា នឹងបានជួយតម្រែតម្រង់មាគ៌ាជីវិតនៃពុទ្ធបរិស័ទគ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈទាំងអស់ ឱ្យដើរឈានទៅរកសេចក្តីសុខ និងការរីកចម្រើននៃជីវិតទាំងនៅក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកនាយ រហូតដល់អស់នូវអាសវៈកិលេស ។

ម្យ៉ាងទៀត សៀវភៅនេះ បើសិនជាមានខុសត្រង់អក្ខរៈព្យញ្ជនៈភាសាបាលីសេចក្តីអធិប្បាយត្រង់ចំណុចណាមួយនោះ សូមមេត្តាខន្តី អភ័យទោសផង ។

ដោយអំណាចមហាកុសលចេតនា ដែលខ្ញុំមានចិត្តជ្រះថ្លាក្នុងព្រះសទ្ធម្មរបស់ព្រះអង្គ ខិតខំកសាងសន្សំព្យាយាមធ្វើសៀវ-ភៅនេះសូមបានជាឧបនិស្ស័យដ៏ល្អបានពាល់ត្រូវនូវព្រះនិព្វានក្នុងពេលដ៏ខ្លីខាងមុខនេះផងចុះតែបើមិនទាន់បានសម្រេចទេ សូមកើតជាតិណា ៗក៏ដោយ សូមកុំឱ្យស្គាល់ពាក្យថាអត់ ពាក្យថាគ្មាន ពាក្យថាក្រ ពាក្យថាលំបាក និងសូមឱ្យមានតែសិរីសួស្តី មិនមានសេចក្តីប្រមាទក្នុងជីវិត និងសូមឱ្យខ្ញុំមានបញ្ញាមោះមុតឆាប់ចាក់ធ្លុះនូវអរិយសច្ចធម៌ បានដល់នូវអមតដ្ឋាន **ក្នុងសាសនានៃព្រះសិរអារ្យមេត្រីយ៍**កុំបីអាក់ខានឡើយ,ម្យ៉ាងទៀតសូមឧទ្ទិសបុណ្យកុសលនេះ ជូនដល់បុព្វការីជនទាំងឡាយ ដែលបានបែកធ្លាយរាងកាយទៅ និងពួកសត្វទាំងឡាយផង សូមបាននូវសេចក្តីសុខ ចូរជាអ្នកបានសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ មួយអន្លើយដោយព្រះករុណាគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទ ។

**សូមអនុមោទនា !!!**

**ថ្ងៃ៧កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧**

**ភិក្ខុ សីលប្បញ្ញោ នៃ សុផល្លី**

# បញ្ជីមាតិកា

**មាតិកា** **មង្គលកថា** **ទំព័រ**


អារម្ភកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ក

**បឋមនិទ្ទេស** ... ... ... ... ... ... ... ... ... ... ... ... ... ... ១

ហេតុនៃការចំរើនទៅមុខ ... ... ... ... ... ... ... ... ... ... ២

ហេតុនាំឱ្យសិក្សាមង្គលសូត្រ ... ... ... ... ... ... ... ... ៣

ការកើតឡើងនៃមង្គលសូត្រ ... ... ... ... ... ... ... ... ៤

អ្វីគឺជាមង្គល ... ... ... ... ... ... ... ... ... ... ... ... ... ... ៦

ពណ៌នា ពហូ ទេវា ... ... ... ... ... ... ... ... ... ... ... ... ១៩

មង្គលសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ២៥

រាយមាតិកាមង្គលកថាទាំង ៣៨ ប្រការ ... ... ... ... ៣០

**មង្គលទី ១ មិនសេពគប់បុគ្គលពាល** ... ... ... ... ... ៣៥

ព្រឹត្តិកម្មដែលហៅថា គប់ គឺយ៉ាងណា ... ... ៣៥

រឿងភិក្ខុច្រើនរូប ... ... ... ... ... ... ... ... ... ... ... ... ៣៦

រឿងភិក្ខុអ្នកសេពគប់ភិក្ខុមួយរូប ... ... ... ... ... ... ៤៥

បុគ្គលបសាទសូត្រ ... ... ... ... ... ... ... ... ... ... ... ៥០

បុគ្គលពាលគឺជាអ្នកណា ... ... ... ... ... ... ... ... ... ... ៥៣

**មាតិកា** **ទំព័រ**

លក្ខណៈរបស់បុគ្គលពាល ... ... ... ... ... ... ... ... ... ៥៧
ប្រភេទនៃមិត្តសម្លាញ់ ... ... ... ... ... ... ... ... ... ... ... ៥៩
លក្ខណៈរបស់អមិត្ត៤ យ៉ាង ... ... ... ... ... ... ... ... ៦១
លក្ខណៈមិត្តគិតតែប្រយោជន៍ខ្លួន៤ យ៉ាង ... ... ... ៦៤
លក្ខណៈរបស់មិត្តល្អតែសម្តី៤ យ៉ាង ... ... ... ... ... ៦៦
លក្ខណៈមិត្តនិយាយចាក់បណ្តោយ៤ យ៉ាង ... ... ... ៦៩
លក្ខណៈមិត្តក្នុងផ្លូវវិនាស៤ យ៉ាង ... ... ... ... ... ... ៧០
ទោសនៃសេចក្តីជាមនុស្សពាល ... ... ... ... ... ... ... ៧៣
វិធីសង្កេតបុគ្គលពាល ... ... ... ... ... ... ... ... ... ... ៧៤
ជដិលសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ៧៦
ទោសនៃការសេពគប់បុគ្គលពាល ... ... ... ... ... ... ៩១
រឿងកូនសត្វសេក ... ... ... ... ... ... ... ... ... ... ... ... ៩២
រឿងដំរីឈ្មោះមហិឡាមុខ ... ... ... ... ... ... ... ... ១០០
រឿងសេះឈ្មោះបណ្ឌវៈ ... ... ... ... ... ... ... ... ... ... ១០៣
មកសជាតក ... ... ... ... ... ... ... ... ... ... ... ... ... ១០៥
ប្រភេទនៃបុគ្គលពាល ... ... ... ... ... ... ... ... ... ... ១១០
ពាលនិងបណ្ឌិត ... ... ... ... ... ... ... ... ... ... ... ... ... ១១២

**មាតិកា** **ទំព័រ**

គោលធម៌បដិបត្តិក្នុងជីវិតប្រចាំ … … … … … … ១១៦
សត្វសេពគប់រាប់អានគ្នាជាមិត្តភក្តិដោយធាតុ ១១៨
សេចក្តីផ្សេងគ្នារវាងបណ្ឌិតនិងបុគ្គលពាល … … ១៨០
ចង្កមសូត្រ … … … … … … … … … … … … … … ១១៩
ហីនាធិមុត្តិសូត្រ … … … … … … … … … … … … ១៣១
សតារបារទ្ធសូត្រ … … … … … … … … … … … ១៣៣
បឋមអស្សសូត្រ … … … … … … … … … … … … ១៣៩
ព្រះគាថាប្រារព្ធចំពោះបុរសម្នាក់ … … … … … … ១៤៥
ព្រះគាថាប្រារព្ធសទ្ធិវិហារព្រះមហាកស្សបៈ … … ១៤៨
ព្រះគាថាប្រារព្ធចំពោះអានន្ទ … … … … … … … … ១៥១
ព្រះគាថាប្រារព្ធចំពោះចោរទម្លាយបង្វិចទ្រព្យ … ១៥៣
ព្រះគាថាប្រារព្ធចំពោះឧទាយិត្ថេរៈ … … … … … ១៥៥
ព្រះគាថាប្រារព្ធចំពោះភិក្ខុអ្នកដែនបាឋេយ្យ … ១៥៧
ព្រះគាថាប្រាចំពោះសុប្បពុទ្ធកុដិ … … … … … … ១៥៨
ព្រះគាថាប្រារព្ធចំពោះបុរសអ្នកភ្ជួរស្រែ … … … … ១៥៩
ព្រះគាថាប្រារព្ធចំពោះនាយសុមនមាលាការ … ១៦០
ព្រះគាថាព្រះនាងឧប្បលវណ្ណាថេរនសត្វសេក … ១៦១

**មាតិកា** **ទំព័រ**

ព្រះគាថាប្រារព្ធចំពោះជម្ពុកាជីវក ... ... ... ... ... ១៦២
ព្រះគាថាប្រារព្ធចំពោះអហិប្រេត ... ... ... ... ... ... ១៦៥
ព្រះគាថាប្រារព្ធចំពោះសដ្ឋិកូដប្រេត ... ... ... ... ១៦៧
ព្រះគាថាប្រារព្ធចំពោះព្រះសុធម្មត្ថេរ: ... ... ... ... ១៦៩
ព្រះគាថាប្រារព្ធចំពោះព្រះវនវាសីតិស្សត្ថេរ: ... ១៧៣
សេចក្ដីផ្សេងគ្នារវាងបណ្ឌិតនិងបុគ្គលពាល ... ... ១៧៧
អច្ចយសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ១៧៨
តិកណ្ឌកីវគ្គទី៥ មិត្តសូត្រ ... ... ... ... ... ... ... ... ១៨១
ពួកសូត្រមិនស្រ្គោះក្នុងវគ្គមិត្តសូត្រ ... ... ... ... ... ១៨៤
បឋមខតសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ១៨៦
ទុតិយអតសូត្រ ... ... ... ... ... ... ... ... ... ... ... ... ១៩២
ជិគុច្ឆិតព្វសូត្រ ... ... ... ... ... ... ... ... ... ... ... ... ... ១៩៩
អយោនិសោសូត្រ ... ... ... ... ... ... ... ... ... ... ... ២០៨
ជនពាលដូចអមិត្ត បណ្ឌិតដូចញាតិ ... ... ... ... ... ២១២
តាបសឱ្យជម្ប្រូន្ទាដល់បុត្រ ... ... ... ... ... ... ... ... ២១៧
ភ័យឧបទ្រពនិងឧបស័គ្គកើតមានព្រោះជនពាល ២២២
អកិត្តិបណ្ឌិតមិនចង់ជួបប្រទះជនពាល ... ... ... ... ២៣១

**មាតិកា** **ទំព័រ**

វិនាសឬចម្រើនព្រោះការសេពគប់ ... ... ... ... ... ២៣៨
សេរិវតព្វសូត្រ ... ... ... ... ... ... ... ... ... ... ... ... ២៤៣
កិរិយាប្រកាន់ខ្លួននាំឱ្យធ្លាក់នរក ... ... ... ... ... ... ២៥១
ជនពាលតែងធ្វើខ្លួនមិនឱ្យមានសិរី ... ... ... ... ... ២៥២
ប្រវត្តិរបស់បូរណកស្សបៈ ... ... ... ... ... ... ... ... ២៥២
ប្រវត្តិរបស់មក្ខលិគោសាល ... ... ... ... ... ... ... ២៥៤
ប្រវត្តិរបស់និគ្រន្ថនាដបុត្រ ... ... ... ... ... ... ... ២៥៤
ប្រវត្តិរបស់សញ្ជ័យវេលដ្ឋបុត្រ ... ... ... ... ... ... ២៥៥
ប្រវត្តិរបស់បកុធកច្ចាយនៈ ... ... ... ... ... ... ... ... ២៥៥
ប្រវត្តិរបស់អជិតកេសកម្ពល ... ... ... ... ... ... ... ... ២៥៦
រឿងគ្រូសុនេត្រ ... ... ... ... ... ... ... ... ... ... ... ... ២៥៧
សេពគប់នូវបុគ្គលពាលមិនមែនជាមង្គល ... ... ២៥៨
អានិសង្សការមិនសេពគប់បុគ្គលពាល ... ... ... ២៦៤
មិត្តប្លមលប្រការ ... ... ... ... ... ... ... ... ... ... ... ... ២៦៦
គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ.... . ២៦៩

# មង្គលកថា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

### សូមនមស្ការចំពោះព្រះមានព្រះភាគ

### ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

# បឋមនិទ្ទេស

**មង្គល** *គឺជាអ្វី ?*

*អ្នកប្រាជ្ញទាំងឡាយ លោកតែងពោលថា* **មង្គល** *គឺជាការឈានទៅមុខ សេចក្តីសុខ សេចក្តីចម្រើន ។*

*នៅក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ភាគ១,ទំព័រ៦២៥ បានពន្យល់ថា ៖*

*ពាក្យថា* **មង្គល** *ប្រែថា សេចក្តីចម្រើន, សេចក្តីសុខ, ហេតុដែលនាំឱ្យកើតសេចក្តីសុខចម្រើន, ស្រីសួស្តី ។*

*ដូច្នេះពាក្យថា* **មង្គល** *ទើបរួមសេចក្តីមកថា គឺជាហេតុនៃ*

សេចក្តីសុខ និងសេចក្តីចម្រើនឈានទៅមុខនៃជីវិតជាព្រះសូត្រមួយ ដែលព្រះសម្មាសម្ពុទ្ធត្រាស់សម្តែងទុកជាគោលការណ៍ប្រព្រឹត្តបដិបត្តិ ដែលមានទាំងអស់ ៣៨ ប្រការ ។

## ហេតុនៃការចម្រើនទៅមុខ

សេចក្តីចម្រើនទៅមុខមាន ៤ ប្រការ

**១- សេចក្តីចម្រើនទៅមុខដោយសម្បត្តិទាំងឡាយ** ទាំងមនុស្សសម្បត្តិ ទិព្វសម្បត្តិ និងនិព្វានសម្បត្តិ ។

**២- សេចក្តីចម្រើនទៅមុខដោយបញ្ញា** ដែលជាគ្រឿងទម្លាយឧបសគ្គនៃជីវិត និងសេចក្តីអាក្រក់ផ្សេង ៗ ។

**៣- សេចក្តីចម្រើនទៅមុខដោយសេចក្តីល្អស្អាត** ទាំងតាមផ្លូវកាយ វាចា ចិត្តទាំងខាងដើម កណ្តាលនិងខាងចុង ។

**៤- សេចក្តីចម្រើនទៅមុខដោយប្រយោជន៍ទាំង ៣ គឺ**

- ប្រយោជន៍ក្នុងលោកនេះ **គឺមនុស្សលោក**
- ប្រយោជន៍ក្នុងលោកខាងមុខ **គឺស្ថានសួគ៌**
- ប្រយោជន៍យ៉ាងក្រៃលែង **គឺព្រះនិព្វាន ។**

កាលបើយើងប្រព្រឹត្តបដិបត្តិតាមមង្គលទាំង ៣៨ ប្រការនេះហើយ សូម្បីត្រឹមតែមង្គលណាមួយក៏ដោយ ក៏បានឈ្មោះថាប្រកបដោយហេតុដែលនាំមកនូវសេចក្តីចម្រើនទៅមុខ ៤ យ៉ាងនេះ និងធ្វើឱ្យយើងអាចបំពេញប្រយោជន៍ទាំងចំពោះខ្លួនឯង និងចំពោះក្រុមគ្រួសារ ដល់សង្គមនិងមនុស្សឯទៀត ។

## ហេតុដែលនាំឱ្យសិក្សានូវមង្គលសូត្រ

មានវត្ថុដែលគួរឱ្យគិត គឺ ការកើតមកជាមនុស្សត្រឹមតែការសិក្សាស្វែងរកចំណេះដឹង ដើម្បីឱ្យមានសតិបញ្ញាក្នុងការរកស៊ីចិញ្ចឹមជីវិតបានដោយងាយស្រួល មិនខ្វះខាតអាចស្វែងរកសេចក្តីសុខបាន ព្រោះការចេះដឹងនៅក្នុងលោកជាទូទៅ គ្រាន់តែដើម្បីចិញ្ចឹមមាត់ ចិញ្ចឹមផ្ទៃ គឺចិញ្ចឹមតែកាយប៉ុណ្ណោះ តែចំណែកចិត្តវិញគ្មានអ្វីចិញ្ចឹមសោះ ។

មនុស្សយើងមានចំណែកសំខាន់ ២ យ៉ាងគឺ**កាយ**និង **ចិត្ត** រូបកាយក៏ត្រូវការអាហារទៅចិញ្ចឹមដើម្បីឱ្យផុតរោគា គឺសេចក្តីស្រេកឃ្លាននិងឱ្យរាងកាយបានចម្រើនធំធាត់ឡើង ចំណែកចិត្ត

ក៏ដូចគ្នា ត្រូវការអាហារគឺព្រះធម៌មកចិញ្ចឹមដើម្បីបានជាគ្រឿងរំដោះឱ្យផុតអំពីសេចក្តីលោភ សេចក្តីខឹងក្រោធ សេចក្តីវង្វេងនិងដើម្បីលើកតម្កើងចិត្តឱ្យបានខ្ពស់ឡើង ហើយនឹងបានជួបប្រទះតែសេចក្តីសុខ ព្រមទាំងប្រកបការចិញ្ចឹមជីវិត បានដោយងាយស្រួល ។

ព្រោះហេតុនោះ យើងត្រូវតែសិក្សាព្រះធម៌ដោយចំពោះគឺសិក្សាមង្គលសូត្រនេះតែម្តង ព្រោះមង្គលសូត្រនេះមិនត្រឹម តែមានសេចក្តីសំខាន់ដូចពោលមកនេះទេ ថែមទាំងងាយស្រួល នៅក្នុងការប្រព្រឹត្តទៀតផង ។

## ការកើតឡើងនៃមង្គល

### (មូលហេតុកើតឡើងនៃមង្គលប្បញ្ហា)

ក្នុងការពណ៌នាមង្គលសូត្រនោះ ព្រោះហេតុដែលខ្ញុំតាំងមាតិកាទុកថា កាលនឹងពណ៌នាសេចក្តីនៃបាឋៈមានអាទិថា **ឯវំ** ដោយប្រការផ្សេង ៗនិងពោលដល់សមុដ្ឋានមូលហេតុដូច្នេះ នេះជាឱកាសដែលនឹងពោលដល់សមុដ្ឋានមូលហេតុនោះ ដូច្នោះនឹងពោលដល់សមុដ្ឋាន មូលហេតុកើតមង្គលបញ្ហាជាមុនសិន ខាង

ក្រោយ ទើបនឹងពោលពណ៌នាសេចក្ដីនៃបទគាថាទាំងនោះ ។ តើសមុដ្ឋានមូលហើយឱ្យកើតមង្គលបញ្ហាយ៉ាងដូចម្ដេច ។

បានឮមកថា ក្នុងជម្ពូទ្វីប មហាជនជុំនុំគ្នាក្នុងទីនោះ ៗ ដូចជាជិតទ្វារនគរ សភានៃកន្លែងរាជការជាដើម ប្រគល់ទ្រព្យសម្បត្តិមាស ប្រាក់ឱ្យគេនិទានរឿងផ្សេង ៗដូចជារឿងនាំនាងសីតាមកជាដើម ។ រឿងមួយ ៗនិទានដល់ទៅ ៤ ខែទើបចប់ ។ ក្នុងទីនោះថ្ងៃមួយ រឿងមង្គលបញ្ហាក៏កើតឡើងថា **អ្វីហ្ន៎ជាមង្គល** ។ វត្ថុដែលឃើញឬ**ជាមង្គល** រឿងដែលបានឮឬ**ជាមង្គល** ឬថា រឿងដែលដឹង**ជាមង្គល** អ្នកណាហ្ន៎ ដឹងនូវមង្គលដូច្នេះ ។

យើងសាកក្រឡេកមើលទៅក្រោយ ប្រជាជនជម្ពូទ្វីប មាននៅរោគម្យ៉ាង គឺរោគរាលដាលយ៉ាងរហ័ស មនុស្សសម័យនោះ កំពុងភ្ញាក់ខ្លួនក្នុងការស្វែងរកបញ្ហាដែលជាប់ទាក់ទិនជាមួយជីវិត ដូចជាថាមនុស្សកើតមកអំពីណា, ពេលស្លាប់ទៅកាន់ទីណា ធ្វើយ៉ាងណា ទើបមានសេចក្ដីសុខក្នុងជីវិត, ធ្វើយ៉ាងណា ទើបអាចមានសេចក្ដីសម្រេចក្នុងការងារជាដើម មានការប្រជុំគ្នាតាមសួនសាធារណៈខ្លះ ត្រង់ទ្វារក្រុងខ្លះ ត្រង់ទ្វារទាំងបួនខ្លះ ដើម្បី

ពិភាក្សានៅក្នុងបញ្ហានេះ ។

កាលបើមានអ្នកពិភាក្សាចូលមកច្រើន ក៏បានគំនិត ច្រើននាក់, ម្នាក់ ៗក៏បានផ្សព្វផ្សាយការយល់ឃើញរបស់ខ្លួន អ្នកណាមានគេជឿតាមច្រើន អ្នកនោះក៏បានក្លាយទៅជាអាចារ្យម្នាក់ដែលមានកូនសិស្សច្រើន ។

ខណៈដែលការប្រជុំកំពុងប្រព្រឹត្តឡើង ការពិភាក្សាកំពុងប្រព្រឹត្តទៅយ៉ាងស្រួល បញ្ហាផ្សេង ៗ មានការជំទាស់គ្នាដោយវាទះផ្សេង ៗ ។

ដោយមិនមានអ្នកណាអាចដោះស្រាយបាន ពេលនោះមានបុរសម្នាក់បានចូរទៅក្នុងវង្សពិភាក្សា ហើយបានដាក់សំនួរមួយថា

## មង្គលគឺជាអ្វី?

កាលនោះ មានបុរសម្នាក់ឈ្មោះ **ទិដ្ឋមង្គលិកៈ** ( កាន់យកវត្ថុដែលឃើញជាមង្គល ) ពោលថាខ្ញុំស្គាល់ច្បាស់នូវមង្គល ។

**វត្ថុដែលឃើញជាមង្គលក្នុងលោក ។ រូបដែលសន្មតិថាជាមង្គលដ៏ក្រៃលែង ឈ្មោះថា ទិដ្ឋៈ ។ រូបដូចម្តេចទៅមនុស្សពួកខ្លះក្នុងលោកនេះភ្ញាក់ពីព្រឹក ឃើញសត្វកង្អែនខ្លះឃើញដើម**

ញោទិ៍ខ្លះ ឃើញស្ត្រីមានគភ៌ខ្លះ ឃើញកូនក្មេងតាក់តែងប្រដាប់កាយ ទូលក្អមពេញដោយទឹកខ្លះ ត្រីឆ្អិនក្រហមស្រុទ្ធខ្លះ សេះអាជានេយ្យខ្លះ រថទឹមដោយសេះខ្លះ គោឈ្មោលខ្លះ គោញីខ្លះ គោក្រហមខ្លះ ឬក៏ឃើញសូម្បីរូបដទៃឯណាប្រាកដដូច្នោះ ដែលសន្មតិថា ជាមង្គលដ៏ក្រៃលែង រូបសូម្បីឃើញនេះ ហៅថា **ទិដ្ឋមង្គលិកៈ** ។

៦. មនុស្សពួកខ្លះ ក៏រមែងទទួលពាក្យរបស់គេ ពួកខ្លះក៏មិនព្រមទទួល ក៏បដិសេធនឹងគេ ។

ពេលនោះ **ទិដ្ឋមង្គលិកៈ**និយាយចប់ មានបុរសម្នាក់ទៀត ម្នាក់ទៀតឈ្មោះ **សុតមង្គលិកៈ** ក៏និយាយឡើងថា អ្នកអើយ ឈ្មោះថា**ភ្នែក**រមែងឃើញរបស់ស្អាតខ្លះមិនស្អាត ខ្លះរបស់ល្អខ្លះមិនល្អខ្លះ របស់ពេញចិត្តខ្លះ របស់មិនពេញចិត្តខ្លះ ប្រសិនបើរូបដែលអ្នកនោះ ឃើញគប្បីជាមង្គលពិត ក៏នឹងគប្បីជាមង្គលទាំងអស់ដែរ ព្រោះហេតុនោះ រូបដែលឃើញមិនជាមង្គល ។ ក៏ប៉ុន្តែសម្លេងដែលបានឮឯណាទេជាមង្គល ។ សម្លេងដែលគេសន្មតិថា ជាមង្គលក្រៃលែង ។ ឈ្មោះថា **សុតៈ** ដូចម្តេចទៅ ។

មនុស្សពួកខ្លះក្នុងលោកនេះ ក្រោកឡើងពីព្រឹក បានឮ

សំឡេងដូច្នេះថា ចម្រើនហើយ កំពុងចម្រើនពេញ ស គ្រោកអរ សិរីចម្រើនដោយសិរី ថ្ងៃនេះឫក្សល្អ យាមល្អ ថ្ងៃល្អ មង្គលល្អ ឬសំឡេងដែលសន្មតិថា មង្គលដ៏ក្រៃលែង ។ សំឡេងដែលបាន ឮនេះ ហៅថា **សុតមង្គល** ។

៦. ពួកខ្លះក៏រមែងព្រមទទួលពាក្យរបស់គាត់ ពួកខ្លះក៏មិន ព្រមទទួល ពួកដែលមិនព្រមទទួល ក៏ជំទាស់ជាមួយគាត់ ។

សុត្តមង្គលិកពោលមិនដាច់ស្រេច ក៏មានបុរសម្នាក់ទៀត ឈ្មោះ**មុតមង្គលិកៈ** ពោលថា អ្នកអើយ ពិតណាស់ ឈ្មោះថា ត្រចៀក រមែងបានឮសំឡេងល្អខ្លះ មិនល្អខ្លះ ពេញចិត្តខ្លះ មិន ពេញចិត្តខ្លះ ប្រសិនបើសំឡេងអ្នកនោះ បានឮ គប្បីជាមង្គលពិត ក៏នឹងជាមង្គលទាំងអស់ ។ ព្រោះហេតុដូច្នោះ សំឡេងដែលបាន ឮទើបជាមង្គល ។ ក៏ប៉ុន្តែថា រឿងដែលជ្រាបហើយឯណោះទេ ជាមង្គល ។ ក្លិន រស និងផោដ្ឋព្វៈវត្ថុដែលគប្បីពាល់ត្រូវ ឈ្មោះ ថា **មុតៈ** ។ យ៉ាងដូចម្តេចទៅ ។

មនុស្សពួកខ្លះក្រោកពីព្រឹកហិតក្លិនផ្កា មានក្លិនផ្កាបទុមជា ដើមខ្លះ ទំពាឈើស្ទន់ខ្លះ ចាប់ពាល់ផែនដីខ្លះ ចាប់ពាល់សំណាប

**ទៀវខ្លះ អាចម៍គោស្រស់ខ្លះ អណ្តើកខ្លះ ល្វខ្លះ ផ្កាឈើខ្លះ ផ្លែឈើខ្លះបូកលាបដោយដីសដែលល្អខ្លះ ស្បៀកសំពត់ខ្លះ ទទូរសំពត់ខ្លះ ឬក៏ហិតក្លិនលិទ្ទរស ឬពាល់ត្រូវផោដ្ឋព្វៈ ដែលសន្មតិថាជាមង្គលដ៏ក្រៃលែងយ៉ាងដទៃណាប្រាកដដូច្នោះ វត្ថុដូចពោលមកនេះ** ហៅថា **មុតមង្គល** ។

៦. បុគ្គលពួកខ្លះក៏ព្រមទទួលពាក្យសូម្បីរបស់គាត់ បុគ្គលពួកខ្លះក៏មិនព្រមទទួល ។

( គ្រានោះ ស្រាប់តែមានអ្នកពិភាក្សាម្នាក់ទៀតនិយាយជំទាស់ភ្លាមថា **ប្រព្រឹត្តទៅមិនបានទេ បើសិនជាយ៉ាងនោះមែន នៅពេលដែលយើងធុំក្លិនស្អុយ ៗចាប់របស់ល្អ គិតរឿងអាក្រក់ អារម្មណ៍បែបនេះ និងជាមង្គលដែរឬ** ) ។

បណ្តា ៣ ពួកនោះ **ទិដ្ឋមង្គលិកបុរស** ក៏មិនអាចធ្វើឱ្យ **សុតមង្គលិកបុរស** និង **មុតមង្គលិកបុរស**យល់ព្រមបានទាំង ៣ ចំណែកនេះ ចំណែកណាមួយ ក៏ធ្វើចំណែកពីរទៀតឱ្យយល់ព្រមមិនបាន បណ្តាមនុស្សទាំងនោះ ពួកណាព្រមទទួលពាក្យរបស់ទិដ្ឋមង្គលិកបុរស ពួកនោះក៏ប្រកាន់ថា រូបដែលឃើញ

ហើយប៉ុណ្ណោះ **ជាមង្គល** ។

ពួកណាព្រមទទួលពាក្យរបស់ **សុតមង្គលិកបុរស** និង **មុតមង្គលិកបុរស** ពួកនោះក៏ប្រកាន់ថា សំឡេងដែលបានឮប៉ុណ្ណោះ **ជាមង្គល** រឿងដែលបានដឹងប៉ុណ្ណោះ **ជាមង្គល** ។

រឿងមង្គលបញ្ហានេះ ប្រាកដទូទាំងជម្ពូទ្វីបដោយប្រការដូច្នេះ ។

កាលនោះ មនុស្សទូទាំងជម្ពូទ្វីបប្រកាន់គ្នាជាពួក ៗនាំគ្នាគិតរកមង្គលទាំងឡាយថា **អ្វីហ្ន៎ជាមង្គល** ។ អារក្ខទេវតារបស់មនុស្សពួកនោះស្តាប់រឿងនោះហើយ ក៏នាំគ្នាគិតរក្សាមង្គលទាំងឡាយដូចគ្នា ។ ពួកភុម្មទេវតាជាមិត្ររបស់ទេវតាទាំងនោះ ស្តាប់រឿងអំពីអារក្ខទេវតានោះហើយ ក៏នាំគ្នាគិតរកមង្គលយ៉ាងនោះដូចគ្នា ។ អាកាសដ្ឋកទេវតាជាមិត្តរបស់ទេវតានោះ ចតុម្មហារាជិកទេវតាជាមិត្តរបស់អាកាសដ្ឋកទេវតាទាំងនោះដោយឧបាយនេះ ដរាបដល់អកនិដ្ឋទេវតាជាមិត្ររបស់សុទស្សីទេវតា ស្តាប់រឿងអំពីសុទស្សីទេវតានោះហើយក៏ប្រកាន់គ្នាជាពួក ៗ នាំគ្នាគិតរកមង្គលទាំងឡាយ ដោយឧបាយយ៉ាងនេះ ។ ការគិតរកមង្គល

ក៏កើតឡើងក្នុងទីគ្រប់កន្លែងរហូតដល់ម៉ឺនចក្រវាឡ ។ ក៏ការគិតរកមង្គលកើតឡើងហើយ សូម្បីវិនិច្ឆ័យថានេះជាមង្គល នេះជាមង្គល ក៏មិនទាន់ដាច់ស្រេច **ទើបតាំងនៅអស់ ១២ ឆ្នាំ** ។ ទាំងមនុស្សទាំងទេវតា ទាំងព្រហ្មទាំងអស់គ្នា វៀរតែព្រះអរិយសាវ័កចេញ បែកគ្នាជា ៣ ពួកគឺ **ទិដ្ឋមង្គលិកៈ សុតមង្គលិកៈ មុតមង្គលិកៈ** សូម្បីតែមួយពួក ក៏មិនបានយល់តាមការពិតថា នេះប៉ុណ្ណោះជាមង្គល ។ **មង្គលកោលាហល** ការបែករឿងមង្គលកើតឡើងហើយក្នុងលោក ។

ឈ្មោះថា **កោលាហលមាន ៥** គឺ **កប្បកោលាហល ចក្កវត្តិកោលាហល ពុទ្ធកោលាហល មង្គលកោលាហល មោនេយ្យកោលាហល** ។

៦. បណ្ដាកោលាហលទាំង ៥ នោះ ពួកទេវតាជាន់កាមាវចរ បណ្ដោយសិរសា រំសាយសក់ យំ សោកយកដៃជូតទឹកភ្នែក ស្លៀកសំពត់ពណ៌ក្រហម ទ្រទ្រង់ភេទប្លែក ៗ យ៉ាងក្រៃលែង ត្រាច់ទៅតំបន់មនុស្សស្រែកប្រាប់ថា កន្លងទៅសែនឆ្នាំកប្បនឹងប្រាកដ លោកនេះនឹងវិនាស មហាសមុទ្រ នឹងរីងស្ងួត

មហាប្រថពីនេះ និងស្តេចភ្នំឈ្មោះ **សិនេរុ** នឹងត្រូវភ្លើងឆេះ នឹងវិនាស លោកនឹងវិនាស និងដល់ទៅព្រហ្មលោក ។ ម្នាលអ្នកនិរទុក្ខ សូមអ្នកទាំងឡាយនាំគ្នាចម្រើនមេត្តាចុះ ចូរនាំគ្នាចម្រើនករុណា មុទិតា ឧបេក្ខាចុះ ម្នាលអ្នកនិរទុក្ខ ចូរបម្រើមាតាបិតា ចូរធ្វើការកោតក្រែងអ្នកជារាមច្បងក្នុងត្រកូល ដាស់តឿនគ្នា កុំប្រមាទឡើយ ។ នេះឈ្មោះថា **កប្បកោលាហល** ។

៦. ទេវតាជាន់កាមាវចរនោះឯង ត្រាច់ទៅតំបន់មនុស្សប្រកាសថា កន្លងទៅរយឆ្នាំ ស្តេចចក្រពត្តិនឹងកើតឡើងក្នុងលោក ។ នេះឈ្មោះថា **ចក្កវត្តកោលាហល** ។

៧. ចំណែកទេវតាជាន់សុទ្ធាវាស ប្រដាប់អង្គដោយអាភរណព្រហ្មជួតសំពត់របស់ព្រហ្មនៅលើក្បាល កើតបីតិបាមោជ្ជៈពោលព្រះពុទ្ធគុណ ត្រាច់ទៅក្នុងតំបន់មនុស្សពោលថា កន្លងទៅពាន់ឆ្នាំ ព្រះពុទ្ធនឹងកើតឡើងក្នុងលោក ។ នេះឈ្មោះថា **ពុទ្ធកោលាហល** ។

៨. ទេវតាជាន់សុទ្ធាវាសនោះឯង ស្គាល់ចិត្តរបស់ពួកមនុស្សនិងទេវតាទាំងឡាយ ត្រាច់ទៅក្នុងតំបន់ពួកមនុស្សប្រកាស

ថាកន្លងទៅ ១២ ឆ្នាំ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នឹងត្រាស់សម្តែង មង្គល ។ នេះឈ្មោះថា **មង្គលកោលាហល** ។

៥. ទេវតាជាន់សុទ្ធាវាសនោះឯង ត្រាច់ទៅក្នុងតំបន់ពួកមនុស្សប្រកាសថាកន្លងទៅ៧ ឆ្នាំ ភិក្ខុមួយអង្គសមាគមជាមួយព្រះដ៏មានព្រះភាគនឹងទូលសួរមោនេយ្យបដិបទា ។ នេះឈ្មោះថា **មោនេយ្យកោលាហល** ។

ក្នុងអដ្ឋកថា **សុត្តនិបាត** ឈ្មោះ **បរមត្ថជោតិកា** ត្រង់នាឡកសុត្តវណ្ណនា បានសម្តែងអំពីបុគ្គល**អ្នកបដិបត្តិនូវមោនេយ្យបដិបទា** មានសេចក្តីយ៉ាងនេះថា បានឮមកថា តាបសមួយរូបឈ្មោះ **នាឡកៈ** ត្រូវជាក្មួយរបស់ឥសី ឈ្មោះ **អសិតៈ** បានបំពេញបារមីអស់មួយសែនកប្ប ចាប់តាំងពីបានឃើញនូវសាវករបស់ព្រះមានព្រះ**ភាគបទុមុត្តរៈ** អ្នកបដិបត្តិនូវមោនេយ្យបដិបទាហើយក៏បានប្រាថ្នានូវភាពយ៉ាងនោះ បានចូលទៅសួរព្រះមានព្រះភាគ នូវមោនេយ្យបដិបទាក្នុងថ្ងៃទី ៧ អំពីថ្ងៃសម្តែងធម្មចក្កប្បវត្តនសូត្រ ដោយគាថាទាំងឡាយពីរយ៉ាងនេះថា "**អញ្ញាតមេតំ**"ដូច្នេះជាដើម ។ នេះជាសេចក្តីផ្តើមនៃនាឡកសូត្រដែលមានក្នុងអដ្ឋកថា ។ ហើយខាងចុងលោកបានសម្តែងបន្ត

ទៀតថា ព្រះនាឡកត្ថេរ ក្រោយពីបានស្តាប់នូវនាឡកសូត្រនេះហើយ លោកជាអ្នកប្រាថ្នាតិចក្នុងឋានៈបីគឺ **ការមើល ការស្តាប់ និងការសួរ** ។ មែនពិត ក្នុងកាលជាទីបំផុតនៃទេសនា ព្រះថេរៈអង្គនោះ មានចិត្តជ្រះថ្លាបានថ្វាយបង្គំព្រះមានព្រះភាគ ចូលទៅកាន់ព្រៃ មិនបានញ៉ាំងចិត្តលោកឱ្យកើតឡើងយ៉ាងនេះថា "ឱហ្ន៎ ! អាត្មាអញនឹងមកគាល់ព្រះមានព្រះភាគម្តងទៀតទេ" ។ នេះជាការប្រាថ្នាតិចក្នុងការឃើញរបស់ព្រះថេរៈអង្គនោះ ។ លោកមិនបានញ៉ាំងចិត្តលោកឱ្យកើតឡើងយ៉ាងនេះថា "ឱហ្ន៎! អាត្មាអញនឹងមកស្តាប់ព្រះធម្មទេសនា របស់ព្រះមានព្រះភាគម្តងទៀតទេ" ។ *តទៅទំព័រមុខ* នេះការប្រាថ្នាតិចក្នុងការស្តាប់របស់លោក ។ លោកមិនបានញ៉ាំងចិត្តលោកឱ្យកើតឡើងយ៉ាងនេះថា "ឱហ្ន៎! អាត្មាអញនឹងសាកសួរនូវមោនេយ្យបដិបទា នឹងព្រះមានព្រះភាគមតងទៀតទេ" ។ នេះជាការប្រាថ្នាតិចក្នុងការសាកសួររបស់លោក ។ ក៏ព្រះថេរៈអង្គនោះ ជាអ្នកប្រាថ្នាតិចបាននិមន្តទៅកាន់ជើងភ្នំ មិនអាស្រ័យនៅក្នុងដងព្រៃពីរថ្ងៃឡើយ មិនគង់ទៀបគល់ឈើមួយដើមចំនួនពីរថ្ងៃឡើយ មិននិមន្តចូលទៅបិណ្ឌបាតក្នុងស្រុកមួយចំនួនពីរថ្ងៃឡើយ ។ ព្រោះដូច្នោះព្រះថេរៈ តែងនិមន្តពីដងព្រៃ

មួយទៅកាន់ដងព្រៃមួយ ពីដើមឈើមួយទៅដើម ឈើមួយ ពីស្រុកមួយទៅកាន់ស្រុកមួយ បដិបត្តិនូវបដិបទាតាមសមគួរ តាំងនៅក្នុងផលដ៏ប្រសើរ ។ ព្រោះថា ភិក្ខុអ្នកបដិបត្តិឱ្យបរិបូណ៌នូវមោនេយ្យបដិបត្តិយ៉ាងឧក្រិដ្ឋមានព្រះជន្មត្រឹមតែ ៧ ខែ,បដិបត្តិយ៉ាងកណ្តាលមានព្រះជន្មត្រឹមតែ ៧ ឆ្នាំ, បដិបត្តិយ៉ាងថូរមានព្រះជន្មត្រឹមតែ១៦ ឆ្នាំ ចំណែកព្រះនាឡកត្ថេរអង្គនេះ បានបដិ-បត្តិឱ្យបរិបូណ៌យ៉ាងឧក្រិដ្ឋ ព្រោះហេតុនោះ លោកមានព្រះជន្មត្រឹមតែ ៧ខែ បានដឹងនូវការបរិនិព្វានរបស់ខ្លួន ក៏ស្រង់ទឹកស្លៀកសំពត់កាសាយៈ ចងកាយពន្ធន៍ដណ្តប់នូវសង្ឃាដិពីរជាន់ មានព្រះភក្ត្រឆ្ពោះទៅរកព្រះទសពល ថ្វាយបង្គំដោយបញ្ចង្គប្រដិស្ឋានផ្គងអញ្ជលី អាស្រ័យនូវហិង្គុលកបព៌ត ឈរបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវការបរិនិព្វានរបស់ព្រះថេរៈ បានយាងទៅកាន់ទីនោះ ជាមួយនឹងភិក្ខុសង្ឃធ្វើនូវសរីរកិច្ច ឱ្យភិក្ខុទាំងឡាយកាន់យកនូវធាតុទុកដាក់ក្នុងព្រះចេតិយ ហើយនិមន្តយាងជៀសចេញទៅ ។ ចំណែកសេចក្តីរបស់ព្រះសូត្រនេះ មានសម្តែងក្នុងសុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត លេខ ៥៤ ទំព័រ ២៣៥ ។

៦. បណ្ដាកោលាហលទាំង ៥ នោះ មង្គលកោលាហល របស់ទេវតា និងមនុស្សទាំងឡាយកើតឡើងហើយក្នុងលោក ។

កាលនោះទេវតា និងមនុស្សទាំងឡាយនាំគ្នាជ្រើសយក ក៏មិនបានមង្គលទាំងឡាយកន្លងទៅ ១២ ឆ្នាំ ទេវតាជាន់តាវត្តិង្ស សមាគមគ្នា ក៏ជួយគ្នាគិតយ៉ាងនេះថា ម្ចាស់ផ្ទះ ក៏ជាប្រធាន របស់មនុស្សក្នុងផ្ទះ មេស្រុក ក៏ជាប្រធានរបស់អ្នកស្រុក ព្រះ រាជា ក៏ជាប្រធានរបស់មនុស្សទាំងឡាយ សក្កទេវរាជជាកំពូល នៃទេវតាអង្គនេះ ក៏ជាអ្នកប្រសើរបំផុតរបស់ពួកយើងគឺអធិបតី របស់ទេវលោកទាំងពីរ ( ជាន់ចាតុម្មហារាជិកានិងជាន់តាវត្តិង្ស ) ដោយបុណ្យ តេជះ ឥស្សរិយៈនិងបញ្ញា ។ ប្រសិនបើហេតុនោះ មាន យើងគប្បីនាំគ្នាទៅទូលសួរសេចក្ដីនេះនឹងសក្កទេវរាជ ជា កំពូលនៃពួកទេវតាចុះ ។ ទេវតាទាំងនោះក៏នាំគ្នាទៅកាន់សម្នាក់ ទេវរាជ ថ្វាយបង្គំសក្កទេវរាជជាកំពូលរបស់ទេវតា ដែលមាន សរីរៈមានអាភរណៈប្រចាំព្រះអង្គ ដែលសមរម្យដល់ខណៈនោះ មានពួកអប្សរ ២៥០ កោដិចោមរោមប្រថាប់លើបណ្ឌុកម្ពល-សិលាសនៈដ៏ប្រសើរ ក្រោមដើមបារិច្ឆត្តកៈហើយឈរក្នុងទីសម

គូរទូលថា សូមប្រទានព្រះវរោកាស ព្រះអង្គអ្នកនិរទុក្ខសូមទ្រង់ជ្រាបចុះ ឥឡូវនេះ មង្គលបញ្ហាកើតឡើងហើយ មួយពួកដែលពោលថា **រូបដែលឃើញហើយជាមង្គល** មួយពួកពោលថា **សំឡេងដែលបានឮជាមង្គល** មួយពួកពោលថា **រឿងដែលបានដឹងហើយជាមង្គល** បណ្ដាអ្នកទាំងនោះពួកខ្ញុំព្រះអង្គនិងពួកអ្នកឯទៀត មិនទាន់បានសម្រេចយកមួយណាទេ សូមព្រះអង្គមេត្តាព្យាករណ៍តាមការពិត ដល់ពួកខ្ញុំព្រះអង្គផងចុះ ។ សក្កទេវរាជសូម្បីដោយប្រក្រតីទ្រង់មានបញ្ញាទើបត្រាស់ថា រឿងមង្គលនេះកើតឡើងពីទីណាមុនគេ ។ ទូលថាបពិត្រសក្កទេវរាជ ពួកខ្ញុំព្រះអង្គស្ដាប់ពាក្យរបស់ទេវតាជាន់ចាតុម្មហារាជិកា តពីនោះពួកទេវតាជាន់ចាតុម្មហារាជិកា ក៏បានស្ដាប់ពាក្យរបស់អាកាសដ្ឋកទេវតា ពួកអាកាសដ្ឋកទេវតា បានស្ដាប់ពាក្យរបស់ភូម្មទេវតា ពួកភូម្មទេវតា ស្ដាប់ពាក្យរបស់ទេវតារក្សាមនុស្ស ពួកទេវតារក្សាមនុស្សពោលថា រឿងមង្គលកើតឡើងពីមនុស្សលោក ។

លំដាប់នោះ សក្កទេវរាជជាកំពូលនៃទេវតាត្រាស់សួរទេវតាទាំងនោះថា ព្រះសម្មាសម្ពុទ្ធប្រថាប់នៅទីណា ។ ទេវតាទាំងឡាយ

ទូលថា ប្រថាប់នៅក្នុងមនុស្សលោក ។ ត្រាស់សួរថា មានអ្នកណាទូលសួរព្រះមានព្រះភាគអង្គនោះហើយឬ ។ ទូលថា មិនមានទេ ព្រះអង្គ ។ ត្រាស់ថា ម្នាលអ្នកនិរទុក្ខ ហេតុអ្វីហ្ន៎ អ្នកទាំងឡាយ ទើបបោះបោលជុំភ្លើង ហើយមកតាមរកជុំភ្លើងអំពីអំពិលអំពែកព្រោះហេតុអ្វី ? អ្នកទាំងឡាយ ទើបកន្លងព្រះមានព្រះភាគដែលសម្តែងមង្គលមិនមានសេសសល់ បែរជាយល់ថា គួរមកសាកសួរខ្ញុំ មកអ្នកនិរទុក្ខទាំងឡាយយើងនឹងទូលសួរព្រះមានព្រះភាគអង្គនោះ ពួកយើងប្រហែលបានការព្យាករណ៍បញ្ហា ដែលមានសិរីពិតប្រាកដ ទើបមានទេវឱង្ការប្រើទេវបុត្រមួយអង្គថា អ្នកចូលទៅទូលសួរព្រះមានព្រះភាគចុះ ។ ទេវបុត្រអង្គនោះប្រដាប់ដោយគ្រឿងអលង្ការដ៏សមរម្យដល់ខណៈនោះ រុងរោចន៍ដូចផ្លេកបន្ទោរ មានពួកទេវតាបោមរោម ទៅកាន់វត្តជេតពនមហាវិហារថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងទីសមគួរ មួយកាលទូលសួរមង្គលបញ្ហា ទើបពោលជាគាថាថា **ពហូ ទេវា មនុស្សា ច** ជាដើម ។

# ពណ៌នា ពហូ ទេវា

ការពណ៌នាគាថាថា ពហូ ទេវា ឥឡូវនេះ នឹងពណ៌នាសេចក្តីនៃបទគាថា ។ សព្ទថា ពហូ សម្តែងចំនួនមិនពិតប្រាកដ ព្រោះហេតុនោះ លោកទើបអធិប្បាយថា ច្រើនរយ ច្រើនពាន់ ច្រើនសែន ។ ឈ្មោះថា **ទេវៈ** ព្រោះលេង អធិប្បាយថា លេងជាមួយនឹងកាមគុណ ៥ ឬស្វាងស្វៃដោយពន្លឺរបស់ខ្លួន ។ ន័យម្យ៉ាងទៀត បទថា **ទេវា** បានដល់ទេវៈទាំង ៣ គឺ **សម្មតិទេព ឧបត្តិទេព និងវិសុទ្ធិទេព** ដូចដែលលោកពោលថា ៖

បទថា **ទេវា** បានដល់ ទេព ៣ គឺ **សម្មតិទេព ឧបត្តិទេព វិសុទ្ធិទេព** ។

๑. បណ្តាទេពទាំង ៣ នោះ ព្រះរាជា ព្រះរាជនី ព្រះរាជកុមារ ឈ្មោះថា **សម្មតិទេព** ។

๒. ទេពតាំងពីជាន់ចាតុម្មហារាជិកា និង ខ្ពស់ជាងនោះ ឈ្មោះ **ឧបត្តិទេព** ។

๓. ព្រះអរហន្តតែម្យ៉ាងប៉ុណ្ណោះ ឈ្មោះ **វិសុទ្ធិទេព** ។

បណ្ដាទេពទាំង ៣ នោះ ក្នុងសូត្រនេះលោកបំណងយកឧបត្តិទេព ។ ឈ្មោះថា **មនុស្ស** ព្រោះជាពូជរបស់មនុស្ស ។ ប៉ុន្តែ បូរាណាចារ្យពោលថា ឈ្មោះថា មនុស្ស ព្រោះជាអ្នកមានចិត្តខ្ពស់ ។ មនុស្សទាំងឡាយនោះមាន ៤ គឺអ្នកជម្ពូទ្វីប អ្នកអបរគោយានទ្វីប[១] អ្នកឧត្តរកុរុទ្វីប អ្នកបុព្វវិទេហទ្វីបក្នុងសូត្រនេះ លោកបំណងយកមនុស្សអ្នកជម្ពូទ្វីប ។ ឈ្មោះថា មង្គល ព្រោះសត្វចម្រើនរុងរឿងដោយគុណទាំងនេះ អធិប្បាយថា សត្វដល់សេចក្ដីសម្រេចនិងសេចក្ដីចម្រើន ។ បទថា **អចិន្តយុំ** ប្រែថា គិតហើយ ។ បទថា **អាកង្ខមានា** បានដល់ បំណងប្រាថ្នាការចង់បាន ។ បទថា **សោត្ថានំ** ប្រែថា សិរីសួស្ដី លោកអធិប្បាយថា សេចក្ដីនៃធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងបរលោកស្អាតស្រស់ល្អ ។ បទថា **ព្រូហិ** បានដល់ សម្ដែង ប្រកាស ប្រាប់ បង្ហើប ចែក ធ្វើឱ្យងាយ ។

---

១. ឈ្មោះទ្វីបធំមួយ ក្នុងមហាទ្វីបទាំង ៤ (សរសេរជាគោយានៈក៏បាន ច្រើនហៅក្លាយជាអមរគោយាន សរសេរជាអមរគោយានៈក៏បាន) ។ វចនានុក្រមខ្មែរ ទំព័រ ១៦៤៤ ។

បទថា មង្គលំ បានដល់ ហេតុនៃការសម្រេច ហេតុនៃសេចក្តីចម្រើន ហេតុនៃសម្បត្តិគ្រប់យ៉ាង ។

បទថា ឧត្តមំ បានដល់ វិសេសប្រសើរ នាំប្រយោជន៍សុខមកឱ្យដល់លោកទាំងពួង ដូចពោលមកនេះ ជាការពណ៌នាតាមលំដាប់ នៃបទគាថាទាំងឡាយ ។

ចំណែកសេចក្តីរមមានដូច្នេះ ។ ទេវបុត្រនោះឯង ឃើញទេវតាក្នុងម៉ឺនចក្រវាឡ ជុំនុំគ្នាក្នុងចក្រវាឡនេះ ព្រោះប្រាថ្នានឹងស្តាប់មង្គលបញ្ហា នាំគ្នានិម្មិតអត្តភាពដ៏ល្អិត ១០ ខ្លះ ២០ ខ្លះ ៣០ ខ្លះ ៤០ ខ្លះ ៥០ ខ្លះ ៦០ ខ្លះ ៧០ ខ្លះ ៨០ ខ្លះ ខ្លាតឱកាសប៉ុនចុងខ្សាច់មួយ ឈរចោមរោមព្រះមានព្រះភាគដែលប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលគេរៀបចំទុក បញ្ចេញរស្មីគ្របដណ្តប់ទេវតាមានព្រហ្មទាំងអស់ ដោយសិរីនិងតេជះ ហើយនិងបរិវិតក្កៈនៃចិត្តរបស់ពួកមនុស្សក្នុងជម្ពូទ្វីប ដែលមិនបានមកប្រជុំក្នុងសម័យនោះ ដោយចិត្តព្រះអង្គឯង ទើបពោលគាថាដើម្បីដកកូនសរគឺសេចក្តីសង្ស័យរបស់ទេវតា និងមនុស្សទាំងពួងថា ៖

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។

ទេវតា និងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្តីសួស្តីបានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រាប់នូវមង្គលដ៏ឧត្តម ។

បពិត្រព្រះមានព្រះភាគ ព្រះអង្គត្រូវពួកខ្ញុំព្រះអង្គទូលសួរហើយដោយអនុមតិរបស់ទេវតាទាំងនោះ និងអនុគ្រោះមនុស្សទាំងឡាយ មង្គលឯណាដែលខ្ពង់ខ្ពស់បំផុត ព្រោះនាំមកនូវប្រយោជន៍សុខដល់ខ្ញុំព្រះអង្គទាំងអស់គ្នា ដោយចំណែកមួយសូមព្រះមានព្រះភាគ សម្តែងមង្គលនោះដល់ពួកខ្ញុំព្រះអង្គទាំងឡាយផង ។

កាលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងមង្គលដែលមានទាំងអស់ ៣៨ ប្រការ មង្គលរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ មិនប្រកាន់វត្តតែប្រកាន់ការបដិបត្តិហ្វឹកហាត់ខ្លួនឯង ។

សូម្បីមង្គលដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែង និងប្រកបទៅដោយហេតុផលយ៉ាងច្រើន មិនមានអ្នក

ណាមួយអាចមូលបង្អាច់បាន តែក៏មិនមានសេចក្ដីសំដៅថា គណាចារ្យអ្នកគិតអ្នកកាន់លទ្ធិទាំងឡាយ និងលប់បំបាត់ចោលការគិតហើយ បែរមកជឿព្រះអង្គគ្រប់គ្នាដែរ ព្រោះសុទ្ធតែជាបុគ្គលក្រាស់ដោយទិដ្ឋិទាំងអស់ សូម្បីដឹងថា ខ្លួនខុសតែនៅប្រកាន់ខ្ជាប់នូវវាទៈរបស់ខ្លួន និងសានុសិស្សនីមួយ ៗ ក៏នៅមានការផ្សព្វផ្សាយមិនឈប់ឈរ ប្រកបជាមួយនិស្ស័យរបស់មនុស្សយើង ដែលមានសេចក្ដីខ្ជាប់ប្រចាំខ្លួន ហើយចូលចិត្តធ្វើអ្វីបម្រុងទុកមុន ទើបអ្នកផងព្រមទទួលរាប់កាន់បដិបត្តិតគ្នា មកកើតជាមង្គល ២ ផ្លូវ ពាក់ព័ន្ធគ្នាមករហូតដល់បច្ចុប្បន្នគឺ ៖

**១- មង្គលរបស់អ្នកគិត** ហៅថា **មង្គលមាន** ប្រកាន់យកថា ការមានរបស់នោះ របស់នេះជាមង្គល ដែលសម័យនីមួយ ៗប្រកាន់ផ្សេង ៗគ្នា មិនមានអ្វីពិតប្រាកដ ដែលរាប់ថា **មង្គល** កន្លែងខ្លះអាចរាប់ថា ជាអពមង្គលក៏បាន ។

**២- មង្គលរបស់ព្រះសម្មាសម្ពុទ្ធ** ហៅថា **មង្គលធ្វើ** ប្រកាន់យកការបដិបត្តិហ្វឹកហាត់ខ្លួនឯងជាធំ ជាសច្ចៈដែលមិនប្រែប្រួល អ្នកណាបដិបត្តិតាម រមែងទទួលបានផលយ៉ាងពិតប្រាកដ ។

មង្គលរបស់អ្នកគិតនោះ អ្នកស្មើរសុំឡើងមកហើយ ក៏មានអ្នកក្រោមជំទាស់លប់លាងទៅហើយក៏អ្នកស្មើរសុំឡើងមកឱ្យថ្មីជារឿយ ៗ ទាល់តែរកយុត្តិធម៌មិនបាន, តែចំពោះមង្គលរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ កាលទ្រង់សម្តែងហើយមិនមានអ្នកអាចរកហេតុផលមកលប់លាងបាន សូម្បីព្រះអង្គមានការបើកឱកាសឱ្យជំទាស់ ពិភាក្សាពិចារណាបានរហូត ដូចសេចក្តីក្នុងបទសរសើរព្រះធម្មគុណថា ៖

**ឯហិបស្សិកោ អញ្ជើញមកពិសោធន៍ចុះ ។**

# មង្គលសូត្រ

ឯវម្មេ សុតំ ( សូត្រនេះឈ្មោះមង្គលសូត្រ ) គឺខ្ញុំ ( ឈ្មោះអានន្ទ ) បានស្តាប់មកហើយយ៉ាងនេះថា ៖

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ លំដាប់នោះឯងទេវតាអង្គ ១ កាលដែលវេលារាត្រី បឋមយាមកន្លងទៅហើយ មានរស្មីដ៏ល្អញុំាំងវត្តជេតពនជុំវិញទាំងអស់ឱ្យភ្លឺស្វាង ហើយព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណាក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ ។

ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ កាលទេវតានោះ ឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា( យ៉ាងនេះ )ថា ៖

ពហូ ទេវា មនុស្សា ច មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ ។

ទេវតានិងមនុស្សទាំងឡាយជាច្រើន ប្រាថ្នានូវសេចក្ដីសួស្ដី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាសម្ដែងប្រាប់នូវមង្គលដ៏ឧត្ដម ។ ( ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះថា ៖ )

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្ដម ។

បដិរូបទេសវាសោ ច បុញ្ញេ ច កតបុញ្ញតា
អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ ។

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបាន ធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាដំកល់ខ្លួនដោយប្រពៃ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ចសុសិក្ខិតោ
សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ។

ភាវៈនៃបុគ្គលបានស្តាប់ បានរៀនហើយដោយច្រើន ១ សិល្បសាស្ត្រ គឺសេចក្តីឆ្លៀវឆ្លាសក្នុងហត្ថកម្មរបស់អ្នកបួសនិងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ទាំង៤នេះជាមង្គលដ៏ឧត្តម ។

មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ ។

កិរិយាបម្រើនូវមាតា ១ កិរិយាបម្រើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា ១ ការងារទាំងឡាយដែលមិនប្របូកប្របល់ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។

កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តនូវធម៌ ១ សេចក្ដីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយ ដែលមិនមានទោស ១ ទាំង ៤ នេះជាមង្គលដ៏ឧត្តម ។

**អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ**

**អប្បមាទោ ច ធម្មេសុ ឯតម្មង្គលមុត្តមំ ។**

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១ សេចក្ដីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

**គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា**

**កាលេន ធម្មស្សវនំ ឯតម្មង្គលមុត្តមំ ។**

សេចក្ដីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្ដីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើហើយដល់ខ្លួន ១ កិរិយាស្ដាប់នូវធម៌តាមកាល ១ ទាំង ៥ នេះ ជាមង្គលដ៏ឧត្តម ។

**ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ**

ការេន ធម្មសាកច្ឆា ឯតម្មង្គលមុត្តមំ ។

*សេចក្តីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយាបានឃើញបានជួបនូវសមណៈទាំងឡាយ ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។*

តបោ ច ព្រហ្មចរិយញ្ច អរិយសច្ចាន ទស្សនំ

និព្វាន សច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ ។

*សេចក្តីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១កិរិយាឃើញនូវអរិយសច្ចទាំងឡាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។*

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ

អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ ។

*ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំងឡាយពាល់ត្រូវហើយ មិនរំភើបញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធូលីគឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះ*

ជាមង្គលដ៏ឧត្តម ។

ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា

សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ ។

*ទេវតានិងមនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តីក្នុងទីទាំងពួង (ម្នាលទេវតាអ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់នូវបុគ្គលពាលជាដើមនោះរបស់ទេវតានិងមនុស្សទាំងអម្បាលនោះជាមង្គលដ៏ឧត្តម ។*

## រាយមាតិកាមង្គលកថាទាំង៣៨ ប្រការ

### មង្គលគាថាទី ១

១- អសេវនា ច ពាលានំ *មិនសេពគប់បុគ្គលពាល*

២- បណ្ឌិតានញ្ច សេវនា *សេពគប់បណ្ឌិត*

៣- បូជា ច បូជនីយានំ *បូជាបុគ្គលដែលគួរបូជា*

**ឯតម្មង្គលមុត្តមំ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តមៗ**

## មង្គលគាថាទី ២

៤- បដិរូបទេសវាសោ ច នៅក្នុងប្រទេសដ៏សមគួរ

៥- បុព្វេ ច កតបុញ្ញតា មានបុណ្យធ្វើទុកកាលមុន

៦- អត្តសម្មាបណិធិ ច តម្កល់ខ្លួនទុកដោយប្រពៃ,

ឯតម្មង្គលមុត្តមំ **ទាំង ៣ នេះ ជាមង្គលដ៏ឧត្តមៗ**

## មង្គលគាថាទី ៣

៧- ពាហុសច្ចញ្ច ជាពហុស្សូត

៨- សិប្បញ្ច មានសិល្បៈ

៩- វិនយោ ច សុសិក្ខិតោ មានវិន័យ

១០- សុភាសិតា ច យា វាចា មានវាចាសុភាសិត,

ឯតម្មង្គលមុត្តមំ **ទាំង ៤ នេះ ជាមង្គលដ៏ឧត្តមៗ**

## មង្គលគាថាទី ៤

១១- មាតាបិតុឧបដ្ឋានំ ការទំនុកបម្រុងមាតាបិតា

១២- បុត្តសង្គហោ ចិញ្ចឹមបុត្រ

១៣- ទារស្ស សង្គហោ សង្គ្រោះភរិយា( ស្វាមី )

១៤- អនាកុលា ច កម្មន្តា ការងារមិនច្របូលច្របល់,

ឯតម្មង្គលមុត្តមំ **ទាំង ៤ នេះ ជាមង្គលដ៏ឧត្តមខ**

## មង្គលគាថាទី ៥

១៥- ទានញ្ច ការបំពេញទាន

១៦- ធម្មចរិយា ច ប្រព្រឹត្តធម៌

១៧- ញាតកានញ្ច សង្គហោ សង្គ្រោះញាតិ

១៨- អនវជ្ជានិ កម្មានិ ការងារមិនមានទោស,

ឯតម្មង្គលមុត្តមំ **ទាំង ៤ នេះ ជាមង្គលដ៏ឧត្តមខ**

## មង្គលគាថាទី ៦

១៩- អារតី វិរតី បាបា កិរិយាវៀរបាប

២០- មជ្ជបានា ច សញ្ញមោ វៀរចាកផឹកទឹកស្រវឹង

២១- អប្បមាទោ ច ធម្មេសុ មិនប្រមាទក្នុងធម៌,

ឯតម្មង្គលមុត្តមំ **ទាំង ៣ នេះ ជាមង្គលដ៏ឧត្តមខ**

## មង្គលគាថាទី ៧

២២- គារវោ *មានសេចក្តីគោរព*

២៣- និវាតោ ច *កិរិយាបន្ទាបខ្លួន*

២៤- សន្តុដ្ឋី ច *មានសេចក្តីសន្តោស*

២៥- កតញ្ញុតា *មានសេចក្តីកតញ្ញូ*

២៦- កាលេ ធម្មស្សវនំ *ស្តាប់ធម៌តាមកាល*

**ឯតម្មង្គលមុត្តមំ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តមខ**

## មង្គលគាថាទី ៨

២៧- ខន្តិ ច *មានសេចក្តីអត់ធន់*

២៨- សោវចស្សតា *ភាពជាបុគ្គលងាយប្រដៅ*

៣០- សមណានញ្ច ទស្សនំ *ឃើញសមណៈ*

៣១- កាលេន ធម្មសាកច្ឆា *សន្ទនាធម៌តាមកាល ។*

**ឯតម្មង្គលមុត្តមំ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តមខ**

## មង្គលគាថាទី ៩

៣១- តបោ ច　*ការបំពេញតបៈ*

៣២- ព្រហ្មចរិយញ្ច　*ការប្រព្រឹត្តព្រហ្មចរិយធម៌*

៣៣- អរិយសច្ចានំ ទស្សនំ　*ឃើញអរិយសច្ចៈ*

៣៤- និព្វានសច្ឆិកិរិយា ច　*ធ្វើនិព្វានឱ្យជាក់ច្បាស់,*

ឯតម្មង្គលមុត្តមំ **ទាំង ៤ នេះ ជាមង្គលដ៏ឧត្តមខ**

## មង្គលគាថាទី ១០

៣៥- ផុដ្ឋស្ស លោកធម្មេហិ　*ចិត្តមិនញាប់ញ័រក្នុងលោកធម៌*
ចិត្តំ យស្ស ន កម្បតិ

៣៦- អសោកំ　*ចិត្តមិនសោក*

៣៧- វិរជំ　*ចិត្តប្រាសចាកធូលី*

៣៨- ខេមំ　*ចិត្តក្សេម ។*

ឯតម្មង្គលមុត្តមំ **ទាំង ៥ នេះ ជាមង្គលដ៏ឧត្តមខ**

# មង្គលទី ១ មិនសេពគប់បុគ្គលពាល

ស្លឹកឈើដែលខ្ចប់ត្រីស្អុយ វារមែងស្អុយទៅតាមត្រីដែរ សេចក្តីនេះយ៉ាងណាមិញ អ្នកសេពគប់បុគ្គលពាលក៏រមែងត្រូវស្អុយឈ្មោះ ដូចបុគ្គលពាលដែរ ។

## ព្រឹត្តិកម្មដែលហៅថា គប់ គឺយ៉ាងណា ?

**គប់** សំដៅដល់ព្រឹត្តិកម្មយ៉ាងណាមួយ ដូចតទៅនេះ ៖

- **ការទទួល** ដូចជា ស៊ីរួម ដេករួម ប្រកបការងាររួម និយាយរួម លេងរួមជាដើម ។

- **ការទទួលរួម** ដូចជា ទទួលជាមិត្ត ទទួលជាភរិយា ឬស្វាមីទទួលទុកធ្វើការងារ ទទួលស្តាប់វត្ថុដែលបុគ្គលពាលនិយាយ ឬសរសេរ ។

- **ការឱ្យ** ឱ្យសេចក្តីទុកចិត្ត ឱ្យពាក្យលើកសរសើរ ឱ្យយស ឱ្យតំណែង ឱ្យវត្ថុរបស់ ឱ្យការជួយឧបត្ថម្ភគាំទ្រជាដើម ។ ការមិនសេពគប់បុគ្គលពាល គឺជាការមិនព្រមមាន ។

ព្រឹត្តិកម្មសម្ព័ន្ធណា ៗដូចពោលខាងដើមជាមួយនឹងបុគ្គល

ពាលរួចហើយ បើយើងនៅតែសេពគប់បុគ្គលពាល មិនថា និង នៅទីណាក៏ដោយ ប្រញាប់ដកខ្លួនចេញ កុំប្រមាទ ប្រញាប់ពន្លត ភ្លើងពីលើខ្យល់ បើមិនដូច្នោះទេ និងភ្លាត់ជាប់ជឿបុគ្គលពាល ដោយមិនដឹងខ្លួន ហើយនឹងក្លាយទៅជាបុគ្គលពាលដែរ ។

## រឿងភិក្ខុច្រើនរូប

ព្រះសាស្តា ទ្រង់គង់នៅក្នុងដងព្រៃឈ្មោះ រកចិតៈដែល អាស្រ័យព្រៃឈ្មោះ បាលិលេយ្យកៈ ទ្រង់ប្រារព្ធភិក្ខុច្រើនរូប ត្រាស់ព្រះធម្មទេសនានេះថា "សចេ លភេថ" ជាដើម ។

## (ភិក្ខុ ៥០០ រូបចង់ចូលទៅគាល់ព្រះសាស្តា)

រឿងមានមកក្នុងអដ្ឋកថានៃព្រះគាថាថា " បរេ ច ន វិជានន្តិ"ជាដើម ក្នុងយមកវគ្គហើយ ។ ពិតណាស់រឿងនេះ ខ្ញុំម្ចាស់បានពោលហើយថា "ការគង់នៅរបស់ព្រះមានព្រះភាគ អ្នកដែលស្តេចដំរីក្នុងដងព្រៃឈ្មោះរកចិតៈបម្រើនោះ បានប្រាកដក្នុងជម្ពូទីបទាំងមូល ហើយត្រកូលធំ ៗ មានជាអាទិយ៉ាងនេះ គឺ "អនាថបិណ្ឌិកសេដ្ឋីនាងវិសាខាមហាឧបាសិកា"បញ្ជូនដំណឹងទៅ

អំពីព្រះនគរសាវត្ថីប្រាប់ព្រះអានន្ទត្ថេរថា" បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់សម្តែងព្រះសាស្តា ដល់ខ្ញុំម្ចាស់ទាំងឡាយចុះ" ។ សូម្បីភិក្ខុប្រមាណ ៥០០ រូបដែលមានប្រក្រតីនៅក្នុងទិសបេញវស្សាហើយ បានចូលទៅរកព្រះអានន្ទអង្វរថា " អានន្ទដ៏មានអាយុ យើងទាំងឡាយខានបានស្តាប់ធម្មកថាចំពោះព្រះភក្ត្រព្រះមានព្រះភាគ អស់កាលយូរហើយ,ដូច្នេះ អានន្ទដ៏មានអាយុសូមឱ្យយើងទាំងឡាយ គប្បីបានស្តាប់ធម្មកថានៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ" ។

## [ដំរីបាលិលេយ្យកៈចាប់ឈើបំណងនឹងប្រហារព្រះអានន្ទ]

ព្រះថេរៈនាំភិក្ខុទាំងនោះទៅកាន់ដងព្រៃឈ្មោះរកចិតៈនោះហើយ ត្រិះរិះថា "ការដែលយើងចូលទៅកាន់សម្នាក់ព្រះតថាគតអ្នកមានប្រក្រតីគង់នៅតែមួយព្រះអង្គឯង អស់ត្រៃមាសព្រមជាមួយនឹងភិក្ខុមានប្រមាណប៉ុណ្ណោះ មិនសមគួរឡើយ" លុះគិតដូច្នេះហើយ ក៏បានចូលទៅគាល់ព្រះសាស្តាតែមួយអង្គឯង ។ ដំរីឈ្មោះបាលិលេយ្យកៈឃើញព្រះអានន្ទហើយ ចាប់កំណាត់ឈើស្ទុះចូលទៅរក ។ ព្រះសាស្តាទ្រង់ទតឃើញព្រះអានន្ទហើយ

ត្រាស់ថា "នៃបាលិលេយ្យកៈ អ្នកចូរចៀសចេញ កុំឃាត់ឡើយ, នុ៎ះជាពុទ្ធុប្បដ្ឋាក" ។ ដំរីឈ្មោះបាលិលេយ្យកៈនោះបោះកំណាត់ឈើនោះចោលក្នុងទីនោះឯង សួរដោយអើពើដល់ការទទួលបាត្រនិងចីវរ ។ ព្រះថេរៈមិនឱ្យ ។ ដំរីគិតថា "ប្រសិនបើភិក្ខុនេះជាអ្នកមានវត្តដែលបានរៀនហើយនោះ, លោកនឹងមិនដាក់បរិក្ខាររបស់ខ្លួនលើផែនថ្ម ដែលជាទីគង់នៃព្រះសាស្តាទេ" ។ ព្រះថេរៈ ដាក់បាត្រនិងចីវរលើដី ។ ពិតណាស់ភិក្ខុអ្នកបរិបូណ៌ដោយវត្តទាំងឡាយ រមែងមិនដាក់បរិក្ខាររបស់ខ្លួនលើទីដេក ឬទីអង្គុយរបស់គ្រូឡើយ ។ ព្រះថេរៈថ្វាយបង្គំព្រះសាស្តា ហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តាត្រាស់សួរថា "ម្នាលអានន្ទ អ្នកមកតែម្នាក់ឯងទេឬ ?" ទ្រង់ព្រះសណ្តាប់ថា ព្រះអានន្ទមកជាមួយនឹងភិក្ខុប្រមាណ ៥០០ រូប ក៏ទ្រង់ត្រាស់ថា "ម្នាលអានន្ទ តើភិក្ខុទាំងនោះនៅទីណា ?" កាលព្រះថេរៈក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ កាលមិនជ្រាបព្រះទ័យរបស់ព្រះអង្គ ទើបបញ្ឈប់ភិក្ខុទាំងនោះនៅខាងក្រៅ ហើយចូលមកគាល់ព្រះអង្គតែមួយអង្គឯង", ក៏ទ្រង់ត្រាស់ថា "ម្នាលអានន្ទ អ្នកចូរទៅហៅភិក្ខុ

ទាំងនោះចូលមកចុះ” ។ ព្រះថេរៈក៏បានធ្វើដូច្នោះ ។

**[ត្រាច់ទៅតែម្នាក់ឯងប្រសើរជាងទៅជាមួយមិត្តអាក្រក់]**

ព្រះសាស្ដាទ្រង់ធ្វើបដិសណ្ឋារៈ នឹងភិក្ខុទាំងនោះហើយ កាលភិក្ខុទាំងនោះក្រាបទូលថា “បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គជាព្រះពុទ្ធដ៏សុខុមាល និងជាក្សត្រដ៏សុខុមាល, ព្រះអង្គទ្រង់ឈរផង ទ្រង់គង់ផង តែមួយព្រះអង្គឯងអស់ត្រៃមាសទ្រង់ធ្វើកម្មដែលបុគ្គលធ្វើបានដោយកម្រ, អ្នកធ្វើវត្តធំនិងវត្តតូចក្ដី អ្នកថ្វាយវត្តទាំងឡាយ មានទឹកសម្រាប់លាងព្រះភក្ត្រជាដើមក្ដី ប្រហែលជាមិនមានហើយមើលទៅ” ទើបទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ កិច្ចទាំងពួង ដំរីបាលិលេយ្យកៈជាអ្នកធ្វើ, ពិតណាស់ ការដែលបុគ្គលកាលបានសម្លាញ់បែបនេះនៅរួមជាមួយ ប្រសើរពិត ៗ, កាលបុគ្គលមិនបាន ការត្រាច់ទៅតែម្នាក់ឯងប៉ុណ្ណោះ ប្រសើរជាង” ហើយបានទ្រង់ភាសិតព្រះគាថាទាំងនេះទុកក្នុងនាគវគ្គថា ៖

**សចេ លភេថ និបកំ សហាយំ**

**សទ្ធឹ ចរំ សាធុវិហារិ ធីរំ**

អភិភុយ្យ សព្វានិ បរិស្សយានិ
ចរេយ្យ តេនត្តមនោ សតិមា ។
នោ ចេ លភេថ និបកំ សហាយំ
សទ្ធឹ ចរំ សាធុវិហារិធីរំ
រាជាវ រដ្ឋំ វិជិតំ បហាយ
ឯកោ ចរេ មាតង្គរញ្ញេវ នាគោ ។
ឯកស្ស ចរិតំ សេយ្យោ នត្ថិ ពាលេ សហាយតា
ឯកោ ចរេ ន ច បាបានិ កយិរា
អប្បោស្សុក្កោ មាតង្គរញ្ញេវ នាគោ ។

បើបុគ្គលបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំ មានគុណធម៌ជាគ្រឿងញុំាងប្រយោជន៍ឱ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយ គួរជាអ្នកមានចិត្តត្រេកអរ មានស្មារតី គ្របសង្កត់សេចក្តីអន្តរាយទាំងពួង ហើយត្រាច់ទៅជាមួយនឹងសម្លាញ់នោះឯង ។ បើស្វែងរកមិនបានសម្លាញ់ ដែលមានប្រាជ្ញាជាគ្រឿងរក្សាខ្លួន មានប្រាជ្ញាចងចាំមានគុណធម៌

ជាគ្រឿងញ៉ាំងប្រយោជន៍ឱ្យសម្រេច ជាអ្នកត្រាច់ទៅជាមួយទេ គួរត្រាច់ទៅតែឯងវិញដូចព្រះរាជាលះបង់រដ្ឋ ដែលទ្រង់ឈ្នះហើយ ស្តេចទៅតែឯកអង្គ ពុំនោះសោត ដូចដំរីឈ្មោះមាតង្គៈដែលលះហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។ ការត្រាច់ទៅរបស់បុគ្គលឯកឯង ជាគុណជាតិប្រសើរបំផុត ( ព្រោះថា )សហាយតាគុណរមែងមិនមាន ក្នុងជនពាលឡើយ បុគ្គលនោះគប្បីជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ត្រាច់ទៅតែម្នាក់ឯងផង មិនគប្បីធ្វើអំពើបាបទាំងឡាយផង ដូចដំរីឈ្មោះមាតង្គៈ ជាសត្វមិនមានសេចក្តីខ្វល់ខ្វាយលះបង់ហ្វូងត្រាច់ទៅតែឯកឯងក្នុងព្រៃ ដូច្នោះដែរ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា និបកំ គឺអ្នកប្រកបដោយបញ្ញាជាគ្រឿងរក្សាខ្លួន ។

បទថា សាធុវិហារិំ ធីរំ គឺ អ្នកមានធម៌ជាគ្រឿងនៅដ៏ចម្រើន ជាបណ្ឌិត ។

បទថា បរិស្សយានិ ជាដើម សេចក្តីថា អ្នកកាលបានសម្លាញ់ដែលមានមេត្តាជាវិហារធម៌ដូច្នោះ អាចគ្របសង្កត់អន្ត-

រាយទាំងឡាយ គឺ "អន្តរាយដែលប្រាកដ មានសីហៈនិងខ្លាធំជាដើមនិងអន្តរាយខាងក្នុងមានរាគៈនិងទោសៈជាដើម" ទាំងអស់ហើយ គប្បីជាអ្នកមានចិត្តត្រេកអរ មានសតិតាំងមាំ ត្រាច់ទៅគឺនៅជាមួយនឹងសម្លាញ់នោះ ។

ពីរបទថា រាជាវ រដ្ឋំ សេចក្តីថា ដូចជាព្រះរាជា ទ្រង់លះបង់ដែនហើយបួសជាឥសី ដូច្នោះ ។ លោកអធិប្បាយពាក្យនេះទុកថា "ព្រះរាជាអ្នកមានភូមិប្រទេសដែលព្រះអង្គទ្រង់ឈ្នះវិសេសហើយ ទ្រង់លះបង់ដែនដែលទ្រង់ឈ្នះវិសេសហើយនោះ ដោយទ្រង់ព្រះតម្រិះថា "ឈ្មោះថា ភាពជាព្រះរាជានេះ ជាទីតាំងនៃសេចក្តីប្រមាទដ៏ធំ, ប្រយោជន៍អ្វីរបស់យើងដោយរាជសម្បត្តិ ដែលយើងគ្រប់គ្រងហើយនោះ លំដាប់នោះឯងស្តេចចូលទៅកាន់ព្រៃធំ បួសជាតាបសហើយស្តេចត្រាច់ទៅតែមួយព្រះអង្គឯងក្នុងឥរិយាបថទាំង ៤ យ៉ាងណា, បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯងដូច្នោះដែរ" ។

ពីរបទថា មាតង្គរញ្ញេវ នាគោ សេចក្តីថា ដូចយ៉ាងថាស្តេចដំរីនេះមានឈ្មោះថា "មាតង្គៈ" ព្រោះពិចារណាឃើញច្បាស់

យ៉ាងនេះថា អញជាអ្នកប្រទ្បូកប្រទ្បំដោយហ្វូងដំរីឈ្មោលទាំងឡាយ ដំរីញីទាំងឡាយ ដំរីស្ទាវទាំងឡាយនិងកូនដំរីទាំងឡាយ, យើងតែងតែទំពាស៊ីស្មៅដែលដំរីទាំងនោះ ប្រិបចុងហើយផង, យើងតែងតែទំពាស៊ីកំណាត់ឈើដែលគេបំបាក់ហើយផង, យើងតែងតែផឹកទឹកល្អក់ផង, កាលយើងចុះកាន់កំពង់ទឹក និងឡើងអំពីកំពង់ទឹកមកវិញដំរីញីទាំងឡាយ តែងតែចូលមកត្រដុសយើង, បើដូច្នោះមានតែយើងម្នាក់ឯងប៉ុណ្ណោះ ចៀសចេញចាកហ្វូង" លុះគិតដូច្នេះហើយក៏ធ្វើដំណើរទៅតាមការយល់ឃើញ លះបង់ហ្វូងហើយ រមែងត្រាច់ទៅក្នុងព្រៃតាមសប្បាយតែឯងប៉ុណ្ណោះ ក្នុងឥរិយាបថទាំងបួន យ៉ាងណា, បុគ្គលគប្បីត្រាច់ទៅតែម្នាក់ឯងប៉ុណ្ណោះ ដូច្នោះដែរ ។

បទថា **ឯកាស្ស** សេចក្ដីថា ការត្រាច់ទៅនៃបព្វជិតអ្នកត្រេកអរដ៏ក្រៃលែងហើយ ក្នុងភាវៈតែម្នាក់ឯង ចាប់តាំងអំពីកាលដែលខ្លួនបួសហើយមក អ្នកតែម្នាក់ឯងគាប់ប្រសើរ ។

បាទព្រះគាថាថា នត្ថិ ពាលេ សហាយតា សេចក្ដីថា ព្រោះគុណធម៌ទាំងនេះគឺ "ចុល្លសីលមជ្ឈិមសីលមហាសីល

កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាញាណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ អមតមហានិព្វាន" ឈ្មោះថាសហាយតាគុណ,បុគ្គលមិនអាចបាននូវសហាយតាគុណ អំពីជនពាលទាំងឡាយឡើយ ព្រោះហេតុនោះទើបព្រះមានព្រះភាគសម្តែងថា សហាយតាគុណមិនមានក្នុងជនពាល ។

បទថា **ឯកោ** ជាដើម សេចក្តីថា ព្រោះហេតុនេះ បុគ្គលគប្បីជាអ្នកតែម្នាក់ឯងប៉ុណ្ណោះ ត្រាច់ទៅក្នុងឥរិយាបថទាំងបួន ហើយមិនគប្បីធ្វើបាបទាំងឡាយសូម្បីមានប្រមាណតិច ។ អធិប្បាយថា "បុគ្គលនោះគប្បីជាអ្នកតែម្នាក់ឯងប៉ុណ្ណោះ ត្រាច់ទៅដូចដំរីឈ្មោះមាតង្គៈ អ្នកមានសេចក្តីខ្វល់ខ្វាយតិច គឺ មិនមានសេចក្តីអាល័យ ត្រាច់ទៅជាសុខក្នុងទីដែលខ្លួនប្រាថ្នាហើយ ៗក្នុងព្រៃ ដូច្នោះ, ហើយមិនគប្បីធ្វើបាបទាំងឡាយ សូម្បីមានប្រមាណតិច ។

ព្រោះហេតុនោះព្រះសាស្តា កាលនឹងទ្រង់សម្តែងសេចក្តីនេះថា "សូម្បីអ្នកទាំងឡាយកាលមិនបានសម្លាញ់បែបនោះគប្បីជាអ្នកត្រាច់ទៅតែម្នាក់ឯងប៉ុណ្ណោះ" ទើបទ្រង់សម្តែងព្រះធម្មទេ-

សនានេះចំពោះភិក្ខុទាំងនោះ ។

ក្នុងកាលចប់ទេសនា ភិក្ខុទាំងនោះ សូម្បីទាំង ៥០០ រូប តាំងនៅក្នុងសោតាបត្តិផល ។

**រឿងភិក្ខុអ្នកសេពគប់ភិក្ខុដែលជាបក្ខពួកទេវទត្តមួយរូប**

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធភិក្ខុអ្នកសេពគប់ភិក្ខុ ដែលជាបក្ខពួកអ្នកយល់ខុសមួយរូបត្រាស់ ព្រះធម្មទេសនានេះថា "សលាភំ នាតិមញ្ញេយ្យ" ជាដើម ។

[ ភិក្ខុគប់រកភិក្ខុដែលជាបក្ខពួកព្រះទេវទត្តព្រោះឃើញលាភ ]

បានឮថា ភិក្ខុដែលជាបក្ខពួកព្រះទេវទត្តមួយរូប ជាសម្លាញ់របស់ភិក្ខុរូបនោះ ។ ភិក្ខុដែលជាបក្ខពួករបស់ព្រះទេវទត្តនោះឃើញភិក្ខុនោះត្រាច់ទៅបិណ្ឌបាតជាមួយភិក្ខុទាំងឡាយ ធ្វើភត្តកិច្ចហើយ ( ត្រឡប់ )មក ក៏សួរថា "នែអាវុសោ ទៅណា ?" ។

ភិក្ខុដែលជាបក្ខពួកព្រះសាស្តា. ខ្ញុំទៅកាន់ទីឈ្មោះឯណោះដើម្បីបិណ្ឌបាត ។

ភិក្ខុដែលជាបក្ខពួកព្រះទេវទត្ត. អ្នកបានបិណ្ឌបាតហើយឬ ?

ភិក្ខុដែលជាបក្ខពួកព្រះសាស្តា. អើ ខ្ញុំបានហើយ ។

ភិក្ខុដែលជាបក្ខពួកព្រះទេវទត្ត. នៅទីនេះពួកខ្ញុំមានលាភនិង សក្ការៈច្រើន, អ្នកចូរនៅទីនេះ ២-៣ ថ្ងៃចុះ ។

ភិក្ខុដែលជាបក្ខពួកព្រះសាស្ដានោះ នៅទីនោះ ២-៣ ថ្ងៃតាម ពាក្យរបស់ភិក្ខុនោះហើយ ក៏បានទៅកាន់លំនៅរបស់ខ្លួនវិញ ។

គ្រានោះ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះ ចំពោះព្រះ តថាគតថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះបរិភោគលាភ និង សក្ការៈដែលកើតឡើងចំពោះព្រះទេវទត្ត, លោកជាបក្ខពួករបស់ ព្រះទេវទត្ត" ។

ព្រះសាស្ដា ត្រាស់ឱ្យហៅភិក្ខុនោះមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុ តើអ្នកបានធ្វើយ៉ាងនោះពិតមែនឬ ?" ។

ភិក្ខុ. ព្រះករុណា ព្រះអង្គ, ខ្ញុំព្រះអង្គអាស្រ័យភិក្ខុកំលោះ មួយរូបបាននៅទីនោះ២-៣ ថ្ងៃ, ក៏ប៉ុន្តែ ខ្ញុំព្រះអង្គមិនបានពេញ ចិត្តនឹងលទ្ធិរបស់ព្រះទេវទត្តទេ ។

**[ភិក្ខុគួរគ្រេកអរក្នុងលាភរបស់ខ្លួនប៉ុណ្ណោះ]**

គ្រានោះ ព្រះមានព្រះភាគត្រាស់ទៅកាន់ភិក្ខុនោះថា "ម្នាល ភិក្ខុអ្នកមិនពេញចិត្តនឹងលទ្ធិ (របស់ទេវទត្ត) នោះក៏ពិតមែនហើយ

ក៏ប៉ុន្តែអ្នកបានត្រាច់ទៅជាមួយ ដូចជាពេញចិត្តនឹងលទ្ធិរបស់ជនដែលអ្នកឃើញហើយដោយពិត, អ្នកបានធ្វើយ៉ាងនេះ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ, សូម្បីក្នុងកាលមុន អ្នកក៏ជាបុគ្គលបែបនេះដែរ" កាលភិក្ខុទាំងឡាយទូលអារាធនាថា "បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលឥឡូវនេះ ពួកខ្ញុំព្រះអង្គឃើញភិក្ខុនេះដោយខ្លួនឯងហើយ, ប៉ុន្តែក្នុងកាលមុន ភិក្ខុនេះពេញចិត្តនឹងលទ្ធិរបស់បុគ្គលណា ? សូមព្រះអង្គមេត្តាត្រាស់ប្រាប់ពួកខ្ញុំព្រះអង្គផង" ទើបទ្រង់នាំអតីតនិទានមក ទ្រង់ញ៉ាំងមហិឡាមុខជាតកឱ្យពិស្តារថា ៖

**(អាមាត្យពោធិសត្វពោលថា) ដំរីដ៏ឧត្តម ឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយពីមុនហើយ ក៏ប្រព្រឹត្តតាម បានបោកសម្លាប់ (ហ្មដំរី) លុះបានស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រួមហើយ ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង ។**

ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគប្បីជាអ្នកត្រេកអរនឹងលាភរបស់ខ្លួនប៉ុណ្ណោះ, ការប្រាថ្នាលាភរបស់អ្នកដទៃ មិនសមគួរឡើយ, ព្រោះឈាន វិបស្សនាមគ្គ និងផលទាំងឡាយសូម្បីតែម្យ៉ាង ក៏មិនកើតឡើងដល់ភិក្ខុអ្នកប្រាថ្នាលាភរបស់អ្នក

ដទៃដែរ, ប៉ុន្តែគុណជាតិទាំងឡាយ មានឈានជាដើម រមែងកើតឡើងដល់ភិក្ខុអ្នកត្រេកអរនឹងលាភរបស់ខ្លួនប៉ុណ្ណោះ” ដូច្នេះហើយ កាលនឹងទ្រង់សម្តែងធម៌បានទ្រង់ព្រះភាសិតព្រះគាថាទាំងនេះថា ៖

សលាភំ នាតិមញ្ញេយ្យ នាញ្ញេសំ បិហយញ្ចរេ
អញ្ញេសំ បិហយំ ភិក្ខុ សមាធឹ នាធិគច្ឆតិ ។
អប្បលាភោបិ ចេ ភិក្ខុ សលាភំ នាតិមញ្ញតិ
តំ វេ ទេវា បសំសន្តិ សុទ្ធាជីវមតន្ទិតំ ។

ភិក្ខុ មិនគប្បីមើលងាយលាភរបស់ខ្លួន (ដែលកើតឡើងដោយធម៌) មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ បើចង់បានលាភរបស់ភិក្ខុដទៃ រមែងមិនបានសមាធិឡើយ ។

បើភិក្ខុសូម្បីមានលាភតិច មិនមើលងាយលាភរបស់ខ្លួនទេវតានិងមនុស្សទាំងឡាយ តែងសរសើរភិក្ខុនោះឯង ដែលជាអ្នកព្យាយាមជាគ្រឿងអាស្រ័យរស់នៅ ដោយបរិសុទ្ធ ជាអ្នកមិនខ្ជិលច្រអូស ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា សលាភំ បានដល់ លាភដែលកើតឡើងដល់ខ្លួន ។ ពិតណាស់ ភិក្ខុណាវៀរចាកការត្រាច់ទៅតាមលំដាប់ផ្ទះចិញ្ចឹមជីវិតដោយការស្វែងរកមិនសមគួរ ភិក្ខុនោះឈ្មោះថា មើលងាយ គឺនឿយណាយ បានដល់ ខ្ពើមឆ្អើមនូវលាភរបស់ខ្លួន, ព្រោះហេតុនោះ ភិក្ខុមិនគួរមើលងាយលាភរបស់ខ្លួនដោយការមិនធ្វើយ៉ាងនោះ ។

ពីរបទថា អញ្ញេសំ បិហយំ មិនគប្បីប្រព្រឹត្តចង់បានលាភរបស់ភិក្ខុដទៃ ។

បាទព្រះគាថាថា សមាធឹ នាធិគច្ឆតិ សេចក្តីថា បើចង់បានរបស់ភិក្ខុដទៃ ដល់នូវសេចក្តីខ្វល់ខ្វាយក្នុងការធ្វើបរិក្ខារ មានចីវរជាដើម ឱ្យជនទាំងនោះ រមែងមិនបានអប្បនាសមាធិ ឬឧបចារសមាធិ ។

បាទព្រះគាថាថា សលាភំ នាតិមញ្ញតិ សេចក្តីថា ភិក្ខុសូម្បីជាអ្នកមានលាភតិច កាលត្រាច់ទៅតាមលំដាប់ច្រកដោយ

លំដាប់នៃត្រកូលខ្ពស់និងទាប ឈ្មោះថា មិនមើលងាយលាភរបស់ខ្លួន ។

បទថា តំ វេ ជាដើម សេចក្តីថាទេវតាទាំងឡាយ រមែងសរសើរ គឺស្រឡាញ់ពេញចិត្តភិក្ខុនោះ គឺភិក្ខុបែបនោះ ឈ្មោះថាមានអាជីវៈបរិសុទ្ធ ព្រោះជាអ្នកមានជីវិតជាសារៈឈ្មោះថាអ្នកមិនខ្ជិលច្រអូស ព្រោះជាអ្នកមិនរួញរា មិនខ្ជិលច្រអូសក្នុងការចិញ្ចឹមជីវិត ដោយអាស្រ័យកម្លាំងស្មុង ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។

## បុគ្គលបសាទសូត្រ

នៅក្នុងបិដកលេខ ៤៥, ទំព័រ ២៨០ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងអំពី (**ទោសនៃការជ្រះថ្លាចំពោះបុគ្គល**) មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។ **ទោស ៥ យ៉ាង** គឺអ្វីខ្លះ ។

៥.ម្នាលភិក្ខុទាំងឡាយ បុគ្គលជ្រះថ្លាក្នុងបុគ្គលណា បុគ្គលនោះត្រូវអាបត្តិតាមដែលសង្ឃលើកវត្តនោះ បុគ្គលអ្នកជ្រះថ្លានោះត្រិះរិះយ៉ាងនេះថា បុគ្គលណាជាទីស្រឡាញ់ពេញចិត្តរបស់អាត្មាអញ បុគ្គលនោះត្រូវសង្ឃលើកវត្តហើយ ដូច្នេះ ក៏ច្រើនតែមិនជ្រះថ្លាក្នុងពួកភិក្ខុ កាលមិនជ្រះថ្លាច្រើន ក្នុងពួកភិក្ខុហើយ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនបានស្តាប់ព្រះសទ្ធម្ម កាលមិនស្តាប់ព្រះសទ្ធម្មហើយ រមែងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី១ ។

៥. ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលជ្រះថ្លាក្នុងបុគ្គលណា បុគ្គលនោះត្រូវអាបត្តិតាមដែលសង្ឃឱ្យបុគ្គលនោះ ត្រិះរិះយ៉ាងនេះថា បុគ្គលណាជាទីស្រឡាញ់ពេញចិត្តរបស់អាត្មាអញ បុគ្គលនោះត្រូវឱ្យអង្គុយក្នុងទីចុងបំផុត ដូច្នេះ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនបានស្តាប់ព្រះសទ្ធម្ម កាលមិនបានស្តាប់ព្រះសទ្ធម្មហើយ ក៏នឹងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ២ ក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។

៤. ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលជ្រះថ្លាក្នុងបុគ្គលណា បុគ្គលនោះក៏ចៀសចេញទៅកាន់ទិស ( បុគ្គលនោះត្រិះរិះយ៉ាងនេះថា បុគ្គលណាជាទីស្រឡាញ់ពេញចិត្តរបស់អាត្មាអញ បុគ្គលនោះត្រូវឱ្យអង្គុយក្នុងទីចុងបំផុត ដូច្នេះ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនបានស្តាប់ព្រះសទ្ធម្ម កាលមិនបានស្តាប់ព្រះសទ្ធម្មហើយ ក៏នឹងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៣ ក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ) ។

៥. ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលជ្រះថ្លាក្នុងបុគ្គលណា បុគ្គលនោះក៏សឹកទៅ ( បុគ្គលនោះត្រិះរិះយ៉ាងនេះថា បុគ្គលណាជាទីស្រឡាញ់ពេញចិត្តរបស់អាត្មាអញ បុគ្គលនោះត្រូវឱ្យអង្គុយក្នុងទីចុងបំផុតដូច្នេះ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលមិនសេពគប់នឹងពួកភិក្ខុដទៃហើយក៏មិនបានស្តាប់ព្រះសទ្ធម្មកាលមិនស្តាប់ព្រះសទ្ធម្មហើយ ក៏នឹងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី ៤ ក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ) ។

៥. ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលជ្រះថ្លាក្នុងបុគ្គលណា បុគ្គលនោះក៏ស្លាប់ទៅ (បុគ្គលនោះត្រិះរិះយ៉ាងនេះថា បុគ្គលណា ជាទីស្រឡាញ់ពេញចិត្តរបស់អាត្មាអញ បុគ្គលនោះស្លាប់ទៅហើយ ដូច្នេះ ក៏មិនសេពគប់នឹងពួកភិក្ខុដទៃ កាលមិនសេពគប់នឹងពួកភិក្ខុដទៃហើយ ក៏មិនបានស្តាប់ព្រះសទ្ធម្ម កាលមិនបានស្តាប់ព្រះសទ្ធម្មហើយ ក៏នឹងសាបសូន្យចាកព្រះសទ្ធម្ម ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី៤ ក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។

ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងសេចក្តីជ្រះថ្លាចំពោះបុគ្គល ។

## បុគ្គលពាលគឺជាអ្នកណា ?

**បុគ្គលពាល** គឺជាបុគ្គលដែលមានចិត្តវង្វេងសៅហ្មងជានិច្ច ជាផលឱ្យមានការយល់ឃើញខុស ប្រកាន់ភ្ជាប់តែរបស់ខុស ៗនឹងមិនមានការវិនិច្ឆ័យឡើយ គឺមិនដឹងថា អ្វីល្អ អ្វីអាក្រក់ អ្វីគួរ អ្វីមិនគួរ ដូចជាបណ្ឌិតយល់ឃើញថា ស្រាថា ជារបស់មិនល្អ អាចធ្វើឱ្យបាត់បង់នូវសតិស្មារតី ហើយវាអាចនាំមកនូវ

សេចក្ដីវិនាសគ្រប់យ៉ាង តែបុគ្គលពាលបែរជាយល់ឃើញថា ស្រា គឺជារបស់ប្រសើរ និងធ្វើឱ្យមានមិត្តភក្តិច្រើន,ឬបណ្ឌិតយល់ឃើញថា **ការលេងល្បែង** ជាអបាយមុខ ជាផ្លូវនៃសេចក្ដីវិនាស តែសម្រាប់បុគ្គលពាលវិញត្រឡប់មកជាយល់ឃើញថា **ការលេងល្បែង** គឺជាការល្អអនុវត្តន៍ខួរក្បាលសាកល្បងវិជ្ជារាប់លេខ ដូច្នេះជាដើម ។

បុគ្គលពាលជាមនុស្សដូចយើងដែរ គឺមានរាងកាយដូចយើងដែរ និងអាចមានសេចក្ដីសម្ព័ន្ធទាក់ទងជាមួយយើងក៏បាន ដូចជាញាតិមិត្ត បងប្អូន ស្វាមីភរិយា គ្រូអាចារ្យ ។ល។ ជាដើម តែមិនថាជាអ្វី មានសេចក្ដីទាក់ទងជាមួយយើងយ៉ាងណាក៏ដោយ **ដែលឈ្មោះថា ពាលហើយសូម្បីមានការដឹង មានសេចក្ដីអង់អាច ក៏មិនប្រើសេចក្ដីចេះដឹង សេចក្ដីអាចរបស់ខ្លួនក្នុងផ្លូវដែលត្រឹមត្រូវដែរ ព្រោះគេសម្ដែងសេចក្ដីល្អ ដូចមនុស្សឈើដែលសម្ដែងចំពោះទឹកត្រជាក់ ។**

សត្វទាំងឡាយឯណាមួយ ជាអ្នកប្រកបដោយអកុសលកម្មបថ ១០ មានបាណាតិបាតជាដើម, សត្វទាំងឡាយនោះ ឈ្មោះ

ថា **ពាល ៗ** មួយវិញទៀត គ្រូទាំងឡាយ ៦ នាក់នេះគឺ បូរណកស្សប, មក្ខលិគោសាល, និគ្រន្ថនាដបុត្រ, សញ្ជ័យវេលដ្ឋបុត្រ, បកុធកច្ចាយន, អជិតកេសកម្ពល, និងបាបបុគ្គលទាំងឡាយដទៃទៀតក្រៅពីគ្រូទាំង ៦ នោះ មានភិក្ខុទេវទត្ត និងកោកាលិកភិក្ខុជាដើម គប្បីជ្រាបថា បុគ្គលពាល ៗ មែនពិត ពួកបុគ្គលពាលទាំងអស់នោះឯង លោកហៅថា **ពាល** ព្រោះមិនរស់នៅដោយការរស់នៅដែលប្រកបដោយបញ្ញា រស់នៅដោយហេតុត្រឹមតែការដកដង្ហើម ៗ ដោយហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា ជនទាំងឡាយឯណារស់នៅ អធិប្បាយថា ចិញ្ចឹមជីវិតនៅដោយហេតុត្រឹមតែការដកដង្ហើមចេញចូល មិនមែនរស់នៅដោយការនៅប្រកបដោយបញ្ញាដ៏ប្រសើរឡើយ, ហេតុនោះ ជនទាំងឡាយនោះ ទើបឈ្មោះថា **ជនពាល** ៗ សូម្បីក្នុងគម្ពីរសទ្ទនីតិ ក៏លោកពោលហើយថា **ពល** ធាតុ ប្រព្រឹត្តទៅក្នុងអត្ថថា ប្រាណ, ប្រាណ គឺការរស់នៅនិងការដកដង្ហើម, បុគ្គលឯណាតែងរស់នៅគឺដកដង្ហើមចូលនិងដកដង្ហើមចេញ, មានពាក្យដែលលោកពោលទុកថា ចិញ្ចឹមជីវិតដោយហេតុត្រឹមតែការដក

ជង្រើមចូលចេញ, មិនមែនរស់នៅដោយការរស់នៅប្រកបដោយបញ្ញាដ៏ប្រសើរឡើយ”ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **បុគ្គលពាល** ។

ជនទាំងឡាយឯណា កាត់ចោលនូវប្រយោជន៍ទាំង ២ យ៉ាងកាន់យកនូវហេតុមិនមែនជាប្រយោជន៍ទាំង ២ យ៉ាង, ជនទាំងឡាយនោះ ឈ្មោះថា **ពាល** ។ មែនពិត ជនទាំងឡាយនោះលោកហៅថា **ពាល** ក៏ព្រោះកាន់យកនូវហេតុ ដែលមិនមែនជាប្រយោជន៍ទាំងឡាយ២ ប្រការ និងលោកហៅថា **ពាល** ក៏ព្រោះកាត់ផ្តាច់ចោលនូវប្រយោជន៍ទាំងឡាយ ២ ប្រការ ។ កិរិយាស័ព្ទថា **លទ្តិ** នោះ ចាត់ចូលក្នុងពួកធាតុមាន **ភូ** ធាតុជាដើម ដោយការបង្គាប់ថា **លា** ធាតុ មាន **ទ្វិ** ស័ព្ទ ជាបទប្រៀបធៀប ប្រព្រឹត្តទៅក្នុងអត្ថថា កាន់យក ។ កិរិយាស័ព្ទថា **លុនន្តិ** នោះចាត់ចូលក្នុងពួកធាតុ មាន **កី** ធាតុជាដើម ដោយការបង្គាប់ថា **លុ** ធាតុ មាន **ទ្វិ** ស័ព្ទ ជាបទប្រៀបធៀបប្រព្រឹត្តទៅក្នុងអត្ថថា កាត់ចោល ដូច្នេះ ។

## លក្ខណៈរបស់បុគ្គលពាល

ចំណែកលក្ខណៈរបស់បុគ្គលពាល គប្បីជ្រាបដោយអំណាចនៃទុច្ចរិត មានការគិតរឿងដែលគិតមិនល្អជាដើម ។ មែនពិត បុគ្គលពាលសូម្បីកាលគិត ក៏រមែងគិតតែរឿងដែលគិតមិនល្អ ដោយអំណាចនៃអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិ តែប៉ុណ្ណោះឯង, សូម្បីកាលនិយាយ ក៏រមែងនិយាយចំពោះតែពាក្យដែលនិយាយអាក្រក់ផ្សេងដោយវចីទុច្ចរិត មានមុសាវាទជាដើមប៉ុណ្ណោះឯង សូម្បីកាលធ្វើក៏រមែងធ្វើចំពោះតែកម្មដែលធ្វើអាក្រក់ដោយអំណាចនៃកាយទុច្ចរិត មានបាណាតិបាតជាដើមប៉ុណ្ណោះឯង ។ ព្រោះហេតុនោះ ទុច្ចរិតទាំងឡាយមានការគិតរឿងដែលគិតមិនល្អជាដើមរបស់បុគ្គលនោះ ទើបលោកហៅថា **ពាលលក្ខណៈ** ព្រោះវិគ្រោះថា បុគ្គលពាលជាហេតុដែលបុគ្គលកំណត់ គឺដឹងបាន ដូច្នេះ ហៅថា **ពាលនិមិត្ត** ព្រោះហេតុនៃការស្គាល់ច្បាស់នូវបុគ្គលពាល និងហៅថា **ពាលាបទាន** ព្រោះបុគ្គលពាលប្រព្រឹត្តមិនដែលខាន ។ ព្រោះហេតុនោះ ក្នុងពាលបណ្ឌិតសូត្រ ក្នុងឧបរិបណ្ណាសកៈ ទើបព្រះមានព្រះភាគទ្រង់

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមានហេតុជាគ្រឿងចំណាំថា **ពាល** ( ពាលលក្ខណា ) មានហេតុជាគ្រឿងសម្គាល់ថា **ពាល** ( ពាលនិមិត្ត ) មានចរិតជា **ពាល** ( ពាលាបទាន ) ៣ យ៉ាងនេះ ។ ហេតុ ៣ យ៉ាងតើអ្វីខ្លះ ? ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលក្នុងលោកនេះ ជាអ្នកគិតគំនិតអាក្រក់ ១ និយាយសំដីអាក្រក់ ១ ធ្វើអំពើអាក្រក់ ១ ដូច្នេះ ។

- **ចូលចិត្តគិតគំនិតអាក្រក់ជានិច្ច** បានដល់ គិតតែពីការលួច ឆក់ក្នុងផ្លូវទុច្ចរិត គិតតែពីព្យាបាទអ្នកដទៃ គិតឃើញខុសជានិច្ច ។ល ។

- **ចូលចិត្តនិយាយសម្ដីអាក្រក់ជានិច្ច** បានដល់និយាយភូតភរកុហក និយាយពាក្យទ្រគោះ និយាយពាក្យស៊កសៀតនិយាយពាក្យផ្ដេសផ្ដាសជាដើម ។

- **ចូលចិត្តធ្វើអាក្រក់ជានិច្ច** បានដល់ បំផ្លិចបំផ្លាញ ផឹកសុរាស្រវឹងប៉ោឡែ ចូលចិត្តសម្លាប់ជីវិតមនុស្សសត្វ លួចទ្រព្យគេ ឆក់ដណ្ដើម ប្រព្រឹត្តអនាចារ្យផ្សេង ៗជាដើម ។

**បុគ្គលពាល** មានចិត្តវង្វេងស្រអប់ជានិច្ច ធ្វើឱ្យមិនអាច

ឃុំឃាំងចិត្ត ឱ្យគិតទៅក្នុងផ្លូវដែលត្រឹមត្រូវបានឡើយ ។ នៅក្នុងបិដកលេខ ១៩, ទំព័រ ៥៩ ព្រះអង្គទ្រង់ត្រាស់ **សិង្គាលកសូត្រ** [សូត្រដែលព្រះអង្គទ្រង់សម្ដែងប្រារព្ធចំពោះគហបតិបុត្តឈ្មោះ **សិង្គាលកមាណព** ទាក់ទងទៅនឹងមិត្តដែលមិនគួរសេពគប់ និងមិត្តដែលគួរសេពគប់ព្រមទាំងមានសម្ដែងអំពីតួនាទីផ្សេង ៗទៀត, តែនៅក្នុងទីនេះខ្ញុំសូមលើកយកចំណុចមួយ ដែលព្រះអង្គសម្ដែងអំពីលក្ខណៈមិត្តប្លម ដែលយើងគ្រប់គ្នា គប្បីស្គាល់និងមិនគួរសេពគប់] ដែលមានសេចក្ដីដូចខាងក្រោម ៖

## ប្រភេទនៃមិត្តសម្លាញ់

មិត្តសម្លាញ់មានច្រើនប្រភេទ ដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់ចំពោះសិង្គាលកមាណព មានក្នុងសុត្តន្តបិដកភាគ ១៩ ទំព័រ ៦៧ ថា បុគ្គលខ្លះជាមិត្តសម្លាញ់បានតែក្នុងរោងសុរាក៏មាន បុគ្គលខ្លះថាសម្លាញ់ ៗ តែនៅចំពោះមុខក៏មាន បុគ្គលណាកាលបើប្រយោជន៍(ខ្លួន)កើតឡើងទើបធ្វើជាសម្លាញ់ បុគ្គលនោះមកធ្វើជាសម្លាញ់នឹងខ្លួនក៏មាន ។ កិរិយាដេកដល់ថ្ងៃ១ធ្វើសេវន

កិច្ចជាមួយប្រពន្ធអ្នកដទៃ ១ ភាវៈជាអ្នកមានពៀរច្រើន ១ ភាវៈជាអ្នកធ្វើអំពើឥតប្រយោជន៍ ១ បាបមិត្ត ១ ភាវៈជាអ្នកកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ យ៉ាងនុ៎ះ រមែងបំផ្លាញបុរស ( ឱ្យវិនាស ) ។ នរជនដែលមានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ មានមារយាទ និងគោចរអាក្រក់តែងវិនាសចាកលោកទាំងពីរ គឺលោកនេះនិងលោកខាងមុខ ។ ល្បែងភ្នាល់ល្បែងស្រី និងល្បែងសុរា ១ របាំនិងចំរៀង ១ ការដេកថ្ងៃ ១ ការឱ្យគេបំរើខ្លួនក្នុងកាលមិនគួរ ១ ពួកមិត្តអាក្រក់ ១ ភាវៈជាអ្នកមានសេចក្ដីកំណាញ់ស្វិតស្វាញ ១, ហេតុទាំង ៦ នេះតែងបំផ្លាញបុរសឱ្យវិនាស ។ ពួកជនដែលលេងល្បែងភ្នាល់ ផឹកសុរា ធ្វើសេវនកិច្ចនឹងស្រីដែលស្មើដោយជីវិតរបស់បុរសដទៃ សេពគប់នឹងបុគ្គលថោកទាប ( ខាតលក្ខណ ) មិនសេពគប់នឹងបុគ្គលដែលមានសេចក្ដីចម្រើន ( គ្រប់លក្ខណ ) យសរបស់ពួកជននោះតែងសាបសូន្យដូចព្រះចន្ទ្រខាងរនោច ។ ជនដែលជាអ្នកផឹកសុរាជាអ្នកខ្សត់ទ្រព្យ ជាអ្នកឥតមានកន្លល់ ដោយការផោរចិញ្ចឹមជីវិតមានតែស្រវឹងជានិច្ចប្រាសចាកសេចក្ដីចម្រើន លិចចុះក្នុងបំណុលដូចដុំថ្មលិចទៅក្នុង

ទឹក បុគ្គលនោះតែងធ្វើការងារឱ្យរីកវរដល់ខ្លួនដោយឆាប់ ។ បុគ្គលដេកក្នុងវេលាថ្ងៃជាប្រក្រតី មិនក្រោកឡើងពីយប់ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ច ជាអ្នកលេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។ ប្រយោជន៍ទាំងឡាយតែងកន្លងហួសមនុស្ស ដែលលះបង់ចោលនូវការងារ ដោយពោលអាងថា វេលានេះត្រជាក់ណាស់ ក្តៅណាស់ ល្ងាចណាស់ ។ ជនណាមួយធ្វើនូវកិច្ចការរបស់បុរស មិនអើពើនូវត្រជាក់ និងក្តៅក្រៃលែងជាងស្មៅ ( ទៅទៀត ) ជននោះរមែងមិនសាបសូន្យចាកសេចក្តីសុខឡើយ ។

## លក្ខណៈរបស់អមិត្ត ៤ យ៉ាង

ចត្តារោមេ គហបតិបុត្ត អមិត្តា មិត្តប្បដិរូបកា វេទិតព្វា អញ្ញទត្ថុហរោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ វចីបរមោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ អនុប្បិយភាណី អមិត្តោ មិត្តប្បប្បដិរូបកោ វេទិតព្វោ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ

ម្នាលគហបតីបុត្ត អ្នកត្រូវស្គាល់ពួកមនុស្សដែលជាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ៤ ពួកនេះគឺ ៖

**១- អញ្ញទត្ថុហរោ** អ្នកត្រូវស្គាល់មនុស្សដែលគិតយកតែប្រយោជន៍ខ្លួនថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ។

**២- វចីបរមោ** អ្នកត្រូវស្គាល់មនុស្សល្អតែសម្ដីថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ។

**៣-អនុប្បិយភាណី** អ្នកត្រូវស្គាល់មនុស្សដែលនិយាយចាក់បណ្ដោយឱ្យគាប់ចិត្តថា មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ។

**៤- អបាយសហាយោ** អ្នកត្រូវស្គាល់មនុស្សជាសម្លាញ់ក្នុងការវិនាសភោគៈទាំងឡាយថា មិនមែនជាមិត្តគ្រាន់តែជាមិត្តប្លម ។

## អដ្ឋកថា

ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីសម្ដែងអំពីមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម ជាបុគ្គលពោលថា បុគ្គលធ្វើយ៉ាងនេះ សេចក្ដីវិនាសរមែងកើតមានដល់បុគ្គលនោះ ឬថាភ័យ

ផ្សេង ៗ អន្តរាយទាំងឡាយ និងឧបសគ្គណាមួយ រមែងកើតឡើង ព្រោះតែអាស្រ័យបុគ្គលពាល ព្រោះហេតុដូច្នោះ មិនគួរសេពគប់បុគ្គលពាលដែលមានសភាពបែបនេះ ។ ដូច្នេះ ទើបទ្រង់ត្រាស់នូវព្រះតម្រាស់ជាដើមថា ម្នាលគហបតីបុត្ត មនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លមមាន៤ ពួកនេះដូច្នេះ ។

បទថា **អញ្ញទត្ថុហរោ** (និយាយរកប្រយោជន៍) មានសេចក្ដីថា ខ្លួនឯងមកហើយដោយដៃទទេនាំយករបស់ណាមួយទៅដោយចំណែកម្យ៉ាង ។

បទថា **វចីបរមោ** (ល្អតែសម្ដី) មានសេចក្ដីថា ល្អបានត្រឹមតែសម្ដី ប៉ុន្តែគ្មានបានធ្វើអ្វីទាំងអស់ ។

បទថា **អនុប្បិយភាណី** (និយាយចាក់បណ្ដោយឱ្យគាប់ ចិត្ត) គឺនិយាយចាក់បណ្ដោយតាម ។

បទថា **អបាយសហាយោ** (សម្លាញ់ក្នុងផ្លូវវិនាសនៃភោគៈទាំងឡាយ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងអំពីមនុស្សដែលមិនមែនជាមិត្ត ៤ ពួកយ៉ាងនេះហើយ គ្រាដែលទ្រង់បែងចែកនូវ

*ហេតុនីមួយ ៗ ក្នុងមនុស្សដែលមិនមែនជាមិត្តនោះដោយហេតុ ៤ យ៉ាង ទើបត្រាស់នូវពាក្យជាដើមថា ម្នាលគហបតិបុត្ត ស្ថាន ៤ យ៉ាងដូច្នេះ ។*

## លក្ខណៈមិត្តគិតតែប្រយោជន៍ខ្លួន ៤ យ៉ាង

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អញ្ញទត្ថុហរោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ *ម្នាលគហបតិបុត្ត មនុស្សគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្លម(នោះ) អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ ៖*

១- អញ្ញទត្ថុហរោ ហោតិ ***មិត្តគិតយកតែប្រយោជន៍ខ្លួន*** ។ *អដ្ឋកថា* បទថា អញ្ញទត្ថុហរោ ហោតិ *(មិត្តគិតយកតែប្រយោជន៍ខ្លួន)មានសេចក្ដីថា ជាអ្នកនាំយកទៅដោយចំណែកម្យ៉ាងប៉ុណ្ណោះ គឺជាអ្នកមានដៃទទេមកកាន់ផ្ទះរបស់មិត្ត ហើយនិយាយដល់គុណរបស់សម្ពត់សាដកដែលស្លៀក ។ បុគ្គលអ្នកនិយាយរកប្រយោជន៍ពោលថា ម្នាលសម្លាញ់ អ្នកឯណោះ រមែងពោលអំពីគុណនៃផ្ទាំងសម្ពត់នេះ នឹងអ្នកយ៉ាងក្រៃលែង ដូច្នេះ*

ហើយ ខ្លួនឯងស្លៀកសម្ពត់ថ្មី រួចឱ្យសម្ពត់ដែលខ្លួនស្លៀកនោះទៅមិត្ត ។

២- អប្បេន ពហុមិច្ឆតិ **មិត្តប្រាថ្នាយករបស់ច្រើនដោយ( ឱ្យ )របស់តិចតួច ។** *អដ្ឋកថា* បទថា អប្បេន ពហុមិច្ឆតិ ( ចង់បានរបស់ច្រើនដោយឱ្យរបស់តិច )គឺឱ្យរបស់ឯណានីមួយដែលមានប្រមាណតិចតួច ហើយប្រាថ្នារបស់ច្រើនអំពីគេវិញ ។

៣- ភយស្ស កិច្ចំ ករោតិ **ទាល់តែមានភ័យទើបជួយធ្វើកិច្ចការរបស់មិត្ត ។** *អដ្ឋកថា* បទថា **ភយស្ស កិច្ចំ** ករោតិ ( ទាល់តែមានភ័យទើបធ្វើកិច្ច ) មានសេចក្តីថា កាលបើភ័យកើតឡើងដល់ខ្លួនរមែងធ្វើកិច្ចនោះ ៗ ប្រៀបដូចជាទាសៈរបស់គេ អ្នកនិយាយចាក់បណ្តោយនេះ មិនធ្វើក្នុងកាលទាំងពួងទេ ពេលដែលមានភ័យ ទើបធ្វើ មិនធ្វើដោយសេចក្តីស្រឡាញ់ឡើយ ព្រោះហេតុដូច្នោះហើយ ទើបឈ្មោះថា ជាបុគ្គលមិនមែនមិត្ត ។

៤- សេវតិ អត្ថការណា **សេពគប់មិត្តព្រោះហេតុ**

តែប្រយោជន៍ ។ *អដ្ឋកថា* បទថា សេវតិ អត្ថការណា (សេពគប់មិត្តព្រោះហេតុតែប្រយោជន៍) មានសេចក្តីថា មិនសេពគប់ដោយសេចក្តីស្រឡាញ់ស្និទ្ធស្នាលទេ គឺទាល់តែសម្លឹងឃើញនូវប្រយោជន៍ខ្លួនទើបសេពគប់ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ខោ ឋានេហិ អញ្ញទត្ថុហរោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

## លក្ខណៈរបស់មិត្តល្អតែសម្តី ៤ យ៉ាង

ចតូហិខោគហបតិបុត្ត ឋានេហិ វចីបរមោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តល្អតែសម្តី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ ៖

១- អតីតេន បដិសន្ថរតិ មិត្តទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ ។ *អដ្ឋកថា* បទថា អតីតេ បដិស-

ន្តរតិ(ទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ) មានសេចក្តីថា មនុស្សល្អតែសម្តី កាលបើមិត្តមកដល់ រមែងសង្គ្រោះដោយរបស់ដែលកន្លងទៅ ហើយយ៉ាងនេះថា ថ្ងៃមុនអ្នកមិនមក ព្រោះថ្ងៃមុន ស្រូវសន្ទូងរបស់យើងបានសម្រេចផលដ៏ច្រើនលើសលប់ ពួកខ្ញុំបានសម្រាំងទុកស្រូវសាលី ស្រូវដំណើបទនិងធញ្ញជាតិជាដើមដោយច្រើន ហើយអង្គុយមើលតែផ្លូវអ្នក តែថ្ងៃនេះអស់រលីងទៅហើយដូច្នេះ ។

**២- អនាគតេន បដិសន្ថរតិ (មិត្ត)ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក ។** *អដ្ឋកថា* បទថា អនាគតេ(ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មកដល់) មានសេចក្តីថា មនុស្សល្អតែសម្តីនោះ រមែងសង្គ្រោះដោយរបស់ដែលមិនទាន់មកដល់យ៉ាងនេះថា ក្នុងថ្ងៃនេះ ស្រូវសន្ទូងរបស់ខ្ញុំលូតលាស់ល្អ គួរឱ្យពេញចិត្ត ពេលប្រមូលរួចហើយ បើបានផលពេញបរិបូណ៌ ខ្ញុំនឹងអាចសង្គ្រោះពួកអ្នកដោយស្រូវ មានស្រូវសាលីជាដើមដូច្នេះ ។

៣- និរត្ថកេន សង្គណ្ហាតិ (មិត្ត)**សង្គ្រោះដោយ អំពើឥតប្រយោជន៍** ។ *អដ្ឋកថា* បទថា និរត្ថកេន (*សង្គ្រោះដោយអំពើឥតប្រយោជន៍*) មានសេចក្តីថា មនុស្សល្អតែសម្តី អង្គុយលើដំរីឬលើខ្នងសេះពេលបានឃើញមិត្ត ហើយពោលថា ម្នាលសម្លាញ់ចូរសម្លាញ់មកអង្គុយក្នុងទីនេះមក ។ មនុស្សល្អតែសម្តីនុ៎ះ ស្លៀកសម្ពត់សាកជមួយផ្ទាំងដ៏ល្អ ហើយពោលថា សម្ពត់សាជកនេះសមនឹងសម្លាញ់ឯងណាស់ ទាស់តែខ្ញុំមិនមានសម្ពត់ដទៃទៀត ។ យ៉ាងនេះឈ្មោះថា សង្គ្រោះដោយអំពើឥតប្រយោជន៍ ។

៤- បច្ចុប្បន្នេសុ កិច្ចេសុ ព្យសនំ ទស្សេតិ (មិត្ត) **កាលកិច្ចទាំងឡាយកើតឡើងភ្លាម ៗ ក៏សម្តែងអាងរបស់ខូចខាត** ។ *អដ្ឋកថា* បទថា **បច្ចុប្បន្នេសុ កិច្ចេសុ ព្យសនំ ទស្សេតិ** (*កាលកិច្ចទាំងឡាយកើតឡើងភ្លាម ៗក៏សម្តែងអាងរបស់ខូចខាត*) មានសេចក្តីថា កាលបើមានអ្នកពោលថា ខ្ញុំត្រូវការរទេះ មនុស្សល្អតែសម្តីពោលពាក្យជាដើមថា សោកស្តាយណាស់ កង់រទេះរបស់ខ្ញុំបាក់ទ្រុឌទ្រោមហើយ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ វចីបរមោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាល គហបតិបុត្ត មិត្តល្អតែសម្ដីមិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

## លក្ខណៈមិត្តនិយាយចាក់បណ្ដោយ ៤ យ៉ាង

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អនុប្បយ-ភាណី អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្ដោយឱ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ ៖

១- បាបកម្មំបិស្ស អនុជានាតិ *បើមិត្តធ្វើអំពើអាក្រក់ក៏យល់ព្រមតាម ។ អដ្ឋកថា បទថា* បាបកម្មំបិស្ស អនុជានាត *( បើមិត្តធ្វើអំពើអាក្រក់ក៏យល់ព្រមតាម )* មានសេចក្ដីថា *កាលបើមិត្តនិយាយថា ពួកយើងនិងធ្វើបាណាតិបាត( គឺសម្លាប់សត្វ ) ជាដើម និយាយយ៉ាងណាទីមួយក៏និយាយចាក់បណ្ដោយឱ្យគាប់ចិត្តថា ល្អហើយសម្លាញ់ចូរធ្វើទៅ ។ សូម្បីក្នុងការធ្វើអំពើល្អក៏មានន័យដូចគ្នានេះដែរ ។*

២- កល្យាណំបិស្ស អនុជានាតិ មិត្តធ្វើអំពើល្អក៏យល់ព្រមតាម ។

៣- សម្មុខស្ស វណ្ណំ ភាសតិ ពណ៌នាគុណមិត្តតែក្នុងទីចំពោះមុខ ។

៤- បរម្មុខស្ស អវណ្ណំភាសតិ ពោលទោសមិត្តក្នុងទីកំបាំងមុខ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អនុប្បិយភាណី អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតីបុត្ត មិត្តនិយាយចាក់បណ្ដោយឱ្យគាប់ចិត្ត មិនមែនជាមិត្តទេគ្រាន់តែជាមិត្តបួម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

## លក្ខណៈមិត្តក្នុងផ្លូវវិនាស ៤ យ៉ាង

ចតូហិ ខោ គហបតិបុត្ត ឋានេហិ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ។

ម្នាលគហបតិបុត្ត មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស មិន

មែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងគឺ ៖

១- សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគ សហាយោ ហោតិ ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយ ៗនូវការផឹកទឹកស្រវឹង គឺសុរាមេរ័យដែលជាទីតាំងនៃសេចក្ដីប្រមាទ ។ អដ្ឋកថា បទថា សហាយោ ហោតិ (ជាសម្លាញ់) មានសេចក្ដីថា កាលមិត្តពោលថាជនទាំងឡាយនាំគ្នាផឹកសុរាក្នុងទីនោះ អ្នកចូរមក យើងនឹងទៅក្នុងទីនោះ មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស ឆ្លើយថាតបថាល្អហើយ ហើយក៏ទៅ ។

ក្នុងបទទាំងឡាយដទៃ ក៏មានន័យដូច្នេះដែរ ។

២- វិកាលវិសិខាចរិយានុយោគេ សហាយោ ហោតិ ជាសម្លាញ់ក្នុងការប្រកបរឿយ ៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល ។

៣- សមជ្ជាភិចរណេ សហាយោ ហោតិ ជាសម្លាញ់ក្នុងកិរិយាដើរមើលល្បែងមហោស្រព ។

៤- ជូតប្បមាទដ្ឋានានុយោគេ សហាយោ ហោតិ ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយ ៗ នូវល្បែងភ្នាស់ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ។

ឥមេហិ ខោ គហបតិបុត្ត ចតូហិ ឋានេហិ អបាយសហាយោ អមិត្តោ មិត្តប្បដិរូបកោ វេទិតព្វោ ម្នាលគហបតិបុត្ត មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

## និគមគាថា

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោចសត្ថា ព្រះមានព្រះភាគ ទ្រង់បានសម្តែងសេចក្តីនេះលុះព្រះសុគតជាសាស្តាសម្តែងសេចក្តីនេះហើយ ទើបទ្រង់សម្តែងនូវគាថាព័ន្ធតទៅទៀតថា ៖

អញ្ញទត្ថុហរោ មិត្តោ យោ ច មិត្តោ វចីបរមោ
អនុប្បិយញ្ច យោ អាហុ អបាយេសុ ច យោ សខា

ឯតេ អមិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ
អារកា បរិវជ្ជេយ្យ មគ្គំ បដិភយំ យថាតិ ។

បុគ្គលជាមិត្តគិតយកតែប្រយោជន៍ខ្លួន ១ បុគ្គលជាមិត្តល្អតែសម្ដី ១ បុគ្គលដែលនិយាយចាក់បណ្ដោយឱ្យគាប់ចិត្ត ១ បុគ្គលដែលជាសម្លាញ់ក្នុងផ្លូវវិនាស ១ បណ្ឌិតដឹងថា បុគ្គលទាំង ៤ ពួកនុ៎ះ មិនមែនជាមិត្តហើយ គប្បីជៀសវាងឱ្យឆ្ងាយ ដូចជាអ្នកដំណើរចៀសវាងផ្លូវដែលប្រកបដោយភ័យដូច្នោះ ។

បទថា ឥតិ វិញ្ញាយ ( បណ្ឌិតដឹងច្បាស់យ៉ាងនេះហើយ ) គឺដឹងយ៉ាងនេះថា ជាពួកមិត្តក្លែងក្លាយដូច្នេះ ។

## ទោសនៃសេចក្ដីជាមនុស្សពាល

១- មានសេចក្ដីយល់ឃើញខុស បង្កទុក្ខឱ្យខ្លួនឯង
២- បាត់បង់កេរ្តិ៍ឈ្មោះ ត្រូវគេតិះដៀលនិន្ទា
៣- មិនមានអ្នកណារាប់អាន ត្រូវគេស្អប់ខ្ពើម
៤- បាត់បង់នូវសិរីមង្គល អស់សិរីសួស្ដី
៥- សេចក្ដីអាក្រក់ភេទភ័យទាំងឡាយ នឹងហូរចូលមករក

ខ្លួនជាបុគ្គលពាលនោះមិនខាន

៦- បំផ្លាញប្រយោជន៍ខ្លួនឯងទាំងក្នុងលោកនេះ និងលោកខាងមុខ រហូតដល់ប្រយោជន៍ដ៏ឧត្តម គឺព្រះនិព្វាន

៧- បំផ្លាញវង្សត្រកូលរបស់ខ្លួនឯងចោល

៨- កាលបើបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលដល់អបាយភូមិ មាននរក ប្រេត តិរច្ឆាន អសុរកាយ ។

## វិធីសង្កេតបុគ្គលពាល

បុគ្គលពាលចូលចិត្តធ្វើរឿងដូចតទៅ ៖

**១- បុគ្គលពាលចូលចិត្តដឹកនាំក្នុងផ្លូវដែលខុស**

- **ដឹក** គឺការបបែបបួល អញ្ជើញ បង្ហាញ ឬស្នើរសុំ
- **នាំ** គឺការធ្វើឱ្យឃើញជាតួយ៉ាង ។

**ដូចជា** បបួលឱ្យគេចអំពីសាលារៀន បបួលទៅលួចទ្រព្យគេ បបួលឱ្យសេពថ្នាំញៀន ដឹកនាំឱ្យក្លាយទៅមនុស្សអន្ធពាលជាដើម ការដឹកនាំនេះអាចធ្វើដោយសេចក្តីល្អក៏បាន តែថាវាខុស ដូចជាបានលុយមកក៏បបួលគ្នាទៅផឹកស្រា ដើរ លេងយប់យ៉ាងនេះក៏ចាត់ថាជាពាលដែរ ។

អ្នកដែលនៅវ័យក្មេង ខ្វះការគិត ខ្វះសតិ រមែងត្រូវគេបបួលដឹកនាំបានដោយងាយ ព្រោះដូច្នោះ អ្នកធំនៅក្នុងផ្ទះគួរប្រុងប្រយ័ត្នការធ្វើ និងការនិយាយទាំងខ្លួនឯងនិងអ្នកដែលមកសេពគប់រក ព្រោះក្មេងវាអាចចូលចិត្តធ្វើតាមដោយការមិនដឹង ឬចូលចិត្តយល់ខុសថា ជាការដែលល្អគួរធ្វើ ។

**២- បុគ្គលពាលចូលចិត្តធ្វើក្នុងវត្ថុដែលមិនមែនធុរៈ**

បង្កើតបញ្ហា មុខនាទីការងាររបស់ខ្លួន មិនរៀបចំឱ្យមានរបៀបរៀបរយ តែចូលចិត្តទៅឆ្កឹះកកាយមុខនាទីការងាររបស់អ្នកដទៃ ដូចជាចាប់កំហុសអ្នករួមការងារ សរសេរប័ណ្ណអនាមិកកកេះកកាយ ឆាឆៅ ធ្វើការរំខានឱ្យកើតការក្តៅក្រហាយចិត្ត ។

**៣- បុគ្គលពាលចូលចិត្តតែវត្ថុដែលខុស ៗចូលចិត្តកាន់យកតែវត្ថុដែលអាក្រក់ថាជាវត្ថុល្អ**

ដូចជាចូលចិត្តលេងល្បែង ចូលចិត្តជក់បារី ចូលចិត្តគេចពីសាលារៀន ចូលចិត្តប្រកែកជាមួយមាតាបិតា ។ល ។ ឃើញគេធ្វើត្រូវថាគេជាមនុស្សល្ងង់ ឃើញមនុស្សខ្លាចខុសថាជាមនុស្សកំសាកញីជាដើម ។

**៤- បុគ្គលពាលសូម្បីតែនិយាយពាក្យល្អ ៗក៏ខឹងក្រោធ**

ដូចជាដាស់តឿនឱ្យឧស្សាហ៍មើលសៀវភៅព្រោះជិតប្រឡង ក៏ក្រោធ ដាស់តឿនឱ្យភ្ញាក់ពីព្រឹកក៏ខឹងក្រោធ គ្រាន់តែមើលមុខពេលខ្លះ ក៏ខឹងក្រោធ ។

**៥- បុគ្គលពាលមិនព្រមទទួលស្គាល់របៀបវិន័យ**

ដូចជា ចូលចិត្តឆ្លងកាត់ផ្លូវថ្នល់គ្មានរបៀប បោះចោលកាកសំណល់លើផ្លូវថ្នល់ ទៅសាលារៀនយឺតពេល ទៅធ្វើការយឺតជាដើម ។

## ជដិលសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ២១៣ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងជាមួយនឹងព្រះបាទបសេនទិកោសលអំពី [**មិនគួរទុកចិត្តព្រោះឃើញតែម្តងនោះទេ**] មានសេចក្តីថា ៖

សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅលើមិគារមាតុ-ប្រាសាទក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យ ហើយទ្រង់គង់ត្រង់ក្លោងទ្វារខាងក្រៅ ។ គ្រានោះព្រះបាទបសេន-

ទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគហើយ ទ្រង់គង់នៅក្នុងទីសមគួរ ។

ក៏សម័យនោះឯងពួកជដិល ៧ នាក់ ពួកនិគ្រន្ថ ៧ នាក់ ពួកអចេល ៧ នាក់ ពួកឯកសាដកបុគ្គល ៧ នាក់ ពួកបរិព្វាជក ៧ នាក់ មានរោមក្លៀក មានក្រចកនិងរោមឯទៀតដុះវែង ៗ នាំគ្នារែកអម្បែកផ្សេង ៗ ដើរជិតព្រះមានព្រះភាគហើយហួសទៅ ។ លំដាប់នោះឯងព្រះបាទបសេនទិសកោល ទ្រង់ក្រោកអំពីអាសនៈធ្វើនូវឧត្តរាសង្គឆៀងស្មាម្ខាង លុតព្រះជានុមណ្ឌលខាងស្តាំលើផែនដី ប្រណាមអញ្ជលីចំពោះជដិល ៧ នាក់ផង ពួកនិគ្រន្ថ ៧ នាក់ផង ពួកអចេល ៧ នាក់ផង ពួកឯកសាដកបុគ្គល ៧ នាក់ផង ពួកបរិព្វាជក ៧ នាក់ផង ទ្រង់ប្រកាសព្រះនាមអស់វារៈបីដងថា បពិត្រលោកទាំងឡាយដ៏ចម្រើន ខ្ញុំជាព្រះរាជាបសេនទិកោសល ។ កាលដែលជដិល ៧ នាក់ ពួកនិគ្រន្ថ ៧ នាក់ ពួកអចេល ៧ នាក់ ពួកឯកសាដកបុគ្គល ៧ នាក់ ពួកបរិព្វាជក ៧ នាក់ទាំងនោះ ចៀសចេញទៅមិនយូរប៉ុន្មាន ទើបព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគ លុះស្តេចចូលទៅ ថ្វាយបង្គំព្រះមានព្រះ

ភាគ ហើយទ្រង់គង់ក្នុងទីសមគួរ ។ លុះព្រះបាទបសេនទិកោសល ទ្រង់គង់ក្នុងទីសមគួរហើយ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះ ថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលទាំងឡាយណា ជាព្រះអរហត្ត ក្តី បណ្តាបុគ្គលទាំងនោះ ជាអ្នកដល់នូវព្រះអរហត្តមគ្គក្តី ក្នុង លោក បណ្តាបុគ្គលទាំងនោះ លោកអស់ទាំងនេះ ជាព្រះអរហន្ត មួយដែរ ។

ព្រះអង្គត្រាស់តបថា បពិត្រមហារាជ ពាក្យថា បុគ្គលពួក នោះ ជាព្រះអរហត្តក្តី បុគ្គលពួកនេះ ដល់នូវព្រះអរហត្តមគ្គក្តី ដូច្នេះនេះ ព្រះអង្គជាគ្រហស្ថ នៅបរិភោគកាម អាស្រ័យព្រះ ក្រឡាបន្ទំ ចង្អៀតដោយព្រះរាជបុត្រ ប្រើប្រាស់នូវខ្លឹមចន្ទន៍ដ៏ល្អិត ទ្រទ្រង់នូវកម្រងផ្កា គ្រឿងក្រអូបនិងគ្រឿងលាប ត្រេកអរនូវមាស ក៏ដឹងបានដោយក្រពេកណាស់ បពិត្រមហារាជ **សីល** បុគ្គល គប្បីដឹងបានដោយការនៅរួមគ្នា ក៏សីលនោះឯង បុគ្គលគប្បី ដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីទេ បុគ្គល ធ្វើទុកក្នុងចិត្តទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹង បានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិន

គប្បីដឹងបានឡើយ បពិត្រមហារាជ **សេចក្តីស្អាត** បុគ្គលគប្បីដឹងបានដោយសម្តី ឯសេចក្តីស្អាតនោះបុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីឡើយ បុគ្គលធ្វើទុកក្នុងចិត្តទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្តមិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញាទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ បពិត្រមហារាជ **កម្លាំងបញ្ញា** បុគ្គលគប្បីដឹងក្នុងពេលដែលមានសេចក្តីអន្តរាយ ឯកម្លាំងនោះបុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីឡើយបុគ្គលធ្វើទុកក្នុងចិត្តទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ បពិត្រមហារាជ **បញ្ញា** បុគ្គលគប្បីដឹងបានដោយការសាកសួរ ឯបញ្ញានោះ បុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីឡើយ បុគ្គលធ្វើទុកក្នុងចិត្ត ទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ ។

ព្រះបាទបសេនទិកោសលទូលថា បពិត្រព្រះអង្គដ៏ចំរើន

អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រមហារាជ ពាក្យនេះព្រះអង្គជាគ្រហស្ថ នៅបរិភោគកាម ដឹងបានដោយកម្រ ( **សីល** បុគ្គលគប្បីដឹងបានដោយការនៅរួមគ្នា ក៏សីលនោះឯង បុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីទេ បុគ្គលធ្វើទុកក្នុងចិត្តទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញាមិនគប្បីដឹងបានឡើយ បពិត្រមហារាជ **សេចក្តីស្អាតបុគ្គលគប្បីដឹងបានដោយសម្តី** ឯសេចក្តីស្អាតនោះបុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលឡើយ បុគ្គលធ្វើទុកក្នុងចិត្តទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបានបុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ បពិត្រមហារាជ **កម្លាំងបញ្ញា** បុគ្គលគប្បីដឹងក្នុងពេលដែលមានសេចក្តីអន្តរាយ ឯកម្លាំងនោះ បុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីឡើយ បុគ្គលធ្វើទុកក្នុងចិត្ត ទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយ បុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិន

គប្បីដឹងបានឡើយ បពិត្រមហារាជ **បញ្ញា** បុគ្គលគប្បីដឹងបាន ដោយការសាកសួរ ឯបញ្ញានោះ បុគ្គលគប្បីដឹងបានដោយកាលវែង មិនគប្បីដឹងបានដោយកាលខ្លីឡើយ បុគ្គលធ្វើទុកក្នុងចិត្ត ទើបដឹងបាន បុគ្គលមិនធ្វើទុកក្នុងចិត្ត មិនគប្បីដឹងបានឡើយបុគ្គលមានបញ្ញា ទើបដឹងបាន បុគ្គលឥតបញ្ញា មិនគប្បីដឹងបានឡើយ ) ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកបុរសរបស់ខ្ញុំព្រះអង្គទាំងនេះ ជាអ្នកឈ្លបដើររករឿង បានដឹងរឿងអ្នកជនបទរួចត្រឡប់មកវិញ កាលបើបុរសទាំងនោះ យករឿងបានមុនហើយ ទើបខ្ញុំព្រះអង្គពិនិត្យជាខាងក្រោយ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ បុរសទាំងនោះ បានបន្សាត់បង់នូវធូលីនិងមន្ទិលនោះ ងូតដោយស្រួលបួស លាបដោយប្រពៃ ហើយកោរសក់និងពុកមាត់ ស្លៀកសំពត់មានពណ៌ស ឱ្យគេបម្រើឆ្អែតស្កប់ស្កល់ ដោយកាមគុណទាំង ៥ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវសេចក្តីនុ៎ះហើយ ទើបត្រាស់នូវគាថាទាំងឡាយនេះ ក្នុងវេលាថា ៖

ន វណ្ណរូបេន នរោ សុជានោ
ន វិស្សសេ ឥត្តរទស្សនេន

សុសញ្ញតានម្ហិ វិយញ្ជនេន
អសញ្ញតា លោកមិមំ ចរន្តិ
បដិរូបកោ មត្តិកកុណ្ឌលោ ច
លោហឌ្ឍមាសោ ច សុវណ្ណឆន្នោ
ចរន្តិ លោកេ បរិវារឆន្នា
អន្តោ អសុទ្ធា ពហិ សោភមានាតិ ។

*ជនមិនមែនមានជាតិល្អ ដោយសម្បុរនិងរូបទេ បុគ្គលមិនត្រូវស្និទ្ធស្នាលដោយការឃើញភ្លាមទេ ព្រោះថា ពួកជនមិនសង្រួមត្រាច់ទៅក្នុងលោកនេះបាន ដោយសារភណ្ឌបរិក្ខាររបស់ពួកជនដែលសង្រួមល្អ កុណ្ឌល ជាវិការនៃដី មានរូបប្រៀបដូចជាកុណ្ឌ-លមាសក្តី មាសកជាវិការៈនៃលោហៈ ស្រោបដោយមាសក្តី (យ៉ាងណា) ជនទាំងឡាយមានបរិវារហែហម មិនស្អាតខាងក្នុង ស្អាតតែខាងក្រៅ តែងត្រាច់ទៅក្នុងលោកបាន (យ៉ាងនោះដែរ) ។*

## អដ្ឋកថា

*បទថា* បុព្វារាមេ មិគារមាតុបាសាទេ *មិគារមាតុប្រាសាទក្នុងបុព្វារាម បានដល់ លើប្រាសាទរបស់នាងវិសាខា*

មាតារបស់មិគារសេដ្ឋី ក្នុងវិហារដែលឈ្មោះថា **បុព្វារាម** ។ ក្នុងរឿងបុព្វារាមនោះលំដាប់សេចក្ដីដូច្នេះ ។

## រឿងបុព្វារាម

គ្រាអតីតកាល រាប់ទៅមួយសែនកប្ប ឧបាសិកាម្នាក់និមន្ត ព្រះមានព្រះភាគ ព្រះនាមថា **បទុមុត្តរៈ** ថ្វាយទានដល់ភិក្ខុមួយ-សែនរូប មានព្រះពុទ្ធជាប្រធាន ក្រាបទៀបព្រះបាទរបស់ព្រះមានព្រះភាគធ្វើសេចក្ដីប្រាថ្នាថា "ខ្ញុំព្រះអង្គសូមជាឧបដ្ឋាយិកាដ៏ប្រសើររបស់ព្រះពុទ្ធ ដូចនឹងព្រះអង្គក្នុងអនាគតកាលផងចុះ ។ តមកនាងត្រាច់អន្ទោល ( វិលវល់ស្លាប់កើត ) ក្នុងពួកទេវតានិងមនុស្សដល់សែនកប្ប ចាប់បដិសន្ធិក្នុងគភ៌នាងសុមនទេវី ក្នុងផ្ទះរបស់ធនញ្ជយសេដ្ឋី បុត្រមេណ្ឌកសេដ្ឋីក្នុងភទ្ទិយនគរ ក្នុងសាសនារបស់ព្រះមានព្រះភាគរបស់យើង ។ វេលាកើតបិតាមាតាតាំងនាមថា វិសាខា ។ គ្រាមួយ ព្រះមានព្រះភាគស្ដេចយាងមកភទ្ទិយនគរ គ្រានោះ នាងព្រមដោយក្មេងស្រី ៥០០ នាក់ ក៏នឹងទទួលស្ដេច ព្រះមានព្រះភាគបានជាសោតាបន្ន ក្នុងការជួបគ្រាដំបូងតែម្ដង ។ តមកនាងទៅកាន់ផ្ទះ( មានផ្ទះ )របស់បុណ្ណ-

វឌ្ឍនកុមារ បុត្រមិគារសេដ្ឋី ក្រុងសាវត្ថី ។

ក្នុងទីនោះ មិគារសេដ្ឋីស្ថាបនានាងទុកក្នុងតំណែងមាតា ព្រោះដូច្នោះ នាងទើបត្រូវហៅថា មិគារមាតា ។ ក្នុងប្រាសាទ ដែលមិគារមាតាសាងហើយ ។

បទថា **ពហិទ្វារកោដ្ឋកេ** ត្រង់ក្លោងទ្វារខាងក្រៅគឺខាងក្រៅក្លោងទ្វារប្រាសាទ មិនមែនខាងក្រៅក្លោងទ្វារព្រះវិហារ ។ បានឮថា ប្រាសាទនោះលោមព័ទ្ធដោយកំពែង មានក្លោងទ្វារទុក ៤ ទ្វារ ដោយជុំវិញដូចលោហប្រសាទ ។ បណ្ដាក្លោងទ្វារទាំង ៤ នោះ ព្រះមានព្រះភាគគង់លើពុទ្ធអាសនៈដ៏ប្រសើរត្រួតមើលលោកធាតុផ្នែកខាងកើត ក្រោមម្លប់របស់ប្រាសាទខាងក្រៅក្លោងទ្វារខាងកើត ។

បទថា **បរុឡ្ហកច្ឆនខលោមា** មានរោមក្លៀក មានក្រចកនឹងរោមឯទៀតដុះវែង ៗ បានដល់ មានរោមក្លៀកដុះហើយ មានក្រចកដុះហើយ មានរោមដុះហើយ អធិប្បាយថា មានរោមវែងត្រង់ក្លៀកជាដើម និងមានក្រចកវែង ។

បទថា **ខារិវិវិធំ** វែកអម្រែកផ្សេង ៗ បានដល់ អម្រែកវែក

វត្ថុដែលជាបរិក្ខាររបស់អ្នកបួស ប្រភេទផ្សេង ៗ ។

បទថា **អវិទូរេ អតិក្កមន្តិ** ដើរជិត ( ព្រះមានព្រះភាគ ) ហើយហួសទៅ បានដល់ ចូលទៅកាន់ព្រះនគរដោយផ្លូវនេះមិនឆ្ងាយ ។

បទថា **រាជាហំ ភន្តេ** បពិត្រលោកដ៏ចម្រើន ខ្ញុំជាព្រះរាជា សេចក្តីថា លោកម្ចាស់ ខ្ញុំគឺព្រះបាទបសេនទិកោសល សូមលោកទាំងឡាយចូរជ្រាបនាមរបស់ខ្ញុំចុះ ។

សួរថា ព្រោះហេតុអ្វី ព្រះរាជាប្រថាប់អង្គុយក្នុងសំណាក់របស់បុគ្គលដែលកំពូលលើសហើយ នៅតែទ្រង់ផ្គងអញ្ជលីដល់អ្នកបួសអាក្រាតអ្នកគ្មានសិរីបែបនោះហ្ន៎ ។

ឆ្លើយថា ព្រោះដើម្បីប្រយោជន៍ដល់ការសង្គ្រោះ ។ ពិតមែន ព្រះរាជានោះទ្រង់ព្រះត្រិះរិះយ៉ាងនេះថា បើយើងនឹងមិនធ្វើអញ្ជលីសូម្បីត្រឹមតែប៉ុណ្ណោះ ដល់អ្នកបួសទាំងនោះសោត អ្នកបួសពួកនោះ ក៏នឹងគិតថា "អស់កម្លាំង យើងលះកូនប្រពន្ធទៅសោយទុក្ខ មានស៊ីនិងដេកលំបាកជាដើម ដើម្បីប្រយោជន៍ដល់ព្រះអង្គ ព្រះរាជាអង្គនេះ ក៏មិនធ្វើសូម្បីត្រឹមតែអញ្ជលីដល់យើង

ដូច្នេះហើយ ក៏នឹងបិទបាំងវត្ថុដែលឃើញ ដែលស្តាប់មកដោយខ្លួនឯងហើយ មិនព្រមប្រាប់ តែកាលយើងធ្វើអញ្ជលីយ៉ាងនេះហើយពួកគេក៏នឹងមិនបិទបាំងព្រមប្រាប់" ព្រោះដូច្នោះ ព្រះរាជាទើបទូលយ៉ាងនេះ ។ ម្យ៉ាងទៀត ទ្រង់ធ្វើយ៉ាងនេះ ក៏ដើម្បីទ្រង់ជ្រាបអធ្យាស្រ័យរបស់ព្រះសាស្តា ។

បទថា កាសិកចន្ទនំ ខ្លឹមចន្ទន៍ដែនកាសី បានដល់ ព្រមទាំងចន្ទន៍ដែលល្អិត ។

បទថា មាលាគន្ធវិលេបនំ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប បានដល់ ទ្រទ្រង់ផ្កាឈើដើម្បីប្រយោជន៍ដល់ពណ៌និងក្លិនរបស់ក្រអូបដើម្បីប្រយោជន៍ដល់ភាពជារបស់ក្រអូប និងគ្រឿងលាបស្រឡាប ក៏ដើម្បីប្រយោជន៍ដល់ពណ៌និងក្លិន ។

បទថា សំវាសេន ដោយការនៅព្រម គឺ ដោយការនៅរួមគ្នា ។

បទថា សីលំ វេទិតព្វំ សីលបុគ្គលគប្បីដឹងបាន បានដល់ កាលនៅរួមគ្នា ជិតកៀកគ្នាក៏គប្បីជ្រាបបានថា អ្នកនេះមានសីល

គឺ ប្រក្រតីល្អ ឬប្រក្រតីអាក្រក់ ។

បទថា តញ្ច ខោ ទីឃេន អទ្ធុនា ន ឥត្តរំ នោះ គប្បីដឹងដោយកាលវែង មិនមែនខ្លី សេចក្តីថា ក៏សីលនោះបុគ្គលគប្បីដឹងដោយកាលយូរ ៗ មិនមែនបន្តិចបន្តួច ។ ជាការពិតអាការសង្រួមនិងអាការរបស់អ្នកសង្រួមឥន្ទ្រិយ អាចសម្តែងចេញមក ២-៣ ថ្ងៃ ។

បទថា មនសិករោតា ធ្វើទុកក្នុងចិត្ត សេចក្តីថា សីលសូម្បីនោះ អ្នកដាក់ចិត្ត ពិចារណាមើលថា យើងនឹងកំណត់កាន់យកសីលរបស់អ្នកនោះក៏អាចដឹងបាន ក្រៅនេះក៏ដឹងមិនបាន ។

បទថា បញ្ញវតា បុគ្គលមានបញ្ញា សេចក្តីថា សីលនោះដែលបណ្ឌិតអ្នកមានបញ្ញាប៉ុណ្ណោះទើបដឹងបាន ព្រោះថា អ្នកល្ងង់ខ្លៅទោះជាដាក់ចិត្តក៏មិនអាចនឹងដឹងបាន ។

បទថា សំវោហារេន ដោយពាក្យសំដី គឺ ដោយការសន្ទនាគ្នា ។ វោហារក្នុងពាក្យនេះថា ៖

យោ ហិ កោចិ មនុស្សេសុ វោហារំ ឧបជីវតិ

ឯវំ វាសេដ្ឋ ជានាហិ វាណិជោ សោ ន ព្រាហ្មណោ ក្នុងពួកមនុស្សណាម្នាក់ អាស្រ័យការទិញលក់ចិញ្ចឹមជីវិតម្នាល វាសេដ្ឋៈ លោកចូរដឹងយ៉ាងនេះថា អ្នកនោះជាពាណិជ មិនមែនព្រាហ្មណ៍ ដូច្នេះ ។

ឈ្មោះថា សំវោហារ ។វោហារ ក្នុងពាក្យនេះថា អរិយ-វោហារ ៤ អនរិយវោហារ ៤ ឈ្មោះថា ចេតនាវោហារ ។ វោហារក្នុងពាក្យនេះថា សង្ខ្យាការរាប់, សាមញ្ញាការតាំងឈ្មោះ, បញ្ញត្តិវោហារ វោហារ គឺការបញ្ញត្តិ, ឈ្មោះថា បញ្ញត្តិវោហារ ។ វោហារក្នុងពាក្យនេះថា អ្នកនោះគប្បីនិយាយ ដោយត្រឹមតែថាវោហារ ឈ្មោះថា កថាវោហារ ។ សូម្បីក្នុងទីនេះក៏ប្រាថ្នាយកកថា វោហារនេះប៉ុណ្ណោះ ។ ពិតមែន ពាក្យនិយាយចំពោះមុខរបស់អ្នកខ្លះ មិនសមនឹងពាក្យនិយាយកំបាំងមុខនិងពាក្យនិយាយកំបាំងមុខ មិនសមនឹងពាក្យនិយាយចំពោះមុខ ពាក្យនិយាយមុននឹងពាក្យនិយាយក្រោយ និងពាក្យនិយាយក្រោយនឹងពាក្យនិយា-យមុន ក៏ដូចគ្នា អ្នកនោះ ដែលអ្នកនិយាយជាមួយប៉ុណ្ណោះ អាចដឹងបានថា បុគ្គលនេះមិនស្អាត ។ ចំណែកពាក្យមុននឹងពាក្យ

ក្រោយរបស់អ្នកមានសេចក្ដីស្អាតជាប្រក្រតីនិងពាក្យក្រោយនឹង ពាក្យមុនដែលគេនិយាយចំពោះមុខ រមែងសមនឹងពាក្យដែលគេ និយាយកំបាំងមុខ និងពាក្យនិយាយកំបាំងមុខ ក៏សមនឹងពាក្យ និយាយដែលគេនិយាយចំពោះមុខ ព្រោះដូច្នោះព្រះមានព្រះភាគ

កាលទ្រង់ប្រកាសថា អ្នកនិយាយអាចដឹងភាពជាអ្នក ស្អាតបាន ទើបត្រាស់យ៉ាងនេះ ។

បទថា **ថាមោ** កម្លាំង បានដល់ កម្លាំងនៃញាណ ។ ពិតមែន កម្លាំងញាណរបស់អ្នកណាមិនមាន កាលកើតឧបទ្រវន្ត-រាយឡើងអ្នកនោះក៏មើលមិនឃើញការកាន់យកវត្ថុដែលគួរកាន់ កិច្ចដែលគួរធ្វើ រមែងប្រព្រឹត្តដូចចូលទៅកាន់ផ្ទះដែលងងឹតឈឹង ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ កម្លាំងបញ្ញា បុគ្គលគប្បីដឹងបានក្នុងពេលមានអន្តរាយ ។

បទថា **សាកច្ឆាយ** ការសាកសួរ បានដល់ ការ សន្ទនាគ្នា ។ ពិតមែនពាក្យរបស់អ្នកខ្សោយបញ្ញារមែងអណ្ដែត អណ្ដូងដូចឆ្នុកអណ្ដែតទឹកបដិភាណរបស់អ្នកមានបញ្ញានិយាយ មិនមានទីបំផុត ។ ជាការពិតដោយអាការដែលទឹករញ្ជួយ គេក៏

ដឹងបានថា ត្រីតូចឬធំ ។

បទថា ឱចរកា ធ្លាប់ដើររករឿង បានដល់ ប្រព្រឹត្ត ខាងក្រោម ( ក្រោមដី ) ពិតមែន ពួកចារបុរស សូម្បីនឹងប្រព្រឹត្ត នៅតាមកំពូលភ្នំ ក៏ឈ្មោះថា ប្រព្រឹត្តទាំងនោះឯង ។

បទថា ឱចរិត្វា បានដឹងរឿង បានដល់ប្រព្រឹត្តទាបថោក សាកល្បងហើយ សេចក្ដីថា ដឹងរឿងនោះ ៗ ។

បទថា រជោជល្លំ ធូលីកំទេច គឺ ធូលីនិងកំទេច ។

បទថា វណ្ណរូបេន ដោយពណ៌សម្បុរនិងរូប បានដល់ ដោយពណ៌សម្បុរនិងទ្រង់ទ្រាយ ។

បទថា ឥត្តរទស្សនេន ដោយការឃើញភ្លាម បានដល់ ការឃើញគ្នាបន្តិចបន្តួច ។

បទថា វិយញ្ជនេន គឺ បរិក្ខារភណ្ឌកេន ដោយសារ-ភណ្ឌបរិក្ខារ ។

បទថា បដិរូបកោ មត្តិកាកុណ្ឌលោ ច កុណ្ឌលជាវិការនៃដី មានរូបប្រៀប បានដល់ ក្រវិលត្រចៀកមាសបួម ក្រវិលត្រចៀកដី ។

បទថា លោហាឡមាសោ មាសកៈជាវិការនៃលោហៈ បាន ដល់ មាសកធ្វើដោយលោហៈ ។

## ទោសនៃការសេពគប់បុគ្គលពាល

១- រមែងដឹកនាំឱ្យទៅក្នុងខុស

២- រមែងកើតសេចក្ដីវិនាស ហិនហោចការងាររលាយអស់

៣- រមែងសម្លឹងឃើញក្នុងផ្លូវអាក្រក់ មិនបានទទួលការ ទុកចិត្តពីមនុស្សទូទៅ

៤- រមែងពិបាកចិត្ត ព្រោះបុគ្គលពាលសូម្បីយើងនិយាយ ពាក្យល្អ ៗក៏ខឹងក្រោធ

៥- ពួកគណៈរមែងបែកបាក់សាមគ្គី ព្រោះការព្រុះញង់ និងមិនព្រមទទួលស្គាល់របៀបវិន័យ

៦- ភ័យអន្តរាយផ្សេង ៗរមែងហូរមកដល់ខ្លួន

៧- កាលលះលោកនេះទៅ រមែងមានអបាយភូមិជាទី កើតជាដើម ។

# រឿងកូនសេក

បានឮមកថា ក្នុងអតីតកាល បានមានកូនសត្វសេក ២ បងប្អូននឹងគ្នា( នៅ )ក្នុងព្រៃរកា ក្បែរសានុបពត៌ ។ ក៏ក្នុងទីលើខ្យល់នៃបព្វតាបានមានផ្ទះជាទីនៅអាស្រ័យរបស់ចោរ៥០០នាក ក្នុងទីខាងក្រោមខ្យល់ មានអាស្រមជាទីនៅអាស្រ័យរបស់តាបសឥសី ៥០០ រូប ។ ក្នុងពេលដែលរោមស្លាបរបស់កូនសត្វសេកទាំងឡាយ មិនទាន់ដុះនៅឡើយ ក៏មានខ្យល់ព្យុះកំបុតត្បូងកើតឡើងហើយ ។ កូនសេកទាំង ២ នោះត្រូវខ្យល់ព្យុះកំបុតត្បូងនោះ ផាត់ទៅធ្លាក់ហើយ( ក្នុងទី )ផ្សេង ៗពីគ្នា ។ បណ្ដាកូនសេកទាំង ២ នោះ កូនសេក ១ បានធ្លាក់ទៅក្នុងចន្លោះនៃគ្រឿងសស្រាវុធ ក្នុងផ្ទះរបស់ចោរ ព្រោះធ្លាក់ទៅក្នុងទីនោះ ទើបពួកចោរដាក់ឈ្មោះថា **សត្តិគុម្ព** ធាត់ធំឡើងហើយក្នុងចន្លោះនៃពួកចោរទាំងនោះ ។ កូនសេក ១ បានធ្លាក់ទៅក្នុងចន្លោះនៃផ្កាឈើលើផ្ទៃនៃវាលដីខ្សាច់ ក្បែរអាស្រម ព្រោះហេតុដែលធ្លាក់ទៅក្នុងទីនោះ ទើបបានពួកតាបសឥសី ដាក់ឈ្មោះថា បុប្ផក: បានធាត់ធំឡើងហើយក្នុងចន្លោះនៃពួកតាបសឥសីទាំងនោះ ។

ក្នុងគ្រានោះព្រះរាជាទ្រង់ព្រះនាមបញ្ចាលៈក្នុងនគរឈ្មោះ **ឧត្តរបញ្ចាលៈ** ទ្រង់ប្រដាប់គ្រឿងអលង្ការសព្វគ្រប់ហើយ ទ្រង់ស្តេចយាងឡើងកាន់ព្រះរាជរថយាងទៅកាន់ព្រៃ ដើម្បីទ្រង់បរបាញ់សត្វ ហើយទ្រង់មានព្រះរាជឱង្ការថា សត្វម្រឹគរត់ចេញទៅតាមប្រឡោះនៃបុគ្គលណា បុគ្គលនោះឯង នឹងត្រូវមានទោស ( អាជ្ញា ) ដូច្នេះហើយទ្រង់ស្តេចយាងចុះអំពីព្រះរាជរថ ទ្រង់បានគង់កាន់ផ្ទះក្នុងទីកំបាំងហើយ ។ ក្នុងខណៈនោះ ម្រឹគទ្រាយ ១ កាលបើពួកមនុស្សកំពុងវាយគុម្ពោតព្រៃ ក៏បានក្រោយឡើងសំឡឹងរកមើលផ្លូវដើម្បីនឹងទៅ ក៏ឃើញថា ទីស្ថានដែលព្រះរាជាទ្រង់គង់នៅប៉ុណ្ណោះជាកន្លែងស្រឡះ( ទំនេរ ) ទើបបែរមុខឆ្ពោះទៅទិសខាងនោះ ហើយស្ទុះបោលគេចទៅ ពួកមនុស្សក៏បានធ្វើការបំអកជាមួយនឹងព្រះរាជាហើយ ។ ព្រះអង្គទ្រង់តាំងព្រះទ័យថា អញនឹងចាប់ម្រឹគទ្រាយនោះឱ្យបានក្នុងពេលឥឡូវនេះ ហើយទើបស្តេចទ្រង់ឡើងរាជរថ ហើយទ្រង់ដេញតាមម្រឹគទ្រាយទៅយ៉ាងលឿន ។ ពួកបុរសមិនអាចតាមជាប់ព្រះអង្គបានឡើយ ។ ព្រះរាជាទ្រង់មាននាយសារថីជាគម្រប់២ ទតមិនឃើញម្រឹគទ្រាយ

ហើយ ទើបទ្រង់ស្តេចយាងត្រឡប់មកវិញ ទ្រង់ស្រង់ទឹក និង សោយទឹកក្នុងជ្រោះភ្នំដែលជាទីគួរមនោរម្យ ហើយស្តេចទ្រង់បន្ទំក្រោមម្លប់ឈើ ក្បែរផ្ទះនៃចោរ ។

គ្រានោះពួកចោរក៏បានចូលទៅកាន់ព្រៃទាំងអស់គ្នាហើយ ខាងក្នុងផ្ទះនៅសល់តែសេកឈ្មោះសត្តិគុម្ពៈ ជាមួយនឹងអ្នកចំអិនភត្តម្នាក់ ។ សេកសត្តិគុម្ពៈ ហើរចេញពីផ្ទះឃើញព្រះរាជាទ្រង់បន្ទំយ៉ាងដូច្នោះហើយ ក៏( ហើរ )ចូលផ្ទះ បាននិយាយជាភាសាមនុស្សជាមួយនឹងអ្នកដាំស្លថា ពួកយើងនឹងសម្លាប់ព្រះរាជាចោលប្រមូលយកសំពត់នឹងគ្រឿងអលង្ការរបស់ព្រះអង្គ ហើយចាប់ព្រះអង្គត្រង់កព្រះបាទទាញអូសមក ហើយយកស្លឹកឈើទាំងឡាយ មកគ្របបិទបាំងក្នុងទីកន្លែងមួយ ។ ព្រះរាជាទ្រង់តើនពីព្រះបន្ទំហើយទ្រង់ព្រះសណ្តាប់សំឡេងនោះទ្រង់ជ្រាបថា ទីកន្លែងនេះមានភ័យចំពោះមុខ” ហើយទ្រង់មានព្រះទ័យភ័យខ្លាច ទើបទ្រង់ស្តេចឡើងកាន់រាជរថ ហើយទ្រង់ចៀសចេញពីទីនោះ ស្តេចយាងទៅដល់អាស្រមរបស់តាបសឥសីហើយ ។ ក្នុងគ្រានោះពួកតាបសឥសី ទៅហើយដើម្បីប្រយោជន៍ដល់ផលាផល ក្នុង

អាស្រមនៅសល់តែសត្វសេកឈ្មោះ បុប្ផកៈប៉ុណ្ណោះ ។ សត្វសេក ឈ្មោះបុប្ផកៈនោះឃើញព្រះរាជាហើយ ក៏បានធ្វើនូវបដិសណ្ឋារៈ ដោយន័យមានជាដើមថា ៖

**បពិត្រព្រះមហារាជ ព្រះអង្គទ្រង់ស្តេចយាងមកប្រពៃហើយ មួយទៀត ព្រះរាជដំណើររបស់ព្រះអង្គមិនមែនទាស់ទេ ។**

ព្រះរាជា ទ្រង់មានព្រះទ័យជ្រះថ្លា ក្នុងបដិសណ្ឋាររបស់សត្វសេកឈ្មោះបុប្ផកៈនោះហើយ ទ្រង់ត្រាស់សរសើរនូវសេកឈ្មោះបុប្ផកៈ ទ្រង់បានតិះដៀលនូវសេកឈ្មោះ សត្តិគុម្ពៈ ក្រៅនេះដោយព្រះតម្រាស់ថា ៖

**សត្វបក្សីជាតិ ២ នេះ ជាសត្វដ៏ល្អប្រកបដោយធម៌ដ៏ក្រៃលែងតើហ្ន៎ ចំឡែកតែបក្សីសេកក្រៅពីនេះ និយាយតែពាក្យអាក្រក់ ។**

សេកឈ្មោះបុប្ផកៈ ស្តាប់នូវព្រះរាជាឱង្ការនោះហើយទើបបានក្រាបទូលថា បពិត្រព្រះមហារាជ ទូលព្រះបង្គំមានមាតាជាមួយគ្នានឹងសត្វសេកសត្តិគុម្ពនោះ, ប៉ុន្តែសេកសត្តិគុម្ពនោះ ធាត់

ធំឡើងហើយ ក្នុងសំណាក់នៃពួកមនុស្សមិនល្អ ត្រូវពួកមនុស្សមិនល្អទាំងនោះដឹកនាំហើយដោយចោរធម៌ (ចំណែក)ទូលព្រះបង្គំជាត់ធំឡើយហើយ ក្នុងសំណាក់មនុស្សល្អ ត្រូវបានពួកមនុស្សល្អទាំងនោះដឹងនាំហើយដោយឥសីធម៌ ហេតុនោះ ទើបទូលព្រះបង្គំទាំង ២ ផ្សេងពីគ្នាដោយធម៌ ដូច្នេះហើយកាលសម្តែងធម៌ដល់ព្រះរាជា ទើបបានពោលគាថាទាំងនេះថា ៖

បពិត្រព្រះរាជា ពិតណាស់ បុគ្គលគប់រកនូវបុគ្គលបែបណា ៗ ទោះជាសប្បុរស ឬអសប្បុរស មានសីល ឬឥតសីល រមែងលុះក្នុងអំណាចបុគ្គលនោះឯង ។ បុគ្គលធ្វើបុគ្គលបែបណាឱ្យជាមិត្រ និងចូលទៅគប់រកនូវបុគ្គលបែបណា បុគ្គលនោះក៏មានអាការៈបែបនោះដែរ ព្រោះកិរិយានៅរួម ក៏រមែងប្រាកដដូច្នោះ ។ អាចារ្យត្រូវកូនសិស្សគប់រក រមែងប្រឡាក់នូវកូនសិស្សអ្នកគប់រក ត្រូវកូនសិស្សប៉ះពាល់ ដែលមិនបានប្រឡាក់ហើយប្រៀបឧបមាដូចជាកូនសរ ដែលជ្រលក់ដោយថ្នាំពិស តែងប្រឡាក់បំពង់សរដូច្នោះឯង ព្រោះភ័យខ្លាចអំពីការប្រឡាក់ អ្នកប្រាជ្ញទើបមិនយកបុគ្គលលាមក ជាសំឡាញ់សោះឡើយ ។ ជន

ណាខ្ចប់នូវត្រីស្អុយដោយចុងស្បូវភ្លាំង,សូម្បីស្បូវភ្លាំងក៏មានក្លិនស្អុយផ្សាយចេញទៅដែរ យ៉ាងណាមិញ ការចូលទៅសេពគប់នូវបុគ្គលពាល( របស់ជននោះ )ក៏យ៉ាងដូច្នោះដែរ ។

ជនណាខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ សូម្បីស្លឹកឈើក៏មានក្លិនក្រអូបផ្សាយចេញទៅដែរ យ៉ាងណាមិញ, ការចូលទៅសេពគប់នូវអ្នកប្រាជ្ញ ( របស់ជននោះ )ក៏យ៉ាងនោះដូច្នោះដែរ ។

ព្រោះហេតុនោះ បុគ្គលជាបណ្ឌិតដឹងច្បាស់នូវបញ្ញាចាស់ទុំរបស់ខ្លួន ដូចជាកញ្ចប់ស្លឹកឈើហើយ មិនគួរសេពគប់នូវពួកអសប្បុរស គួរសេពគប់តែពួកសប្បុរស ( ត្បិត )ពួកអសប្បុរសតែងនាំទៅកាន់នរក ពួកសប្បុរសតែងផ្តល់នូវសុគតិ ។

បណ្តាបទទាំងនោះ បទថា សន្តំ បានដល់សប្បុរស ។ បទថា អសំ បានដល់អសប្បុរស ។ បទថា សេវមានោ បានដល់ អាចារ្យ ។ បទថា សេវមានំ បានដល់អន្តេវាសិក ។ បទថា សម្ផុដ្ឋោ បានដល់ អាចារ្យដែលអន្តេវាសិកពាល់ត្រូវហើយ ។ ពីរបទថា សម្ផុសំ បរំ បានដល់បុគ្គលដទៃគឺអន្តេ-

វាសិកដែលប៉ះពាល់នូវអាចារ្យ ។ បទថា អលិត្តំ មានសេចក្តីថា អាចារ្យនោះរមែងប្រឡាក់នូវអន្ទេវាសិកនោះ ជាអ្នកដែលបាបធម៌មិនបានប្រឡាក់ហើយ ប្រៀបដូចជាកូនសរដែលកំណាចគឺ ដែលជ្រលក់ហើយដោយថ្នាំពិស ប្រឡាក់នូវបំពង់សរដែលមិនបានប្រឡាក់យ៉ាងដូច្នោះឯង ។ ពិតណាស់ បុគ្គលអ្នកសេពគប់នូវបុគ្គលពាល សូម្បីមិនបានធ្វើនូវអំពើអាក្រក់ ក៏រមែងបានទទួលនូវការពោលតិះដៀល និងការនិន្ទាថា ជាអ្នកសេពគប់ជាមួយនឹងបុគ្គលពាល ដូច្នេះដែរ ។ ហេតុនោះទើបសេកបុប្ផកៈពោលថា **ឯវំ ពាលូបសេវនា** ។ (ចំណែក)បុគ្គលអ្នកសេពគប់ជាមួយនឹងអ្នកប្រាជ្ញ សូម្បីមិនអាចដើម្បីនឹងកើតជាអ្នកប្រាជ្ញបានក៏រមែងបានទទួលនូវឈ្មោះ សំឡេងដ៏ល្អថាជាអ្នកសេពគប់ជាមួយនឹងកល្យាណមិត្រ ដូច្នេះដែរ ។ ហេតុនោះ ទើបសេកបុប្ផកៈពោលថា **ឯវំ ធីរូបសេវនា** ។

បទថា **បត្តបុដស្សេវ** គឺដូចជាស្លឹកឈើដែលសម្រាប់ខ្ចប់នូវគន្ធជាតិ មានក្រស្នាជាដើមនុ៎ះឯង ។

បទថា សម្បាកំ គឺជីងថា ខ្លួនអប់រំហើយដោយអំណាចនៃការជាប់ជំពាក់ជាមួយនឹងកល្យាណមិត្រ ។

បទថា សណ្តោ មានសេចក្តីថា ពួកជនជាសម្មាទិដ្ឋិរមែងញុំាងពួកសត្វដែលអាស្រ័យខ្លួនឱ្យដល់ឋានសួគ៌តែម្យ៉ាង ។ ព្រះរាជាទ្រង់ជ្រះថ្លាហើយ ក្នុងធម្មកថារបស់សត្វសេកបុប្ផកៈនោះទ្រង់ថ្វាយបង្គំនូវពួកតាឥសីដែលត្រឡប់មកវិញ ហើយទ្រង់មានព្រះរាជឱង្ការថា "**បពិត្រព្រះគុណម្ចាស់ដ៏ចម្រើនទាំងឡាយ បើព្រះគុណម្ចាស់ទាំងឡាយ អនុគ្រោះយើងខ្ញុំក៏សូមគង់នៅក្នុងនគររបស់យើងខ្ញុំ**"ដូច្នេះហើយ ក៏ស្តេចយាងទៅកាន់ព្រះនគរទ្រង់ព្រះរាជទានអភ័យដល់សត្វសេកទាំងឡាយហើយទ្រង់ត្រាស់ឱ្យគណៈតាឥសីដែលមកហើយ ក្នុងព្រះនគរនោះនៅក្នុងព្រះរាជឧទ្យានទ្រង់បានទំនុកបម្រុងរហូតអស់ព្រះជន្មាយុហើយ ទ្រង់បំពេញផ្លូវទៅកាន់ឋានសួគ៌ ។ ចំណែកសត្វសេកបុប្ផកៈអាស្រ័យនៅក្នុងព្រៃទៅតាមយថាកម្មហើយ ។

( រឿងសត្វសេក ក្នុងអដ្ឋកថាសត្តិគុម្ពជាតក ក្នុងវីសតិនិបាត )

# រឿងដំរីឈ្មោះមហិឡាមុខ

ក្នុងអតីតកាល ព្រះរាជាព្រហ្មទត្តក្នុងព្រះនគរពារាណសី បានមានដំរីមង្គល ឈ្មោះមហិឡាមុខ ជាសត្វមានសីលបរិបូណ៌ ដោយមារយាទ មិនចេះបៀតបៀនអ្នកណាម្នាក់ឡើយ ។

ក្រោយមក ថ្ងៃមួយ ក្នុងពេលរាត្រី ពួកចោរមកហើយ បានអង្គុយប្រឹក្សាគ្នា នៅក្បែររោងដំរីរបស់ព្រះរាជាអង្គនោះថា ពួកយើងត្រូវទំលាយឧមង្គ( រូង ) យ៉ាងដូច្នេះ ត្រូវធ្វើកម្មគឺការ កាត់ទីតយ៉ាងដូច្នេះ ការដែលពួកយើងទំលាយនូវឧមង្គនិងធ្វើការ កាត់ទីតហើយលួចយកនូវភណ្ឌទើបគួរ កាលនឹងលួចយកត្រូវតែ សម្លាប់និងវាយដំ( ម្ចាស់ទ្រព្យ ) ហើយទើបលួចយកទៅ កាល ធ្វើយ៉ាងនេះ នឹងមិនមានអ្នកណាអាចដើម្បីនឹងក្រោកឡើង( បាន ) ក៏ធម្មតាចោរមិនត្រូវមានសីលាចារវត្តឡើយ ត្រូវតែជាអ្នកកំណាច ឃោរឃៅ កាចសាហាវដូច្នេះ ។ ពួកចោរទាំងនោះប្រឹក្សាគ្នា យ៉ាងដូច្នេះហើយក៏បានណាត់គ្នាទៅវិញទៅមកស្រេច ទើបនាំគ្នា ទៅហើយ ។ ពួកចោរទាំងនោះមកប្រឹក្សាគ្នាក្នុងទីនោះ ដោយ ឧបាយនេះឯងអស់ជាច្រើនថ្ងៃ ។

ដំរីបានស្តាប់ពាក្យរបស់ពួកចោរទាំងនោះហើយ ក៏សម្គាល់ថា ពួកចោរទាំងនោះញុំាងអញឱ្យសិក្សា ហើយគិតថា"ក្នុងពេលឥឡូវនេះ អញត្រូវតែជាសត្វកំណាចកាចឃោរឃៅ សាហាវដូច្នេះហើយ ក៏បានទៅជាសត្វយ៉ាងដូច្នេះហើយ ។ ដំរីនោះបានយកប្រមោយចាប់អ្នកថែរក្សាដំរីដែលមកហើយ ។ អំពីព្រឹកព្រលឹមស្រាង បោកទៅលើផែនដីឱ្យស្លាប់ហើយ ។

ពួកមនុស្សបានក្រាបទូលហើយដល់ព្រះរាជា ។ ព្រះរាជាទ្រង់បានបញ្ជូននូវអាមាត្យម្នាក់ទៅ ដោយព្រះរាជឱង្ការថា នែបណ្ឌិតអ្នកចូរទៅចុះចូល( ពិនិត្យ )ឱ្យដឹងថាព្រោះហេតុអ្វី ?បានជាដំរីនោះក្លាយទៅជាសត្វកាចសាហាវដូច្នេះ" ។

អាមាត្យនោះទៅហើយ ក៏មិនឃើញមានរោគ ក្នុងខ្លួននៃដំរីទើបគិតថា ដំរីនេះ បានកាចសាហាវហើយ ព្រោះហេតុអ្វី ? ដូច្នេះ កាលពិចារណាទៅ ទើបធ្វើការសន្និដ្ឋានថា ដំរីនោះ ពិតជាបានស្តាប់ពាក្យអាក្រក់របស់ជនពួកខ្លះក្នុងទីមិនឆ្ងាយ ដោយពិត ទើបបានក្លាយទៅជាសត្វកាចសាហាវ ហើយបានសួរពួកជនអ្នកថែរក្សាដំរីថា តើមានបុគ្គលណាខ្លះធ្លាប់និយាយអ្វី ៗ ក្នុង

ពេលរាត្រីនៅក្បែររោងដំរីដែរឬទេ ? ។ ពួកអ្នកថែរក្សាដំរីពោលថា បពិត្រនាយ មានពួកចោរបានមកប្រឹក្សាគ្នា ។ អាមាត្យនោះទៅហើយក្រាបទូលថា បពិត្រព្រះសម្មតិទេពក្នុងខ្លួនដំរីមិនមានការចំឡែកអ្វីដទៃឡើយ ដំរីនោះបានស្តាប់ពាក្យរបស់ពួកចោរហើយទើបបានជាសត្វកាចសាហាវ ឥឡូវនេះគួរតែនិមន្តពួកសមណៈនិងព្រាហ្មណ៍ អ្នកមានសីលឱ្យគង់អង្គុយនៅក្បែររោងដំរី ហើយសូត្ររឿងសីលនិងមារយាទ ។ ព្រះរាជាទ្រង់ត្រាស់ឱ្យធ្វើហើយយ៉ាងដូច្នោះ ។ សមណៈនិងព្រាហ្មណ៍ទាំងឡាយនោះបានពោលរឿងសីលថា អ្នកមិនគួរចាប់អ្នកណាឡើយ មិនគួរសម្លាប់ អ្នកណាម្នាក់ឡើយ គួរជាអ្នកបរិបូរណ៍ដោយសីល និងមារយាទប្រកបដោយខន្តី មេត្តា និងសេចក្តីអនុគ្រោះ ។ ដំរីស្តាប់ពាក្យនោះហើយ ទើបសម្គាល់ថា សមណៈនិងព្រាហ្មណ៍ទាំងនេះញ៉ាំងអញឱ្យសិក្សា ហើយគិតថាតាំងតែអំពីពេលនេះទៅ អញត្រូវតែមានសីលដូច្នេះហើយ ក៏បានក្លាយទៅជាសត្វមានសីលហើយ ។ កាចសាហាវ ឥឡូវនេះគួរតែនិមន្តពួកសមណៈ និងព្រាហ្មណ៍អ្នកមានសីលឱ្យគង់អង្គុយនៅក្បែរ រោងដំរីហើយសូត្ររឿងសីល

និងមារយាទ" ។ ព្រះរាជាទ្រង់ត្រាស់ឱ្យធ្វើហើយយ៉ាងដូច្នោះ ។ សមណៈ និងព្រាហ្មណ៍ទាំងឡាយនោះបានពោលរឿងសីលថា អ្នកមិនគួរចាប់អ្នកណាឡើយ មិនគួរសម្លាប់អ្នកណាម្នាក់ឡើយ គួរជាអ្នកបរិបូរណ៍ ដោយសីល និងមារយាទប្រកបដោយខន្តីមេត្តានិងសេចក្តីអនុគ្រោះ ។ ដំរីស្តាប់ពាក្យនោះហើយ ទើបសម្គាល់ថា សមណៈនិងព្រាហ្មណទាំងនេះ ញ៉ាំងអញឱ្យសិក្សាហើយ គិតថា តាំងតែអំពីពេលនេះទៅអញត្រូវតែមានសីលដូច្នេះហើយ ក៏បានក្លាយទៅជាសត្វមានសីលហើយ ។

## រឿងសេះឈ្មោះបណ្ឌវៈ

ក្នុងអតីតកាល បានមានព្រះរាជាទ្រង់ព្រះនាមថា **សាមៈ** ក្នុងក្រុងពារាណសី ។ ព្រះពោធិសត្វបានជាអាមាត្យអ្នកបង្រៀនអត្ថនិងធម៌របស់ព្រះរាជាអង្គនោះ ។ ក៏ព្រះរាជាទ្រង់មានសេះមង្គលឈ្មោះ **បណ្ឌវៈ** ។ អ្នកគង្វាលសេះរបស់ព្រះអង្គឈ្មោះ **គិរិទត្ត** ជាមនុស្សខ្វិក ។ សេះឃើញអ្នកគង្វាលសេះនោះចាប់ខ្សែបង្ហៀរ ( ដឹក ) នាំមុខ ហើយក៏សម្គាល់ថា អ្នកគង្វាលសេះនេះញ៉ាំងអញឱ្យសិក្សា ដូច្នេះហើយ ទើបយកតម្រាប់តាមអាការៈ

របស់អ្នកគង្វាលសេះនោះបានក្លាយទៅជាសេះខ្ចកហើយ ។ ព្រះរាជាទ្រង់ជ្រាបថា សេះរបស់ព្រះអង្គនោះខ្ចកហើយ ទើបទ្រង់បានត្រាស់បញ្ជូនពេទ្យទៅ ( ឱ្យត្រួតពិនិត្យមើល ) ។ ពួកពេទ្យទាំងនោះទៅហើយ មិនឃើញរោគនៅក្នុងខ្លួនរបស់សេះនោះ ទើប ( ត្រឡប់មក )ក្រាបទូលព្រះរាជាថា ទូលព្រះបង្គំមិនឃើញរោគរបស់សេះនោះទេ ។ ព្រះរាជាទ្រង់បញ្ជូននូវព្រះពោធិសត្វទៅដោយព្រះរាជឱង្ការថា ចូរអ្នកទៅ( ត្រួតពិនិត្យមើលឱ្យ ) ដឹងនូវហេតុក្នុងដំណើរនោះ ។ ព្រះពោធិសត្វនោះទៅហើយបានដឹងថាសេះនោះដើរខ្ចក ៗ ព្រោះការជាប់ទាក់ទងជាមួយគ្នានឹងអ្នក គង្វាលសេះជើងខ្ចកយ៉ាងដូច្នេះ ក្រាបទូលថា បពិត្រព្រះមហារាជ សេះមានជើងខ្ចកយ៉ាងដូច្នោះ ព្រោះទោសនៃការជាប់ទាក់ទងជាមួយគ្នា ដូច្នេះហើយ ទើបបានក្រាបទូលថា សេះនោះបាននូវអ្នកគង្វាលសេះដែលល្អហើយ ក៏នឹងក្លាយជាសេះដូចដើមវិញ ។ ព្រះរាជាទ្រង់ត្រាស់បញ្ជាឱ្យធ្វើហើយយ៉ាងដូច្នោះ ។ សេះបានតាំងនៅក្នុងភាពប្រក្រតីហើយ ។

( រឿងសេះបណ្ឌវៈ ក្នុងអដ្ឋកថាគិរិទត្តជាតក ក្នុងទុកនិបាត )

## មកសជាតក

(កូនយកពូថៅវាយក្បាលឪពុក)

ព្រះបរមសាស្តា កាលដែលព្រះអង្គទ្រង់យាងទៅកាន់ភូមិអ្នកស្រុកមួយក្នុងដែនមគធៈ ទ្រង់ប្រារព្ធពួកមនុស្សមួយចំនួនក្នុងភូមិនោះ ជាបុគ្គលពាលល្ងង់ខ្លៅ ទើបព្រះអង្គទ្រង់ត្រាស់ព្រះធម៌ទេសនានេះថា **សេយ្យោ អមិត្តោ** ដូច្នេះជាដើម ។

បានស្តាប់មកថា ក្នុងសម័យមួយ ព្រះតថាគតព្រះអង្គយាងចេញចាកពីព្រះនគរសាវត្ថី ទៅកាន់ដែនមគធៈទ្រង់បានយាងទៅដល់ភូមិមួយ ។ ក្នុងភូមិនោះសម្បូណ៌ទៅដោយជនអន្ធពាល ។ ថ្ងៃមួយពួកមនុស្សអន្ធពាលទាំងនោះ ប្រជុំប្រឹក្សាគ្នាថា ម្នាលគ្នាយើងពួកមូសវារោមខាំយើង ពេលដែលយើងទៅធ្វើការនៅក្នុងព្រៃ ព្រោះហេតុនោះ ការងាររបស់យើងត្រូវបានខាតបង់ដោយច្រើនដូច្នេះពួកយើងត្រូវនាំយកធ្នូនិងអាវុធផ្សេង ៗទៀត ឱ្យគ្រប់ដៃ នាំគ្នាទៅច្បាំងជាមួយហ្វូងមូសបាញ់សម្លាប់ និងកាប់ចាក់ឱ្យពួកវាស្លាប់អស់ រួចហើយក៏នាំគ្នាទៅព្រៃ ។ ពួកជនល្ងង់ខ្លៅទាំងនោះ នាំគ្នាសំដៅទៅរកសម្លាប់មូស បាញ់កាប់ចាក់សំពងត្រឡប់

ទៅជាប្រហារចំគ្នាឯងទៅវិញទៅមក ។ គ្រប់គ្នាត្រូវរបួសឈឺចាប់ត្រឡប់មកផ្ទះវិញ ដេកនៅក្នុងភូមិក៏មាន កណ្ដាលភូមិក៏មាន មាត់ទ្វារភូមិក៏មាន ។ ព្រះបរមសាស្ដា ហែហមដោយព្រះភិក្ខុសង្ឃ ស្ដេចចូលទៅកាន់ភូមិនោះដើម្បីបិណ្ឌបាត ។ ពួកមនុស្សដែលជាបណ្ឌិត បានឃើញព្រះដ៏មានព្រះភាគហើយ ទើបសាងមណ្ឌបនៅឯមាត់ទ្វារភូមិ ថ្វាយមហាទានដល់ព្រះភិក្ខុសង្ឃ មានព្រះសម្មាសម្ពុទ្ធជាប្រមុខ ថ្វាយបង្គំព្រះសាស្ដានាំគ្នាអង្គុយ ក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះបរមសាស្ដាទតព្រះនេត្រឃើញមនុស្សទាំងឡាយដួលដេកឈឺចាប់ក្នុងទីនោះ ៗ ក៏ត្រាស់សួរឧបាសកទាំងនោះថា មនុស្សទាំងនេះទៅធ្វើអ្វីគ្នា ទើបមកដេកឈឺចាប់ដោយមុខរបួសដូច្នេះ ? ឧបាសកទាំងនោះ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មនុស្សទាំងនេះ បបួលគ្នាថា ពួកយើងនឹងទៅច្បាំងជាមួយហ្វូងមូស ហើយក៏លើកគ្នាទៅ តែបែរជាទៅច្បាំងគ្នាឯងហើយក៏ដល់នូវការឈឺចាប់ដូច្នេះព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា មិនមែនតែក្នុងពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ធ្លាប់ មានមនុស្សគិតថា យើងនឹងប្រហារមូស តែត្រឡប់ទៅជាប្រហារអ្នកដទៃវិញដូចគ្នាដែរ ។ កាលដែលពួក

ឧបាសកទាំងនោះទូលអារាធនាហើយ ទ្រង់ក៏បាននាំយករឿងក្នុងអតីតកាលមកសម្ដែងដូចតទៅ ៖

ក្នុងអតីតកាល ពេលដែលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះបរមពោធិសត្វមានអាជីពជាអ្នកជំនួញ ។ សម័យនោះ នៅទីងភូមិជាយដែនមួយក្នុងដែនកាសីមានពួកជាងឈើអាស្រ័យនៅដោយច្រើនជាមួយគ្នា ។ មានជាងឈើក្បាលតម្ពែកម្នាក់ ក្នុងពួកជាងឈើទាំងនោះ កំពុងតែជាប់ដៃធ្វើការខណៈនោះមានមូសមួយ បានហើរមកខាំត្រង់ក្បាលរបស់គាត់ ។ ជាងឈើទើបប្រាប់កូនរបស់ខ្លួន ដែលអង្គុយនៅជិតគាត់នោះឯងថា នែកូន មូសវាខាំក្បាលឪ ឈឺដូចគេចាក់ដោយលំពែងអ៊ីចឹង ចូរកូនសម្លាប់វាឱ្យឪមើល៍ ! កូននិយាយថា ឪចូរនៅឱ្យស្ងៀម កូននឹងសម្លាប់វាដោយការប្រហារតែម្ដងប៉ុណ្ណោះ ។ កូននិយាយរួចហើយ ក៏លើកពូថៅផ្លែធំឡើង យារតម្រង់មូស ឈរនៅពីក្រោយឪ កាប់ពេញទំហឹងដៃ ដោយគិតថា អញនឹងសម្លាប់មូសនេះ ។ ក្បាលរបស់ឪក៏ត្រូវបែកដាច់ជាពីរ ស្លាប់ទៅក្នុងទីនោះឯង ។ ពេលនោះព្រះបរមពោធិសត្វ ដែលកំពុងឈប់សម្រាក

នៅក្នុងរោងជាងឈើនោះ បានឃើញអំពើរបស់កូនជាងឈើហើយ បានគិតថា បើបច្ចាមិត្តនោះជាបណ្ឌិតក៏នៅប្រសើរជាង ព្រោះគេមានការកោតក្រែងអាជ្ញាក្នុងព្រះនគរ មិនដល់ថ្នាក់សម្លាប់មនុស្សឡើយ ហើយព្រះបរមពោធិសត្វ បានពោលនូវគាថានេះថា ៖

សេយ្យោ អមិត្តោ មតិយា ឧបេតោ
ន ត្វេវ មិត្តោ មតិវិប្បហីនោ
មកសំ វធិស្សន្តិ ហិ ឯលមូគោ
បុត្តោ បិតុ អព្ភិទា ឧត្តមង្គន្តិ ។

បុគ្គលជាសត្រូវ តែប្រកបដោយប្រាជ្ញា ប្រសើរជាង ឯបុគ្គលជាមិត្ត ដែលប្រាសចាកប្រាជ្ញាមិនប្រសើរឡើយ ដូចយ៉ាងកូនបង្កើតដែលល្ងង់ខ្លៅ គិតថាអញនឹងសម្លាប់មូសត្រឡប់ជាពុះបំបែកក្បាលឪទៅវិញ ។

បណ្តាបទទាំងនោះ បទថា សេយ្យោ ដោយសេចក្តីថា ប្រសើរ គឺខ្ពង់ខ្ពស់បំផុត ។

បទថា មតិយា ឧបេតោ ដោយសេចក្តីថា ប្រកបដោយបញ្ញា ។

បទថា **ឯលមូគោ** ប្រែថា ល្ងីល្ងើ គឺល្ងង់ខ្លៅ ។

បទថា **បុត្តោ បិតុ អភិន្ទា ឧត្តមង្គំ** ដោយសេចក្ដីថា ព្រោះភាពនៃខ្លួនជាមនុស្សល្ងង់ខ្លៅ សូម្បីជាកូន គិតថាយើងនឹងសម្លាប់មូស ក៏ញុំាងក្បាលឪពុកឱ្យបែកជាពីរ ព្រោះហេតុនោះបណ្ឌិតសូម្បីតែជាសត្រូវ ក៏នៅល្អជាងមិត្តដែលល្ងង់ល្ងីល្ងើ ។

ព្រះបរមពោធិសត្វ កាលដែលពោលនូវគាថានេះហើយ ក៏ក្រោកឡើងទៅធ្វើការងារតាមតួនាទី ។ ឯពួកញាតិរបស់អ្នកស្លាប់ ក៏បានចាត់ការធ្វើសរីរកិច្ចរបស់ជាងឈើដែលបានទទួលមរណភាពនោះឯង ។

ព្រះបរមសាស្ដា ព្រះអង្គត្រាស់ថា ម្នាលអ្នកទាំងឡាយ សូម្បីក្នុងកាលមុន ក៏ធ្លាប់មានមនុស្សដែលបានគិតថា យើងនឹងប្រហារមូស តែត្រឡប់ជាប្រហារអ្នកដទៃវិញដូចគ្នាដែរ ។ កាលដែលទ្រង់នាំយកព្រះធម៌ទេសនានេះ មកសម្ដែងហើយ ព្រះអង្គក៏បន្តអនុសន្ធិប្រជុំជាតកថា ឈ្មួញបណ្ឌិតដែលពោលគាថាហើយ ចេញទៅបានមកជាតថាគតនេះឯង ។

## អត្ថគួរជ្រាប

គួរខ្លាចសេចក្ដីល្ងង់របស់ខ្លួនឯង ជាងខ្លាចសេចក្ដីល្ងង់នៃអ្នកដទៃ ព្រោះថា បុគ្គលល្ងង់ខ្លៅជាកំពូលសត្រូវនឹងខ្លួនឯង ។

មនុស្សល្ងង់ មិនដឹងហេតុនៃផល មិនដឹងផលរបស់ហេតុ គិតថាធ្វើប្រយោជន៍ បែរទៅជាទម្លាយប្រយោជន៍ដែលមានហើយទៅវិញ ។ មនុស្សល្ងង់រស់នៅជាមួយខ្លួនឯង តែមិនស្គាល់ខ្លួនឯង រស់នៅជាមួយអ្នកដទៃ តែមិនស្គាល់អ្នកដទៃ ដូចជាជន្លេនមិនស្គាល់ដី ត្រីមិនស្គាល់ទឹកដូច្នោះឯង ។ មនុស្សល្ងង់មានចិត្តតែមិនស្គាល់ចិត្ត គ្រប់គ្រងទូន្មានចិត្តរបស់ខ្លួនមិនបាន បែរទៅជាល្ងីល្ងើ ចង់គ្រប់គ្រងចិត្តអ្នកដទៃ ម្ល៉ោះហើយត្រូវកើតទុក្ខក្ដៅក្រហាយ រីងរៃ ព្រោះគ្រប់គ្រងមិនបាន ។

## ប្រភេទនៃបុគ្គលពាល

ពាលមាន ២ ប្រភេទគឺ ៖

**១- ពាលខាងក្រៅ** គឺមនុស្សពាលទូទៅ ពាលនេះ សូម្បីអាក្រក់យ៉ាងណាក៏ដោយ ក៏យើងអាចរកផ្លូវគេចចេញបាន តែនៅមានពាលមួយប្រភេទទៀតដែលក្រៃលែងអាក្រក់ ព្រោះ

វាកើតឡើងដោយមិនដឹងខ្លួន និងមិនមានផ្លូវជៀសចេញបានគឺពាលខាងក្នុង ។

**២. ពាលខាងក្នុង** គឺខ្លួនយើងនឹងឯងពេលដែលគិតអាក្រក់ និយាយអាក្រក់ ធ្វើអាក្រក់ ដូចជា គេចពីការងារខ្លះ ដើរលេងខិតខូចខ្លះ ចូលចិត្តទៅធ្វើការងារយឺតពេលខ្លះ ពួកមនុស្សទាំងឡាយ ដាស់តឿនពាក្យល្អ ៗក៏មានការខឹងក្រោធខ្លះ ជៀសវាងនូវវិនិច្ឆ័យខ្លះ និយាយមិនពីរោះខ្លះ ពេលណាយើងធ្វើដូច្នេះគ្រានោះ យើងជាបុគ្គលពាល មានជាតិពាលនៅខាងក្នុង ដូច្នេះត្រូវប្រញាប់ដោះស្រាយឱ្យបានឆាប់ ដោយការខិតខំអប់រំចិត្ត ឱ្យស្ថិតនៅក្នុងព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ មានសតិស្មារតីក្នុងការធ្វើនូវអ្វី ៗគ្រប់យ៉ាង មិនចំពោះតែការដេក ដើរ ឈរ អង្គុយនោះទេ ហើយត្រូវចេះពិចារណាឱ្យឃើញអំពីទុក្ខ ទោសគ្រប់យ៉ាងដែលកើតពីការធ្វើអំពើអាក្រក់ទៅតាមកាយទ្វារ វចីទ្វារ និង មនោទ្វារ ទើបយើងអាចគេចផុតអំពីពាលខាងក្នុងបាន ។

## ពាល និង បណ្ឌិត

*បុគ្គលពាល* គឺជាបុគ្គលគ្មានដឹងបាបបុណ្យគុណទោសអ្វីឡើយ តែងតែប្រព្រឹត្តអំពើអាក្រក់ដោយកាយ វាចា ចិត្ត កាត់ប្រយោជន៍ខ្លួននិងប្រយោជន៍អ្នកដទៃ កាត់ប្រយោជន៍ជាតិនេះ និងប្រយោជន៍ជាតិខាងមុខ ជាពិសេសកាត់ប្រយោជន៍ព្រះនិព្វាន ការរំលត់ទុក្ខ ។ **ឯបុគ្គលជាបណ្ឌិត** ឬសប្បុរសមានលក្ខណៈផ្ទុយពីបុគ្គលពាល គឺ បុគ្គលជាបណ្ឌិតតែងតែប្រព្រឹត្តអំពើល្អដោយកាយវាចាចិត្ត ផ្តល់សេចក្តីសុខដល់ខ្លួនផងដល់អ្នកដទៃផង ។ តួយ៉ាងដូចព្រះសម្មុទ្ធ ជាអគ្គបណ្ឌិតព្រះអង្គកសាងខ្លួនព្រះអង្គឱ្យបានត្រាស់ជាព្រះពុទ្ធ បន្ទាប់មកព្រះអង្គទេសនាប្រោសព្រះញាតិ និងប្រោសមនុស្សសត្វជាទូទៅដែលមានឧបនិស្ស័យគួរឱ្យព្រះអង្គប្រោសបាន ។ ពាក្យចាស់បុរាណខ្មែរ ក៏មាននិយាយច្រើនពីលក្ខណៈ បុគ្គលពាលនិងបុគ្គលបណ្ឌិត ឬសប្បុរសដូចពាក្យខ្លះតទៅនេះ ។ **នៅជិតសប្បុរស សុខស្រួលទាំងអស់ ឥតមានភិតភ័យ នៅជិតជនពាល មានតែទោសពៃរ៍ ទុក្ខព្រួយរាល់ថ្ងៃ មិនបានក្តីសុខ ។ នៅជិតជនពាលដូចភ្លើងឆេះ**

**ពាលនេះព្រៃព្រឹក្សា ដូចសត្វមានពិសក្លាខ្លាំងអស្ចារ្យ បង្កទុក្ខា រាល់ពេលវេលា ។** ជនពាលសាមាន្យឃោរឃៅឈ្លានពាន **មិនមានមេត្តា ជននោះតែងជួបនឹងទុក្ខទោសា ឈឺចាប់ខ្លោចផ្សា មិនដែលជៀសបាន ។** បាបពុំទាន់ឱ្យផលដល់កាលណា ពាលគិតថាបាបនោះដូចទឹកឃ្មុំ លុះបាបកម្មឱ្យផលដល់ប្រជុំទើបពាលរងទុក្ខធំដល់កាលនោះ ។ ព្រៃគ្មានសត្វជិត ប្រទេសគ្មានបណ្ឌិត ទ្វីបឥតសាសនា គ្រឹហាឥតបុត្រស្រុកគ្មានជាតិជា មេឃឥតចន្ទ្រា សូន្យចក្រវាឡ ។ ត្រង់នេះសំដៅយកទ្វីបលោក បើគ្មានសីលធម៌ និងព្រះពុទ្ធសាសនាទេ ទ្វីបលោកនឹងត្រូវវិនាសដោយសារគ្មានធម៌មេត្តា បៀតបៀនកាប់សម្លាប់គ្នា ។ កង្កែបនៅក្នុងអណ្តូងទឹក ស្មានមេឃតូចប៉ុនគ្របឆ្នាំង បុគ្គលល្ងិតល្ងង់ អវិជ្ជាបាំងតែងតាំងខ្លួនថាប្រសើរឯក ។ ជាតិជាអ្នកស្ទាត់ស្ទៀមកិរិយា មិនចេញក្អេងក្អាងឯសន្តានពាល ចេញឫកអាងយ៉ាងក្លាត់ស្មៀតប្រងាង ព្រោះព្រុសមិនឈប់ ។ ឈ្លោះនឹងពាលពិបាកបន្តិច ហើយកុំស្មានឡើយថាពាលស្តាប់សព្ទវាចា ទុកជាវែកញែកខុសត្រូវទៅផ្លូវណាក៏ពាលពោលថា គេមិនស្តាប់ច្បាប់អ្វីទេ ។ **ទោសគេតូចឆ្មារ**

**ថ្កោលថាជាធំ ទោសឯងប៉ុនភ្នំ មិនយល់ថាទោស ។** ពាក្យបុរាណពោលឱ្យប្រយ័ត្នថា អ្វីដែលជាសត្រូវពីមុនមក ត្រូវលៃលកមើលឱ្យជាក់ការរាក់ជ្រៅ កុំប្រហែសធ្វេសជឿចិត្តមនុស្សឃោរឃៅ គំនុំចងជាប់នៅស្និទ្ធឥតរសាយ ។ គុណទាំងឡាយទាំងអស់ ជារបស់មានក្នុងប្រាជ្ញ ឯទោសពាលកំណាចជាធម្មជាតិមានក្នុងខ្លៅ ។ ពស់កាចមានពិសទោះវាខាំពេទ្យកែដោយថ្នាំអាចស្ងប់បាន មនុស្សកាចលើសពស់ពិស សាមាន្យគ្មានអ្វីកែបានស្ងប់ស្ងាត់ឡើយ ។ **វិស័យពេលថ្ងៃលំអអាទិត្យ ពេលយប់ងងឹតលំអចន្ទ្រា អំពើបាបលំអពួកពាលា កុសលធម្មាលំអសប្បុរស ។** ណែនាំជនពាលឱ្យធ្វើល្អ ពាលមិនត្រេកអរ ប៉ុនចុងសក់ ពាលរឹតបានចិត្តធ្វើអាក្រក់ ភូតភរកុហកថែមខ្លាំងក្លា ។ ប៉ុន្តែមានមនុស្សពាលខ្លះ អាចកែខ្លួនធ្វើល្អបន្ទាប់ពីបាន ស្ដាប់ពាក្យទូន្មានរបស់ពួកលោកអ្នកសប្បុរស ។ កូនប្រុសស្រី ចូរចងចាំបុរាណបានផ្ដាំផ្ដាច់ទុកថា ប្រដៅជនពាលដោយអាជ្ញា ឃុំឃាំងប្រហារ ទើបវាខ្លាច ។ ប៉ុន្តែមានបុគ្គលពាលខ្លះ មិនបាច់ប្រើអាជ្ញាគ្រាន់តែណែនាំពន្យល់ប្រាប់ហេតុផលល្អ អាក្រក់ ក៏ខ្លាចលែង

ហ៊ានធ្វើអាក្រក់ ។ មុននឹងធ្វើទារុណកម្មទៅលើគេ ត្រូវអ្នកផ្ទេរប្តូរមកដាក់រូបអ្នកសិន បើមិនគិតចេះតែសង្កត់សង្កិន ឱ្យគេហីនដោយសារឯងមិនក្រែងខ្លាច ។ ត្រង់នេះមានន័យថា មុននឹងធ្វើទារុណកម្មដល់ជនណាម្នាក់ ត្រូវប្រៀបធៀប កំហុសរបស់ខ្លួនទៅនឹងអ្នកនោះសិន ។ ដូចបានពោលមកហើយ លក្ខណៈរបស់បុគ្គលពាល និង បុគ្គលជាបណ្ឌិតតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធក្តី តាមពាក្យចាស់បុរាណខ្មែរ ទោះបីពាក្យនេះ មិនត្រឹមត្រូវដូចពុទ្ធភាសិតក្តី ក៏បានជាមេរៀនថា បុគ្គលត្រូវតែសេពគប់បុគ្គលជាបណ្ឌិត កុំសេពគប់បុគ្គលពាល ។ ជាពិសេសទៅទៀត គ្រប់ដំណោះស្រាយជម្លោះក្នុងគ្រួសារក្តី ក្នុងប្រទេសជាតិក្តី ក្នុងសហគមនអន្តរជាតិក្តី ត្រូវដោះស្រាយដោយគតិបណ្ឌិត កុំដោះស្រាយតាមគតិពាល ។ ដំណោះស្រាយគតិពាល គឺ ការប្រើហិង្សាកាប់សម្លាប់គ្នា ជាមធ្យោបាយយកឈ្នះចាញ់គ្នា ព្រះពុទ្ធសំដែងថា មធ្យោបាយនេះ មិនអាចបញ្ចប់ការវិវាទគ្នាឡើយ ។ ដំណោះស្រាយតាមគតិបណ្ឌិត គឺដោះស្រាយតាមសន្តិវិធី ឈរលើច្បាប់ទម្លាប់របស់ប្រទេស ។

# គោលធម៌បដិបត្តិក្នុងជីវិតប្រចាំថ្ងៃ

**១- ហាមឃាត់ចិត្តរបស់យើងឱ្យចេញពីសេចក្តីអាក្រក់សូម្បីត្រឹមតែបន្តិចបន្តួច មុនពេលវាកើតឡើង** ដូចជាការដេកភ្ញាក់យឺត ឬមិនសម្អាតទីកន្លែងឱ្យស្អាត ។

**២- កុំតាមនឹកដល់សេចក្តីអាក្រក់ សេចក្តីខុសភ្លាត់អំពីអតីត** ទាំងរឿងរបស់ខ្លួនឯងនឹងរបស់បុគ្គលដទៃរឿងដែលកន្លងទៅហើយឱ្យវាកន្លងទៅ នេះជាមេរៀនមួយសម្រាប់យើង ហើយតាំងចិត្តធ្វើសេចក្តីល្អឱ្យច្រើនតទៅទៀត ដើម្បីទទួលបានមកវិញនូវសេចក្តីសុខដ៏យ៉ាងពិតប្រាកដ ។

**៣- តាំងចិត្តឱ្យទាន រក្សាសីល ចម្រើនសមាធិភាវនាឱ្យបានល្អ** ដើម្បីជាមាគ៌ាឆ្ពោះទៅរកសេចក្តីសុខស្ងប់ ទាំងនៅក្នុងបច្ចុប្បន្ននិងទៅបរលោកនាយ រហូតដល់បានសម្រេចនូវទិសដៅនៃជីវិតពោលគឺព្រះនិព្វាន ។

**៤- ជៀសវាងការអាន ការស្តាប់ ការនិយាយ រឿងទាក់ទងនឹងបុគ្គលពាល** នឹងបានមិនសន្សំការគិតទាក់ទិនជាមួយ

បុគ្គលពាលទុកក្នុងចិត្ត ព្យាយាមសន្សំការគិតដែលល្អស្អាត ដោយការអាន ការស្ដាប់ ការនិយាយតែវត្ថុដែលល្អស្អាត ដូចជាការអានសៀវភៅធម៌ ស្ដាប់ធម៌ទេសនា សន្ទនាធម៌ និយាយដល់បុគ្គលដែលមានគុណលើយើងជាដើម ។

**៥. បើចាំបាច់ត្រូវនៅជិតបុគ្គលពាលហើយ មិនមានផ្លូវជៀសវាងបាន** ដូចជា ធ្វើការក្នុងទីជាមួយគ្នា ជាញាតិមិត្តបងប្អូនគ្នា ក្នុងករណីដូចនេះយើងត្រូវរលឹកឱ្យឃើញថា យើងកំពុងតែនៅជិតវត្ថុដែលជាអន្តរាយ ត្រូវចេះការពារខ្លួនកុំឱ្យមានភាពជាបុគ្គលពាលចូលខ្លួន **ហើយត្រូវឧស្សាហ៍បំពេញទានរក្សាសីល ធ្វើសមាធិដើម្បីឱ្យចិត្តផូរផង់ ។**

***៦. យើងត្រូវរលឹកឱ្យឃើញថា មុខនាទីដែលក្រៃលែង*** **នឹងសំខាន់ជាទីបំផុតក្នុងជីវិតរបស់យើង មិនមានអ្វីក្រៃលែងជាងការបង្ក្រាបពាលខាងក្នុងខ្លួនរបស់យើងឡើយ ។**

## សត្វសេពគប់រាប់អានគ្នាជាមិត្តភក្តិដោយធាតុ

នៅក្នុងលោកនេះ មានមនុស្សច្រើនណាស់ ដែលមានរូបរាងសណ្ឋានប្រហាក់ ប្រហែលគ្នា ហើយក៏មានចិត្ត គំនិតប្រហាក់ប្រហែលគ្នាដែរ តែព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ថា សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ជាមួយពួកជនមានសទ្ធា, ត្រូវគ្នា សមគ្នា ជាមួយពួកជនមានសីល, ត្រូវគ្នា សមគ្នា ជាមួយពួកជនមានចិត្តខ្មាសបាប, ត្រូវគ្នា សមគ្នា ជាមួយពួកជនមានចិត្តខ្លាចបាប, ត្រូវគ្នា សមគ្នា ជាមួយពួកជនមានចិត្តមិនខ្មាសបាប,ត្រូវគ្នា សមគ្នា ជាមួយពួកជនមិនមានចិត្តខ្មាសបាប, ត្រូវគ្នា សមគ្នា ជាមួយពួកជនមិនមានចិត្តខ្មាសបាប, ត្រូវគ្នា សមគ្នា ជាមួយពួកជនមិនមានចិត្តខ្លាចបាប,ត្រូវគ្នា សមគ្នា ជាមួយពួកជនមានបញ្ញា, ត្រូវគ្នា សមគ្នា ជាមួយពួកជនអ្នកវង្វេងស្មារតី,ត្រូវគ្នា សមគ្នា ជាមួយពួកជនអ្នកវង្វេងស្មារតី, ត្រូវគ្នា សមគ្នា ជាមួយពួកជនអ្នកខ្ជិលប្រអូស, ត្រូវគ្នា សមគ្នា ជាមួយពួកជនអ្នកខ្ជិលប្រអូស,ត្រូវគ្នា សមគ្នា ជាមួយពួកជនអ្នកប្រារព្ធព្យាយាម, ត្រូវគ្នា សមគ្នា ជាមួយពួកជនអ្នកប្រារព្ធព្យាយាម,

ត្រូវគ្នា សមគ្នា ជាមួយពួកជនអ្នកមានស្មារតីតម្កល់មាំ, ត្រូវគ្នា សមគ្នា ជាមួយគ្នាពួកជនអ្នកមានស្មារតីតម្កល់មាំជាដើម[១] ។

## ចង្កមសូត្រ

នៅក្នុងបិដកលេខ ៣២ ទំព័រ ៣៣ ព្រះអង្គទ្រង់សម្ដែងព្រះសូត្រមួយ [**ដែលនិយាយអំពីការចង្រ្កមរបស់ភិក្ខុច្រើនរូប**] ដែលមានសេចក្ដីថា ៖

សម័យមួយព្រះមានព្រះភាគទ្រង់គង់ក្បែរភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ ក្នុងសម័យនោះឯង ព្រះសារីបុត្រមានអាយុ កំពុងចង្រ្កមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះមហាមោគ្គល្លានមានអាយុ កំពុងចង្រ្កមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះមហាកស្សបមានអាយុកំពុងចង្រ្កមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះអនុរុទ្ធមានអាយុកំពុងចង្រ្កមក្នុងទីជិតព្រះមានព្រះភាគជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះបុណ្ណមន្តានីបុត្រមានអាយុ កំពុងចង្រ្កមក្នុងទីជិតព្រះមានព្រះភាគ ជា

---

១. សុត្តន្តបិដកភាគ ៣២ ។

មួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះឧបាលិមានអាយុកំពុងចង្ក្រម ក្នុងទីជិតព្រះមានព្រះភាគជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ព្រះអានន្ទមានអាយុ កំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូប ទេវទត្តកំពុងចង្ក្រមក្នុងទីជិតព្រះមានព្រះភាគ ជាមួយនឹងភិក្ខុទាំងឡាយច្រើនរូបដែរ ។

គ្រានោះឯង ព្រះមានព្រះភាគត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញសារីបុត្រកំពុងចង្ក្រមជាមួយភិក្ខុច្រើនរូបដែរឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា ព្រះករុណាព្រះអង្គ ។

**ព.** ( ព្រះអង្គ ) ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះជាអ្នកមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញមហាមោគ្គល្លាន កំពុងចង្ក្រមជាមួយភិក្ខុច្រើនរូបដែរឬ ។

**ភិ.** ( ភិក្ខុ ) ព្រះករុណា ព្រះអង្គ ។

**ព.** ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះ ជាអ្នកមានឫទ្ធិច្រើន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញមហាកស្សបកំពុងចង្ក្រមជាមួយភិក្ខុច្រើនរូបដែរឬ ។

**ភិ.** ព្រះករុណា ព្រះអង្គ ។

**ព.** ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះ ជាធុតវាទ (អ្នកពោលពាក្យកំចាត់បង់កិលេស) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញអានុរុទ្ធ កំពុងចង្ក្រមជាមួយភិក្ខុច្រើនរូបដែរឬ ។

**ភិ.** ព្រះករុណា ព្រះអង្គ ។

**ព.** ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះ ជាអ្នកបានទិព្វចក្ខុ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញបុណ្ណមន្តានីបុត្រ កំពុងចង្ក្រមជាមួយភិក្ខុច្រើនរូបដែរឬ ។

**ភិ.** ព្រះករុណា ព្រះអង្គ ។

**ព.** ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះ ជាធម្មកថិក ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញឧបាលិ កំពុងចង្ក្រមជាមួយភិក្ខុច្រើនរូបដែរឬ ។

**ភិ.** ព្រះករុណា ព្រះអង្គ ។

**ព.** ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះ ជាវិនយធរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញអានន្ទ កំពុងចង្ក្រមជាមួយភិក្ខុច្រើនរូបដែរឬ ។

ភិ. ព្រះករុណា ព្រះអង្គ ។

ព. ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះជាពហុស្សូត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញទេវទត្ត កំពុងចង្រ្កមជាមួយភិក្ខុច្រើនរូបដែរឬ ។

ភិ. ព្រះករុណា ព្រះអង្គ ។

ព. ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នោះ ជាអ្នកមានសេចក្តីប្រាថ្នាលាមក ។

៦. ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយត្រូវគ្នា សមគ្នា[1] ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នាជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យា-ស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីតកាល សត្វទាំងឡាយត្រូវគ្នាសមគ្នាដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជន

---

១. ស្មើគ្នា ប្រហែលគ្នា ។

មានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមាន
អធ្យាស្រ័យល្អ ។

៦. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអនាគតកាល សត្វ
ទាំងឡាយ នឹងត្រូវគ្នា នឹងសមគ្នា ដោយធាតុ គឺពួកជនមាន
អធ្យាស្រ័យថោកទាប នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជន
មានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អនឹងត្រូវ
គ្នា នឹងសមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

៦. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងបច្ចុប្បន្នកាលនេះ សត្វ
ទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមានអធ្យាស្រ័យ
ថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជន មានអធ្យាស្រ័យ
ថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយ
នឹងពួកជនមានអធ្យាស្រ័យល្អ ។

## អដ្ឋកថា

បទថា បស្សថ នោ **អ្នកទាំងឡាយឃើញដែរឬ** គឺ
លោកឃើញឬទេ ។

បទថា សព្វេតេ ឯតេ **ភិក្ខុទាំងអស់នុ៎ះ** សេចក្តីថា ព្រះ

មានព្រះភាគ ទ្រង់តាំងព្រះសារីបុត្តត្ថេរទុកក្នុងឯតទគ្គៈ ក្នុងបណ្តាភិក្ខុអ្នកមានបញ្ញាថា "ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកមានប្រាជ្ញាច្រើន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងព្រះសារីបុត្រប្រសើរជាងគេ"[១] ។ ពួកភិក្ខុអ្នកដែលមានបញ្ញាច្រើន រមែងហែហមព្រះថេរៈនោះ ដោយគិតថាយើងនឹងសួរបញ្ហាដែលជ្រាលជ្រៅដែលកម្ចាត់ត្រែនូវលក្ខណៈបានហើយ ក្នុងលំដាប់ខន្ធធាតុ អាយតនៈសតិប្បដ្ឋាន និងពោធិបក្ខិយធម៌ ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ រមែងតបបញ្ហាដែលគេសួរហើយ និងសួរហើយដល់ពួកភិក្ខុទាំងនោះ ដូចលាតនូវផែនដី ដូចលើកខ្សាច់អំពីភ្នំសិនេរុ ដូចទម្លាយភ្នំចក្រវាឡដូចលើកភ្នំសិនេរុឡើង ដូចពង្រីកអាកាសឱ្យធំទូលាយនិងដូចឱ្យព្រះចន្ទ និងព្រះអាទិត្យឡើងដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ មហាបញ្ញា" ភិក្ខុទាំងអស់នេះ សុទ្ធតែជាអ្នកមានបញ្ញាច្រើន ដូច្នេះ ។

---

១. ១.២. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៦/៥៣ ។

ព្រះមានព្រះភាគ ទ្រង់តាំងព្រះមហាមោគ្គល្លានៈទុកក្នុងឯតទគ្គៈក្នុងបណ្តាភិក្ខុដែលមានឫទ្ធិថា "ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកមានឫទ្ធិ ដែលជាសាវករបស់តថាគត ស្រេចនឹងព្រះមោគ្គល្លានប្រសើរជាងគេ"[១] ពួកភិក្ខុដែលមានឫទ្ធិ រមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរនូវបរិកម្មអានិសង្ស អធិដ្ឋានការធ្វើផ្សេង ៗ ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ តបបញ្ហាដែលគេសួរហើយនិងសួរហើយដល់ភិក្ខុទាំងនោះ ដោយន័យដែលពោលហើយ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ មហិទ្ធិកា ភិក្ខុទាំងអស់នោះ សុទ្ធតែជាអ្នកមានឫទ្ធិច្រើន ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះមហាកស្សបៈទុកក្នុងឯតទគ្គៈក្នុងបណ្តាភិក្ខុអ្នកធុតវាទថា "ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុអ្នកពោលពាក្យកំចាត់បង់កិលេស ដែលជាសាវករបស់

---

១. ១.២. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៦/៥៣ ។

តថាគតស្រេចនឹងព្រះមហាកស្សបៈប្រសើរជាងគេ”[២] ។ ពួកភិក្ខុដែលធុតវាទៈ រមែងហៅហាមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរនូវការបរិហារធុតង្គ អានិសង្សការសមាទាន ការអធិដ្ឋានសេចក្តីផ្សេងគ្នា ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះបានតបបញ្ហាដែលគេសួរហើយនិងសួរហើយ ឱ្យជាក់ច្បាស់យ៉ាងនោះដូចគ្នា ដល់ភិក្ខុទាំងនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សព្វេ ខោ ឯតេ ភិក្ខវេ ភិក្ខូ ធុតវាទា ម្នាលភិក្ខុទាំងឡាយភិក្ខុទាំងអស់នេះសុទ្ធតែជាធុតវាទ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះអនុរុទ្ធត្ថេរទុកក្នុងឯតទគ្គៈក្នុងបណ្តាភិក្ខុដែលមានទិព្វចក្ខុថា “ម្នាលភិក្ខុទាំងឡាយបណ្តាភិក្ខុអ្នកមានទិព្វចក្ខុ ដែលជាសាវករបស់តថាគត ស្រេចនឹងព្រះអនុរុទ្ធប្រសើរជាងគេ”[១] ។ ពួកភិក្ខុដែលមានទិព្វចក្ខុរមែងហៅហាមព្រះថេរៈនោះដោយគិតថា យើងនឹងសួរនូវបរិកម្មអានិសង្ស ឧបក្កិលេសរបស់ភិក្ខុអ្នកដែលមានទិព្វចក្ខុ ដោយ

១. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៦/៥៣ ។

ប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ រមែងតបបញ្ហាដែលគេសួរ ហើយនិងសួរហើយយ៉ាងនោះដូចគ្នា ដល់ភិក្ខុទាំងនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សព្វេ ខោ ឯតេភិក្ខវេ ភិក្ខូ ធិព្វចក្ខុកា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នេះ សុទ្ធតែជាអ្នកមានទិព្វចក្ខុ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះបុណ្ណត្ថេរទុកក្នុងឯតទគ្គៈក្នុងបណ្ដាភិក្ខុដែលជាព្រះធម្មកថិកថា "ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុអ្នកធម្មកថិក ដែលជាសាវករបស់តថាគតស្រេចនឹងព្រះបុណ្ណមន្តានីបុត្រប្រសើរជាងគេ"[១] ។ ពួកភិក្ខុដែលជាធម្មកថិក រមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរអាការនោះ ៗ ក្នុងសេចក្ដីសង្ខេបពិស្ដារ លំបាកងាយ និងពាក្យពិរោះជាដើមនៃធម្មកថាដោយប្រការដូច្នេះ សូម្បីព្រះថេរៈនោះ រមែងប្រាប់ន័យធម្មកថានោះយ៉ាងនេះ ដល់ភិក្ខុទាំងនោះថា អ្នកមានអាយុ ធម្មតាព្រះធម្មកថិក គួរចាប់ផ្ដើមការពណ៌នាគុណបរិស័ទ ត្រង់កណ្ដាលគួរប្រកាសសុញ្ញតធម៌ ទីបំផុតគួរ

១. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៦/៥៣ ។

កាន់យកកំពូលដោយអំណាចសច្ចៈ ៤ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សព្វេវេតេ ឯតេ ភិក្ខវេ ភិក្ខូ ធម្មកថិកា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់ នេះសុទ្ធតែជាធម្មកថិកដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះឧបាលីត្ថេរទុកក្នុងឯតទគ្គៈក្នុងបណ្ដាភិក្ខុដែលទ្រទ្រង់វិន័យថា" ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុអ្នកទ្រទ្រង់វិន័យ ដែលជាសាវ័ករបស់តថាគត ស្រេចនឹងព្រះឧបាលីប្រសើរជាងគេ"[១] ។ ពួកភិក្ខុដែលទ្រទ្រង់វិន័យរមែងហែហមព្រះថេរៈនោះ ដោយគិតថា យើងនឹងសួរអាបត្តិធ្ងន់ អាបត្តិស្រាល អាបត្តិកែខៃបាន កែខៃមិនបាន អាបត្តិនិងអនាបត្តិ ដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ រមែងតបបញ្ហាដែលគេសួរហើយនិងសួរហើយ ដល់ភិក្ខុទាំងនោះយ៉ាងនោះដូចគ្នា ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សព្វេវេតេ ឯតេ-ភិក្ខវេ ភិក្ខូ វិនយធរា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នេះសុទ្ធតែជាអ្នកទ្រទ្រង់វិន័យ ដូច្នេះ ។

---

១. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៩/៥៥ ។

ព្រះមានព្រះភាគ ទ្រង់តាំងសូម្បីព្រះអានន្ទត្ថេរទុកក្នុងឯតទគ្គៈក្នុងបណ្ដាភិក្ខុអ្នកដែលពហុស្សុតថា "ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុអ្នកពហុស្សុត ដែលជាសាវ័ករបស់តថាគត ស្រេចនឹងព្រះអានន្ទប្រសើរជាងគេ"[១] ។ ពួកភិក្ខុពហុស្សុត រមែងហែហមព្រះថេរៈនោះដោយគិតថា យើងនឹងសួរសេចក្ដីជឹងក្នុងព្យញ្ជនៈ ១០ យ៉ាង ហេតុកើតអនុសន្ធិខាងដើមនិងខាងចុងដោយប្រការដូច្នេះ ។ សូម្បីព្រះថេរៈនោះ ក៏ប្រាប់រឿងទាំងពួងដល់ភិក្ខុទាំងនោះថា នេះគួរថា យ៉ាងនេះ នេះគួរកាន់យកយ៉ាងនេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សព្វេ ហោន្តិ ភិក្ខវេ ភិក្ខូ ពហុស្សុតា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នេះ សុទ្ធតែជាពហុស្សុត ដូច្នេះ ។

ចំណែកទេវទត្តប្រាថ្នាលាមក ត្រូវសេចក្ដីប្រាថ្នាគ្របសង្កត់ ។ ព្រោះហេតុនោះ ពួកភិក្ខុអ្នកប្រាថ្នាលាមក ហែហមទេវទត្តនោះ ដោយគិតថា យើងនឹងសួរការឃុំគ្រង ដើម្បីការ

---

១. អង្គុ. ឯក. ឯតទគ្គបាលី. ៤០. ១៤៩/៥៥ ។

សង្គ្រោះត្រកូលសេចក្ដីបញ្ឆោតបន្ទំមានប្រការផ្សេង ៗគ្នា ។

សូម្បីទេវទត្តនោះ  ក៏ប្រាប់ការកំណត់នោះដល់ភិក្ខុទាំងនោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សព្វេ ចា ឯតេ ភិក្ខវេ ភិក្ខូ បាបិច្ឆា ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអស់នេះ សុទ្ធតែមានសេចក្ដីប្រាថ្នាលាមក ដូច្នេះ ។

សួរថា ក៏ព្រោះហេតុអ្វី ភិក្ខុទាំងនោះ ចង្រ្កមហើយក្នុងទីមិនឆ្ងាយ ?

ឆ្លើយថា ដើម្បីកាន់ការរក្សាថា ទេវទត្តគិតប្រទូស្តក្នុង ព្រះសាស្ដាព្យាយាមនឹងធ្វើសេចក្ដីវិនាសមិនមែនប្រយោជន៍ ។

សួរថា គ្រានោះ ទេវទត្តចង្រ្កមហើយ ព្រោះហេតុអ្វី ?

ឆ្លើយថា ដើម្បីបិទបាំងទោសដែលខ្លួនធ្វើហើយ ជាហេតុឱ្យអ្នកដទៃដឹងថាអ្នកនេះមិនធ្វើ បើធ្វើគេក៏មិនមកក្នុងទីនេះ ។

សួរថា ក៏ទេវទត្តជាអ្នកអាចដើម្បីនឹងធ្វើសេចក្ដីវិនាសចំពោះព្រះមានព្រះភាគបានឬ នាទីត្រូវរក្សាព្រះមានព្រះភាគមានឬ ?

ឆ្លើយថា មិនមាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ម្នាលអានន្ទ អ្នកណាព្យាយាមសម្លាប់ តថាគត

សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុមិនមែនជាឱកាស(គួរធ្វើបានឡើយ)”[១] ។ ចំណែកភិក្ខុទាំងឡាយមកហើយ ដោយសេចក្តីគោរពក្នុងព្រះសាស្តា ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ទើបបង្គាប់ឱ្យបណ្តេញភិក្ខុទាំងនោះ ទៅដោយព្រះតម្រាស់ថា អានន្ទ លោកចូរបណ្តេញភិក្ខុសង្ឃចុះ ដូច្នេះ ។

## ហីនាធិមុត្តិសុត្រ

នៅក្នុងបិដកលេខ ៣២ ទំព័រ ៣០ ព្រះអង្គទ្រង់សម្តែងព្រះសូត្រ [***ដែលនិយាយអំពីសត្វមានអធ្យាស្រ័យអាក្រក់នឹងអធ្យាស្រ័យល្អ***] មានសេចក្តីថា ៖

ព្រះមានព្រះភាគ ទ្រង់គង់នៅជិតក្រុងសាវត្ថី.... ក្នុងទីនោះឯង ព្រះមានព្រះភាគ...ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា[២] ដោយធាតុ គឺពួកជនមាន

---

១. វិន. ចូឡ. សង្ឃភេទក្ខន្ធកៈ. ១១. ៣៦/៤៤; បិដកថា ម្នាលភិក្ខុទាំងឡាយ ។

២. ស្មើគ្នា ប្រហែលគ្នា ប្រជុំគ្នា ជួបគ្នា ចូលចិត្តនឹងគ្នា ។

អធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

១. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីតកាល សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

១. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអនាគតកាល សត្វទាំងឡាយ នឹងត្រូវគ្នា នឹងសមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

១. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងបច្ចុប្បន្នកាល សត្វទាំងឡាយ ក៏ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យា-

ស្រ័យថោកទាប ពួកជនមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នាជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

## អដ្ឋកថា

បទថា សំសន្ទន្តិ **ត្រូវគ្នា** គឺជាពួកតែមួយ ។ បទថា សមេន្តិ **សមគ្នា** បានដល់ រមែងសមាគមគ្នា គឺជានិរន្ត ។ បទថា ហីនាធិមុត្តិកា **ពួកជនមានអធ្យាស្រ័យថោកទាប** គឺ មានអធ្យាស្រ័យអាក្រក់ ។ បទថា កល្យាណាធិមុត្តិកា **ពួកជនមានការបង្អោនទៅល្អ** **គឺ** មានអធ្យាស្រ័យល្អ ។

## សគាថាធាតុសូត្រ

នៅក្នុងបិដកលេខ ៣២ ទំព័រ ៣៥ ព្រះអង្គទ្រង់សម្តែងព្រះសូត្រ [**ដែលនិយាយអំពីសត្វសេពគប់គ្នាដោយធាតុ**] មានសេចក្តីថា ៖

ព្រះមានព្រះភាគ ទ្រង់គង់នៅជិតក្រុងសាវត្ថី ... ក្នុងទីនោះឯង ព្រះមានព្រះភាគ... ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមាន

អធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមាន អធ្យាស្រ័យថោកទាប ។

ᨁ. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីតកាល សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ។

ᨁ. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអនាគតកាល សត្វទាំងឡាយ នឹងត្រូវគ្នា នឹងសមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យ ថោកទាប ។

ᨁ. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងបច្ចុប្បន្នកាលនេះ សត្វទាំងឡាយ ក៏ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមាន អធ្យាស្រ័យថោកទាប ។

ម្នាលភិក្ខុទាំងឡាយ លាមក ត្រូវគ្នា សមគ្នា ដោយលាមក មូត្រ ត្រូវគ្នា សមគ្នា ដោយមូត្រ ទឹកមាត់ ត្រូវគ្នា

សមគ្នា ដោយទឹកមាត់ ខ្ទុះ ត្រូវគ្នា សមគ្នា ដោយខ្ទុះ ឈាម ត្រូវគ្នា សមគ្នា ដោយឈាម យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាប ។

សូម្បីក្នុងអតីកាល... សូម្បីក្នុងអនាគតកាល... សូម្បីក្នុងបច្ចុប្បន្នកាលនេះ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យថោកទាប តែងត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យថោកទាបយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុគឺពួកអ្នកមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

៦. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីតកាល សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុគឺពួកអ្នកមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

៦. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអនាគតកាល សត្វ

ទាំងឡាយ នឹងត្រូវគ្នា នឹងសមគ្នា ដោយធាតុ គឺពួកអ្នកមាន អធ្យាស្រ័យល្អ នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមាន អធ្យាស្រ័យល្អ ។

៦. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងបច្ចុប្បន្នកាលនេះ សត្វទាំងឡាយ ក៏ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកអ្នកមាន អធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យា-ស្រ័យល្អ ។

ម្នាលភិក្ខុទាំងឡាយ ទឹកដោះស្រស់ ត្រូវគ្នា សមគ្នា ដោយទឹកដោះស្រស់ ប្រេង ត្រូវគ្នា សមគ្នា ដោយប្រេង ទឹកដោះរាវ ត្រូវគ្នា សមគ្នា ដោយ ទឹកដោះរាវ ទឹកឃ្មុំ ត្រូវគ្នា សមគ្នា ដោយទឹកឃ្មុំ ទឹកអំពៅ ត្រូវគ្នា សមគ្នា ដោយទឹក អំពៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកអ្នកមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ។

សូម្បីក្នុងអតីតកាល... សូម្បីក្នុងអនាគតកាល... សូម្បី ក្នុងបច្ចុប្បន្នកាលនេះ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយ

ធាតុគឺពួកអ្នកមានអធ្យាស្រ័យល្អ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានអធ្យាស្រ័យល្អ ក៏យ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះហើយ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់ពាក្យនេះហើយ ក៏ទ្រង់ត្រាស់គាថានេះតទៅថា ៖

សំសគ្គា វនថោ ជាតោ អសំសគ្គេន ឆិជ្ជតិ
បរិត្តំ ទារុមារុយ្ហ យថា សីទេ មហណ្ណវេ
ឯវំ កុសីតមាគម្ម សាធុជីវិបិ សីទតិ
តស្មា តំ បរិវជ្ជេយ្យ កុសីតំ ហីនវីរិយំ
បវិវេត្តេហិ អរិយេហិ បហិតត្តេហិ ឈាយិភិ
និច្ចំ អារទ្ធវីរិយេហិ បណ្ឌិតេហិ សហាវសេតិ ។

ព្រៃគឺកិលេសដុះឡើង ព្រោះការប្រឡូកប្រឡំ ព្រៃគឺកិលេសដាច់ទៅ ព្រោះការមិនប្រឡូកប្រឡំ បុគ្គលឡើងដើមឈើទាប មុខជាលិចចុះក្នុងអន្លង់ធំ យ៉ាងណាមិ បុគ្គលអធ្យាស្រ័យនឹងជនខ្ជិលប្រអូស ទោះបីចិញ្ចឹមជីវិតដោយស្រួល ក៏រមែងលិចចុះទៅ យ៉ាងនោះឯង ហេតុដូច្នោះ បុគ្គលគប្បីវៀរ

ស្រឡះចាកបុគ្គលខ្ជិលច្រអូស មានសេចក្ដីព្យាយាមថោកទាប នោះចេញ គប្បីនៅជាមួយនឹងជនជាបណ្ឌិត អ្នកស្ងប់ស្ងាត់អ្នកប្រសើរ អ្នកមានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន អ្នកមានឈានអ្នកផ្ដើមព្យាយាមជានិច្ច ។

## អដ្ឋកថា

បទថា គូថោ គូថេន សំសន្ទតិ សមេតិ **លាមក ត្រូវគ្នា សមគ្នា ដោយលាមក** សេចក្ដីថា លាមកសូម្បីនៅចន្លោះសមុទ្រ ចន្លោះជនបទ ចន្លោះចក្រវាឡ ដោយពណ៌ក្ដី ដោយក្លិនក្ដី ដោយរសក្ដី មិនចូលដល់សេចក្ដីផ្សេងគ្នា រមែងចូលគ្នាបាន រួមគ្នាបាន គឺដូចគ្នានឹងជានិរន្តរ ។ សូម្បីក្នុងបទដែលសល់ក៏មានន័យនេះឯង ។ ក៏ឧបមាដោយរបស់មិនគួរប្រាថ្នានេះ លោកនាំមកដើម្បីសម្ដែងអធ្យាស្រ័យ របស់អ្នកមានអធ្យាស្រ័យអាក្រក់ស្មើគ្នា ។ ឧបមាដោយរបស់ល្អ ប្រសើរមានទឹកដោះជាដើម លោកនាំមកដើម្បីសម្ដែងសេចក្ដីនូវអធ្យាស្រ័យរបស់អ្នកមានអធ្យាស្រ័យល្អស្មើគ្នា ។

បទថា សំសគ្គា **ព្រោះការប្រឡូកប្រឡំ** សេចក្ដីថា

ដោយសេចក្ដីស្នេហា ដោយតណ្ហា មានការឃើញការស្ដាប់និង ការសេពគប់គ្នាជាដើមជាទីតាំង ។

បទថា វនថោ ជាតោ **ព្រៃគឺកិលេសដុះឡើង** បានដល់ ព្រៃគឺ កិលេសកើតហើយ ។

បទថា អសំសគ្គេន ឆិជ្ជតិ **ព្រៃគឺកិលេសដាច់ទៅ ព្រោះការមិនប្រឡូកប្រឡំ** សេចក្ដីថា កាលមិនធ្វើការឈរ និងការអង្គុយរួមគ្នា ក៏រមែងដាច់ ព្រោះមិនសេពគប់ សមាគម គឺមិនជួបគ្នា ។

បទថា សាធុជីវិបិ ទោះបីចិញ្ចឹមជីវិតដោយស្រួល បាន ដល់ កាលនៅមានជីវិត ក៏មានជីវិតបរិសុទ្ធិ ។

បទថា សហាវសេ បានដល់ គប្បីនៅរួមគ្នា ។

## បឋមអស្សទ្ធសូត្រ

នៅក្នុងបិដកលេខ ៣២ ទំព័រ ៣៩ ព្រះអង្គទ្រង់សម្ដែង ព្រះសូត្រ [**ដែលនិយាយអំពីសត្វសេពគប់គ្នាដោយធាតុតែ មួយ៉ាង**] មានសេចក្ដីថា ៖

ព្រះមានព្រះភាគ ទ្រង់គង់នៅជិតក្រុងសាវត្ថី ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមិនមានសទ្ធា ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនមានសទ្ធា ពួកជនមិនខ្មាស់បាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនខ្មាស់បាប ពួកជនមិនខ្លាចបាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនខ្លាចបាប ពួកជនមិនចេះដឹង ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនចេះដឹង ពួកជនខ្ជិលច្រអូស ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនខ្ជិលច្រអូស ពួកជនវង្វេងស្មារតី ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនវង្វេងស្មារតី ពួកជនមិនមានបញ្ញា ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនមានបញ្ញា ។ ( ពួកជនមានសទ្ធាត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានសទ្ធា ពួកជនមានចិត្តខ្មាសបាបត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានចិត្តខ្មាសបាប ពួកជនមានសេចក្តីខ្លាចបាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជន មានសេចក្តីខ្លាចបាប ពួកជនអ្នកចេះដឹងច្រើន ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនអ្នកចេះដឹងច្រើន ពួកជនប្រារព្ធព្យាយាម ត្រូវគ្នា សមគ្នា ជាមួយនឹង

ពួកជនប្រារព្ធព្យាយាម ពួកជនមានស្មារតីមាំមួន ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមាន ស្មារតីមាំមួន ពួកជនមានបញ្ញា ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានបញ្ញា ) ។

៦. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីតកាល សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមិនមានសទ្ធា ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនមានសទ្ធា ពួកជនមិនខ្មាសបាប ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនខ្មាសបាប ពួកជនមិនចេះដឹងច្រើន ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនចេះដឹងច្រើន ពួកជនខ្ជិលច្រអូស ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនខ្ជិលច្រអូស ពួកជនភ្លេចស្មារតី ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនភ្លេចស្មារតី ពួកជនឥត បញ្ញា ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនឥតបញ្ញា ។

៦. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអនាគតកាល សត្វទាំងឡាយ នឹងត្រូវគ្នា នឹងសមគ្នា ដោយធាតុ គឺពួកជនមិនមានសទ្ធា នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមិនមានសទ្ធា ពួកជនមិនខ្មាសបាប នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមិនខ្មាសបាប ពួកជនមិនខ្លាចបាប នឹងត្រូវគ្នា នឹងសមគ្នា ជា

មួយនឹងពួកជនមិនខ្លាចបាប ពួកជនមិនចេះដឹង នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនមិនចេះដឹង ពួកជនខ្ជិលច្រអូសនឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនខ្ជិលច្រអូស ពួកជនវង្វេងស្មារតី នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនវង្វេងស្មារតី ពួកជនឥតបញ្ញា នឹងត្រូវគ្នា នឹងសមគ្នា ជាមួយនឹងពួកជនឥតបញ្ញា ។

៦. ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងបច្ចុប្បន្នកាល សត្វទាំងឡាយត្រូវគ្នា សមគ្នា ដោយធាតុ គឺពួកជនមិនមានសទ្ធា ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមិនមានសទ្ធា ពួកជនមិនខ្មាសបាប ជាមួយនឹងពួកជនមិនខ្មាសបាប ។បេ ។ ពួកជនមិនខ្លាចបាប ជាមួយនឹងពួកជនមិនខ្លាចបាប... ពួកជនមិនចេះដឹង ជាមួយនឹងពួកជនមិនចេះដឹង ពួកជនខ្ជិលច្រអូស ជាមួយនឹងពួកជនខ្ជិលច្រអូស... ពួកជនវង្វេងស្មារតីជាមួយនឹងពួកជនវង្វេងស្មារតី... ពួកជនឥតបញ្ញាត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនឥតបញ្ញា ។

៦. ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយ ត្រូវគ្នា សមគ្នា ដោយធាតុគឺពួកជនមានសទ្ធា ត្រូវគ្នា សមគ្នា ជាមួយនឹងពួក

ជនមានសទ្ធា ពួកជនមានចិត្តខ្មាស់បាប ត្រូវគ្នា សមគ្នាជាមួយនឹងពួកជនមានចិត្តខ្មាស់បាប ពួកជនមានសេចក្តីខ្លាចបាបត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានសេចក្តីខ្លាចបាប ពួកជនអ្នកចេះដឹងច្រើន ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជន អ្នកចេះដឹងច្រើន ពួកជនប្រារព្ធព្យាយាម ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនប្រារព្ធព្យាយាម ពួកជនមានស្មារតីតម្កល់មាំ ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានស្មារតីតម្កល់មាំ ពួកជន មានបញ្ញា ត្រូវគ្នា សមគ្នា ជាមួយនឹងពួកជនមានបញ្ញា ។

ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីកាល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអនាគតកាល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងបច្ចុប្បកាលនេះ ។ បេ ។ ត្រូវគ្នា សមគ្នា ។

## អដ្ឋកថា

ក្នុងបទជាដើមថា អស្សទ្ធា អស្សទ្ធេហិ **ពួកជនមិនមានសទ្ធានិងពួកជនមិនមានសទ្ធា** សេចក្តីថា បុគ្គលមិនមានឱជា (មិនស្វែងរកក្នុងសទ្ធា) មិនមានរស (រសអំពីសទ្ធា) វៀរជាច់ចាកសទ្ធាក្នុងព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃ នៅត្រើយសមុទ្រនេះ

ក៏អាក្រក់និវន្តរដូចគ្នានឹងបុគ្គលមិនមានសទ្ធា ដែលនៅត្រើយឯណោះ ព្រោះភាពជាអ្នកមិនមានសទ្ធានោះ ។ បុគ្គលមិនមានហិរិគឺ គ្មានមារយាទ ជាមួយនឹងបុគ្គលមិនមានហិរិ ។ អ្នកមិនមានឱត្តប្បៈ គឺ មិនខ្លាចចំពោះការធ្វើបាប ក៏ដូចគ្នានឹងអ្នកមិនមានឱត្តប្បៈ ។ អ្នកមានសុតៈតិចគឺរៀនដាច់ចាកសុតៈ ក៏ដូចគ្នានឹងអ្នកមានសុតៈតិច ។ អ្នកខ្ជិលច្រអូស គឺអ្នកមានសេចក្ដីខ្ជិលច្រអូស ក៏ដូចគ្នានឹងអ្នកខ្ជិលច្រអូស ។ អ្នកមានសតិវង្វេងភ្លេច គឺដូចនឹងក្អែករក្សាអាហារនិងចចក រក្សាសាច់ ក៏ដូចគ្នានឹងអ្នកមានសតិវង្វេងភ្លេច ។ អ្នកមានបញ្ញាទន់ខ្សោយ គឺឈ្មោះថា អត់បញ្ញា ព្រោះមិនមានបញ្ញាដែលនិងកំណត់ខន្ធជាដើម ក៏ដូចគ្នានឹងអ្នកមានបញ្ញាទន់ខ្សោយ ។ មនុស្សអ្នកជល់ព្រមដោយសទ្ធា គឺអ្នកខ្វល់ខ្វាយក្នុងកិច្ចមានការសំពះព្រះចេតិយជាដើម ក៏ដូចគ្នានឹងអ្នកមានសទ្ធា ។ អ្នកមានហិរិ គឺអ្នកមានសេចក្ដីខ្មាស ក៏ដូចគ្នានឹងអ្នកមានហិរិ ។ អ្នកមានឱត្តប្បៈ គឺខ្លាចបាបក៏ដូចគ្នានឹងអ្នកមានឱត្តប្បៈ ។ អ្នកមានសុតៈច្រើនគឺទ្រទ្រង់សុតៈ ទ្រទ្រង់អាគមរក្សាបែបផែន រក្សាវង្ស ក៏ដូចគ្នានឹងអ្នកមានសុតៈច្រើន ។ អ្នក

ប្រារព្ធសេចក្ដីព្យាយាម គឺមានសេចក្ដីព្យាយាម បរិបូណ៌ ក៏ដូច គ្នានឹងអ្នកប្រារព្ធសេចក្ដីព្យាយាម ។ អ្នកមានសតិរឹងមាំ គឺប្រកប ដោយសតិដែលកំណត់កិច្ចទាំងពួងបាន ក៏ដូចគ្នានឹងអ្នកមានសតិ រឹងមាំ ។ អ្នកមានបញ្ញា សូម្បីនៅក្នុងទីឆ្ងាយនឹងមនុស្សអ្នកមាន បញ្ញាច្រើន គឺអ្នកមានបញ្ញាមានសេចក្ដីដឹងប្រៀបដូចកែវវេជិរ រមែងគប់រកគ្នាបាន សមាគមគ្នាបាន ដោយបញ្ញាសម្បត្តិនោះ ។

## ព្រះគាថាប្រារព្ធចំពោះបុរសម្នាក់

ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ។

រាត្រីវែងចំពោះតែអ្នកភ្ញាក់រឭក ( អ្នកដេកមិនលក់ ) យោជន៍វែងចំពោះតែអ្នកនឿយហត់ សង្សារវដ្ដវែងចំពោះតែ បុគ្គលពាល មិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ទីឃា ជាដើម សេចក្ដីថា ដែលឈ្មោះថា រាត្រី មានត្រឹមតែ ៣ យាមប៉ុណ្ណោះ ប៉ុន្ដែ

សម្រាប់អ្នកភ្ញាក់រឭក( ដេកមិនលក់ )ដូចជាវែង គឺថា រមែង ប្រាកដដូចជាគុណានឹង២ឬគុណានឹង ៣ បុគ្គលដែលខ្ជិលច្រអូស គ្មានសេចក្ដីព្យាយាមធ្វើខ្លួនឱ្យជាចំណីនៃពួកសង្កើច ដេកប្រែប្រួល ៗ រហូតដល់ព្រះអាទិត្យរះឡើងក្ដី បុគ្គលអ្នកសេពកាមបរិភោគភោជនដ៏ប្រណីត ហើយដេកនៅលើទីដ៏មានសិរីក្ដី រមែងមិនដឹងនូវភាវៈនៃរាត្រីនោះជាវេលាដ៏វែង ចំណែកព្រះយោគាវចរអ្នកប្រារព្ធសេចក្ដីព្យាយាមរហូតអស់រាត្រីទាំងមូលក្ដី អ្នកដែលត្រូវរោគទាំងឡាយ មានរោគក្នុងក្បាលជាដើមពាល់ត្រូវហើយ ឬអ្នកដល់នូវសេចក្ដីទុក្ខមានការកាត់ដៃជើងជាដើម ត្រូវវេទនាគ្របសង្កត់ក្ដី អ្នកដើរផ្លូវឆ្ងាយ ដើររហូតអស់រាត្រីទាំងមូលក្ដី រមែងដឹងនូវភាវៈនៃរាត្រីនោះ ជាវេលាដ៏យូរ ។

បទថា យោជនំ ជាដើម សេចក្ដីថា សូម្បីយោជន៍ក៏មានត្រឹមតែ ៤ គាវុតប៉ុណ្ណោះ ប៉ុន្តែសម្រាប់អ្នកនឿយហត់ គឺអ្នកស្បើយកម្លាំង ដូចជាវែងឆ្ងាយ គឺថារមែងប្រាកដដល់បុគ្គលនោះ ដូចជាគុណានឹង ២ ឬនឹង ៣ ។

ដូចយ៉ាងថាបុគ្គលអ្នកទៅកាន់ផ្លូវឆ្ងាយធ្វើដំណើរអស់

ពេញមួយថ្ងៃនៀយហត់ហើយ ជួបបុរសដែលធ្វើដំណើរបញ្ច្រាស ទិសគ្នា ក៏សួរថា ៗស្រុកខាងមុខនៅឆ្ងាយប៉ុន្មាន ? កាលគេប្រាប់ ថាមួយយោជន៍ ដើរទៅបានបន្តិច ក៏សួរអ្នក ដទៃទៀត សូម្បី កាលអ្នកដទៃនោះប្រាប់ថា មួយយោជន៍ ដើរទៅបានបន្តិចទៀត ក៏សួរអ្នកដទៃទៀត សូម្បីគេក៏ពោលថា មួយយោជន៍ បុគ្គល ទាំងនោះត្រូវអ្នកដំណើរផ្លូវនោះសួរហើយ ក៏ប្រាប់ថាមួយយោជន៍ អ្នកដំណើរទាំងនោះគិតថា យោជន៍នេះឆ្ងាយពិត មែនហ្ន៎ រមែង សម្គាល់មួយយោជន៍ ដូចជា ២-៣ យោជន៍ ។

បទថា ពាលានំ ជាដើម សេចក្តីថា ចំណែកសង្សារវដ្ត របស់ជនពាលទាំងឡាយ ដែលជាអ្នកមិនដឹងប្រយោជន៍ ក្នុង លោកនេះ និងប្រយោជន៍ក្នុងលោកមុខគឺអ្នកមិនអាចដើម្បីធ្វើទី បំផុតនៃសង្សារវដ្ត អ្នកមិនដឹងច្បាស់នូវព្រះសទ្ធម្ម មានពោធិ- បក្ខិយធម៌ ៣៧ ប្រការជាដើមដែលព្រះអរិយៈទាំងឡាយ ដឹង ហើយ ធ្វើទីបំផុតនៃសង្សារបាន រមែងវែងឆ្ងាយ ។ ពិតណាស់ សង្សារវដ្តនោះ រមែងវែងឆ្ងាយតាមធម្មតារបស់ខ្លួនឯង ។ សមដូចព្រះពុទ្ធវចនៈ ដែលព្រះដ៏មានព្រះភាគត្រាស់ ទុកថា

ម្នាលភិក្ខុទាំងឡាយ សង្សារវដ្តនេះ មានទីបំផុតដែលបុគ្គលណាដឹងមិនបាន ទីបំផុតខាងដើម ខាងចុង (នៃសង្សារវដ្តនោះ) រមែងមិនប្រាកដ ។ ក៏ប៉ុន្តែសម្រាប់ជនពាលទាំងឡាយជាអ្នកមិនអាចនឹងធ្វើទីបំផុតនៃសង្សារវដ្តបាន រមែងជាសភាពដ៏វែងក្រៃពេកមែនពិត ។

## ព្រះគាថាប្រារព្ធចំពោះសទ្ធិវិហារិករបស់ព្រះមហាកស្សបៈ

ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ
ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តនៅតែម្នាក់ឯងឱ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណមិនមាន ក្នុងបុគ្គលពាលឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ក្នុងបទថា ចរំ សេចក្តីថា បណ្ឌិតគប្បីជ្រាបការត្រាច់ទៅដោយចិត្ត មិនគប្បីកាន់យកនូវការត្រាច់

ទៅដោយឥរិយាបថ អធិប្បាយថា កាលស្វែងរកនូវកល្យាណមិត្ត ។

បាទព្រះគាថាថា **សេយ្យំ សទិសមត្តនោ** សេចក្តីថា ប្រសិនបើមិនបានសម្លាញ់ដ៏ប្រសើរជាង ឬ ស្មើដោយគុណគឺសីលសមាធិ បញ្ញារបស់ខ្លួនទេ ។

បទថា **ឯកចរិយំ** សេចក្តីថា ក៏ក្នុងបណ្តាសម្លាញ់ទាំងនោះ បុគ្គលកាលបានសម្លាញ់ប្រសើរជាងខ្លួនជាង រមែងចម្រើនដោយគុណទាំងឡាយ មានសីលជាដើម កាលបានសម្លាញ់ស្មើនឹងខ្លួន រមែងមិនសូន្យចាកគុណមានសីលជាដើម ប៉ុន្តែ កាលនៅរួមជាមួយនឹងសម្លាញ់ថោកទាប អប្បឥតប្រាជ្ញា ធ្វើនូវការសម្ភោគនឹងបរិភោគដោយភាវៈជាមួយគ្នា រមែងសាបសូន្យចាកគុណទាំងឡាយមានសីលជាដើម ។

ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា បុគ្គលបែបនោះ បណ្ឌិតមិនគប្បីសេព មិនគប្បីគប់រក មិនគប្បីចូលទៅអង្គុយជិតវៀរតែសេចក្តីអាណិត វៀរតែការអនុគ្រោះ ។

ព្រោះហេតុនោះ ប្រសិនបើបុគ្គលអាស្រ័យសេចក្តីករុណា

គិតថា បុគ្គលនេះអាស្រ័យយើងនឹងចម្រើនដោយគុណទាំងឡាយ មានសីលជាដើមមិនសង្ឃឹមការតបស្នងសងគុណអំពីបុគ្គលនោះ ឈ្មោះថា រមែងអាចសង្គ្រោះបុគ្គលនោះបាន ការអាស្រ័យសេចក្តីករុណាសង្គ្រោះដូច្នេះនោះជាការល្អ បើមិនអាចសង្គ្រោះ(យ៉ាងនោះបានទេ គប្បីត្រាច់ទៅតែម្នាក់ឯង ដោយសេចក្តីមិនប្រមាទ គឺថា ធ្វើនូវភារៈជាអ្នកត្រាច់ទៅតែម្នាក់ឯងឱ្យមាំទាំ នៅតែម្នាក់ឯងក្នុងឥរិយាបថទាំងពួង ។)

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះគុណធម៌ដែលជាសម្លាញ់ រមែងមិនមានក្នុងបុគ្គលពាល ។ អធិប្បាយថា ចូឡសីល មជ្ឈិមសីល មហាសីល កថាវត្ថុ១០ ធុតង្គគុណ ១៣ វិបស្សនាគុណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ ឈ្មោះថា គុណធម៌ ជាសម្លាញ់ គុណធម៌ជាសម្លាញ់នេះ រមែងមិនមានក្នុងបុគ្គលពាលឡើយ ។ ក្នុងកាលចប់ទេសនា អាគន្តុកភិក្ខុ បានសម្រេចសោតាបត្តិផល សូម្បីជនដទៃជាច្រើនក៏សម្រេច អរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ទេសនាបានជាកថា មានប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះឯង ។

## ព្រះគាថាត្រាស់ព្រួចំពោះអានន្ទសេដ្ឋី

បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។

ជនពាលតែងព្រួយលំបាក ដោយសេចក្តីសំគាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិតសូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយនឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា ?

បុគ្គលពាលរមែងក្តៅក្រហាយ ព្រោះការជាប់ជំពាក់ក្នុងបុត្រនិងការជាប់ជំពាក់ក្នុងទ្រព្យថា បុត្រទាំងឡាយរបស់យើងមាន ទ្រព្យរបស់យើងមាន រមែងលំបាកគឺរមែងដល់នូវសេចក្តីទុក្ខគឺរមែងកន្ទក់កន្ទេញថា បុត្រទាំងឡាយរបស់យើងវិនាសហើយរមែងវិនាសនឹងវិនាស សូម្បីក្នុងទ្រព្យក៏ មានន័យដូច្នេះដែរ ។

បុគ្គលពាល រមែងកន្ទក់កន្ទេញដោយអាការ ៦ យ៉ាងដោយប្រការដូច្នេះ បុគ្គលពាលកាលព្យាយាមក្នុងទីទាំងឡាយ

មានផ្លូវគោកនិងផ្លូវទឹកជាដើម ទាំងពេលយប់ និងពេលថ្ងៃដោយប្រការផ្សេងដោយគិតថា យើងនឹងចិញ្ចឹមបុត្រទាំងឡាយឈ្មោះថា រមែងក្តៅក្រហាយ សូម្បីធ្វើកម្មទាំងឡាយ មានការធ្វើស្រែនិងការជួញជាដើម ដោយគិតថា យើងនឹងញ៉ាំងទ្រព្យឱ្យកើតឡើងក៏ឈ្មោះថា រមែងក្តៅក្រហាយដូចគ្នាដែរ ក៏កាលបុគ្គលពាលក្តៅក្រហាយយ៉ាងនេះ ខ្លួនឈ្មោះថា រមែងមិនមានដល់ខ្លួន កាលបុគ្គលពាលមិនអាចធ្វើខ្លួនដែលដល់ សេចក្តីទុក្ខដោយការបង្អៀតបង្អល់នោះឱ្យដល់នូវសេចក្តីសុខ បានសូម្បីក្នុងបច្ចុប្បន្ន កាលខ្លួនរបស់គេឈ្មោះថា រមែងមិនមានដល់ខ្លួនកាលបុគ្គលពាលដេកនូវលើគ្រែដែលជាទីស្លាប់ ត្រូវវេទនាទាំងឡាយ មានសេចក្តីស្លាប់ជាទីបំផុតដុតរោល ហាក់ដូចជាត្រូវអណ្តាតភ្លើងដុត កាលគ្រឿងគនិងគ្រឿងចង( សរសៃពួរ )នឹងដាច់ទៅ កាលរាងឆ្អឹងនឹងបែកធ្លាយទៅ សូម្បីកាលគេបិទភ្នែកឃើញលោកខាងមុខ បើកភ្នែកឃើញលោកនេះ ខ្លួនដែលគេផ្ងូតទឹកឱ្យមួយថ្ងៃ ២ ដង ឱ្យបរិភោគមួយថ្ងៃ ៣ ដង ប្រកដាប់តុបតែងដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ចិញ្ចឹមថែរក្សារហូតដល់អស់ជីវិត ក៏ឈ្មោះថា រមែង

មិនមានដល់ខ្លួន ព្រោះមិនអាចការពារទុក្ខឱ្យខ្លួនឯង បានបុត្រនឹងមានអំពីណា ?ទ្រព្យនឹងមានអំពីណា ? គឺថា ក្នុងសម័យនោះ បុត្រនិងទ្រព្យនឹងធ្វើអ្វីបានទៅ ? សូម្បីកាលអានន្ទសេដ្ឋីមិនឱ្យអ្វីដល់នណា សន្សំទ្រព្យទុកដើម្បីប្រយោជន៍ដល់បុត្រ ដេកលើគ្រែដែលជាទីស្លាប់ក្នុងកាលមុនក្តី ដល់នូវសេចក្តីទុក្ខក្នុងបច្ចុប្បន្នក្តី បុត្រនឹងមានអំពីណា ? ទ្រព្យនឹងមានអំពីណា ? គឺថាបុត្រនិងទ្រព្យនាំទុក្ខអ្វីទៅបាន ? ឬញុំាំងសុខអ្វីឱ្យកើតឡើងបានទៅ ? ក្នុងកាលចប់ធម្មទេសនា ការត្រាស់ដឹងធម៌ មានដល់សត្វ ៨៤,០០០នាក់ ទេសនាបានជាកថា មានប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះឯង ។

## ព្រះគាថាត្រាស់ព្ធចំពោះចោរឆម្លាយបន្ទិចទ្រព្យ

យោ ពាលោ មញ្ញតី ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិត មានី ស វេ ពាលោតិ វុច្ចតិ ។

អ្នកណាជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថា ជាពាលអ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួនថា

ជាពាលនោះ ម្យ៉ាងទៀត អ្នកណាជាមនុស្សពាល មានសេចក្តីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះឈ្មោះថា ជាមនុស្សពាលដោយពិត ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា យោ ពាលោ សេចក្តីថា បុគ្គលណាជាមនុស្សពាល គឺមិនមែនជាបណ្ឌិត ហើយសម្គាល់ គឺដឹងនូវភាវៈនៃខ្លួនថា ជាមនុស្សពាល គឺភាពជាមនុស្សល្ងង់ខ្លៅនោះដោយខ្លួនឯងថា យើងជាមនុស្សល្ងង់ខ្លៅ ។

ពីរបទថា តេន សោ សេចក្តីថា ដោយហេតុនោះបុគ្គលនោះនឹងជាបណ្ឌិតក៏ថាបាន ឬ ស្មើនឹងបណ្ឌិតក៏ថាបាន ។

ពិតមែន បុគ្គលនោះកាលគេដឹងថា យើងជាបុគ្គលពាល ចូលទៅរក ចូលទៅអង្គុយជិតអ្នកដទៃដែលជាបណ្ឌិត កាលបណ្ឌិតនោះពោលទូន្មានប្រៀបប្រដៅ ដើម្បីជាប្រយោជន៍ដល់ភាពជាបណ្ឌិត រៀនយកឱវាទនោះហើយ រមែងជាបណ្ឌិត ឬជាបណ្ឌិតដ៏ឆ្នើមជាងបណ្ឌិតបាន ។

ពីរបទថា ស វេ ពាលោ សេចក្តីថា ចំណែកបុគ្គល

ណា ជាបុគ្គលពាលហើយសម្គាល់ខ្លួនថា ជាបណ្ឌិតតែម្យ៉ាង យ៉ាងនេះថា អ្នកដទៃណាទៅជាពហុស្សូត ជាធម្មកថិកជាអ្នកទ្រទ្រង់វិន័យ មានវាទៈពោលនូវគុណដែលជាគ្រឿងជុសខាត់កិលេស ប្រាកដស្មើនឹងយើងបុគ្គលនោះមិនចូលទៅរក មិនចូលទៅអង្គុយជិតបុគ្គលដទៃដែលជាបណ្ឌិត រមែងមិនរៀនយកព្រះបរិយត្តិ រមែងមិនបំពេញនូវវត្តបដិបត្តិ រមែងដល់នូវភាពជាបុគ្គលពាលដោយចំណែកមួយពិត បុគ្គលនោះ រមែងដូចជាចោរដែលទម្លាយនូវបង្វិចទ្រព្យដូច្នោះ ។ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគត្រាស់ពាក្យនេះថា ស វេ ពាលោតិ វុច្ចតិ ។

ក្នុងកាលចប់ទេសនា មហាជនព្រមទាំងញាតិទាំងឡាយរបស់ចោរដែលជាសោតាបន្ននោះ សម្រេចសោតាបត្តិផលដូច្នេះឯង ។

## ព្រះគាថាប្រារព្ធចំពោះព្រះឧទាយិត្ថេរៈ

យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ
ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។

មនុស្សពាលបើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់

មួយជីវិត ក៏ឥតមានដឹងរសធម៌អ្វីឱ្យច្បាស់លាស់ឡើយ ដូចវែក ដែលមិនដឹងរសសម្ល ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានេះថា ៖

បុគ្គលពាល បើចូលទៅរក ចូលទៅអង្គុយជិតបណ្ឌិត សូម្បីអស់មួយជីវិត ក៏រមែងមិនដឹងនូវព្រះបរិយត្តិធម៌យ៉ាងនេះថា នេះជាព្រះពុទ្ធវចនៈ ព្រះពុទ្ធវចនៈមានប្រមាណប៉ុណ្ណេះ ឬមិនដឹងនូវបដិបត្តិធម៌ និងបដិវេធធម៌យ៉ាងនេះថា ធម៌នេះ ជាគ្រឿងនៅ ធម៌នេះជាមារយាទ នេះជាគោចរកម្ម កម្មនេះ មានទោស កម្មនេះមិនមានទោសកម្មនេះគួរសេព កម្មនេះមិនគួរសេព ធម៌នេះគប្បីចាក់ធ្លុះ ធម៌នេះគួរធ្វើឱ្យច្បាស់ ។

សួរថា ដូចអ្វី ?

ឆ្លើយថា ដូចវែកមិនដឹងរសសម្លដូច្នោះ ។

អធិប្បាយថា ដូចយ៉ាងថា វែកសូម្បីអ្នកស្ល ក្ករក្នុងសម្ល គ្រឿងមានប្រការផ្សេង ដរាបដល់រលួយអស់ទៅក៏រមែងមិនដឹងនូវរសសម្លថាមានរសប្រៃ មានរសសាប មានរស ល្វីង មានរសហាង មានរសហឹរ មានរសជូរ មានរសចត់ យ៉ាងណា

បុគ្គលពាលសូម្បីចូលទៅអង្គុយជិតបណ្ឌិតរហូត អស់មួយជីវិត ក៏រមែងមិនដឹងនូវធម៌មានប្រការដូចពោល ហើយនោះដែរ ។

## ព្រះគាថាត្រាស់ព្រួចំពោះភិក្ខុអ្នកដែនបាឋេយ្យ

មុហុត្តមបិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រស់ធម៌ដោយឆាប់រហ័ស ដូចអណ្តាតដឹងនូវរសសម្ល ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា ៖

បើវិញ្ញូជន គឺ បុរសដែលជាបណ្ឌិតចូលទៅអង្គុយជិតបណ្ឌិតដទៃសូម្បីត្រឹមតែមួយភ្លែត បណ្ឌិតនោះរៀនសាកសួរបណ្ឌិតដទៃនោះ បុគ្គលដែលជាបណ្ឌិតនោះ ឱ្យបណ្ឌិតដទៃប្រាប់នូវកម្មដ្ឋាន ហើយព្យាយាមនៅក្នុងវត្តបដិបត្តិ រមែងដឹងច្បាស់សូម្បីនូវលោកុត្តរធម៌បានយ៉ាងឆាប់រហ័ស ដូចបុរស អ្នកមានជិវ្ហាប្រសាទដែលរោគមិនទាន់កម្ចាត់ លុះដាក់អាហារត្រង់អណ្តាត

ដើម្បីទឹងដឹងរសរមែងដឹងរសផ្សេង មានរសប្រែជាដើមបានយ៉ាង ឆាប់រហ័សដូច្នោះដែរ ។

## ព្រះគាថាត្រាស់ព្ធចំពោះសុប្បពុទ្ធកុដ្ឋី

ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា

ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ ។

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវតែងធ្វើ កម្មលាមក ដែលជាអំពើមានផលក្តៅក្រហាយ ។

### អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ចរន្តិ** សេចក្តីថា រមែងត្រាច់ ទៅធ្វើនូវកម្មដែលជាអកុសលតែម្យ៉ាង ដោយឥរិយាបថទាំង៤ ។

ជនទាំងឡាយ អ្នកមិនដឹងនូវប្រយោជន៍ក្នុងលោកនេះ និង ប្រយោជន៍ក្នុងលោកខាងមុខឈ្មោះថា **ពាល** ក្នុងបទថា **ពាលា** នេះ ។

បទថា ទុម្មេធា គឺអ្នកមានបញ្ញាអាក្រក់ ( ឥតបញ្ញា ) ។

បទថា អមិត្តេនេវ សេចក្តីថា ដូចជាសត្រូវមិនមែន ជាមិត្ត ។

បទថា កដុកប្ផលំ សេចក្តីថា មានផលដ៏ឈឺផ្សា គឺមានទុក្ខជាផល ។

## ព្រះគាថាប្រារព្ធចំពោះបុរសអ្នកភ្ជួរស្រែ

ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ
យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយឬមានមុខប្រឡាក់ដោយទឹកភ្នែកស្រែកយំ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះ ឈ្មោះថា ជាកម្មមិនល្អឡើយ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា យំ កត្វា សេចក្តីថា បុគ្គលធ្វើនូវកម្មណា ដែលអាចញ៉ាំងសត្វឱ្យកើតក្នុងអបាយ ក្រុមទាំងឡាយ មាននរកជាដើម បានដល់ មានទុក្ខជាកម្រៃ កាលតាមរឭកដល់ឈ្មោះថា រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ គឺរមែងសោយសោករឿយ ៗ ក្នុងខណៈដែលរលឹកដល់កម្មនោះ ដែលបុគ្គលធ្វើមិនល្អឡើយ គឺមិនប្រពៃ បានដល់ មិនមែនជាកម្មថ្លៃថ្នូរ ។

ពីរបទថា យស្ស អស្សុមុខោ សេចក្តីថា ជាអ្នកមានមុខ ទទឹកជោគដោយទឹកភ្នែក ទួញយំសោយនូវផលនៃកម្មណា ។

## ព្រះគាថាប្រារព្ធចំពោះនាយសុមនមាលាការ

តញ្ច កម្មំ កតំ សាធុ  យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ  វិបាកំ  បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ ពីរបទថា **យំ កត្វា** សេចក្តីថា បុគ្គលធ្វើកម្មណា គឺកម្មដែលអាចញ៉ាំងសម្បត្តិទេវតា និង សម្បត្តិមនុស្សនិងនិព្វានសម្បត្តិឱ្យកើតគឺមានសុខជាកម្រៃ រមែងមិនក្តៅក្រហាយក្នុងកាលខាងក្រោយដោយពិត បុគ្គលនោះឈ្មោះថា ជាអ្នកឆ្អែតហើយ ដោយកម្លាំងនៃបីតិ និងឈ្មោះថា មានចិត្តរីករាយដោយកម្លាំងនៃសោមនស្ស ក្នុងខណៈដែលរឭកជាអ្នកកើតបីតិ និងសោមនស្សក្នុងកាលតទៅ រមែងសោយផលក្នុងទិដ្ឋធម៌

*នោះឯង កម្មនោះដែលបុគ្គលធ្វើហើយជាកម្មញុំាងប្រយោជន៍ឱ្យសម្រេចគឺជាកម្មល្អ បានដល់ ជាកម្មថ្លៃថ្នូរ ។*

## ព្រះគាថាត្រាស់ព្រួចំពោះព្រះនាងឧប្បលវណ្ណាថេរី

មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ

យទា ច បច្ចតី បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ ។

*បាបមិនទាន់ឱ្យផលត្រឹមណា ជនពាលតែងសម្គាល់នូវបាបនោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឱ្យផល ជនពាលទើបប្រទះនូវសេចក្តីទុក្ខ ក្នុងកាលណោះ ។*

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា* **មធុវា** *ជាដើម សេចក្តីថា ក៏កាលជនពាលធ្វើបាបគឺអកុសលកម្ម កម្មនោះរមែងប្រាកដដូចទឹកឃ្មុំ គឺដូចជាវត្ថុដែលមានរស់ផ្អែម បានដល់ ដូចជា អមពើដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តដល់បុគ្គលពាលនោះ បុគ្គលពាលនោះរមែងសម្គាល់បាបនោះថា ដូចជាទឹកឃ្មុំ ដោយប្រការដូច្នេះ ។*

បទថា យាវ គឺដរាបណា ។

ពីរបទថា ធាបំ ន បច្ចតិ សេចក្ដីថា បុគ្គលពាលរមែងសម្គាល់បាបនោះយ៉ាងនោះ ដរាបណាដែលបាបមិនទាន់ឱ្យផលក្នុងទិដ្ឋធម៌ ឬ ក្នុងសម្បរាយភព ។

បទថា យទា ច សេចក្ដីថា ក៏ក្នុងកាលណាបុគ្គលពាលនោះត្រូវទទួលទារុណកម្មផ្សេង ៗ ក្នុងទិដ្ឋធម៌ ឬសោយទុក្ខធំក្នុងអបាយ មាននរកជាដើម ក្នុងសម្បរាយភព បាបនោះ ឈ្មោះថារមែងឱ្យផលក្នុងកាលនោះ បុគ្គលពាលនោះ រមែង ចូលដល់គឺជួបប្រសព្វ បានដល់ រមែងបានចំពោះនូវទុក្ខ ។

## ព្រះគាថាប្រារព្ធចំពោះជម្ពុកាជីវក

មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ
ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ
សោឡសឹ ។

ជនពាល ទុកជាបរិភោគភោជនដោយចុងស្បូវរាល់ ៗខែ ជនពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ ៗ លើក

របស់បុគ្គលទាំងឡាយដែលមានធម៌បានដឹង ឬ បានពិចារណា
ហើយឡើយ ។

## អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា ៖

ប្រសិនបើបុគ្គលពាល គឺបុគ្គលអ្នកមានធម៌មិនទាន់កំណត់ដឹង ឃ្លាតឆ្ងាយអំពីគុណ មានសីលជាដើម បួសក្នុងលទ្ធិតិរ្ថិយ បរិភោគភោជនដោយចុងស្បូវគ្រប់ ៗខែ ដែលដល់ព្រមដោយសេចក្តីសង្ឃឹមថា យើងនឹងបំពេញធម៌ឈ្មោះថា គប្បីបរិភោគភោជនរហូតដល់អស់ ១០០ ឆ្នាំ ។

ក្នុងកន្លះព្រះគាថាថា **ន សោ** សង្ខាតធម្មានំ **កលំ អគ្ឃតិ សោឡសឹ** សម្តែងជាបុគ្គលាធិដ្ឋានមានបុគ្គលជាទីតាំងថា ព្រះអរិយបុគ្គលអ្នកមានធម៌បានដឹងហើយ គឺអ្នកមានធម៌ប្រៀបធៀបថ្លឹងថ្លែងបានហើយ ហៅថាអ្នកមានធម៌ដែលបានពិចារណាហើយ បណ្តាព្រះអរិយទាំងនោះ ព្រះសោតាបន្នឈ្មោះថា ព្រះអរិយបុគ្គលអ្នកមានធម៌ដែលបានពិចារណាហើយ មានធម៌ដែលបានដឹងហើយថ្នាក់ខ្ពស់បំផុត ព្រះខីណាស្រព ឈ្មោះថា ព្រះ

អរិយបុគ្គលអ្នកមានធម៌ដែលបានពិចារណាហើយ មានធម៌ដែលបានដឹងហើយថ្នាក់ខ្ពស់បំផុត បុគ្គលពាលរមែងមិនដល់ចំណែកទី១៦ ដែលបណ្ឌិតចែកជា ១៦ ចំណែក អស់វារៈ ១៦ ដង នៃព្រះអរិយបុគ្គល អ្នកមានធម៌ដែលបានឃើញហើយ ។

ចំណែកសេចក្តីក្នុងកន្លះព្រះគាថានេះ គប្បីជ្រាបដូច្នេះ ក៏ចេតនារបស់ជនពាលនោះ អ្នកបំពេញការប្រព្រឹត្តតបៈយ៉ាងនោះ រហូតដល់អស់ ១០០ ឆ្នាំ ប្រព្រឹត្តទៅអស់រាត្រីដ៏យូរដល់ម្លោះ ក៏មិនដល់ចំណែកទី ១៦ ដង ដែលបណ្ឌិចែជា ១៦ ចំណែក អស់វារៈ ១៦ ដង នៃកុសលចេតនាដែលជាគ្រឿងកាត់បង់នូវភត្តមួយដងរបស់បុគ្គលអ្នកមានធម៌ដែលបានឃើញហើយរង្កៀសត្រកូល ឬភត្តហើយមិនបរិភោគ ។

ព្រះសាស្តា ត្រាស់អធិប្បាយទុកដូច្នេះថា ផលនៃចំណែកនីមួយអំពីចំណែកទី ១៦ ដែលមានផលនៃចេតនារបស់បុគ្គលអ្នកមានធម៌បានហើយនោះឱ្យជា ១៦ចំណែក ហើយធ្វើចំណែកមួយអំពី ១៦ចំណែកនោះឱ្យជា ១៦ចំណែកទៀត នៅតែច្រើនជាងការប្រព្រឹត្តតបៈរបស់បុគ្គលពាលនោះ ។

## ព្រះគាថាប្រារព្ធចំពោះអហិប្រេត

ន ហិ បាបំ កតំ  កម្មំ សជ្ជុខីរំវ មុច្ចតិ

ឌហន្តំ ពាលមន្វេតិ  ភស្មាច្ឆន្នោវ បាវកោ ។

កម្មលាមកដែលជនពាលធ្វើហើយ  មិនទាន់ឱ្យផលនោះក៏មាន ដូចទឹកដោះស្រស់ដែលមិនទាន់ប្រែក្លាយ ( ក្នុងមួយរំពេច )

ដូច្នោះបាបកម្មនោះ  តាមដុតបុគ្គលពាលដូចរងើកភ្លើង ដែលបិទបាំងទុកដោយផេះដូច្នោះ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា សជ្ជុខីរំ សេចក្តីថា ទឹកដោះស្រស់ដែលហូរចេញចាកដោះមេគោក្នុងខណៈនោះ នៅក្តៅមិនប្រែក្លាយ មិនទាន់ប្រែប្រួលនៅឡើយ ។ ព្រះសាស្តាទ្រង់ត្រាស់ពាក្យអធិប្បាយទុកដូច្នេះថា ទឹកដោះស្រស់ដែលគេ ទើបតែរីតភ្លាម ៗនោះមិនទាន់ប្រែប្រួល គឺមិនក្លាយបានដល់ មិនទាន់លះបង់ភាពប្រក្រតីក្នុងខណៈនោះភ្លាមទេគឺថា កាលដែលគេរីតដាក់ក្នុងភាជនៈណាហើយ មិនដាក់ចូលទៅដរាបណា វាមិនទាន់ជូរដរាបនោះ លុះដាក់របស់ជូរចូលទៅ ឬក៏ដាក់ទៅក្នុងភាជន គឺ

សម្រាប់ដាក់វត្ថុមានទឹកដោះជូរជាដើម ទើបលះបង់នូវភាពប្រក្រតីរបស់ខ្លួនដរាបនោះយ៉ាងណា សូម្បីបាបកម្មដែលបុគ្គលកំពុងធ្វើក៏មិនទាន់ឱ្យផលក្នុងខណៈនោះ ដូច្នោះដែរ ប្រសិនបើបាបកម្មឱ្យផល (ក្នុងខណៈកំពុងធ្វើសោត) គ្មានអ្នកណាហ៊ានធ្វើបាបឡើយ ខន្ធទាំងឡាយដែលកើតអំពីកុសលនៅមានដរាបណា ខន្ធទាំងនោះ រមែងរក្សាបុគ្គលនោះទុកបានដរាបនោះ កាលខន្ធទាំងឡាយកើតក្នុងអបាយ ព្រោះការបែកធ្លាយទៅនៃខន្ធទាំងនោះបាបរមែងឱ្យផល ក៏កាលឱ្យផល ឈ្មោះថា រមែងតាមដុតបំផ្លាញបុគ្គលពាល ។

សួរថា ដូចអ្វី ?

ឆ្លើយថា ដូចរងើកភ្លើងបិតបាំងដោយផេះ (ផេះគ្របពីលើ) ។

អធិប្បាយថា ដូចយ៉ាងថា រងើកភ្លើងមានអណ្តាតទៅប្រាសហើយ ដែលបិទបាំងដោយផេះ សូម្បីបុគ្គលជាន់ហើយក៏មិនទាន់រលាកភ្លាមទេ ព្រោះផេះបិទបាំង ប៉ុន្តែញ៉ាំងផេះឱ្យក្តៅហើយ រមែងធ្វើឱ្យរលាករហូតដល់ខួរក្បាល ដោយអំណាចនៃការឆេះអវយវៈ មានស្បែកជាដើមយ៉ាងណា សូម្បីបាបកម្មក៏

ដូច្នោះដែរ ជាបាបកម្មដែលបុគ្គលណាធ្វើទុក រមែងតាមដុតបុគ្គលនោះដែលជាបុគ្គលពាលកើតហើយក្នុងអបាយ មាននរកជាដើមក្នុងអត្តភាពទី ២ ឬទី ៣ ។

## ព្រះគាថាប្រារព្ធចំពោះសដ្ឋិកូដប្រេត

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ ។

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ រមែងញុំាងបញ្ញាឱ្យធ្លាក់ចុះ បំផ្លេចបំផ្លាញចំណែកធម៌ស គឺកុសលរបស់បុគ្គលពាលនោះ ។

## អធិប្បាយគាថា

សព្ទថា យាវទេវ ក្នុងគាថានេះជានិបាត ក្នុងអត្ថ គឺការកំណត់នូវព្រំដែន ។

ការចេះដឹង ឈ្មោះថា ញត្តំ ។

បុគ្គលរមែងចេះដឹងនូវសិល្បៈឯណានីមួយ ឬបុគ្គលតាំងនៅក្នុងភាពជាធំឯណានីមួយ ឬដោយការដល់ព្រមដោយយស

ឯណាដែលជនរមែងដឹង គឺប្រាកដបានដល់ ជាអ្នកដឹងទូទៅ ។

ពាក្យថា ញត្តំ នេះ ជាឈ្មោះនៃសិល្បៈ ភាពជាធំនិងការដល់ព្រមដោយយសនោះឯង ។

ពិតប្រាកដ សិល្បៈ ឬភាពជាធំជាដើម កើតឡើងដល់បុគ្គលពាលគ្រាន់តែសេចក្តីវិនាសប៉ុណ្ណោះ គឺបុគ្គលពាលនោះអាស្រ័យសិល្បៈនោះហើយ រមែងធ្វើសេចក្តីវិនាសដល់ខ្លួនឯងតែម្យ៉ាង ។

បទថា ហន្តិ បានដល់ ឱ្យវិនាស ។

បទថា សុក្កំសំ គឺចំណែកនៃកុសល ។ អធិប្បាយថា សិល្បៈ ឬភាពជាធំ ការកើតឡើងដល់បុគ្គលពាល រមែងកើតឡើង ដើម្បីសម្លាប់នូវចំណែកនៃកុសលតែប៉ុណ្ណោះ ។

បទថា មុទ្ធំ ជាឈ្មោះនៃបញ្ញា ។

បទថា វិបាតយំ គឺកម្ចាត់ អធិប្បាយថា ក៏ការចេះដឹងនោះ រមែងសម្លាប់ចំណែកនៃកុសលរបស់បុគ្គលពាលនោះញ៉ាំងសទ្ធាពោលគឺបញ្ញាឱ្យធ្លាក់ចុះគឺកម្ចាត់នោះឯងឈ្មោះថា សម្លាប់ ។

## ព្រះគាថាប្រារព្ធចំពោះព្រះសុធម្មត្ថេរៈ

អសន្តំ ភាវមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ
អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។
មមេវ កត មញ្ញន្តុ គិហិប្បព្វជិតា ឧភោ
មមេវ អតិវសា អស្សុ កិច្ចាកិច្ចេសុ កិស្មិចិ ឥតិ
ពាលស្ស សង្កប្បោ ឥច្ឆា មានោ ច វឌ្ឍតិ ។

*ភិក្ខុពាល រមែងប្រាថ្នានូវសេចក្ដីសរសើរ ដែលមិនមាន (ក្នុងខ្លួន)ផង នូវការធ្វើក្នុងខាងមុខ គឺជាប្រមុខក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលនៃជនទាំងឡាយដទៃផង ភិក្ខុពាលតែងមានសេចក្ដីត្រិះរិះថា គ្រហស្ថនឹងបព្វជិតទាំងពីរពួក ចូរសំគាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយថា ជាកិច្ចរបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរមានក្នុងកិច្ចតូច ធំណា ៗមួយ (កាលបើយ៉ាងនេះ)ឫស្យានឹងមានរមែងចំរើន ។*

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា អសទ្ធំ សេចក្ដីថា ភិក្ខុពាល រមែងប្រាថ្នាសេចក្ដីសរសើរដែលមិនមានក្នុងខ្លួន គឺភិក្ខុអ្នកពាល មិនមានសទ្ធា ជាអ្នកទ្រុស្ដសីល ស្ដាប់តិច មិនស្ងប់ស្ងាត់ ខ្ជិល ច្រអូស មានសតិមិនតាំងមាំ មានចិត្តមិនតាំងមាំជាអ្នកមានបញ្ញា អន់ថយ មិនមែនព្រះខីណាស្រព រមែងប្រាថ្នាការសរសើរដែល មិនមាននេះថា ដូចម្ដេចហ្ន៎ ជនទាំងឡាយគប្បីដឹងយើងថា ភិក្ខុ នេះមានសទ្ធា មានសីល ជាពហុស្សូត ជាអ្នកស្ងប់ស្ងាត់ ប្រារព្ធ សេចក្ដីព្យាយាម មានសតិតាំងមាំ មានចិត្តតាំងមាំ មានបញ្ញា ជាព្រះខីណាស្រព សមដូចន័យដែលព្រះធម្មសេនាបតីសារីបុត្រ ពោលទុកក្នុងបាបិច្ឆតានិទ្ទេសថា ភិក្ខុពាលជាអ្នកមិនមានសទ្ធា រមែងប្រាថ្នាថា ជនទាំងឡាយចូរដឹងថាជាអ្នកមានសទ្ធាជាដើម ។

បទថា បុរេក្ខារំ បានដល់ បរិវារ គឺការចោមរោម ។ អធិប្បាយថា ភិក្ខុអ្នកពាល តាំងនៅក្នុងសេចក្ដីប្រាថ្នាយ៉ាងនេះថា ដូចម្ដេចហ្ន៎ ភិក្ខុក្នុងវិហារទាំងអស់ គប្បីចោមរោមសួរបញ្ហា យើងឈ្មោះថា ប្រាថ្នាការចោមរោមហែហមអំពីភិក្ខុទាំងឡាយ ។

បទថា អាវាសេសុ បានដល់ ក្នុងអាវាសដែលជារបស់សង្ឃ ។ អធិប្បាយថាភិក្ខុពាលចាត់ចែងសេនាសនៈដ៏ប្រណីត ៗ ក្នុងកណ្ដាលវិហារ ដើម្បីភិក្ខុទាំងឡាយដែលជាមិត្តត្រឹមតែឃើញនិងមិត្តសេពគប់ជាដើមរបស់ខ្លួន ដោយប្រាប់ថា ពួកលោកចូរនៅក្នុងសេនាសនៈនេះ ចំណែកខ្លួនឯងខ្វល់ខ្វាយរើសរកតែសេនាសនៈល្អ ៗ សម្រាប់ខ្លួនឯង ចាត់ចែងសេនាសនៈដ៏ស្មោកគ្រោក និងសេនាសនៈដែលអមនុស្សហួងហែងដែលតាំងនៅខាងចុងវិហារ ដើម្បីអាគន្តុកដ៏សេសទាំងឡាយ ដោយប្រាប់ថាពួកលោកចូរនៅក្នុងសេនាសនៈនេះឈ្មោះថា ប្រាថ្នាភាពជាធំក្នុងអាវាស ។

បាទព្រះគាថាថា បូជា បរកុលេសុ ច សេចក្ដីថាភិក្ខុពាល រមែងមិនប្រាថ្នាការបូជាដោយបច្ច័យ ៤ ក្នុងត្រកូលរបស់មាតានិងបិតាឡើយ ហើយសូម្បីតែត្រកូលរបស់ពួកញាតិក៏មិនប្រាថ្នាដែរ (តែ)រមែងប្រាថ្នាក្នុងត្រកូលរបស់ពួកជនដទៃប៉ុណ្ណោះយ៉ាងនេះថា ដូចម្ដេចហ្ន៎ជនទាំងនេះគប្បីឱ្យតែយើងម្នាក់កុំគប្បីឱ្យដល់ភិក្ខុដទៃឡើយ ។

បាទព្រះគាថាថា **មមេវ កត មញ្ញន្តុ** សេចក្ដីថា ក៏សេចក្ដីត្រិះរិះ រមែងកើតឡើងដល់ភិក្ខុអ្នកពាលឯណាថា ពួកគ្រហស្ថនិងបព្វជិត សូម្បីទាំងពីរពួកចូរសម្គាល់នូវកិច្ចដែលខ្លួនធ្វើហើយ ជាកិច្ចសម្រេចហើយ ព្រោះអាស្រ័យអាត្មាអញប៉ុណ្ណោះវិញ ដោយបំណងយ៉ាងនេះថា នវកម្មឯណានីមួយដែលគេធ្វើហើយក្នុងវិហារ ដោយអំណាចការធ្វើនវកម្មមានរោងឧបោសថជាដើម នវកម្មទាំងអស់នោះព្រះថេរៈធ្វើហើយ ដើម្បីពួកយើងទាំងឡាយ ។

បាទព្រះគាថាថា **មមេវ អតិវសា អស្សុ** សេចក្ដីថា សេចក្ដីត្រិះរិះរមែងកើតឡើង( ដល់ភិក្ខុពាលនោះ )ថា គ្រហស្ថនិងបព្វជិត សូម្បីទាំងអស់ ចូរប្រព្រឹត្តទៅក្នុងអំណាចរបស់យើងតែមួយនាក់ គឺពាហនៈនិងគ្រឿងឧបករណ៍ទាំងឡាយជាដើមថា រទេះ គោ កាំបិតព្រា ពូថៅ ឬយ៉ាងហោចទៅ កិច្ចត្រឹមតែការកម្ដៅបបរឱ្យក្ដៅហើយហុត ដែលគ្រហស្ថនិងបព្វជិតគប្បីបានក៏ដោយចុះ ប៉ុន្តែបណ្ដាកិច្ចតូច និងកិច្ចធំទាំងឡាយ គឺបណ្ដាករណីយកិច្ចទាំងតូចទាំងធំបែបនេះគ្រហស្ថនិងបព្វជិតទាំងឡាយ ចូរប្រព្រឹត្ត

ទៅតាមអំណាចរបស់យើងប៉ុណ្ណោះក្នុងកិច្ចអ្វីមួយ គឺសូម្បីក្នុងកិច្ចតែមួយ ។ អធិប្បាយថា ចូរសួរយើងប៉ុណ្ណោះហើយទើបធ្វើ ។

ពីរបទថា ឥតិ ពាលស្ស សេចក្ដីថា សេចក្ដីប្រាថ្នានោះនិងសេចក្ដីត្រិះរិះបែបនេះ រមែងកើតឡើងដល់ភិក្ខុអ្នកពាលណា វិបស្សនាមគ្គនិងផល រមែងមិនចម្រើនដល់ភិក្ខុពាលនោះដោយពិតប្រាកដ ក៏ប៉ុន្តែអគតិធម៌មានតណ្ហាដែលអាស្រ័យឆន្ទៈជាដើម ដែលកើតតាមទ្វារ ៦ និងមានះ ៩ យ៉ាង[1] រមែងចំរើនឡើងដល់ភិក្ខុពាលដោយពិត ដូចទឹករមែងចម្រើន ដល់សមុទ្រក្នុងវេលាព្រះច័ន្ទខាងខ្នើតដូច្នោះ ។

## ព្រះគាថាប្រារព្ធចំពោះព្រះវនវាសីតិស្សត្ថេរៈ

អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី
ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ

---

១. មានះ ៩ យ៉ាងមើលពិស្ដារក្នុងបរិច្ឆេទទី ២ ។ នេះប្រែតាមច្បាប់សីហឡនិងអឺរ៉ុប តែតាមច្បាប់ថៃ វេលាប្រែខាងដើម និស្សាយចូលមក ។ ប្រែថា តណ្ហាដែលអស្រ័យឆន្ទៈជាដើម កើតឡើងក្នុងទ្វារ ៦ និងមានះ ៩ យ៉ាងរមែងចំរើន ។

សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។

បដិបទាអាស្រ័យនូវលាភផ្សេង ១ បដិបទាជាដំណើរទៅកាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវ័ករបស់ព្រះពុទ្ធដឹងច្បាស់នូវហេតុនោះយ៉ាងនេះ ហើយមិនគួរត្រេកអរចំពោះសក្ការៈឡើយ គប្បីញុំាងវិវេកឱ្យចំរើនដោយលំដាប់ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បាទព្រះគាថាថា អញ្ញា ហិ លាភូ-បនិសា សេចក្ដីថាដែលឈ្មោះថា បដិបទាដែលចូលទៅអាស្រ័យលាភនោះផ្សេងបដិបទាដែលញុំាងសត្វឱ្យដល់ព្រះនិព្វានផ្សេង ។

ពិតណាស់ភិក្ខុញុំាងលាភឱ្យកើតឡើង គួរធ្វើអកុសលកម្មបន្ទិចបន្តួចដោយអំពើទាំងឡាយ មានការវៀរដោយកាយជាដើម ជាអំពើដែលភិក្ខុគប្បីធ្វើដើម្បីលាភ ។ ត្បិតថា ក្នុងកាលណាភិក្ខុធ្វើអំពើវៀចទាំងឡាយ មានវៀចដោយកាយជាដើម ។ ក្នុងកាលនោះ លាភរមែងកើតឡើង ។ ដូចយ៉ាងថា កាលភិក្ខុលូកដៃចុះទៅក្នុងផ្តិលនៃមធុបាយាសដោយត្រង់ មិនឱ្យងឡើង ហើយលើកឡើងវិញ ដៃគ្រាន់តែប្រលាក់មធុបាយាស

ប៉ុណ្ណោះ ប៉ុន្តែភិក្ខុកាលធ្វើដៃឱ្យវៀចហើយ លូកទៅលើកឡើង វិញ ដៃរមែងគាស់ឡើងនូវដុំមធុបាយាសចេញមកដោយពិត លាភនិងសក្ការៈរមែងកើតឡើងក្នុងកាលធ្វើអំពើវៀចទាំងឡាយ មានវៀចដោយកាយជាដើមយ៉ាងនេះ នេះចាត់ជាឧបដិបទាដែល ចូលទៅអាស្រ័យលាភដែលមិនប្រកបដោយធម៌ ។ ប៉ុន្តែលាភ ដែលកើតឡើងដោយហេតុបែបនេះ គឺការដល់ព្រមដោយឧបធិ[១] ការទ្រទ្រង់នូវចីវរ (ការគ្រងនូវចីវរ) ភាពជាពហុស្សូត ការមាន បរិវារ ការនៅព្រៃ ឈ្មោះថា ប្រកបដោយធម៌ ។

ក៏ភិក្ខុអ្នកបំពេញបដិបទាដែលញ៉ាំងសត្វឱ្យដល់ព្រះនិព្វាន មិនមែនជាមនុស្សខ្វាក់ គប្បីធ្វើដូចជាមនុស្សខ្វាក់ មិនមែនមនុស្ស គ គប្បីធ្វើដូចជាមនុស្សគ មិនមែនមនុស្សថ្លង់ គប្បីធ្វើដូចជា មនុស្សថ្លង់ទើបគួរ ។

បទថា **ឯវមេតំ** ជាដើម សេចក្តីថា ភិក្ខុឈ្មោះថា ជា សាវ័ក ព្រោះអត្ថថា កើតក្នុងទីបំផុតនៃការស្តាប់ ឬព្រោះអត្ថថា

១. ឧបធិសម្បទា ច្បាប់អឺរ៉ុបជា ឧបសម្បទា ។ ពាក្យថា ឧបធិ ជាឈ្មោះរបស់ កិលេសក៏មាន របស់រាងកាយក៏មាន ក្នុងទីនេះជាឈ្មោះរបស់រាងកាយឧបធិសម្បទា ទើបសំដៅដល់រូបសម្បត្តិ ។

ស្តាប់ឪវាទ និងអនុសាសនីរបស់បុគ្គលអ្នកឈ្មោះថា ពុទ្ធ ព្រោះអត្ថថា ត្រាស់ដឹងនូវសង្ខតធម៌ និងអសង្ខតធម៌ទាំងអស់ ដឹងច្បាស់នូវបដិបទា ដែលជាគ្រឿងញុំាងលាភឱ្យកើតឡើង និងឧបដិបទាញុំាងសត្វឱ្យដល់ព្រះនិព្វានយ៉ាងនោះហើយ មិនគួរត្រេកអរចំពោះលាភសក្ការៈគឺបច្ច័យ[១] ៤ ដែលមិនប្រកបដោយធម៌ និងមិនគប្បីហាមឃាត់សក្ការៈដែលប្រកបដោយធម៌ឡើយ គប្បីញុំាងវិវេក មានកាយវិវេកជាដើម ឱ្យចំរើនតាមលំដាប់ ។

បណ្តាវិវេកទាំងនោះ ភាពជាអ្នកមានកាយតែម្នាក់ឯង ឈ្មោះថា កាយវិវេក្ខ សមាបត្តិ[២] ៨ ឈ្មោះថា ចិត្តវិវេក្ខ ព្រះនិព្វាន ឈ្មោះថា ឧបធិវិវេក[៣] ។

បណ្តាវិវេកទាំងនោះ កាយវិវេក រមែងបន្ទោបង់នូវការប្រឡូកប្រលំដោយគណៈចិត្តវិវេករមែងបន្ទោបង់សេចក្តីប្រឡាក់ប្រឡូសដោយកិលេស ឧបធិវិវេករមែងបន្ទោបង់នូវការជាប់ជំពាក់ដោយសង្ខារ កាយវិវេករមែងជាបច្ច័យនៃចិត្តវិវេក ចិត្តវិវេក

---

១. ចីវរ ១. បិណ្ឌបាត ១. សេនាសនៈ ១. គិលានភេសជ្ជ ។

១. រូបឈាន ៤ អរូបឈាន ៤ សេចក្តីពិស្តារមើលក្នុងអភិធម្មវិភាគបរិច្ឆេទទី ២. ឧបធិមាន ៤ គឺ ឃន្ធូបធិ កិលេសូបធិ អសង្ខារូបធិ កាមូបធិ ។

រមែងជាបច្ច័យនៃឧបធិវិវេក សមដូចពាក្យដែលព្រះសារីបុត្តត្ថេរៈពោលទុកថា កាយវិវេករបស់អ្នកមានកាយស្ងប់ហើយ ត្រេកអរក្រៃលែងហើយក្នុងការចេញបួស ចិត្តវិវេករបស់អ្នកមានចិត្តបរិសុទ្ធិហើយដល់ការផូរផង់យ៉ាងក្រៃលែង និងឧបធិវិវេករបស់បុគ្គលអ្នកមិនមានឧបធិ រមែងដល់ព្រះនិព្វាន គប្បីចម្រើន គឺគប្បីបង្កើតឡើង អធិប្បាយថា គប្បីចូលទៅដល់វិវេក ៣ នេះហើយនៅចុះ ។

## សេចក្ដីផ្សេងគ្នារវាងបណ្ឌិតនិងបុគ្គលពាល

ដូចដែលយើងបានដឹងហើយថា **បណ្ឌិត** ជនទាំងឡាយឯណា រមែងបានទទួលនូវប្រយោជន៍ទាំងឡាយ ២ គឺប្រតិបត្តិដើម្បីបានទទួលនូវប្រយោជន៍ទាំង ២ នោះ ជនទាំងឡាយនោះឈ្មោះថា **បណ្ឌិត** ។ ព្រោះព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយក្នុង**ឧភោអត្ថសូត្រ** ក្នុងកោសលសំយុត្ត យ៉ាងដូច្នេះថា ៖

"ធីរជន លោកហៅថា **"បណ្ឌិត"** ព្រោះទាញយកប្រយោជន៍ (ទាំង ២)បាន គឺប្រយោជន៍ក្នុងបច្ចុប្បន្ន និងប្រយោជន៍ក្នុងសម្បរាយិកភព" ។

ឯចំណែកបុគ្គលពាលវិញគឺ ខុសអំពីបុគ្គលជាបណ្ឌិតនៅត្រង់ថា ជនទាំងឡាយឯណា កាត់ចោលនូវប្រយោជន៍ទាំង ២ យ៉ាងកាន់យកនូវហេតុមិនមែនជាប្រយោជន៍ទាំង ២ យ៉ាង ជនទាំងឡាយនោះឈ្មោះថា **ពាល ។** មែនពិតជនទាំងឡាយនោះលោកហៅថា **"ពាល"** ក៏ព្រោះកាន់យក នូវហេតុដែលមិនមែនជាប្រយោជន៍ទាំងឡាយ ២ ប្រការ និងលោកហៅថា **"ពាល"** ក៏ព្រោះកាត់ផ្តាច់ចោលនូវប្រយោជន៍ទាំងឡាយ ២ ប្រការ ។

## អច្ចយសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ៣០៣ ព្រះអង្គទ្រង់ត្រាស់សម្តែងជាមួយអនាថបិណ្ឌិកសេដ្ឋី [**ដែលនិយាយអំពីបុគ្គលពាលនិងបុគ្គលជាបណ្ឌិត**] ដោយមានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។

សម័យមួយនោះឯង ភិក្ខុពីររូបទាស់ទែងគ្នា ។ បណ្តាភិក្ខុពីររូបនោះ ភិក្ខុមួយរូបនិយាយរំលោភហួស ។

គ្រានោះឯង ភិក្ខុនោះសម្តែងទោសតាមសមគួរដល់ទោសក្នុងសំណាក់ភិក្ខុនោះ ។ តែភិក្ខុនោះមិនទទួល ។

គ្រានោះឯង ពួកភិក្ខុជាច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះកើតការទាស់ទែងគ្នា បណ្ដាភិក្ខុពីររូបនោះភិក្ខុមួយរូបនិយាយរំលោភហួសប ពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង ភិក្ខុនោះសម្ដែងទោសតាមសមគួរដល់ទោស ក្នុងសំណាក់ភិក្ខុនោះ តែភិក្ខុនោះមិនទទួល ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយបុគ្គលពាលនេះមានពីរពួក ។ **គឺបុគ្គលដែលមិនឃើញទោសតាមទោស ១ បុគ្គលដែលគេកាលសម្ដែងទោស មិនទទួលតាមធម៌ ១ ។** ម្នាលភិក្ខុទាំងឡាយ នេះឯងបុគ្គលពាលពីរពួក ។ ម្នាលភិក្ខុទាំងឡាយបុគ្គលជាបណ្ឌិតនេះក៏មានពីរពួក ។ **គឺបុគ្គលដែលឃើញទោសតាមទោស ១ បុគ្គលដែលគេកាលសម្ដែងទោសទទួលតាមធម៌ ១ ។** ម្នាលភិក្ខុ នេះឯងបណ្ឌិតមានពីរពួក ។

ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ សក្កទេវរាជមិនុ

ពន្យល់ពួកទេវតានៅឋានតាវត្តិង្ស ក្នុងរោងប្រជុំឈ្មោះ សុធម្មា បានពោលគាថានេះក្នុងវេលានោះថា ៖

កោធោ វោ វសមាយាតុ មា ច មិត្តេ ហិ វោ ជរា
អគរហិយំ មា គរហិត្ថ មា ច ភាសិត បេសុណំ
អថ បាបជនំ កោធោ បព្វតោវាភិមទ្ទតីតិ ។

សេចក្តីក្រោធ ចូរមកក្នុងអំណាចរបស់អ្នកទាំងឡាយ សេចក្តីប្រែប្រួលរបស់អ្នកទាំងឡាយ កុំកើតក្នុងមិត្តធម៌ ពួកអ្នក កុំតិះដៀលបុគ្គលដែលមិនគួរតិះដៀល ទាំងកុំនិយាយពាក្យសិក សៀតឡើយ ព្រោះសេចក្តីក្រោធដូចជាភ្នំសង្កត់សង្កិនជនអាក្រក់ ។

## អដ្ឋកថា

បទថា សម្បយោជេសុំ ប្រែថា ឈ្លោះគ្នា ។

បទថា អច្ចសរា បានដល់ កន្លងលើស ។ អធិប្បាយថា ភិក្ខុមួយរូប បានពោលពាក្យកន្លងល្មើសភិក្ខុមួយរូប ។

បទថា យថាធម្មំ ន បដិគ្គណ្ហាតិ បានដល់ មិនលើក ទោស ។

បទថា គោចោ វោ វសមាយាតុ លោកសម្ដែងថា សេចក្ដីក្រោធចូរមកកាន់អំណាចរបស់ពួកលោក ពួកលោកកុំទៅកាន់អំណាចរបស់សេចក្ដីក្រោធ ។ ពាក្យថា ហិ ក្នុងបទនេះថា មា ច មិត្តេ ហិ វោជរា ត្រឹមតែជានិបាត ។ សេចក្ដីសាបសូន្យក្នុងមិត្តធម៌ កុំកើតដល់ពួកលោក ។ ម្យ៉ាងទៀត តតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ អធិប្បាយថា សេចក្ដីសាបសូន្យក្នុងមិត្តធម៌កុំកើតមាន គឺថាសេចក្ដីជាប្រការដទៃអំពីភាពជាមិត្តចូរកុំមានឡើយ ។

បទថា អគរហិយំ មា គរហិត្ថ សេចក្ដីថា កុំតិះដៀលអ្នកមិនគួរតិះដៀល គឺបុគ្គលដែលជាខីណាស្រព ។

## តិកណ្ឌកីវគ្គទី ៥ មិត្តសូត្រ

នៅក្នុងបិដកលេខ ៤៥, ទំព័រ ៨៦ ព្រះអង្គទ្រង់ត្រាស់ជាមួយភិក្ខុទាំងឡាយ[**ដែលនិយាយអំពីធម៌របស់ភិក្ខុដែលគួរសេពគប់និងមិនគួរសេពគប់**] ដោយមានសេចក្ដីថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង មិនគួរគប់រកយកជាមិត្រឡើយ ។

**ប្រកបដោយធម៌ ៥ យ៉ាង ដូចម្ដេចខ្លះ ?**

១- កាមន្តំ ការេតិ *គឺភិក្ខុប្រើឱ្យគេធ្វើការងារ,*

២- អធិករណំ *បន្តអធិករណ៍,*

៣- អាទិយតិ បាមោក្ខេសុ ភិក្ខូសុ បដិវិរុទ្ធោ ហោតិ *ជាសឹកសត្រូវក្នុងពួកភិក្ខុជាប្រធាន,*

៤- ទីឃចារិកំ អនវត្ថានចារិកំ អនុយុត្តោ វិហរតិ *ត្រេចទៅក្នុងទីឆ្ងាយនឹងទីមិនមានកំណត់រឿយ ៗ*

៥- បដិពលោ ហោតិ កាលេន កាលំ ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ *មិនអង់អាចដើម្បីពន្យល់ឱ្យកាន់តាម ឱ្យអាចហាន ឱ្យរីករាយដោយធម្មីកថាតាមកាលគួរ ។*

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង នេះ មិនគួរគប់រកយកជាមិត្រឡើយ ។*

*ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង នេះ គួរគប់រកយកជាមិត្របាន ។*

**ប្រកបដោយធម៌ ៥ យ៉ាង ដូចម្តេចខ្លះ ។**

១- ន កម្មន្តំ ការេតិ គឺភិក្ខុមិនប្រើឱ្យគេធ្វើការងារ

២- ន អធិករណំ មិនបង្កអធិករណ៍

៣- អាទិយតិ ន ធាមោក្ខេសុ ភិក្ខូសុ បដិវិរុទ្ធោ ហោតិ មិនជាសឹកសត្រូវក្នុងពួកភិក្ខុជាប្រធាន

៤- ន ទីឃចារិកំ អវត្ថានចារិកំ អនុយុត្តោ វិហរតិ មិនត្រេចទៅក្នុងទីឆ្ងាយនឹងទីមិនមានកំណត់រឿយ ៗ

៥- ន បដិពលោ ហោតិ កាលេន កាលំ ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ ជាអ្នកអង់អាចដើម្បីពន្យល់ឱ្យកាន់តាម ឱ្យអាចហាន ឱ្យរីករាយដោយធម្មីកថាតាមកាលគួរ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះ គួរគប់រកយកជាមិត្របាន ។

## អដ្ឋកថា

បទថា កម្មន្តំ ការេតិ បានដល់ ប្រើឱ្យធ្វើការងារ មានធ្វើស្រែជាដើម ។

បទថា អធិករណំអាទិយតិ បានដល់ បង្កអធិករណ៍៤ ។

បទថា ធាមោក្ខេសុ ភិក្ខូសុ បានដល់ ក្នុងភិក្ខុអ្នកជាទិសាបាមោក្ខ គឺជាប្រធាន ។

បទថា បដិវិរុទ្ធោ ហោតិ បានដល់ ជាអ្នកទាស់ទែង គ្នាព្រោះប្រកាន់ថាជាសត្រូវ ។

បទថា អវដ្ឋានចារិកំ បានដល់ ត្រេចទៅមិនមានគោលដៅ ។

## ពួកសូត្រមិនគ្រោះក្នុងវគ្គ មិត្តសូត្រ

នៅក្នុងបិដកលេខ ៤៦ ទំព័រ ២៨៦ ព្រះអង្គទ្រង់ត្រាស់នូវធម៌ [**ដែលនិយាយអំពីគុណនិងទោសរបស់ការមានមិត្ត**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះឯងមានមិត្តអាក្រក់ មានសំឡាញ់អាក្រក់ បែរទៅរប់រកតែបុគ្គលអាក្រក់ សេពគប់ ចូលទៅអង្គុយជិតពួកមិត្តអាក្រ់ យកតម្រាប់តម្រាតាមពួកមិត្តអាក្រក់ទាំងនោះ នឹងបំពេញអភិសមាចារិកធម៌ឱ្យបរិបូណ៌បាន ហេតុនេះមិនដែលមានឡើយ ។ បើមិនបានបំពេញអភិសមាចារិកធម៌ឱ្យ

បរិបូណ៌ហើយ នឹងបំពេញសេក្ខធម៌ឱ្យបរិបូណ៌បាន ហេតុនេះមិនដែលមានទេ ។ បើមិនបានបំពេញសេក្ខធម៌ ឱ្យបរិបូណ៌ហើយ នឹងបំពេញសីលទាំងឡាយឱ្យបរិបូណ៌បាន ហេតុនេះមិនដែលមានទេ ។ បើមិនបានបំពេញសីលទាំងឡាយឱ្យបរិបូណ៌បានទេ នឹងលះបង់កាមរាគ ឬ រូបរាគ ឬក៏អរូបរាគបាន ហេតុនេះក៏មិនដែលមានទេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះមានមិត្តល្អ មានសំឡាញ់ល្អ បែរទៅរាប់រកតែបុគ្គលល្អ សេពគប់ ចូលទៅអង្គុយជិតចំពោះពួកមិត្តល្អ ហើយក៏យកតម្រាប់តម្រាតាមពួកមិត្តល្អទាំងនោះនឹងបំពេញអភិសមាចារិកធម៌ឱ្យបរិបូណ៌បាន ហេតុនេះ ទើបមានមែន ។ បើបានបំពេញអភិសមាចារិកធម៌ឱ្យបរិបូណ៌ហើយ នឹងបំពេញសេក្ខធម៌ឱ្យបរិបូណ៌បានទៀត ហេតុនេះទើបមិនមាន ។ បើបានបំពេញសេក្ខធម៌ឱ្យបរិបូណ៌ហើយ នឹងបំពេញសីលទាំងឡាយឱ្យបរិបូណ៌បានទៀត ហេតុនេះទើបមិនមាន ។ បើបានបំពេញសីលទាំងឡាយហើយ នឹងលះបង់កាមរាគ ឬរូបរាគ ឬក៏អរូបរាគចេញបាន ហេតុនេះទើបមិនមាន ។

## អដ្ឋកថា

បទថា អភិសមាចារិកំ បានដល់ ធម៌ដែលជាទីសមា-ចារខ្ពង់ខ្ពស់ គឺសីលដែលជាឧបញ្ញត្តិ ដោយអំណាចនៃវត្ត ។

បទថា សេក្ខធម្មំ បានដល់ សីលដែលជាឧបញ្ញាត្តិទាក់ទងជាមួយសេក្ខិយវត្ត ។ បទថា សីលានិ បានដល់ មហា-សីល ៤ យ៉ាង ។

## បឋមខតសូត្រ

នៅក្នុងបិដកលេខ៤២, ទំព័រ ៥ ព្រះអង្គទ្រង់ត្រាស់អំពី [**ធម៌៤ យ៉ាងរបស់បុគ្គលពាលនិងបណ្ឌិត**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរស ប្រកបដោយធម៌ ៤ យ៉ាង រមែងរក្សាខ្លួនដែលខូនជីកគាល់កំចាត់គុណចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង បាននូវបាបដ៏ច្រើនផង ។ **ធម៌ ៤ យ៉ាង តើដូចម្តេចខ្លះ ។**

១- អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ

ភាសតិ បុគ្គលនោះមិនបានពិចារណា ស្ទាបស្ទង់មើលហើយ ពោលសរសើរ បុគ្គលដែលគួរតិះដៀល

២. អននុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ ភាសតិ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយ ពោលតិះដៀល

៣. អននុវិច្ច អបរិយោគាហេត្វា អប្បសាទនីយេ ឋានេ បសាទំ ឧបធំសេតិ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយកើតសេចក្តីជ្រះថ្លាក្នុង ហេតុដែលមិនគួរជ្រះថ្លា

៤. អននុវិច្ច អបរិយោគាហេត្វា បសាទនីយេ ឋានេ អប្បសាទំ ឧបធំសេតិ មិនបានពិចារណា ស្ទាបស្ទង់មើល ហើយកើតសេចក្តីមិនជ្រះថ្លា ក្នុងហេតុដែលគួរជ្រះថ្លា ។

៦. ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលមិនឈ្លាសវៃ ជាអសប្បុរសប្រកបដោយធម៌ទាំង ៤ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលខ្លួនជីកគាល់កំចាត់គុណាចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយ

ផង បាននូវបាបដ៏ច្រើនផង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ ៤ យ៉ាង រមែងរក្សាខ្លួនដែលខ្លួនជីកគាស់កំចាត់គុណចោល ហើយជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង បាននូវបាបដ៏ច្រើនផង ។ **ធម៌ ៤ តើដូចម្តេចខ្លះ ។**

**១- អនុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស អវណ្ណំ** ភាសតិ គឺបុគ្គលនោះមិនបានពិចារណាស្ទាបស្ទង់មើល រួចហើយ ទើបពោលតិះដៀលបុគ្គលដែលគួរតិះដៀល ។

**២- អនុវិច្ច អបរិយោគាហេត្វា អវណ្ណារហស្ស វណ្ណំ** ភាសតិ មិនបានពិចារណាស្ទាបស្ទង់មើល រួចហើយទើបពោលសរសើរបុគ្គលដែលគួរសរសើរ

**៣- អនុវិច្ច អបរិយោគាហេត្វា អប្បសាទនីយេ** ឋានេ បសាទំ ឧបទំសេតិ ពិចារណាស្ទាបស្ទង់មើល រួចហើយទើបកើតសេចក្តីមិនជ្រះថ្លាក្នុងហេតុ ដែលមិនគួរជ្រះថ្លា

៤. អនុវិច្ច អបរិយោគាហេត្វា បសាទនីយេ ឋានេ អប្បសាទំ ឧបទំសេតិ ពិចារណាស្ទាបស្ទង់មើល រួចហើយ ទើបកើតសេចក្តីជ្រះថ្លាក្នុងហេតុដែលគួរជ្រះថ្លា ។

៦. ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ ៤ យ៉ាងនេះឯង រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនកំចាត់គុណចោលហើយ ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។

## និគមគាថា

យោ និន្ទិយំ បសំសតិ
តំ វា និន្ទតិ យោ បសំសិយោ
វិចិនាតិ មុខេន សោ កលឹ
កលិនា តេន សុខំ ន វិន្ទតិ ។
អប្បមត្តោ អយំ កលិ
យោ អក្ខេសុ ធនបរាជយោ

សព្វស្សាបិ សហាបិ អត្តនា
អយមេវ មហត្តរោ កលិ
យោ សុគតេសុ មនំ បទោសយេ
សតំ សហស្សានំ និរព្ពុទានំ
ឆត្តឹសតិ បញ្ច ច អព្ពុទានិ
យមរិយំ គរហីយំ និរយំ ឧបេតិ
វាចំ មនញ្ច បណិធាយ បាបកន្តិ ។

បុគ្គលណាសរសើរបុគ្គលដែលគួរតិះដៀលក្តី តិះដៀលបុគ្គលដែលគួរសរសើរក្តី បុគ្គលនោះឈ្មោះថា ជ្រើសរើសយកកំហុសដោយមាត់ពាក្យ រមែងមិនបានសេចក្តីសុខ ព្រោះកំហុសនោះឡើយ ។ ការចាញ់ដោយទ្រព្យណា ព្រមទាំងទ្រព្យរបស់ខ្លួនក្តី ទាំងខ្លួនក្តី ព្រោះល្បែងភ្នាល់ ការចាញ់ដោយទ្រព្យនេះ ជាកំហុសមានប្រមាណតិចទេ បុគ្គលណាញុំាងចិត្តឱ្យប្រទូស្ត ក្នុងពួកបុគ្គលដែលស្រេះស្រួលមូលមិត្តគ្នា កំហុសរបស់បុគ្គលនោះឯង ទើបធំជាងបុគ្គលដែលជំកល់វាចា នឹងចិត្តដ៏លាមកតិះដៀល

ព្រះអរិយៈរមែងទៅកើតក្នុងអស់ ១ សែនកប្បនឹង៣៦ និរព្វុទៈផង នឹង៥ អព្វុទៈផង ។

## អដ្ឋកថា៖

បទថា និន្ទិយំ បានដល់ អ្នកគួរនិន្ទា ។

បទថា និន្ទតិ បានដល់ រមែងតិះដៀល ។

បទថា បសំសិយោ បានដល់ អ្នកគួរសរសើរ ។

បទថា វិចិណាតិ មុខេ សោ កលឹ សេចក្តីថា អ្នកនោះប្រព្រឹត្តយ៉ាងនេះហើយ ឈ្មោះថា រមែងបន្កសេចក្តីវិនាសដោយមាត់នោះ ។

បទថា កលិនា តេន សុខំ ន វិន្ទតិ សេចក្តីថា គេរមែងមិនបានសេចក្តីសុខ ព្រោះទោសនោះ ។

បទថា សព្វស្សាបិ សហាបិ អត្តនា សេចក្តីថា ការបរាជ័យភ្នាល់ ទាំងទ្រព្យរបស់ខ្លួនគ្រប់វត្ថុ និងទាំងតួឯង ( អស់សាច់ប្រជាតួ ) ឈ្មោះថា ជាទោសប្រមាណតិចអ្នក ។

បទថា យោ សុគតេសុ សេចក្តីថា ចំណែកអ្នកណា

គប្បីធ្វើចិត្តគិតប្រទូសរ៉ាយក្នុងបុគ្គលទាំងឡាយ អ្នកដំណើរទៅដោយប្រពៃ ហើយសេចក្តីមានចិត្តគិតប្រទូសរ៉ាយរបស់អ្នកនោះនេះឯង មានទោសច្រើនជាងទោសនោះ ។ ឥឡូវនេះកាលទ្រង់សម្តែងសេចក្តីដែលមានចិត្តគិតប្រទូសរ៉ាយនោះ មានទោសច្រើនជាង ទើបត្រាស់ពាក្យថា សតំសហស្សានំ ជាអាទិ ។ បណ្តាបទទាំងនោះ បទថា សតំ សហស្សានំ បានដល់ អស់សែនដោយការរាប់តាមនិរព្វុទៈ ។

បទថា ឆត្តឹសតិ បានដល់ ទៀត ៣៦ និរព្វុទៈ ។

បទថាបញ្ច ច គឺ ៥ អព្វុទដោយការរាប់តាមអព្វុទៈ ។

បទថា យមរិយំ គរហិ សេចក្តីថា បុគ្គលកាលតិះដៀលព្រះអរិយៈទាំងឡាយ រមែងចូលដល់នរកណា ក្នុងនរកនោះប្រមាណអាយុមានប៉ុណ្ណោះ ។

## ទុតិយអតសូត្រ

នៅក្នុងបិដកលេខ ៤២, ទំព័រ ៨ ព្រះអង្គទ្រង់ត្រាស់នូវធម៌ [**ដែលនិយាយអំពីពាលនិងបណ្ឌិត**] ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គល៤ ពួក ឈ្មោះថារក្សាខ្លួនដែលខ្លួនជីកគាស់កំចាត់គុណាចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង បាននូវបាបដ៏ច្រើនផង ។ **បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។**

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលបើប្រតិបត្តិខុសក្នុងមាតា ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កំចាត់គុណាចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង

ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលប្រតិបត្តខុសក្នុងបិតា (ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កំចាត់គុណាចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង) ។

ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលប្រតិបត្តិខុសក្នុងព្រះតថាគត (ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កំចាត់គុណាចោលហើយ

ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបាបដ៏ច្រើនផង ) ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាសវៃ ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងសាវ័ករបស់ព្រះតថាគតឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កម្ចាត់គុណាចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលផង របស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបាបដ៏ច្រើនផង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មិនឈ្លាស ជាអសប្បុរស កាលប្រតិបត្តិខុសក្នុងបុគ្គល ៤ ពួកនេះឯង ឈ្មោះថា រក្សាខ្លួនដែលខ្លួនជីកគាស់កំចាត់គុណាចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀលផង របស់អ្នកប្រាជ្ញទាំងឡាយផង តែងបាននូវបាបដ៏ច្រើនផង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបុគ្គល ៤ ពួក ឈ្មោះថា រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនកំចាត់គុណាចោលហើយ ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀល របស់អ្នកប្រាជ្ញទាំង

ឡាយផង តែងបាននូវបុណ្យដ៏ច្រើនផង ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលបើប្រតិបត្តិត្រូវក្នុងមាតា ឈ្មោះថា រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកំចាត់គុណចោលហើយ ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបុណ្យដ៏ច្រើនផង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលបើប្រតិបត្តិត្រូវក្នុងបិតា (ឈ្មោះថា រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកំចាត់គុណចោលហើយ ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបុណ្យដ៏ច្រើនផង) ។

ម្នាលភិក្ខុទាំងឡាយ កាលប្រតិបត្តិត្រូវក្នុងព្រះតថាគត (ឈ្មោះថារក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកំចាត់គុណចោលហើយ ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបុណ្យដ៏ច្រើនផង) ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងសាវករបស់ព្រះតថាគតឈ្មោះថា រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកំចាត់គុណចោលហើយ ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបុណ្យដ៏ច្រើនផង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលជាបណ្ឌិតឈ្លាសវៃ ជាសប្បុរស កាលប្រតិបត្តិត្រូវក្នុងបុគ្គល ៤ ពួកនេះឯង ឈ្មោះថា រក្សាខ្លួនដែលខ្លួនមិនបានជីកគាស់ មិនបានកំចាត់គុណចោលហើយ ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀលរបស់អ្នកប្រាជ្ញទាំងឡាយផង តែងបានបុណ្យដ៏ច្រើនផង ។

## និគមគាថា

មាតរិ បិតរិ ចាបិ យោ មិច្ឆាបដិបជ្ជតិ
តថាគតេ ច សម្ពុទ្ធេ អថវា តស្ស សាវកេ
ពហុញ្ច សោ បសវតិ អបុញ្ញំ តាទិសោ នរោ ។
តាយ អធម្មចរិយា មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ គរហន្តិ បេច្ចាបាយញ្ច គច្ឆតិ ។

ជនណាប្រតិបត្តិត្រូវក្នុងមាតា ១ ក្នុងបិតា ១ ក្នុងព្រះតថាគតសម្ពុទ្ធ ១ ក្នុងសាវករបស់ព្រះតថាគតនោះ ១ ជនដូច្នោះនោះ រមែងបានបុណ្យដ៏ច្រើន ។ ក្នុងលោកនេះ បណ្ឌិតទាំងឡាយរមែងសរសើរជននោះ លុះបុគ្គលនោះទៅកាន់លោកខាងមុខហើយ រមែងរីករាយក្នុងស្ថានសួគ៌ ព្រោះការប្រព្រឹត្តត្រូវតាមធម៌នោះ ចំពោះមាតានឹងក្នុងបិតាទាំងឡាយ ។

មាតរិ បិតរិ ចាបិ យោ សម្មាបដិបជ្ជតិ
តថាគតេ ច សម្ពុទ្ធេ អថវា តស្ស សាវកេ
ពហុញ្ច សោ បសវតិ បុញ្ញំបិ តាទិសោ នរោ ។

ជនណាប្រតិបត្តិខុសក្នុងមាតា ១ ក្នុងបិតា ១ ក្នុងព្រះតថាគតសម្ពុទ្ធ ១ ក្នុងសាវករបស់ព្រះតថាគតនោះ ១ ជនដូច្នោះនោះ រមែងបានបាបដ៏ច្រើន ។ ក្នុងលោកនេះ បណ្ឌិតទាំងឡាយ រមែងតិះដៀលបុគ្គលនោះ លុះបុគ្គលនោះទៅកាន់លោកខាងមុខហើយ រមែងទៅកាន់អបាយទៀត ព្រោះការប្រព្រឹត្តមិនត្រូវតាមធម៌នោះ ក្នុងមាតានឹងក្នុងបិតាទាំងឡាយ ។

## អដ្ឋកថា

ក្នុងបទថា មាតរិ បិតរិ ច ជាអាទិ **នាយមិត្តវិទូកៈ** ឈ្មោះថា បដិបត្តិខុសក្នុងមាតា ។ ព្រះបាទអជាតសត្រូវឈ្មោះថា បដិបត្តិខុសក្នុងបិតា ។ **ទេវទត្ត** ឈ្មោះថា បដិបត្តិខុស ក្នុងព្រះតថាគត ។ **កោកាលិកៈ** ឈ្មោះថា បដិបត្តិខុសក្នុងព្រះសាវ័ករបស់ព្រះតថាគត ។

បទថា ពហុញ្ច ប្រែថា ច្រើន ។

បទថា បសវតិ ប្រែថា រមែងបាន ។

បទថា **ស្លាប់** សេចក្តីថា ដោយការប្រព្រឹត្តអធម៌ ពោលគឺសេចក្តីបដិបត្តិខុសនោះ ។

បទថា បេច្ច គឺ ទៅចាកពីលោកនេះ ។

បទថា **អបាយញ្ច** គច្ឆតិ គឺគេនឹងត្រូវកើតក្នុងនរកជាដើមកន្លែងណាមួយ ។ ចំណែកក្នុងសុក្កបក្ខ ( ធម៌ចំណែកល្អ ) ក៏ន័យនេះដូចគ្នា ។

# **ជិគុច្ឆិតព្វសុត្រ**

នៅក្នុងបិដកលេខ ៤១, ទំព័រ ៨ ព្រះអង្គទ្រង់ត្រាស់នូវធម៌(**ដែលនិយាយអំពីបុគ្គលគួរសេពគប់ នឹងមិនគួរសេពគប់**) ដោយមានសេចក្ដីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះរមែងមាននៅក្នុងលោក ។ បុគ្គល ៣ តើដូចម្ដេច ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរខ្ពើម មិនគួរសេព មិនគួរគប់ មិនគួរចូលទៅអង្គុយជិត ១,

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរព្រងើយកន្តើយ មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ១,

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរសេព គួរគប់រកគួរចូលទៅអង្គុយជិត ១ ។

៤. ម្នាលភិក្ខុទាំងឡាយ **ចុះបុគ្គលដែលគេគួរខ្ពើម មិនគួរសេព មិនគួរគប់ មិនគួរចូលទៅអង្គុយជិត** តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មិនស្អាត មានកិរិយាមារយាទប្រកបដោយ

សេចក្ដីវង្វៀស មានការងារលាក់លៀមទុក មិនមែនជាសមណៈ មិនមែនព្រហ្មចារី ប្ដេជ្ញាថាជាព្រហ្មចារី ស្អុយខាងក្នុងមានចិត្តជោគជាំដោយរាគៈ មានចិត្តជ្រោកជ្រាក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថា ជាបុគ្គលដែលគេគួរខ្ពើម មិនគួរសេព មិនគួរគប់ មិនគួរចូលទៅអង្គុយជិត ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលមិនលុះទៅតាមដំណើរទិដ្ឋិរបស់បុគ្គលមានសភាពយ៉ាងនេះ ក៏ពិតមែនហើយ ប៉ុន្តែថា បុគ្គលនោះគង់មានកិត្តិស័ព្ទដ៏លាមកល្បីឡើងថា បុរសបុគ្គលមានមិត្តអាក្រក់ មានសំឡាញ់អាក្រក់ មានគូកនអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ **ដូចជាពស់លូនទៅក្នុងលាមកទុកជាមិនចិកក៏ពិតមែន ប៉ុន្តែថា លាមកគង់ប្រឡាក់ពស់នោះមិនខាន យ៉ាងណា** ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលុះទៅតាមដំណើរទិដ្ឋិ របស់បុគ្គលមានសភាពយ៉ាងនេះ ក៏ពិតមែន ប៉ុន្តែថា បុគ្គលនោះមានកិត្តិស័ព្ទដ៏លាមកល្បីឡើងថា បុរសបុគ្គលមានមិត្តអាក្រក់ មានសំឡាញ់អាក្រក់ មានគូកនអាក្រក់ ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ **បុគ្គលមានសភាពយ៉ាងនេះថា ជាបុគ្គលដែលគេគួរខ្ពើម មិនគួរសេព មិនគួរគប់ មិនគួរចូលទៅ**

**អន្ទុយជិត ។**

៤. ម្នាលភិក្ខុទាំងឡាយ **ចុះបុគ្គលដែលគេគួរព្រងើយកន្តើយ មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអន្ទុយជិត** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះជាអ្នកក្រោធ ច្រើនដោយសេចក្តីតានតឹង សូម្បីគេនិយាយតែបន្តិចបន្តួច ក៏ជាប់ចិត្តក្រោធ ព្យាបាទ ប្រកាន់ រឹង ត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ នឹងសេចក្តីមិនសប្បាយចិត្តឱ្យប្រាកដឡើង ។ ម្នាលភិក្ខុទាំងឡាយ **ដូចជាដំបៅចាស់ដែលត្រូវប៉ះទង្គិចដោយកំណាត់ឈើឬអំបែង រមែងក្លាយឡើងលើសប្រមាណយ៉ាងណា** ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះជាអ្នកក្រោធ ច្រើនដោយសេចក្តីតានតឹង សូម្បីគេនិយាយតែបន្តិចបន្តួច ក៏ជាប់ចិត្តក្រោធ ព្យាបាទ ប្រកាន់រឹងត្អឹង ធ្វើសេចក្តីក្រោធទោសៈ នឹងសេចក្តីមិនសប្បាយចិត្តឱ្យប្រាកដឡើងយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ **ដូចជាអង្កត់ភ្លើងឧសជង្គោ ដែលគេកៀសដោយកំណាត់ឈើ ឬអំបែង រមែងធ្វើសម្លេងឮចិចិដៈ[១] ធ្វើសម្លេង**

---

១. សំឡេងផ្ទុះប្រែះ ៗ ព្រូសរងើកចេញ ។

**ញួចិចិជៈ ដោយក្រៃលែង លើសប្រមាណយ៉ាងណា** ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះជាអ្នកក្រោធ ច្រើនដោយសេចក្តីតានតឹង សូម្បីគេនិយាយបន្តិចបន្តួចក៏ជាប់ចិត្តក្រោធ ព្យាបាទ ប្រកាន់ រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនសប្បាយចិត្តឱ្យប្រាកដឡើង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ**ដូចជារណ្តៅលាមកដែលបុគ្គលឆ្កឹស ដោយកំណាត់ឈើ ឬអំបែងរមែងមានក្លិនស្អុយដោយក្រៃលែង លើសប្រមាណយ៉ាងណា** ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះជាអ្នកក្រោធ ច្រើនដោយសេចក្តីតានតឹង សូម្បីតែគេនិយាយបន្តិចបន្តួចក៏ជាប់ចិត្តក្រោធ ព្យាបាទ ប្រកាន់ រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនសប្បាយចិត្តឱ្យប្រាកដឡើង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថាជាបុគ្គលដែលគេគួរព្រងើយកន្តើយមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះគេគិតថា ជន( នេះ )គប្បីជេរអាត្មាអញខ្លះ ផ្តាសាអាត្មាអញខ្លះ ធ្វើអាត្មាអញឱ្យខូចប្រយោជន៍ខ្លះ ។ ព្រោះហេតុនោះ **បុគ្គល**

**មានសភាពយ៉ាងនេះ ឈ្មោះថា ជាបុគ្គលដែលគេគួរព្រងើយកន្តើយមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។**

ម្នាលភិក្ខុទាំងឡាយ **ចុះបុគ្គលដែលគេគួរសេព គួរគប់រក គួរ ចូលទៅអង្គុយជិត** តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសីល មានកល្យាណធម៌ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថា ជាបុគ្គលគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។ ដំណើរនោះព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលុះទៅតាមដំណើរទិដ្ឋិរបស់បុគ្គលមានសភាពយ៉ាងនេះ ក៏ពិតមែន ប៉ុន្តែបុគ្គលនោះគង់មានកិត្តិស័ព្ទដ៏ពីរោះល្បីឡើងថា បុរសបុគ្គលមានមិត្តល្អ មានសំឡាញ់ល្អ មានគូកនល្អ ។ ព្រោះហេតុនោះ **បុគ្គលមានសភាពយ៉ាងនេះឈ្មោះថា ជាបុគ្គលគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។** ម្នាលភិក្ខុទាំងឡាយបុគ្គល ៣ ពួកនេះរមែងមាននៅក្នុងលោក ។ ព្រះមានព្រះភាគជាម្ចាស់ បានត្រាស់ព្រះធម្មទេសនានេះហើយ ទើបត្រាស់និគមគាថាទៀតថា ៖

និហីយតិ បុរិសោ និហីនសេវី

ន ច ហាយេថ កទាចិ តុល្យសេវី
សេដ្ឋមុបនមំ ឧទេតិ ខិប្បំ
តស្មា អត្តនោ ឧត្តរី ភជេថាតិ ។

បុរសអ្នកសេពគប់បុគ្គលថោកទាបរមែងសាបសូន្យ បើសេពគប់បុគ្គលស្មើគ្នា មិនគប្បីសាបសូន្យក្នុងកាលណាឡើយ បើបុរសចូលទៅគប់រកបុគ្គលប្រសើរ(ជាងខ្លួន) រមែងចម្រើនឆាប់ ព្រោះហេតុនោះ បុរសគួរគប់នឹងបុគ្គលដែលប្រសើរលើសខ្លួន (ទើបប្រសើរ) ។

## អដ្ឋកថា

បទថា ជិគុច្ឆិតព្វោ សេចក្ដីថា បុគ្គលដែលអ្នកណា ៗ គប្បីរង្កៀសដូចលាមកដូច្នោះ ។

បទថា អជេលា នំ ប៉ុននឹង អជេលា អស្ស ។

បទថា កិត្តិសទ្ទោ គឺ សម្លេងដែលពោលហៅគ្នា ។ ក្នុងបទថា ឯវមេវ ខោ នេះ គប្បីជ្រាបសេចក្ដីប្រៀបធៀបដូចតទៅនេះ ៖

ភាពជាអ្នកទ្រុស្តសីលគប្បីឃើញដូចរណ្តៅលាមក ។ បុគ្គលអ្នកទ្រុស្តសីល គប្បីឃើញដូចពស់ដែលធ្លាក់ចុះទៅក្នុងរណ្តៅលាមកដូច្នោះ ភាវៈដែលបុគ្គលគប្បីនឹងគប់រកបុគ្គលដែលទ្រុស្តសីល (តែ)មិនធ្វើតាមបុគ្គលដែលទ្រុស្តសីលនោះ គប្បីឃើញដូចភាវៈដែលបុគ្គលត្រូវពស់ ដែលគេលើកឡើងពីរណ្តៅលាមកវារឡើងកាន់រាងកាយតែមិនខាំ ដូច្នោះ វេលាដែលបុគ្គលគប់រកអ្នកទ្រុស្តសីល ជរាបកេរ្តិ៍ឈ្មោះដែលមិនល្អខ្ចរខ្ចាយទៅគ្រប់ទី គប្បីជ្រាបដូចវេលាដែលគេត្រូវពស់ប្រឡាក់លាមកហើយ ខាំដូច្នោះ ។

បទថា តិណ្ឌុកាលាតំ បានដល់ ឧសឈើទន្លាប់ ។

បទថា ភិយ្យោសោ មត្តាយ ចិចិដាយតំ សេចក្តីថាក៏ឧសឈើទន្លាប់នោះ កាលត្រូវដុតតាមប្រក្រតី ក្រមរខ្ទាត បេញបញ្ចេញសំឡេងលាន់ចិចិដៈ ចិចិដៈ ។ អធិប្បាយថា តែឧសដែលត្រូវគោះ នឹងបញ្ចេញសំឡេងខ្លាំងជាង ។

បទថា ឯវមេវ ខោ សេចក្តីថា បុគ្គលដែលប្រាថ្នាក្រោធ

ក៏យ៉ាងនោះដែរ គឺសូម្បីតាមធម្មតារបស់ខ្លួន ក៏ជាអ្នកមិនស្ងប់ប្រទូសរ៉ាយត្រាច់ទៅ ។ តែក្នុងវេលាដែលបានស្តាប់ពាក្យនិយាយសូម្បីត្រឹមតែបន្តិចបន្តួច ក៏ត្រឡប់ត្រាច់ដើរស្តីបន្ទោស យ៉ាងខ្លាំងក្រៃលែងឡើងទៅទៀតថា អ្នកនេះនិយាយយ៉ាងនេះ ៗនឹងអ្នកដូចយើងបាន ។ បទថា គូថក្ខូបោ បានដល់ រណ្តៅដែលពេញទៅដោយលាមកឬរណ្តៅលាមកនុ៎ះឯង ។ ក៏ក្នុងទីនេះគប្បីជ្រាបការប្រៀបធៀបដោយន័យមុននោះឯង ។

បទថា តស្មា ឯវរូបោ បុគ្គលោ អជ្ឈុបេក្ខិតព្វោ ន សេវិតព្វោ សេចក្តីថា ព្រោះហេតុតែបុគ្គលដែលប្រាថ្នាក្រោធកាលអ្នកណាគប់រកជិតកៀកក៏ក្រោធ ( គេ )ដូចគ្នា រមែងក្រោធសូម្បីចំពោះបុគ្គលដែលជេរតបមកឱ្យថា អ្នកនេះមានប្រយោជន៍អ្វី ដូច្នោះ គេទើបដូចជាភ្លើងឆេះចំបើងដែលគ្រប់អ្នកគួរប្រងើយ មិនគួរចូលទៅគប់រក សមាគម ។ លោកពោលអធិប្បាយទុកយ៉ាងណា ? លោកពោលអធិប្បាយទុកថា បុគ្គលដែលចូលទៅ ជិតភ្លើងឆេះចំបើងពេក រាងកាយរបស់គេនឹងអណ្តែតត្រូវឆេះទៅផង បុគ្គលដែលថយចេញឆ្ងាយពេក នឹង

(មិន)ក្តៅ ការរងាររបស់គេក៏នៅតែមិនបាត់ ចំណែកបុគ្គលដែលអាំងភ្លើង នៅក្នុងរយៈល្មមល្អ មិនចូលជិតពេក មិនថយឆ្ងាយពេក សេចក្តីត្រជាក់ក៏នឹងបាត់ ព្រោះដូច្នោះ បុគ្គលដែលប្រាថ្នាក្រោធដូចជាភ្លើងឆេះចំបើង ទើបគួរត្រូវព្រងើយដោយការដាក់ខ្លួនជាកណ្តាល មិនគួរដល់អ្នកណា ៗនឹងសេព មិនគួរដល់អ្នកណា ៗនឹងគប់រក មិនគួរដល់អ្នកណា ៗនឹងចូលទៅអង្គុយជិត ។

បទថា កល្យាណមិត្តោ បានដល់ មិត្តអ្នកដែលល្អ ។

បទថា កល្យាណសហាយោ បានដល់ សម្លាញ់អ្នកស្អាត ។ ដែលឈ្មោះថា សម្លាញ់ បានដល់ អ្នកមានប្រក្រតីទៅរួមគ្នានិងត្រាច់ទៅរួមគ្នា ។

បទថា កល្យាណសម្បវង្កោ បានដល់ អ្នកឱនទៅក្នុងកល្យាណមិត្តទាំងឡាយ គឺ ក្នុងបុគ្គលដែលស្អាត អធិប្បាយថា អ្នកមានចិត្តបង្អោនទៅក្នុងកល្យាណមិត្តនោះ ។

# អយោនិសោសូត្រ

នៅក្នុងបិដកលេខ ៤១, ទំព័រ ៦ ព្រះអង្គទ្រង់ត្រាស់នូវ [**អំពីធម៌ដែលបង្ហាញថាជាពាលឬបណ្ឌិត**] មានសេចក្ដីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង គប្បីដឹងថា ជាពាល ។ **ធម៌ ៣ តើដូចម្ដេច ។** គឺជាអ្នកតាក់តែងនូវប្រស្នាដោយមិនត្រូវទំនង ១, ជាអ្នកដោះស្រាយប្រស្នាដោយមិនត្រូវទំនង ១, បើអ្នកដទៃដោះស្រាយប្រស្នាដោយត្រូវទំនងហើយ ក៏មិនសរសើរដោយបទនឹងព្យញ្ជនៈ ជាបរិមណ្ឌលស្រួលបរិបូណ៌ឡើយ ១ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគួរស្គាល់បានថា ជាជនពាល ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គួរស្គាល់បានថា ជាបណ្ឌិត ។ ធម៌ ៣ តើដូចម្ដេច ។ គឺជាអ្នកតាក់តែងនូវប្រស្នាដោយត្រូវទំនង ១, ជាអ្នកដោះស្រាយប្រស្នាដោយត្រូវទំនង ១, បើអ្នកដទៃដោះស្រាយប្រស្នាដោយត្រូវទំនងហើយ ក៏សរសើរដោយបទនឹងព្យញ្ជនៈ ជាបរិមណ្ឌលស្រួលបរិបូណ៌

ឡើយ ១ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគួរស្គាល់បានថា ជាបណ្ឌិត ។

## អដ្ឋកថា

បទថា អយោនិសោ បញ្ហំ កត្តា ហោតិ សេចក្តីថា ជនពាលរមែងធ្វើវត្ថុដែលមិនជាបញ្ហានុ៎ះឯងឱ្យជាបញ្ហា ព្រោះគិតមិនត្រូវវិធីដូចព្រះលោឡុទាយីត្ថេរ កាលត្រូវសួរថា ឧទាយីទីតាំងរបស់អនុស្សតិមានប៉ុន្មាន ក៏គិតថា ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងភពមុនទើងជាទីតាំងរបស់អនុស្សតិ ដូច្នេះហើយធ្វើវត្ថុដែលមិនជាបញ្ហាឱ្យជាបញ្ហាដូច្នោះ ។

បទថា អយោនិសោ បញ្ហំ វិសជ្ជេតា ហោតិ សេចក្តីថាក៏ជនពាល សូម្បីកាលទើងវិសជ្ជនាបញ្ហាដែលគិតទៀត[១] ក៏ត្រឡប់វិសជ្ជនាដោយមិនជាឧបាយនៃប្រាជ្ញាដូចព្រះថេរៈនោះឯង ដោយន័យមានជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ

---

១. ( បាលីថា ចិន្តិតំ បុន ច្បាប់ភូមាជា ឯវំ ចិន្តិតំ បន ។

រមែងរលឹកដល់ខន្ធដែលអាស្រ័យនៅក្នុងភពមុនបានច្រើនណាស់ គឺរលឹកបានមួយជាតិខ្លះ គឺរមែងពោលវត្ថុដែលមិនជាបញ្ហានុ៎ះឯងឱ្យជាបញ្ហា ។

ក្នុងបទថា បរិមណ្ឌលេហិ បទព្យញ្ជនេហិ នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បទនុ៎ះឯង ឈ្មោះថា បទព្យញ្ជនៈ ព្រោះធ្វើអត្ថន័យឱ្យប្រាកដបទព្យញ្ជនៈនោះដែលពោល ធ្វើអក្សរឱ្យបរិបូណ៌ មិនឱ្យខូចអត្ថន័យរបស់ព្យញ្ជនៈ ១០ យ៉ាង ឈ្មោះថាជាបរិមណ្ឌល ( មូល ) ។ អធិប្បាយថា ដោយបទព្យញ្ជនៈបែបនេះ ។

បទថា សិលិដ្ឋេហិ បានដល់ ដែលឈ្មោះថា ស្អាតរៀបរយ ព្រោះមានបទដែលស្អាតរៀបរយ ។

បទថា ឧបគតេហិ បានដល់ ចូលដល់ផលនិងហេតុ ។

បទថា ឆាត្តានុមោទិតា[១] សេចក្តីថា ជនពាលរមែងមិនអនុមោទនា គឺមិនត្រេកអរបញ្ហារបស់បុគ្គលដទៃដែលវិសជ្ជនាដោយឧបាយប្រាជ្ញាយ៉ាងនេះ គឺដែលវិសជ្ជនាធ្វើឱ្យបរិបូណ៌

---

១. ថៃ. នាភិនុមោទតិ ។

ដោយអាការគ្រប់យ៉ាង ។ ដូចព្រះលោឡុទាយីត្ថេរ មិនអនុមោ-ទនា បញ្ហារបស់ព្រះសារីបុត្រ ដូច្នោះ ។ ដូចដែលលោកពោល ទុកថា អាវុសោសារីបុត្រ មិនមែនឋានៈ មិនមែនឱកាសឡើយ ដែលព្រះអនាគាមីនោះ កន្លងហួសភាពជាសម្លាញ់របស់ពួក ទេវតា អ្នកមានកវឡិង្ការាហារ ជាភក្សាចូលដល់ពួកទេវតាដែល ជាមនោមយៈ ពួកណាមួយហើយនឹងគប្បីចូលសញ្ញាវេទយិត-និរោធក៏បាន នឹងគប្បីចេញចាកសញ្ញាវេទយិតនិរោធក៏បានឋានៈ នេះមិនមានឡើយ ។

ក្នុងពាក្យថា យោនិសោ បញ្ហំ កត្តា ជាដើម គប្បីជ្រាប វិនិច្ឆ័យដូចតទៅនេះ ៖

បណ្ឌិតគិតបញ្ហាដោយឧបាយប្រាជ្ញាហើយ រមែងវិសជ្ជនា បញ្ហាដោយឧបាយប្រាជ្ញាដូចព្រះអានន្ទត្ថេរដូច្នោះ ។ ជាសេចក្តី ពិត ព្រះថេរៈត្រូវព្រះសាស្តាត្រាស់សួរថា ម្នាលអានន្ទ ទីតាំង របស់អនុស្សតិមានប៉ុន្មាន ? ក៏គិតដោយឧបាយប្រាជ្ញាមុនថា នេះ នឹងជាបញ្ហា កាលនឹងវិសជ្ជនាដោយឧបាយប្រាជ្ញា ទើប ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ស្វាត់

ហើយចាកកាមទាំងឡាយ ។ល។ ហើយចូលចតុត្ថឈាន បពិត្រព្រះអង្គដ៏ចម្រើន ទីតាំងរបស់អនុស្សតិនេះ ដែលចម្រើនហើយយ៉ាង នេះ ធ្វើឱ្យច្រើនហើយយ៉ាងនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីនៅ ជាសុខក្នុងបច្ចុប្បន្ន ។

បទថា អត្ថានុមោទិតា ហោតិ សេចក្ដីថា បណ្ឌិតរមែងអនុមោទនាដោយឧបាយប្រាជ្ញា ដូចព្រះតថាគតអនុមោទនាដូច្នោះ ។ ជាសេចក្ដីពិត ព្រះតថាគតកាលព្រះអានន្ទត្ថេរវិសជ្ជនាបញ្ហាហើយ ក៏ត្រាស់ព្រះតម្រាស់មានជាដើមថា "ល្អហើយ ល្អហើយ អានន្ទ បើយ៉ាងនោះ អានន្ទ អ្នកចូរចងចាំទីតាំងនៃអនុស្សតិទី ៦នេះទុកចុះ អានន្ទ ភិក្ខុក្នុងសាសនានេះ មានសតិឈានទៅខាងមុខ មានសតិថយក្រោយ" ។

## ជនពាលដូចអមិត្ត បណ្ឌិតដូចញាតិ

មួយវិញទៀត បុគ្គលពាលទាំងឡាយ ប្រៀបដូចជាអមិត្តដែលមានដាវនៅនឹងដៃ បណ្ឌិតទាំងឡាយ ប្រៀបដូចជាញាតិដែលជាទីស្រឡាញ់ ។ ពិតមែនដូច្នោះ ព្រះដ៏មានព្រះភាគកាលទ្រង់ប្រជាប់គង់ធ្វើតំបន់វេឡុវគ្រាម ដែលតាំងនៅមិនឆ្ងាយខាង

ទិសទក្សិណនៃទីក្រុងសាវត្ថី ឱ្យជាគោចរគ្រាម បានកើតប្រឈួន ធ្លាក់ព្រះលោហិត ។ ស្ដេចសក្កទេវរាជទ្រង់ជ្រាបហេតុនោះហើយ ស្ដេចយាងមកឧបដ្ឋាកព្រះសាស្ដា ទ្រង់មិនឱ្យអ្នកដទៃប៉ះពាល់នូវភាជនៈសម្រាប់វេសវីរវេលច្ចៈ (លាមកក្នុងសរីរៈ)របស់ព្រះសាស្ដា សូម្បីដោយដៃឡើយ ទ្រង់ទូលលើព្រះសិរសីតែម្ដងហើយនាំយកទៅ ដូចជាបុគ្គលនាំយកភាជនៈសម្រាប់ដាក់គ្រឿងក្រអូបទៅ ដូច្នោះ ។ ស្ដេចសក្កទេវរាជនោះទ្រង់ឧបដ្ឋាកយ៉ាងដូច្នេះហើយ ក្នុងពេលដែលព្រះសាស្ដាទ្រង់បានសប្បាយ ទើបស្ដេចយាងទៅកាន់ទេវលោក ។

ពួកភិក្ខុទាំងឡាយបាននិយាយគ្នាថា "គួរឱ្យអស្ចារ្យមែន ! ស្ដេចសក្កទេវរាជ មានសេចក្ដីស្រឡាញ់ចំពោះព្រះសាស្ដា ព្រះអង្គទ្រង់បានលះបង់នូវទិព្វសម្បត្តិ ទ្រង់មកឧបដ្ឋាកហើយ" ។ ព្រះសាស្ដាទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ស្ដេចសក្កទេវរាជទ្រង់ពិចារណាឃើញថា កិរិយាជួបប្រទះនូវព្រះអរិយបុគ្គលទាំងឡាយក្ដី ភាវៈមានកិរិយាការអង្គុយជាដើម ក្នុងទីកន្លែងជាមួយគ្នានឹងព្រះអរិយបុគ្គលទាំងឡាយនោះក្ដី ភាវៈគឺការបានធ្វើនូវវត្តនិង

វត្តបទដល់ព្រះអរិយៈទាំងឡាយនោះក្តី ជាហេតុញុំាងប្រយោជន៍ឱ្យសម្រេចបានដូច្នេះហើយ ទើបទ្រង់ស្តេចយាងមកឧបដ្ឋាកនូវតថាគត” ដូច្នេះ កាលទ្រង់សម្តែង(សេចក្តីនោះ)ទើបទ្រង់បានទ្រង់ភាសិតគាថាទាំងឡាយ ក្នុងរឿងនៃស្តេចសក្កទេវិន្ទ **ក្នុងសុត្តន្តបិដកលេខ ៥២, ទំព័រ ៦៤-៦៥** នៃធម្មបទនោះថា ៖

ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា ។
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ
ធីរញ្ច បញ្ញញ្ច ពហុស្សុតញ្ច
ធោរយ្ហសីលំ វតវន្តមរិយំ
តំ តាទិសំ សប្បុរិសំ សុមេធំ
ភជេថ នក្ខត្តបថំវ ចន្ទិមា ។

មែនពិត បុគ្គលអ្នកប្រព្រឹត្តសេពគប់ដោយជនពាលរមែងសោកសៅអស់កាលដ៏យូរអង្វែង ការនៅរួមគ្នាជាមួយនឹងជនពាលរមែងជាទុក្ខសព្វកាល ដូចជាការនៅរួមជាមួយគ្នា នឹងសត្រូវ

ចំណែកខាងបណ្ឌិត មានការនៅរួមជាសុខ ប្រៀបដូចជាការជួបជុំនៃញាតិទាំងឡាយ ព្រោះហេតុនោះឯង បុគ្គលគួរសេពគប់សប្បុរស ជាអ្នកមាំមួនផង មានបញ្ញាផង មានសេចក្តីចេះដឹងច្រើនផង មានកិរិយានាំទៅនូវធុរៈជាប្រក្រតីផង មានសីលវត្តនិងធុតង្គវត្តផង ជាអ្នកឆ្ងាយចាកកិលេសផង មានបញ្ញាដ៏ល្អផងប្រាកដដូច្នោះ ឱ្យដូចជាព្រះច័ន្ទគប់រកនូវផ្លូវនៃនក្ខត្តឫក្សយ៉ាងដូច្នោះដែរ ។

## អដ្ឋកថា

បណ្តាបទទាំងនោះ បាទគាថា ថា ពាលសង្គតចារី ហិ មានសេចក្តីថា មែនពិត គឺពិតណាស់ បុគ្គលអ្នកមានកិរិយាប្រព្រឹត្តសេពគប់ជាមួយនឹងជនពាល ។ បទថា ទីឃមទ្ធានំ មានសេចក្តីថា ជាអ្នកមានឆន្ទៈដូចគ្នាជាមួយនឹងជនពាល កាលធ្វើនូវកម្មអាក្រក់ មានការកាត់នូវទីតជាដើម ទីបានជួបប្រទះនូវសេចក្តីទុក្ខ មានត្រូវគេកាត់ដៃជាដើម ឈ្មោះថា រមែងសោកសៅអស់កាលជាយូរអង្វែង ។ ការរស់នៅជាមួយគ្នាឈ្មោះថា ការនៅរួម បទថា អមិត្តេនេវ មានសេចក្តីថា ប្រៀបដូចជាការនៅរួមជា

មួយនឹងសត្រូវដែលមានដាវជាប់នឹងដៃ ។ ឬសត្វសាហាវមានអាសិរពិសជាដើម ។ បទថា សព្វទា គឺការនៅរួមនឹងពួកជនពាលរមែងជាទុក្ខជាប់ជានិច្ច ។ ការនៅរួមជាមួយនឹងបណ្ឌិតនោះរមែងជាសុខ ព្រោះហេតុនោះ បណ្ឌិត ទើបឈ្មោះថា មានការនៅរួមជាសុខ អធិប្បាយថា "ការនៅរួមក្នុងទីជាមួយគ្នានឹងបណ្ឌិត ជាហេតុនាំសេចក្តីសុខមកឱ្យ" ។ ប្រៀបដូចជាអ្វី ? ។ ប្រៀបដូចជាសមាគមនៃពួកញាតិ ។ អធិប្បាយថា ប្រៀបដូចជាការជួបជុំនៃពួកញាតិទាំងឡាយដែលជាទីស្រឡាញ់ជាហេតុឱ្យបានសុខ" ។ បទថា តស្មា ហិ មានសេចក្តីថា ការនៅរួមជាមួយជនពាលរមែងជាទុក្ខ ព្រោះហេតុណា ការនៅរួមជាមួយបណ្ឌិតរមែងជាសុខព្រោះហេតុនោះ ។ បទថា ធីរំ គឺជាអ្នកដល់ព្រមដោយបញ្ញាជាគ្រឿងទ្រង់ចាំ ។ បទថា បញ្ញំ បានដល់ អ្នកដល់ព្រមដោយបញ្ញាដែលជាលោកិយៈនិងលោកុត្តរៈ ។ បទថា ពហុស្សុតំ គឺជាពហុស្សុតដោយបរិយត្តិ បដិបត្តិនិងបដិវេធ ។ បទថា ធោរយ្ហសីលព្វតវន្តំ បានដល់ ឈ្មោះថា ជាអ្នកមានកិរិយានាំទៅនូវធុរៈ ពោលគឺការញុំាងខ្លួនឱ្យបានសម្រេចព្រះអរហត្ត ជាអ្នកមាន

សីលទីឯធុតង្គ ។ បទថា អរិយំ ប្រែថា អ្នកស្ថិតនៅឆ្ងាយចាក កិលេស ។ បទថា សុមេធំ បានដល់ អ្នកមានបញ្ញាល្អ ។ បទថា នក្ខត្តបថំ វ មានសេចក្តីថា ប្រៀបដូចជាព្រះច័ន្ទគឺវិមាននៃព្រះ ច័ន្ទ គប់រកនូវអាកាសដែលជាផ្លូវនៃនក្ខត្តឫក្សទាំងឡាយ ដូច្នោះ ឯង ។

## តាបសឱ្យដម្បូន្មានដល់បុត្រ

សូម្បីព្រះពោធិសត្វ កាលកើតជាតាបសនៅក្នុងព្រៃហេម-វន្តប្រទេស កាលទីឯទូន្មាននូវតាបសកុមារ ជាបុត្ររបស់ខ្លួន ធុញទ្រាន់ ប្រាថ្នាចង់ចេញអំពីព្រៃហើយ ទៅរស់នៅក្នុងទីលំនៅ ស្ថាននៃមនុស្ស ទើបបានពោលនូវគាថាទាំងឡាយនេះក្នុង***ហលិ-ទ្ទរាគជាតក*** ក្នុងនវកនិបាត បិដកលេខ ៥៩ ទំព័រ ១៥៣ ថា ៖

យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កដំ

ឧរសីវ បតិដ្ឋាយ តំ ភជេហិ ឥតោ គតោ ។

បុគ្គលណា មិនមានអំពើអាក្រក់ដោយកាយ វាចា ចិត្ត អ្នកចេញអំពីព្រៃនេះទៅហើយ ចូរតាំងខ្លួនឱ្យដូចជាកូនដែលកើត អំពីទ្រូង ហើយចាំសេពគប់នូវបុគ្គលនោះចុះ ។

យោ ច ធម្មេន ចរតិ ចរន្តោបិ ន មញ្ញតិ
វិសុទ្ធការី សប្បញ្ញំ តំ ភជេហិ ឥតោ គតោ ។

មួយទៀត បុគ្គលណាប្រព្រឹត្តធម៌ ទោះកំពុងប្រព្រឹត្តក៏មិនប្រកាន់ខ្លួន អ្នកចេញអំពីព្រៃនេះទៅហើយ ចូរសេពគប់នូវបុគ្គលដែលជាអ្នកធ្វើនូវអំពើដ៏បរិសុទ្ធ ប្រកបដោយបញ្ញានោះចុះ ។

ហលិទ្ទរាគំ កបិចិត្តំ បុរិសំ រាគវិរាគិនំ
តាទិសំ តាត មាសេវិ និម្មនុស្សម្បិ ចេ សិយា ។

នែបា បុគ្គលណា មានចិត្តដូចជាសំពត់ដែលជ្រលក់ល្មៀត មានចិត្តដូចសត្វស្វាត្រេកអរហើយ បែរជាមិនត្រេកអរវិញ បើទុកជាផ្ទៃនៃជម្ពូទ្វីបទាំងមូលនេះ មិនមានមនុស្សសោះ ក៏ដោយ អ្នកចូរកុំសេពគប់នូវបុរសបែបនោះឡើយ ។

អាសីវិសំវ កុប្បិតំ មិឡ្ហលិត្តំ មហាបថំ
អារកា បរិវជ្ជេហិ យានីវ វិសមំ បថំ ។

អ្នកចូរចៀសវាង ( បុគ្គលបែបនោះ )អំពីចម្ងាយឱ្យដូចជាបុគ្គលអ្នកភ័យខ្លាច ចៀសវាងអាសិរពិសដ៏កាចសាហាវអំពីចម្ងាយ

ឬដូចជាបុគ្គលផ្ដើមលាមក ចៀសវាងនូវផ្លូវធំដែលប្រឡាក់ដោយលាមក ឬដូចបុគ្គលអ្នកទៅដោយយាន ចៀសវាងនូវផ្លូវមិនរាបស្មើដូច្នោះ ។

អនត្ថា តាត វឌ្ឍន្តិ ពាលំ អច្ចុបសេវតោ
ហាស្ស ពាលេន សង្គច្ឆិ អមិត្តេនេវ សព្វទា ។

នែបា អំពើដែលមិនមែនជាប្រយោជន៍ទាំងឡាយ រមែងចំរើនដល់បុគ្គលដែលសេពគប់នូវបុគ្គលពាលជ្រុលពេក អ្នកចូរកុំគប់រកជាមួយនឹងបុគ្គលពាល នែបា ព្រោះការនៅរួមជាមួយនឹងបុគ្គលពាល ជាហេតុនាំសេចក្ដីទុក្ខមកឱ្យ ប្រៀបដូចជាការនៅរួមជាមួយនឹងសត្រូវសព្វ ៗ កាល ។

តំ តាហំ តាត យាចាមិ ករស្សុ វចនំ មម
មាស្សុ ពាលេន សង្គច្ឆិទុក្ខោ ពាលេហិ សង្គមោតិ ។

នែបា ព្រោះហេតុនោះហើយ បានជាយើងសូមអង្វរអ្នក ចូរអ្នកធ្វើតាមពាក្យរបស់យើង ចូរអ្នកកុំគប់រកជាមួយនឹងបុគ្គលពាលឡើយ ( ព្រោះ )ការសមាគមជាមួយបុគ្គលពាលទាំងឡាយរមែងជាហេតុនាំសេចក្ដីទុក្ខមកឱ្យ ។

## អដ្ឋកថា

បណ្ដាបទទាំងនោះ បទថា ឱរសំវ មានសេចក្ដីថា ចូរតាំងចំពោះ( នូវខ្លួន ) ឱ្យដូចជាកូនដែលកើតហើយអំពីទ្រូងនៃមាតា១ដូច្នោះ ។ អធិប្បាយថា "អ្នកលុះតាំង( ខ្លួន )ទុកយ៉ាងដូច្នេះហើយគប្បីសម្គាល់ឱ្យដូចជាមាតារបស់ខ្លួន ហើយសេពគប់នូវបុគ្គលនោះចុះ" ។

បទថា ធម្មេន បានដល់ ដោយធម៌ គឺសុចរិតទាំង ៣ យ៉ាងនុ៎ះឯង ។ បទថា ន មញ្ញតិ មានសេចក្ដីថា ម្យ៉ាងទៀតសូម្បីកាលប្រព្រឹត្តយ៉ាងដូច្នោះ ក៏មិនធ្វើការប្រកាន់ខ្លួនថា អាត្មាអញប្រព្រឹត្តនូវធម៌ ។ បទថា វិសុទ្ធការី បានដល់ អ្នកធ្វើកម្មដែលបរិសុទ្ធ គឺកុសលកម្មបថ ១០ ប្រការ ។

បទថា ហលិទ្ទរាគំ គឺឈ្មោះថា ជាអ្នកប្រៀបដូចជាសំពត់ដែលជ្រលក់ដោយល្មៀត ព្រោះជាអ្នកមានចិត្តមិនស្ថិតស្ថេរ ។ បទថា គាបិចិត្តំ បានដល់ មានចិត្តកំរើកញាប់ញ័រគឺមានចិត្តរំជើបរំជួយ ។ បទថា បុរិសំ បានដល់បុគ្គល ។ បទថា

ភាគវិភាគិនំ គឺត្រេកអរហើយ និងបែរជាមិនត្រេកអរទៅវិញ អធិប្បាយថា មានសភាវៈគឺស្រឡាញ់ហើយ ស្អប់ខ្ពើមទៅវិញ ក្នុងខណៈនោះភ្លាម ៗ ។ មានសេចក្ដីថា ក៏ទោះបីជាផ្ទៃនៃជម្ពូទ្វីប ទាំងមូល នឹងជាទីស្ថានដែលគ្មានមនុស្សក៏ដោយ មានជនពាល នោះ ជាមនុស្សស្ថិតនៅម្នាក់ឯងប៉ុណ្ណោះ សូម្បីជាដូច្នោះក៏ដោយ ចូរអ្នកកុំសេពគប់នូវបុគ្គលបែបនោះឡើយ ។

បាទគាថាថា មិឡ្ហលិត្តំ មហាបថំ គឺប្រៀបដូចជាផ្លូវដ៏ ធំដែលប្រឡាក់ដោយលាមក ។ បទថា យានិវ គឺប្រៀបដូចជា បុគ្គលអ្នកធ្វើដំណើរទៅដោយយាន ។ បទថា វិសមំ បានដល់ មិនបានរាបស្មើដោយភាវៈជាទីទំនាបនិងទីទួល និងដោយវត្ថុមាន ជន្លត់ និងថ្មជាដើម ។

បាទគាថាថា ពាលំ អច្ចុបសេវតោ បានដល់ ជាអ្នក សេពគប់យ៉ាងស្និទ្ធស្នាលនូវបុគ្គលអ្នកមានបញ្ញាតិច ។ បទថា សព្វធា មានសេចក្ដីថា ឈ្មោះថា ការនៅរួមជាមួយនឹងបុគ្គល ពាល រមែងនាំសេចក្ដីទុក្ខមកឱ្យអស់កាលជានិច្ចតែម្ដងប្រៀបដូច

ជាការនៅរួមជាមួយនឹងសត្រូវ ដូច្នោះឯង ។

បទថា តន្តាហំ មានសេចក្តីថា ព្រោះហេតុនោះ បាន ជាយើង( ឪពុក )សូមអង្វរអ្នក ។

## ភ័យឧបទ្រព និងឧបសគ្គកើតមានព្រោះជនពាល

មួយទៀតសោត ភ័យឧបទ្រពនិងឧបសគ្គទាំងឡាយណា មួយដែលមានភ័យ ឧបទ្រព និងឧបសគ្គទាំងឡាយទាំងអស់នោះ កើតឡើង ព្រោះអាស្រ័យបុគ្គលពាលទាំងស្រុង ។ មែនពិត បុគ្គពាលកាលប្រាថ្នានូវភាវៈជាព្រះរាជាក្តី ភាវៈជាឧបរាជក្តី ឬ ក៏នូវមុខតំណែងដ៏ធំផ្សេងទៀត បបួលពួកអ្នកលេងធំ ៗចំនួន ២-៣ នាក់ ដែលស្មើនឹងខ្លួនបានហើយនិយាយថា "អ្នកទាំងឡាយ ចូរ មកចុះ ខ្ញុំនឹងធ្វើពួកអ្នកឱ្យជាធំ" ដូច្នេះហើយ អាស្រ័យទីស្ថាន ស្ងាត់ ៗមានទីញៀតស្បាតនៃភ្នំជាដើម ហើយប្លន់ស្រុកដែលនៅ ជាប់ស្រយាល ប្លន់និគមខ្លះ ជនបទខ្លះតាមលំដាប់ ។

មនុស្សទាំងឡាយ នាំគ្នាបោះបង់បោលផ្ទះហើយប្រាថ្នានូវ ស្ថានទីដ៏ក្សេមក្សាន្ត ភៀសខ្លួនចេញទៅ ។ ពួកភិក្ខុក្តី ពួកភិក្ខុនី

ទាំងឡាយក្តី ដែលនៅអាស្រ័យមនុស្សទាំងឡាយនោះ ក៏រមែងនាំគ្នាបោះបង់ចោលនូវទីលំនៅរបស់ខ្លួន ៗ ចៀសចេញទៅដែរ ។ ភិក្ខាក្តី សេនាសនៈក្តី ក្នុងពេលដែលភិក្ខុនិងភិក្ខុនីទាំងនោះបានទៅហើយ ៗជារបស់រកបានដោយកម្រ ។ សូម្បីក្នុងបព្វជិតទាំងឡាយ ភិក្ខុពាល ២ រូប បង្កើតនូវវិវាទដល់គ្នាហើយ ចាប់ផ្តើមគ្នាឡើង ។ ព្រោះហេតុនេះ សេចក្តីឈ្លោះប្រកែកគ្នាដ៏ធំ រមែងកើតឡើង ដល់ពួកបព្វជិតទាំងនោះប្រៀបដូចជាសេចក្តីឈ្លោះវិវាទគ្នា ដែលកើតឡើងដល់ពួកភិក្ខុក្រុងកោសម្ពីដូច្នោះ ។ ហេតុនៃសេចក្តីទុក្ខ មានភ័យជាដើមមកដល់ពួកបរិស័ទទាំង ៥ ព្រោះអាស្រ័យនូវជនពាលដោយប្រការដូច្នេះឯង ។

ព្រោះហេតុនោះក្នុងលក្ខណសូត្រ[១] មុនព្រះសូត្រទាំងពួងក្នុងតិកនិបាត អង្គុត្តរនិកាយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយថា "ម្នាលភិក្ខុទាំងឡាយ ភ្លើងតែងឆេះរាលអំពីផ្ទះបបុសឬផ្ទះស្មៅ មកឆេះផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុងទាំងខាងក្រៅ មិនមានខ្យល់ចូលបាន មានសន្ទះទ្វារដ៏ពិតស្និទ្ធមាន

១ ត្រៃបិដក ភាគទី ៤១/ ទំព័រទី២

បន្ទួចបិទជិតហើយដូចម្តេចមិញ, ម្នាលភិក្ខុទាំងឡាយភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះតែងកើតឡើងអំពីជនពាល មិនមែនកើតឡើងអំពីបណ្ឌិតទេ ឧបស័គ្គទាំងឡាយណាមួយកើតឡើង ឧបស័គ្គទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតឡើងអំពីបណ្ឌិតទេ ក៏យ៉ាងដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយបុគ្គល ពាលប្រកបដោយភ័យដ៏ពន្លឹក បណ្ឌិតមិនមានភ័យដ៏ពន្លឹកទេ បុគ្គលពាលប្រកបដោយឧបស័គ្គដ៏ពន្លឹក បណ្ឌិតមិនមានឧបស័គ្គដ៏ពន្លឹកទេដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភ័យមិនមានមកអំពីបណ្ឌិត ឧបទ្រពមិនមានមកអំពីបណ្ឌិត ឧបស័គ្គមិនមានមកអំពីបណ្ឌិត" ដូច្នេះ ។

អដ្ឋកថានៃលក្ខណសូត្រនោះថា បណ្តាបទទាំងនោះបទថា **នឡាគារា វា** គឺអំពីផ្ទះដែលគេប្រក់ ( បាំង ) ដោយបបុសទាំងឡាយ ប៉ុន្តែគ្រឿងសម្ភារៈដែលសេសសល់ទាំងឡាយក្នុងផ្ទះនេះរមែងសម្រេចដោយឈើពិត ៗ ។ សូម្បីក្នុងផ្ទះស្មៅ ក៏មានន័យដូចនេះដែរ ។ បទថា **កូដាគារានិ** បានដល់ផ្ទះ ដែលសង្គ្រោះដោយកំពូល ។ បទថា **ឧលិត្តាវលិត្តានិ** គឺដែលគេបូកហើយ

ទាំងខាងក្នុងទាំងខាងក្រៅ ។ បទថា **និវាតានិ** គឺបិទផ្លូវខ្យល់មិនឱ្យចូលទៅបាន ។ បទថា **ផុសិតគ្គឡានិ** គឺឈ្មោះថាមានសន្ទះទ្វារ ត្រង់ក្របខាងខ្នងបិទជិត ល្អហើយ ព្រោះជារបស់ដែលនាយជាងទាំងឡាយ ដែលឆ្លាតធ្វើទុកហើយ ។ បទថា **បិហិត-វាតបានានិ** បានដល់ ដែលគេភ្ជាប់បង្អួចទុកហើយ ។ ដោយពីរបទនេះ ព្រះដ៏មានព្រះភាគទ្រង់មិនបានត្រាស់ភាវៈនៃសន្ទះទ្វារនិងបង្អួចថា ជារបស់ដែលបុគ្គលបិទហើយជាប្រចាំឡើយ ( តែ ) ទ្រង់ត្រាស់ការដល់ព្រម( នៃផ្ទះកំពូល )តែប៉ុណ្ណោះ ។ ក៏សន្ទះទ្វារនិងបង្អួចទាំងឡាយនោះ គឺបុគ្គលតែងបិទនឹងបើកបានគ្រប់ពេលដែលខ្លួនប្រាថ្នាហើយ ៗ ។ ពីរបទថា **ពាលតោ ឧប្បជ្ជន្តិ** គឺតែងកើតឡើង ព្រោះអាស្រ័យនូវបុគ្គលពាលទាំងស្រុង ។ សេចក្តីកត់ស្លុតនៃចិត្តឈ្មោះថាភ័យ ។ អាការគឺភាវៈនៃចិត្តជាប់ជំពាក់នៅក្នុងអារម្មណ៍នោះ ៗឈ្មោះថាឧបស័គ្គ" ដូច្នេះ ។ ដីកានៃលក្ខណសូត្រនោះថា "ពាក្យថា **ឆន្នបរិច្ឆន្នា** គឺខាងលើគេប្រក់បាំងដោយដើមបបុសទាំងឡាយ ដោយសង្ខេប គឺការប្រក់បាំងដោយស្មៅ ដោយជុំវិញគឺគេប្រក់បាំងដោយដើមបបុសទាំងឡាយ

នោះដូចគ្នាដែរ ដោយទំនងនៃជញ្ជាំងឈើ(ក្តារ) ។ សេចក្តីតក់ស្លុតនៃចិត្តរបស់បុគ្គលដែលភ័យខ្លាច ហើយឈ្មោះថា ភ័យ ព្រោះហេតុនោះទើបព្រះអដ្ឋកថាចារ្យពោលថា "សេចក្តីតក់ស្លុតនៃចិត្ត" ។ សេចក្តីអន្តរាយឈ្មោះថា ឧបទ្រព ។ ក៏ព្រះអដ្ឋកថា-ចារ្យពោលថា "អាការគឺភាវៈនៃចិត្តមានអារម្មណ៍មិនមែនតែមួយ ព្រោះសេចក្តីអន្តរាយនោះ ជាហេតុនៃសេចក្តីរាយមាយចិត្ត ។ សេចក្តីទើសទាក់ គឺការជួបប្រទះនូវសេចក្តីចង្អៀតចង្អល់ ព្រោះការធ្វើតបវិញមិនបាន ដោយហេតុមានត្រូវទេវតាបៀតបៀនជាដើម ឈ្មោះថា ឧបសគ្គ ក៏ការជួបប្រទះនូវសេចក្តីចង្អៀតចង្អល់នោះ ជាហេតុនៃសេចក្តីរញ្ជួរាស្ទាក់ស្ទើរ របស់បុគ្គលដែលកំពុងក្តៅក្រហាយ អ្នកមិនអាចដើម្បីធ្វើអ្វី ៗបាន ដោយភាវៈគឺធ្វើតបវិញមិនបាន ព្រោះហេតុណា ព្រោះហេតុនោះទើបលោកពោលថា អាការ គឺភាវៈដែលចិត្តជាប់ជំពាក់ក្នុងអារម្មណ៍នោះ ៗដូច្នេះ" ។

ព្រោះហេតុនោះ បុគ្គលពាលទាំងឡាយ គឺអ្នកមានប្រាថ្នាគប្បីជ្រាបថាប្រៀបដូចផ្ទះដែលត្រូវភ្លើងឆេះហើយដូច្នោះ ព្រោះថាបុគ្គលពាលទាំងនោះ ជាអ្នកអាចក្នុងការនាំសេចក្តីទុក្ខ មាន

ភ័យជាដើមគ្រប់យ៉ាង មកប្រគល់ឱ្យដល់បុគ្គលទាំងឡាយ អ្នកធ្វើតាមពាក្យរបស់ខ្លួន ។ គប្បីជ្រាបបណ្ឌិតទាំងឡាយប្រៀបដូចជាការថែរក្សាក្នុងទីដែលមានភ័យ ប្រៀបដូចជាប្រទីបក្នុងទីដែលងងឹត និងប្រៀបដូចជាការបានទទួលបាយ និងទឹកជាដើមក្នុងវេលាដែលត្រូវសេចក្តីទុក្ខ មានការស្រេក និងឃ្លានជាដើមមកគ្រប់សន្តត់ដូច្នេះឯង ។ ព្រោះថា បណ្ឌិតទាំងឡាយនោះជាអ្នកអាចក្នុងការកម្ចាត់សេចក្តីទុក្ខមានភ័យជាដើម គ្រប់យ៉ាង ដល់បុគ្គលទាំងឡាយដែលធ្វើតាមពាក្យរបស់ខ្លួនបាន ដូច្នេះឯង ។ បុគ្គលជ្រាបនូវភាវៈនៃជនពាលទាំងឡាយ ប្រៀបស្មើនឹងរបស់ដែលស្មោកគ្រោកមានត្រីស្អុយជាដើម និង បណ្ឌិតទាំងឡាយប្រៀបស្មើនឹងគ្រឿងសំអាង មានគ្រឿងក្រអូបជាដើមទាំងការសេពគប់រកនូវបុគ្គលពាល ជាហេតុនាំឱ្យកើតទុក្ខ និងការសេពគប់រកនូវបណ្ឌិត ជាហេតុនាំឱ្យកើតសេចក្តីសុខយ៉ាងដូច្នេះ ហើយគប្បីសេពគប់រកតែបណ្ឌិតប៉ុណ្ណោះ មិនគួរសេពគប់រកបុគ្គលពាលឡើយ ។

សូម្បីព្រះដ៏មានព្រះភាគ កាលនឹងទ្រង់អប់រំទូន្មានព្រះ-

ឆន្នត្ថេរ ទ្រង់បានត្រាស់ហើយនូវព្រះគាថានេះ ក្នុងបណ្ឌិតវគ្គ នៃធម្មបទថា ៖

**"អ្នកមានប្រាជ្ញា មិនគួរគប់មិត្រអាក្រក់ មិនគួរគប់បុរសថោកទាប គួរគប់រកតែមិត្រដែលល្អប្រសើរ គួរគប់រកតែបុរសខ្ពង់ខ្ពស់" ។**

បណ្តាបទទាំងនោះ បទថា **ភជេ** សេចក្តីថា បណ្ឌិតគួរគប់រកគឺចូលទៅអង្គុយជិត ។ បទថា **បុរិសាធមេ** បានដល់នូវបុរសថោកទាប គឺបុរសដែលអាក្រក់ ។ បទថា **ភជេថ** ប្រែថា គួរសេពគប់ ។ ក៏ក្នុងបុគ្គលទាំង ២ ពួកនេះបុគ្គលទាំងឡាយណា រមែងត្រេកអរក្រៃលែងក្នុងទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម បុគ្គលទាំងនោះឈ្មោះថា បាបមិត្រ ។ ចំណែកបុគ្គលទាំងឡាយណា រមែងប្រកបក្នុងទីមិនមែនជាឋានៈមានការកាត់នូវទីតជាដើម ឬផ្សេងដោយកម្មមានអនេសនា ២១ ប្រការជាដើម បុគ្គលទាំងឡាយនោះឈ្មោះថាបុរសថោកទាប ។ម្យ៉ាងទៀតបុគ្គលទាំង ២ ពួកនុ៎ះឯងជាបាបមិត្រផង ជាបុរសដែលថោកទាបផង ។ បុគ្គលដែលផ្ទុយគ្នាអំពីបុគ្គលទាំង ២ពួកនោះ

ជាកល្យាណមិត្រផង ជាបុរសដ៏ខ្ពង់ខ្ពស់ផង ដូច្នេះឯង ។

ក៏ការសេពគប់នូវបណ្ឌិត សូម្បីតែអស់រយៈពេលមួយដង ក៏ឈ្មោះថា រមែងរក្សាឃុំគ្រងខ្លួនបាន ការសេពគប់នូវបុគ្គល សូម្បីអស់កាលជាយូរ ក៏មិនឈ្មោះថា ជាការថែរក្សាឃុំគ្រងនូវខ្លួនបានឡើយ ។ ពិតមែនដូច្នេះ ឆន្ទព្រាហ្មណ៍បានទៅកាន់នគរឥន្ទបត្តបុរី ក្នុងទីបំផុតនៃផ្លូវចម្ងាយ ១២០ យោជន៍អំពីទីក្រុងតក្កសីលា កាលនឹងសំដែងធម៌ ដល់ព្រះរាជាទ្រង់ព្រះនាមមហា-សុតសោម បានពោលគាថានេះ ក្នុងមហាសុតសោមជាតកថា **"បពិត្រព្រះមហារាជ ទ្រង់ព្រះនាមសុតសោម ការជួបប្រទះដោយសប្បុរសទាំងឡាយ សូម្បីអស់វារៈតែម្តង ការជួបប្រទះនោះរមែងថែរក្សានូវបុគ្គលនោះបាន ការជួបប្រទះដោយអសប្បុ-រសទាំងឡាយ អស់វារៈច្រើនដង រមែងថែរក្សានូវបុគ្គលនោះមិនបានឡើយ"** ។

បណ្តាបទទាំងនោះបទថា **"សកិទេវ"** ប្រែថា អស់វារៈមួយដងប៉ុណ្ណោះ ។ បទថា **"សព្ភិ"** ប្រែថាដោយសប្បុរសទាំង

ឡាយ ។ ប្រើនបទថា "**សា នំ សង្គតិ**" មានសេចក្ដីថា ការ
សមាគមដោយសប្បុរសទាំងឡាយនោះ សូម្បីប្រព្រឹត្តទៅអស់
រារៈតែម្ដង រមែងឃុំគ្រងគឺថែរក្សានូវបុគ្គលនោះបាន ។ បាទ-
គាថា ថា **នាសត្តិ ពហុ សង្គមោ** មានសេចក្ដីថា ចំណែកការ
សមាគម គឺការនៅអាស្រ័យក្នុងទីស្ថានជាមួយគ្នា ដោយពួក
អសប្បុរសទាំងឡាយដែលបុគ្គលបានធ្វើហើយ សូម្បីអស់កាល
ដ៏យូរ ក៏រមែងឃុំគ្រង (បុគ្គលនោះ)មិនបានឡើយ អធិប្បាយ
ថា "មិនមែនជាការស្ថិតស្ថេរបានឡើយ" ។

ហេតុនោះ បុគ្គលគួរសេពគប់តែពួកបណ្ឌិតប៉ុណ្ណោះ
មិនគួរសេពគប់ពួកជនពាលឡើយ ។ មិនមែនតែមិនគួរសេព
គប់នូវពួកជនពាល គួរសេពគប់តែពួកបណ្ឌិត តែម្យ៉ាងប៉ុណ្ណោះ
ទេ តាមពិតហើយ បុគ្គលនឹងធ្វើបុណ្យអ្វីមួយក៏គួរ តែធ្វើសេចក្ដី
ប្រាថ្នាផងដែរថា "ដោយបុណ្យនេះ ខ្ញុំគប្បីជួបប្រទះតែពួកបណ្ឌិត
ទាំងឡាយប៉ុណ្ណោះ មិនគួរជួបប្រទះនូវពួកជនពាលឡើយ" ដូច្នេះ
ប្រៀបដូចជាអកិត្តិបណ្ឌិតយ៉ាងដូច្នោះឯង ។

# អកិត្តិបណ្ឌិតមិនចង់ជួបប្រទះជនពាល

បានស្តាប់មកថា អកិត្តិបណ្ឌិតនោះ កើតជាបុត្ររបស់ព្រាហ្មណ៍មហាសាល អ្នកមានទ្រព្យសម្បត្តិដល់ទៅ ៨០កោដិ ក្នុងទីក្រុងពារាណសី កាលបើមាតា និងបិតាបានស្លាប់ចោលទៅហើយ ក៏បានលះបង់ទ្រព្យសម្បត្តិទាំងអស់ ហើយក៏បួសជាតាបសឥសី បានមកដល់ទីក្រុងឈ្មោះកបិឡរដ្ឋ ដោយលំដាប់ ហើយក៏អាស្រ័យនៅក្នុងឧទ្យាន ក្បែរទីក្រុងកបិឡរដ្ឋញ៉ាំងឈាន និងអភិញ្ញាឱ្យកើតឡើងហើយ ក៏ហោះមកតាមអាកាស ចុះត្រង់កោះដើមដង្ហៀបក្តាមនៅក្បែរកោះដើមខ្ទឹង អាស្រ័យនូវដើមដង្ហៀបក្តាមដ៏ធំហើយ ក៏បានសាងបណ្ណសាលានៅក្នុងកោះដើមខ្ទឹងនោះហើយ ។ តាបសឈ្មោះអកិត្តិបណ្ឌិតនោះ មិនបាននិមន្តទៅក្នុងទីណាមួយឡើយ ព្រោះជាអ្នកមានសេចក្តីប្រាថ្នាតិច ក្នុងពេលដែលដើមឈើនោះមានផ្លែ ក៏ឆាន់ផ្លែក្នុងពេលមានសន្លឹក ក៏ឆាន់សន្លឹកដែលស្ងោរស្រុសដោយទឹកក្តៅ ។ អាសនៈរបស់ស្តេចសក្កទេវរាជបានក្តៅហើយ ព្រោះតេជៈនៃសីលរបស់តាបសនោះ ។ ស្តេចសក្កទេវរាជ ទ្រង់ជ្រាបហេតុនោះហើយ ទ្រង់បានផ្លាស់ភេទជា

ព្រាហ្មណ៍ ទ្រង់ស្ដេចយាងទៅប្រថាប់ឈរ ធ្វើទំនងដូចជាអ្នកសុំនៅក្នុងកោះនោះ ។ តាបសស្រុសស្លឹកជន្ទៀបក្ដាមហើយ ដាក់ចុះ( អំពីជើងក្រាន )ហើយបានគង់នៅត្រង់មាត់ទ្វារបណ្ណសាលា ដោយតាំងចិត្តថា "អាត្មាអញនឹងឆាន់ស្លឹកជន្ទៀបក្ដាមដែលត្រជាក់ហើយ" ដូច្នេះហើយ បានឃើញស្ដេចសក្កទេវរាជនោះក៏សោមនស្ស បានដាក់ស្លឹកជន្ទៀបក្ដាមទៅក្នុងភាជនៈភិក្ខារបស់ស្ដេចសក្កទេវរាជនោះ មិនបានទុកឱ្យនៅសល់សំរាប់ខ្លួនសោះឡើយ មិនបានស្រុសម្ដងទៀត ហើយញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយសេចក្ដីសុខដែលកើតអំពីបីតិតែប៉ុណ្ណោះឯង ។ ចំណែកស្ដេចសក្កទេវរាជ ទ្រង់បានទទួលយកស្លឹកជន្ទៀបក្ដាមនោះហើយស្ដេចយាងទៅបន្តិច ទ្រង់បានបាត់ទៅហើយ ។ ស្ដេចសក្កទេវរាជទ្រង់ស្ដេចយាងទៅដោយឧបាយនោះឯង រហូត ៣ ថ្ងៃ ។ ចំណែកតាបស ក៏បានថ្វាយអាហារទាំងអស់ ដល់ស្ដេចសក្កទេវរាជនោះ រហូតទាំង៣ ថ្ងៃ ខ្លួនឯងក៏បានអត់អាហារហើយ ។ ក្រោយមកក្នុងថ្ងៃទី៣ ស្ដេចសក្កទេវរាជទ្រង់ជ្រះថ្លាហើយ ក៏ទ្រង់បានប្រទានពរដល់តាបសនោះ ។

តាបសនោះកាលនឹងទទួលនូវពរបានពោលគាថានេះ ក្នុងអកិត្តិជាតក ក្នុងតេរសនិបាតថា ៖

**“អាត្មាសូមកុំឱ្យជួបប្រទះនឹងមនុស្សពាល” សូមកុំឱ្យឮដំណឹងមនុស្សពាល សូមកុំឱ្យនៅរួមនឹងមនុស្សពាល សូមកុំឱ្យបានធ្វើ ទាំងកុំឱ្យពេញចិត្តនឹងការចរចាទៅមកនឹងមនុស្សពាល”** ។

បណ្តាបទទាំងនោះបទថា **“ន សុណេ”** មានសេចក្តីថា អាត្មាមិនគប្បីបានឮ ដោយត្រចៀកទាំងសងខាងនេះថា “ជនពាលរស់នៅក្នុងទីឈ្មោះនោះ” ដូច្នេះឡើយ ។

ស្តេចសក្កទេវរាជ ទ្រង់ព្រះសណ្តាប់នូវពាក្យនោះហើយ កាលនឹងទ្រង់ត្រាស់សួរហេតុ ក្នុងការមិនចង់ជួបប្រទះនូវមនុស្សពាលនោះ ទ្រង់បានត្រាស់គាថានេះថា ៖

**“បពិត្រកស្សបៈ ជនពាលបានធ្វើអ្វីដល់លោក ? សូមលោកមេត្តាប្រាប់ហេតុ, បពិត្រកស្សបៈ ព្រោះហេតុអ្វី ? បានជាលោកមិនប្រាថ្នាចង់ជួបនូវមនុស្សពាល”** ។

បណ្តាបទទាំងនោះ ច្រើនបទថា **កឹនុ តេ អករំ** សេចក្តីថា មាតា ឬបិតារបស់លោកត្រូវជនពាលសម្លាប់ហើយឬ ? ឬក៏

បុគ្គលពាលបានធ្វើនូវសេចក្តីវិនាសអ្វីមួយដទៃទៀតដល់លោក ។

តាបសនោះ កាលទូលហេតុដល់ស្តេចសក្កៈនោះ បាន ពោលថា ៖

**"បុគ្គលពាល រមែងណែនាំនូវអំពើដែលមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ, ការណែនាំទៅរកអាក្រក់ជាការប្រសើរ ( របស់ជនពាលនោះ ), ជនពាលបើទុកជាគេនិយាយត្រូវក៏នៅតែខឹង, ជនពាលនោះមិនដឹងវិន័យទេ, ការមិនជួបប្រទះជនពាលនោះ ជាការប្រពៃ"** ។

បណ្តាបទទាំងនោះ ពីរបទថា **អនយំ នយតិ** មានសេចក្តីថា បុគ្គលពាលប្រកាន់យករបស់ដែលមិនមែនជាហេតុថា "ជាហេតុ" នឹកគិតតែអំពើដែលគ្មានប្រយោជន៍យ៉ាងដូច្នេះថា "អញនឹងធ្វើនូវកម្មទាំងឡាយ មានបាណាតិបាតជាដើម ហើយចិញ្ចឹមជីវិត"ដូច្នេះ ។ បទថា **អធុរាយំ** គឺមិនប្រកបក្នុងសទ្ធាធុរៈ សីលធុរៈ និងបញ្ញាធុរៈទាំងឡាយ ( បែរជា ) ប្រកបក្នុងរឿងដែលមិនគួរប្រកបវិញ ។ បទថា **ទុន្នយោ** មានសេចក្តីថាការណែនាំអាក្រក់តែប៉ុណ្ណោះជាការប្រសើររបស់បុគ្គលពាលនោះ ។ គឺបុគ្គលពាល

នោះ តែងប្រកាន់យ៉ាងនេះថា "ការសមាទានកម្មគឺការទ្រទ្រង់សីល ៥ យ៉ាង ហើយប្រព្រឹត្តទុំះឯងជាការប្រសើរ" ។ ម្យ៉ាងទៀត បុគ្គលពាលនោះ គឺបណ្ឌិតណែនាំបានដោយលំបាក គឺជាអ្នកដែលបុគ្គលណាមួយ មិនអាចដើម្បីនឹងណែនាំក្នុងខប្រតិបត្តិដែលមានប្រយោជន៍បានឡើយ ។ បទថា **សម្មា** គឺសូម្បីអ្នកដទៃនិយាយហើយដោយហេតុ គឺដោយការណ៍ ។ បទថា **វិនយំ** មានសេចក្តីថា ជនពាលមិនស្គាល់ច្បាស់នូវមារយាទ និងឧបាយគ្រឿងណែនាំថា "គប្បីឈានទៅខាងមុខយ៉ាងនេះ" ដូច្នេះជាដើម និងមិនព្រមទទួលយកនូវឱវាទឡើយ ។ បទថា **សាធុ តស្ស** មានសេចក្តីដោយហេតុទាំងឡាយនេះ ការមិនជួបប្រទះនូវជនពាលជាដាច់ខាត ជាការប្រសើរណាស់ ។

តាបសកាលនឹងទទួលពរដទៃថ្មីទៀត ទើបបានពោលថា ៖

**"អាត្មាភាព សូមឱ្យបានជួបប្រទះតែនឹងអ្នកប្រាជ្ញ សូមឱ្យបានស្តាប់ឮតែអ្នកប្រាជ្ញ សូមឱ្យបាននៅរួមគ្នា ជាមួយនឹងអ្នកបានប្រាជ្ញ សូមឱ្យបានធ្វើទាំងសូមបានចូលចិត្តនូវការចរចាប្រាស្រ័យគ្នាទៅវិញទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ"** ។

ស្តេចសក្កទេវរាជ ទ្រង់បានត្រាស់សួរថា ៖

"បពិត្រកស្សបៈ អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីខ្លះដល់លោក ? សូមលោកប្រាប់នូវហេតុ, បពិត្រកស្សបៈ ព្រោះហេតុអ្វី ? បានជាលោកចង់ជួបប្រទះតែនឹងអ្នកប្រាជ្ញ" ។

តាបសបានទូលហើយថា ៖

"អ្នកប្រាជ្ញ មិនណែនាំនូវហេតុដែលមិនគួរណែនាំ រមែងមិនប្រកបក្នុងកិច្ចដែលមិនមែនជាធុរៈ, ការណែនាំល្អ ជាការប្រសើររបស់អ្នកប្រាជ្ញនោះ, អ្នកប្រាជ្ញ បើទុកជាគេនិយាយត្រូវហើយ ក៏នៅតែមិនក្រោធខឹងដែរ, អ្នកប្រាជ្ញនោះរមែងដឹងច្បាស់នូវឧបាយគ្រឿងណែនាំ, ការសេពគប់រកជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃណាស់" ។

មែនពិត ការជួបប្រទះនឹងបណ្ឌិត ជាហេតុនាំឱ្យបាននូវសេចក្ដីសុខ, ឯការជួបប្រទះនឹងបុគ្គលពាល ជាហេតុនាំឱ្យបាននូវសេចក្ដីទុក្ខ, ដោយហេតុនោះ ក្នុងសក្កទេវិន្ទវត្ថុ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ទុកហើយថា ៖

"ការជួបប្រទះនូវព្រះអរិយទាំងឡាយ ជាការប្រពៃ ការនៅរួមជាមួយគ្នា ជាហេតុឱ្យបានសេចក្ដីសុខក្នុងទីសព្វ ៗកាល,

**បុគ្គលគប្បីជាអ្នកមានសេចក្តីសុខ អស់កាលជានិច្ចនិរន្តរ៍ ដោយពិតប្រាកដបាន ព្រោះការមិនជួបប្រទះនូវជនពាលទាំងឡាយ"** ។

បណ្តាបទទាំងនោះ បទថា **អរិយានំ** មានសេចក្តីថា ម្នាល ភិក្ខុទាំងឡាយ កិរិយាជួបប្រទះនូវសប្បុរសទាំងឡាយ គឺបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម ជាការប្រពៃគឺជាការប្រសើរបានដល់ជាការល្អ, អធិប្បាយថា ជាហេតុឱ្យបានសេចក្តីសុខ ។ មិនមែនតែបានជួបប្រទះ នូវព្រះអរិយទាំងឡាយនោះតែម្យ៉ាងប៉ុណ្ណោះទេ (ជាការប្រសើរ) តាមពិតហើយ សូម្បីភាវៈគឺការអង្គុយជាដើម ក្នុងទីជាមួយគ្នានឹងព្រះអរិយទាំងឡាយនោះ ក៏ជាការប្រសើរបានដូចគ្នាដែរ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា "ការនៅរួមជាមួយគ្នា" ដូច្នេះជាដើម ។

មែនពិត បុគ្គលអ្នកសេពគប់នូវជនពាលជាប្រក្រតី កាលធ្វើតាមពាក្យរបស់ជនពាល រមែងជួបប្រទះនូវសេចក្តីទុក្ខ ចំណែកបុគ្គលអ្នកសេពគប់នូវបណ្ឌិតជាប្រក្រតី កាលធ្វើតាមពាក្យរបស់បណ្ឌិត រមែងបាននូវសេចក្តីសុខ ។ នៅក្នុងសេចក្តីនេះមានរឿងភិក្ខុទេវទត្ត នឹងព្រះបាទអជាសត្រូវជាដើម ។

## វិនាស ឬចម្រើនព្រោះការសេពគប់

ព្រះមានព្រះភាគអង្គណា ជា**ព្រះសយម្ភូ** ឥតមានគ្រូអាចារ្យ បានត្រាស់ដឹងសច្ចធម៌ដោយព្រះអង្គឯង ក្នុងធម៌ទាំងឡាយដែលមិនធ្លាប់ឮក្នុងកាលមុនផង ទ្រង់ដល់នូវសព្វញ្ញុតញ្ញាណក្នុងសច្ចៈនោះផង ទ្រង់ដល់នូវភាវៈស្ទាត់ក្នុងពលៈទាំងឡាយផង ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **ពុទ្ធ** ។

ទ្រង់ព្រះនាមថា **ព្រះពុទ្ធ** ព្រោះហេតុព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំងឡាយ ។ ព្រះនាមថា **ព្រះពុទ្ធ** ព្រោះហេតុព្រះអង្គញ៉ាំងពួកសត្វឱ្យត្រាស់ដឹង ។ ព្រះអង្គនោះទ្រង់ជាព្រះសាស្តាទ្រង់ប្រៀនប្រដៅសព្វសត្វដោយប្រយោជន៍ក្នុងបច្ចុប្បន្ន ប្រយោជន៍លោកខាងមុខ និងប្រយោជន៍ដ៏ខ្ពង់ខ្ពស់គឺព្រះនិព្វានតាមសមគួរ ។ ទ្រង់ត្រាស់ដឹងចំពោះការសេពគប់មិត្តថា ៖

"បុគ្គគប់រកបុគ្គលណា ៗជាសប្បុរស ឬអសប្បុរស មានសីល ឬមិនមានសីល រមែងលុះក្នុងអំណាចនៃបុគ្គលនោះ ៗ ឯង ។ បុគ្គលធ្វើបុគ្គលបែបណាឱ្យជាមិត្តផង សេពគប់បុគ្គលបែបណាផង បុគ្គលនោះរមែងប្រាកដដូចជាបុគ្គលនោះដែរ ព្រោះ

ជាការទូទៅរួមគ្នា រមែងប្រឡាក់នូវកូនសិស្សដែលមិនទាន់ប្រឡាក់ កាលកូនសិស្សពាល់ត្រូវអាចារ្យដទៃ រមែងប្រឡាក់ដូចព្រួញលាបថ្នាំពិស ប្រឡាក់បំពង់ព្រួញ ដូច្នោះ អ្នកប្រាជ្ញមិនត្រូវមានសម្លាញ់ដ៏លាមក ព្រោះខ្លាចអំពីការប្រលាក់ ។ ជនណាខ្ចប់ត្រីស្អុយដោយស្បូវភ្លាំង ស្បូវភ្លាំងរបស់ជននោះទៅជាមានក្លិនស្អុយផ្សាយទៅយ៉ាងណាមិញ ការសេពគប់នឹងបុគ្គលពាលក៏យ៉ាងនោះដែរ ។ ជនណាខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ ស្លឹកឈើរបស់ជននោះទៅជាមានក្លិនប្រអូបផ្សាយទៅយ៉ាងណាមិញ ការសេពបុគ្គលជាអ្នកប្រាជ្ញក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បណ្ឌិតកាលដឹងច្បាស់នូវភាពនៃខ្លួនដែលប្រែប្រួលបាន ដូចជាកញ្ចក់នៃស្លឹកឈើ មិនត្រូវសេពគប់អសប្បុរសទេ ត្រូវសេពគប់តែពួកសប្បុរស ។ ព្រោះថា ពួកអសប្បុរសតែងនាំទៅកាន់នរក ពួកសប្បុរសតែងឱ្យដល់សុគតិ” ។

ក៏សម្បទា ៨ យ៉ាង ទ្រង់ត្រាស់នូវគោលធម៌សម្រាប់ប្រតិបត្តិដើម្បីសេចក្តីចម្រើន និងប្រយោជន៍ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងលោកខាងមុខផង ក្នុងនោះក៏មាននូវភាពជាអ្នកមានមិត្តល្អ( កល្យាណមិត្តា )មួយផងដែរ ។

"បុគ្គលអ្នកប្រើងប្រែងមានវិធានការមិនបណ្ដែតបណ្ដោយ ក្នុងការងារទាំងឡាយ តែងចិញ្ចឹមជីវិតស្មើ រក្សាទ្រព្យដែលខំនរក បានមកមានសទ្ធា បរិបូរណ៍ដោយសីល ឈ្លាសក្នុងសម្ដី លះបោលសេចក្ដីកំណាញ់ ជម្រះនូវផ្លូវសម្រាប់ទៅកាន់លោកខាងមុខ ឱ្យមានសួស្ដីជានិច្ច ធម៌ទាំង ៨ យ៉ាងនេះ នាំមកនូវសេចក្ដីសុខ ក្នុងលោកទាំងពីរ ដែលព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា **សច្ចៈ** ទ្រង់សម្ដែងហើយដល់កុលបុត្រអ្នកមាន សទ្ធានៅគ្រប់គ្រងផ្ទះ មួយទៀត ការបរិច្ចាគ និងបុណ្យដ៏សេសនេះ តែងចម្រើនដល់ពួកគ្រហស្ថដើម្បីសេចក្ដីចម្រើននិងប្រយោជន៍ក្នុងបច្ចុប្បន្នផងដើម្បីសេចក្ដីសុខក្នុងលោកខាងមុខផង យ៉ាងនេះ" ។

***ភាពជាអ្នកមានមិត្តល្អ នេះពិតជានាំឱ្យបានសម្រេចនូវប្រយោជន៍ទាំង៣ព្រោះបានការណែនាំល្អ*** ។ បើយើងសេពគប់ខុស គឺសេពគប់បាបមិត្ត បានការណែនាំខុស រមែងសាបសូន្យចាកប្រយោជន៍ ។ ដូចជាមហាធនសេដ្ឋីបុត្រ ៖

ក្នុងអដ្ឋកថាធម្មបទ មានសម្ដែងថា មហាសេដ្ឋីបុត្រ មានទ្រព្យ ១៦០ កោដិ តែមិនបានការណែនាំល្អពីមាតាបិតា សេពគប់

មិត្តមិនល្អ មិនប្រព្រឹត្តព្រហ្មចរិយធម៌ ។ មាតាបិតារបស់គេគិតថា "ក្នុងត្រកូលរបស់យើងមានគំនរភោគៈជាច្រើន យើងនឹងប្រគល់គំនរភោគៈនោះទុកក្នុងដៃបុត្ររបស់យើង ធ្វើឱ្យប្រើប្រាស់យ៉ាងសប្បាយ កិច្ចដោយការងារយ៉ាងដទៃមិនត្រូវមាន" ដូច្នេះហើយទើបឱ្យគេសិក្សាសិល្បៈត្រឹមតែការរាំ ច្រៀង និងប្រគំតែម្យ៉ាង ។ ខាងក្រោយមកមាតាបិតាក៏បានស្លាប់ទៅ ។ បុត្រសេដ្ឋីនោះ សេពគប់ជាមួយមិត្តមិនល្អដែលជាបាបមិត្ត បានញុំាងទ្រព្យសម្បត្តិ ១៦០ កោដិនោះរបស់ជនដទៃកាន់បំណែកអម្បែងត្រាច់ទៅសូមទាន ។

គ្រានោះ ព្រះសាស្តាទតព្រះនេត្រឃើញគេឈរទៀបទ្វាររោងឆាន់ ច្បាប់ទទួលភោជនដែលសល់អំពីភិក្ខុកម្លោះ និងសាមណេរឱ្យ ក្នុងថ្ងៃមួយទើបទ្រង់ធ្វើការញញឹមព្រះឱស្ឋ ។ លំដាប់នោះ ព្រះអានន្ទត្ថេរ ទូលសួរដល់ហេតុដែលទ្រង់ញញឹមចំពោះព្រះអង្គ ។ ព្រះសាស្តាក៏នឹងបានសម្រេចអរហត្ត, សម្បត្តិភរិយារបស់គេក៏នឹងតាំងនៅក្នុងអនាគាមិផល ។ បើមិនញុំាងទ្រព្យឱ្យអស់ទៅទេ នឹងប្រកបការងារក្នុងមជ្ឈិមវ័យនឹងបានជាសេដ្ឋីទី២ ចេញបួសនឹងបានជាអនាគាមី សម្បត្តិភរិយារបស់គេក៏នឹងតាំងនៅក្នុងសកទាគាមិផល ។ បើមិនញុំាងទ្រព្យឱ្យអស់ទៅទេ ប្រកប

កាផារក្នុងបច្ឆិមវ័យនឹងបានជាសេដ្ឋីទី ៣ សូម្បីចេញបួសក៏នឹងបាន ជាសកទាគាមី សូម្បីភិរិយារបស់គេក៏នឹងតាំងនៅក្នុងសោតាបត្តិ-ផល ។ តែឥឡូវនេះ បុត្រសេដ្ឋីនោះសាបសូន្យហើយចាកភោគៈ ជារបស់គ្រហស្ថ ទាំងសាបសូន្យហើយចាកសាមញ្ញផល ។ ក៏ឯគ្រាសាបសូន្យហើយ ទើបដូចជាសត្វក្រៀលក្នុងភក់ស្ងួត ដូច្នោះ ។

**ការសេពគប់ខុស ដូចជាស្តេចអជាសត្តុជាដើម បដិបត្តិខុសក្នុងបិតា ( គឺសម្លាប់បិតា ) ព្រោះតែសេពគប់ជាមួយភិក្ខុទេវទត្ត ដែលជាបាបមិត្ត ត្រូវសាបសូន្យចាកសាមញ្ញផល ។**

ក្នុងសាមញ្ញផលសូត្រ ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះ ជីករំលើងគុណធម៌របស់ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើព្រះរាជាអង្គនេះ មិនផ្តាច់បង់ព្រះជន្មាយុនៃព្រះបិតា ដែលជាព្រះធម្មរាជប្រកបដោយធម៌ទេ ធម្មចក្ខុគឺសោតាបត្តិមគ្គដែលប្រាសចាកចាកធូលី ប្រាសចាកមន្ទិលនឹងកើតដល់ព្រះរាជាអង្គនោះ លើអាសនៈនេះមិនខានឡើយ" ដូច្នេះ ។

# សេវិតព្វសូត្រ

នៅក្នុងបិដលលេខ ៤២, ទំព័រ ៥៦ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី [**បុគ្គលគួរសេពគប់និងមិនគួរសេពគប់**] មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ **បុគ្គល ៣ ពួកតើដូចម្តេច ។**

➲. ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេមិនសេពគប់ មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ១

➲. ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ១

➲. ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរធ្វើសក្ការ ធ្វើសេចក្តីគោរពហើយទើបសេពគប់ចូលទៅអង្គុយជិត ១ ។

✴. ម្នាលអង្គុយទាំងឡាយ **ចុះបុគ្គលដែលគេមិនគួរសេពមិនគួរគប់រក មិនគួរចូលទៅអង្គុយជិត តើដូចម្តេច ។** ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកសាបសូន្យចាក

សីល សមាធិ បញ្ញា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាព យ៉ាងនេះ គេមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត លើកលែងតែមានសេចក្ដីអាណិត ឬលើកលែងតែមានសេចក្ដី អនុគ្រោះចេញ ។

✳. ម្នាលភិក្ខុទាំងឡាយ **ចុះបុគ្គលដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត តើដូចម្ដេច** ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកស្មើគ្នាដោយសីល សមាធិ បញ្ញា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះគេគិតថា សីលកថារបស់ពួកសប្បុរស អ្នកមានសីលស្មើគ្នា នឹងមានដល់ពួកយើងផង សីលកថានោះនឹងមានសេចក្ដីចំរើនដល់ពួកយើងផង សីលកថានោះនឹងនាំឱ្យបានសុខដល់ពួកយើងផង សមាធិកថារបស់ពួកសប្បុរស អ្នកមានសមាធិស្មើគ្នានឹងមានដល់ពួកយើងផង សមាធិកថា នោះនឹងមានសេចក្ដីចំរើនដល់ពួកយើងផង សមាធិកថានោះនឹងនាំឱ្យបានសេចក្ដីសុខដល់ពួកយើងផង បញ្ញាកថារបស់ពួកសប្បុរស អ្នកមានបញ្ញាស្មើ

គ្មានទឹងមានដល់ពួកយើងផង បញ្ហាកថានោះនឹងមានសេចក្ដីបច្រើន ដល់ពួកយើងផង បញ្ហាកថានោះ នឹងនាំឱ្យបានសេចក្ដីសុខដល់ពួកយើងផង ។ ហេតុនោះបុគ្គលមានសភាពយ៉ាងនេះ ដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។

✻. ម្នាលភិក្ខុទាំងឡាយ **ចុះបុគ្គលដែលគេគួរធ្វើសក្ការៈធ្វើ សេចក្ដីគោរពហើយទើបសេពគប់ ចូលទៅអង្គុយជិតតើដូចម្ដេច ។** ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកលើសដោយសីល សមាធិ បញ្ញា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះដែលគួរធ្វើសក្ការៈធ្វើសេចក្ដីគោរព ហើយទើបសេពគប់ចូលទៅអង្គុយជិត ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះគតិថា អាត្មាអញនឹងបំពេញសីលក្ខន្ធដែលមិនទាន់បរិបូរណ៍ឱ្យបរិបូរណ៍ឡើងផងនឹងអនុគ្រោះសីលក្ខន្ធដែលបរិបូរណ៍ហើយក្នុងទីនោះ ៗដោយបញ្ញាផង នឹងបំពេញសមាធិក្ខន្ធដែលមិនទាន់បរិបូរណ៍ឱ្យបរិបូរណ៍ឡើងផង នឹងអនុគ្រោះសមាធិក្ខន្ធ ដែលបរិបូរណ៍ហើយក្នុងទីនោះ ៗដោយបញ្ញាផង នឹងបំពេញបញ្ញាខន្ធដែលបរិបូរណ៍ហើយក្នុងទីនោះ ៗនឹងអនុគ្រោះបញ្ញាខន្ធ ដែល

បរិបូរណ៍ហើយក្នុងទីនោះ ៗដោយបញ្ញាផង ។

៦. ហេតុនោះបុគ្គលមានសភាពយ៉ាងនេះ ដែលគេគួរធ្វើសក្ការៈ ធ្វើសេចក្ដីគោរព ហើយទើបសេពគប់ចូលទៅអង្គុយជិត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះរមែងមាននៅក្នុងលោក ។

និហីយតិ បុរិសោ និហីនសេវី

ន ច ហាយេថ កទាចិ តុល្យសេវី

សេដ្ឋមុបនមំ ឧទេតិ ខិប្បំ

តស្មា អត្តនោ ឧត្តរឹ ភជេថាតិ ។

បុរសអ្នកសេពគប់បុគ្គលថោកទាប រមែងសាបសូន្យ បើសេពគប់បុគ្គលស្មើគ្នា មិនគប្បីសាបសូន្យក្នុងកាលណាឡើយ បើបុរសចូលទៅគប់រកបុគ្គលដែលប្រសើរ ( ជាងខ្លួន ) រមែងចម្រើនឆាប់ ព្រោះហេតុនោះ បុរសគួរគប់នឹងបុគ្គលដែលប្រសើរលើសខ្លួន ( ទើបប្រសើរ ) ។

## អដ្ឋកថា

បទថា សេវិតព្វោ បានដល់ គប្បីចូលទៅរក ។

បទថា ភជិតព្វោ បានដល់ គប្បីស្និទ្ធស្នាល ។

បទថា បយិរុបាសិតព្វោ បានដល់ គប្បីចូលទៅរឿយ ៗ ដោយការអង្គុយក្នុងទីជិត ។

បទថា សក្កត្វា គរុកត្វា សេចក្ដីថា ធ្វើទាំងសក្ការៈ និងសេចក្ដីគោរព ។

ក្នុងបទថា ហីនោ ហោតិ សីលេន ជាដើម គប្បីជ្រាប សេចក្ដីទាប(ជាងគ្នា) ដោយប្រៀបធៀបគ្នា ។ អធិប្បាយថា ក្នុងបណ្ដាអ្នកទាំងនោះ អ្នករក្សាសីល ១០ មិនគួរសេពគប់ អ្នករក្សាសីល ៥ ។ អ្នករក្សាចាតុបារិសុទ្ធិសីល មិនគួរសេព គប់អ្នករក្សាសីល ១០ ។[១]

---

១. គឺមិនគួរប្រព្រឹត្តតាម មានន័យថា មិនគួរបោះបង់សីលខ្ពស់ មករក្សាសីលទាប, តែងអ្នករក្សាសីលទាបអាចមករក្សាសីលខ្ពស់បានជាការល្អ ។

បទថា អញ្ញត្រ អនុទយា អញ្ញត្រ អនុកម្បា សេចក្ដីថា ក្រៅពីការអាណិតនឹងអនុគ្រោះ ។ ព្រោះថា ដើម្បីប្រយោជន៍ខ្លួនហើយ ក៏មិនគួរសេពគប់អ្នកដូច្នេះ ។ តែនឹងចូលទៅរកគេដោយសេចក្ដីអាណិត ដោយអនុគ្រោះក៏គួរ ។

បទថា សីលសាមញ្ញគតានំ សតំ សេចក្ដីថា សូម្បីយើងទាំងឡាយ ដល់ភាពជាអ្នកមានសីលស្មើគ្នាមាន ។

បទថា សីលកថា ច នោ ភវិស្សតិ សេចក្ដីថា ការពោលប្រារព្ធសីលទុំះឯង នឹងមានដល់យើងទាំងឡាយ អ្នកមានសីលស្មើគ្នាយ៉ាងនេះ ។

បទថា សា ចនោ បវត្តនី ភវិស្សតិ សេចក្ដីថា កថារបស់ពួកយើងទាំងឡាយ ដែលនិយាយគ្នា សូម្បីអស់ថ្ងៃនោះ នឹងដំណើរទៅ គឺមិនដាច់រយៈ ។

បទថា សា ច នោ ផាសុ ភវិស្សតិ សេចក្ដីថា និងសីលកថាដែលដំណើរទៅរហូតអស់ថ្ងៃនោះ នឹងជាការនៅយ៉ាងសប្បាយរបស់យើងទាំងឡាយ ។ សូម្បីក្នុងសមាធិបញ្ញាកថា

ក៏មានន័យដូចគ្នានេះឯង ។

បទថា សីលក្ខន្ធំ បានដល់កងសីល ។ បុគ្គលវៀរធម៌ដែលមិនជាសប្បាយរបស់សីល គឺមិនជាឧបការៈដល់សីលសេពសោយ (ប្រព្រឹត្ត)ធម៌ដែលជាសប្បាយគឺធម៌ដែលជាឧបការៈដល់សីល ឈ្មោះថា អនុគ្រោះសីលក្ខន្ធ ដោយបញ្ញាក្នុងទីនោះ ៗ ក្នុងបទថា តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ នេះ ។ សូម្បីក្នុងសមាធិខន្ធ និងបញ្ញាខន្ធ ក៏មានន័យនេះដូចគ្នា ។

បទថា និហីយតិ សេចក្តីថា បុគ្គលកាលគប់រកអ្នកដែលអាក្រក់ជាងខ្លួន រមែងសាបសូន្យគឺរមែងវិនាសជាប់តគ្នារឿយ ៗ ទៅ ដូចទឹកដែលចាក់ទៅក្នុងឆ្នាំងតម្រងទឹកក្បុង ។ បទថា តុល្យសេវី បានដល់ សេពគប់អ្នកដែលស្មើនឹងខ្លួន ។

បទថា សេដ្ឋមុបនមំ បានដល់ បង្អោនចូលទៅរកអ្នកប្រសើរ ។

បទថា ឧទេតិ ខិប្បំ សេចក្តីថា រមែងចម្រើនរហ័សនោះឯង ។

បទថា តស្មា អត្តនោ ឧត្តរី ភជេថ សេចក្តីថា ព្រោះហេតុដែលបុគ្គលបង្អោនខ្លួនចូលទៅ រកបុគ្គលដែលប្រសើរ រមែងចម្រើនរហ័សដូច្នោះទើបគួរសេពគប់អ្នកដ៏ក្រៃលែងជាង គឺអ្នកដែលខ្ពស់ជាង បានដល់ អ្នកដែលប្រសើរជាងខ្លួន ។

➥. ការបានពួកមិត្តដ៏មាំមួន មានសភាពមិនបែកចិត្តគ្នា មានប្រាជ្ញាដ៏ស្អាត រមែងជួយទល់ទ្រ មិនឱ្យសាបសូន្យចាកសិរីដូចជាក្នុង **កុក្កុជាតក** ព្រះពោធិសត្វពោលថា ៖

***បន្ទង់ទាំងឡាយណាចំនួន ៣០ ខ្ចីមសុទ្ធ ឥតមានស្រោយ ឋិតនៅតំរៀបគ្នាជុំវិញ ( កំពូលនោះ ) បន្ទង់ទាំងឡាយនោះ ទល់ទ្រផង គាបដោយកម្លាំងផង ឋិតនៅស្មើភាគគ្នា ទើបមិនធ្លាក់របូតអំពីខាងលើមក ។ បណ្ឌិតបានពួកមិត្តដ៏មាំមួន មានសភាពមិនបែកចិត្តគ្នា មានប្រាជ្ញាដ៏ស្អាត ជួយទល់ទ្រហើយ រមែងមិនសាបសូន្យចាកសិរី ដូចជាកំពូល ( ជញ្ជ ) ដែលបន្ទង់នាំទៅនូវភារៈយ៉ាងនោះឯង ។***

ភាពនៃបុគ្គលដែលជានេយ្យបុគ្គល ( បុគ្គលត្រាស់ដឹងធម៌

ដែលគួរនឹងណែនាំបាន ) មិនអាចវៀរចាកកល្យាណមិត្តបានទេ កាលសាកសួរដោយឧទ្ទេស ធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា សេពគប់រក ចូលទៅអង្គុយជិតកល្យាណមិត្តទាំងឡាយ ទើបមានការត្រាស់ដឹងធម៌បានដោយលំដាប់ ។

ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់សម្តែងការអាស្រ័យគប់រកកល្យាណមិត្តទុកខាងដើម ហើយទ្រង់សម្តែងសេចក្តីព្យាយាមទុកកណ្តាល ហើយទើបត្រាស់ប្រាប់ព្រះអរហត្តក្នុងខាងក្រោយ ។

## កិរិយាប្រកាន់ខ្លួននាំឱ្យធ្លាក់នរក

ក្នុងអតីតកាល សូម្បីបងប្រុសរបស់និគ្រន្ថឈ្មោះ **ទីឃវិជៈ** មានអត្តភាពប្រមាណ ៦០ យោជន៍ ជាអ្នកដេកផ្ងារធ្លាក់ទៅឆេះក្នុងមហានរកអស់ ៤ ពុទ្ធន្តរ ព្រោះកម្មដែលខ្លួនបានប្រកាន់ខុស ។ ត្រកូលទាំង ៥០០ ដែលរាប់អាននូវទិដ្ឋិរបស់គេនោះ បានចូលដល់ភាពជាសំឡាញ់របស់អ្នកនោះឯង ហើយក៏ឆេះក្នុងមហានរក ( ដូចគ្នាដែរ ) ។

## ជនពាលតែងធ្វើខ្លួនមិនឱ្យមានសិរី

សូម្បីគ្រូទាំង ៦ មានបូរណកស្សបៈជាដើម ប្តេជ្ញាថា "ពួកយើងជាអ្នកបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណ" ដូច្នេះ រមែងធ្វើខ្លួនឱ្យវិនាសព្រោះអំពើដែលខ្លួនប្រកាន់ខុស ។ សូម្បីពួកជនអន្ធពាលទាំងឡាយដ៏ច្រើន ដែលចូលចិត្តនូវទិដ្ឋិរបស់គ្រូទាំង ៦ នាក់នោះ ក៏តែងដល់នូវសេចក្តីវិនាស ។ មែនពិត ជនពាលទាំងនោះ ជាអ្នកមានទុគ្គតិប្រព្រឹត្តទៅខាងមុខគ្រប់ ៗគ្នា ។

សួរថា "ក៏គ្រូទាំង ៦ នាក់នោះ បានឈ្មោះបូរណៈជាដើម តើព្រោះហេតុអ្វី ?" ។ ខ្ញុំនឹងឆ្លើយដូចតទៅ ៖

## ប្រវត្តិរបស់បូរណកស្សបៈ

បានឮថា ត្រកូលមួយមានខ្ញុំបម្រើ៩៩ នាក់ ខ្ញុំបម្រើម្នាក់បានកើតមកគម្រប់ ( ត្រូវជា ១០០ នាក់ល្មម ) ។ ព្រោះហេតុដូច្នោះពួកចៅហ្វាយនាយ ទើបបានដាក់ឈ្មោះ អ្នកបម្រើនោះថា "បូរណៈ" ។ ក៏ពួកចៅហ្វាយនាយ អ្នកដែលពោលថា "ការងារគឺនាយបូរណៈនោះធ្វើល្អហើយ ធ្វើមិនល្អ" ដូច្នេះ ឬក៏ការងារគឺនាយបូរណៈនោះមិនបានធ្វើហើយ ឬបានធ្វើហើយ" ដូច្នេះមិន

មានឡើយ ព្រោះនាយបូរណៈនោះ ជាអ្នកបម្រើដែលមានសិរីសួស្តី ។ នាយបូរណៈនោះ គិតថា "នឹងមានប្រយោជន៍អ្វីទៅដល់អាត្មាអញ ដោយការរស់នៅក្នុងទីនេះ" ដូច្នេះហើយក៏បានរត់គេចចេញទៅ ។

គ្រានោះ ពួកចោរក៏ដណ្ដើមយកសំពត់ទាំងឡាយ របស់នាយកបូរណៈនោះហើយ ។ នាយបូរណៈនោះ កាលមិនដឹងសូម្បីដើម្បីនឹងបិទបាំងដោយស្មៅនិងស្លឹកឈើ ក៏ជាអ្នកអាក្រាតចូលទៅកាន់ស្រុកមួយ ។ មនុស្សទាំងឡាយឃើញនាយបូរណៈនោះហើយក៏សម្គាល់ថា "បុរសនេះ ជាសមណៈ ជាព្រះអហរន្តជាអ្នកមានសេចក្ដីប្រាថ្នាតិច បុគ្គលដទៃទៀតដែលស្មើនឹងបុរសនេះ រមែងមិនមាន" ហើយទើបបានឱ្យហើយនូវវត្ថុទាំងឡាយមាននំ និងភត្តជាដើម ។ នាយកបូរណៈនោះគិតថា "នំ និងភត្តជាដើមនេះ បានកើតឡើងហើយ ព្រោះអញមិនស្លៀកសំពត់" ដូច្នេះតាំងអំពីពេលនោះមក សូម្បីបានសំពត់ហើយ ក៏មិនព្រមស្លៀកពាក់បានប្រកាន់យកនូវភេទ អាក្រាតនោះឯង ធ្វើជាបព្វជ្ជា ។ ពួកមនុស្ស ៥០០ នាក់ បានបួសហើយក្នុងសំណាក់របស់នាយ

បូរណៈនោះ ។ នាយកបូរណៈនោះឯង បានទូវឈ្មោះ ដោយអំណាចនៃអាក្រាតថា "កស្សបៈ" ។

## ប្រវត្តិរបស់មក្ខលិគោសាល

ចំណែកបុរសម្នាក់ ជាអ្នកបម្រើរបស់ចៅហ្វាយនាយម្នាក់ សែងក្រឡប្រេង ដើរទៅលើផែនដីដែលមានភក់ ត្រូវចៅហ្វាយនាយប្រាប់ថា "នែ អ្នកចូរកុំរអិលដួលឡើយ" ដូច្នេះក៏រអិលដួលដោយសេចក្ដីប្រមាទហើយ បានប្រារព្ធដើម្បីនឹងរត់គេចទៅ ព្រោះភ័យខ្លាចចៅហ្វាយនាយ ។ ចៅហ្វាយនាយបានរត់តាមទៅចាប់ជាយសំពត់ ។ បុរសនោះបានបោះចោលសំពត់ ជាអ្នកអាក្រាតបានរត់គេចទៅហើយ ។ ពាក្យដ៏សេសសល់ ក៏ដូចគ្នានឹងនាយបូរណៈកស្សបៈនុ៎ះឯង ។ នាយមក្ខលិនោះឯងគេហៅថា "គោសាល"ដូច្នេះក៏មាន ព្រោះជាអ្នកកើតក្នុងក្រោលគោ ។

## ប្រវត្តិរបស់និគ្រន្ថនាដបុត្រ

ចំណែកបុរសម្នាក់បានឈ្មោះថា "និគ្រន្ថ" ព្រោះជាអ្នកមានប្រក្រតីពោលយ៉ាងនេះថា "ពួកយើងមិនមានកិលេសដែលជា

គ្រឿងចងរឹត ពួកយើងជាអ្នកប្រាសចាកកិលេស ដែលជាគ្រឿងចងរឹត" ដូច្នេះទើងគេហៅថា "ទាជបុត្រ" ព្រោះគេជាកូនរបស់កូនរបាំ ។

ក៏កិលេសជាគ្រឿងចងរឹតឈ្មោះថា "កិលេសជាគ្រឿងចងរឹត"ក្នុងពាក្យនោះ ។ កិលេសមានរាគៈជាដើម របស់បុរសនោះ មានការជាប់ជំពាក់ក្នុងផ្ទះសម្បែងជាកិច្ច មានស្រែ ចំការ បុត្រនិងភរិយាជាដើម ជាអារម្មណ៍ ។

## ប្រវត្តិរបស់សញ្ជ័យវេលដ្ឋបុត្រ

ចំណែកបុរសម្នាក់គេហៅថា "សញ្ជ័យ" ដោយអំណាចនៃឈ្មោះ និងគេហៅថា "វេលដ្ឋបុត្រ" ព្រោះជាកូនរបស់ជាងត្បាញផែង ។

## ប្រវត្តិរបស់បកុធកច្ចាយនៈ

ចំណែកបុរសម្នាក់គេហៅថា "បកុធ" ដោយអំណាចនៃឈ្មោះនិងគេហៅថា"កច្ចាយនៈ"ដោយអំណាចគោត្រ ។ បុរសនេះជាអ្នកបដិសេធនូវត្រជាក់ ។ មែនពិត បុរសនោះបន្ទោរបង់

ឧច្ចារៈក្តី បរិភោគភោជនក្តី របស់មិនស្អាតឯណាមួយប្រឡាក់ក្តី ក៏មិនធ្វើកិច្ចជម្រះដោយទឹក ( ត្រជាក់ ) ដែរ, បានទឹកក្តៅ ឬ ទឹកបាយហើយទើបធ្វើ ឆ្លងទន្លេ ឬកណ្តាលផ្លូវក៏គិតថា "សីលរបស់អញធ្លុះធ្លាយហើយ" ដូច្នេះ ពូនដីខ្សាច់ជាពំនូកដោយអំណាចវត្តហើយ ក៏អធិដ្ឋានសីលស្រេចហើយ ទើបដើរទៅ ។ បុរសនេះប្រកាន់នូវលទ្ធិដែលមិនមានសិរីយ៉ាងដូច្នេះ ។

## ប្រវត្តិរបស់អជិតកេសកម្ពល

ឯបុរសម្នាក់គេហៅថា "អជិតៈ" ដោយអំណាចឈ្មោះនិងគេហៅថា "កេសកម្ពល" ព្រោះអត្ថថា "ទ្រទ្រង់នូវសំពត់កម្ពលដែលគេធ្វើហើយ ដោយសក់មនុស្សទាំងឡាយ" ដូច្នេះឯង ។ រឿងគ្រូទាំង៦ នាក់ មកក្នុងអដ្ឋកថាសាមញ្ញផលសូត្រ ។

ពួកជនពាលរមែងញ៉ាំងខ្លួន និងពួកជនអ្នកដែលធ្វើ តាមរបស់ខ្លួនឱ្យវិនាស ព្រោះកម្មដែលខ្លួនប្រកាន់យកហើយ មិនល្អដោយប្រការដូច្នេះឯង ។

## បណ្ឌិតធ្វើខ្លួននិងជនអ្នកធ្វើតាមខ្លួនឱ្យចម្រើន

ចំណែកបណ្ឌិតទាំងឡាយ រមែងមិនញ៉ាំងខ្លួន និងពួកជនអ្នកធ្វើតាមពាក្យរបស់ខ្លួនឱ្យវិនាសឡើយ រមែងឱ្យបានដល់(តែ) សេចក្ដីចម្រើន ព្រោះកម្មដែលខ្លួនបានប្រកាន់យកល្អហើយ ដូចជាអ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ។ មែនពិតព្រះពុទ្ធទ្រង់បានសម្រេចនូវព្រះសព្វញ្ញុតញ្ញាណ ដែលប្រដាប់ដោយគុណទាំងពួង ព្រោះកម្មដែលព្រះអង្គទ្រង់ប្រកាន់យកល្អហើយ ព្រះថេរៈទាំងឡាយ មានព្រះសារីបុត្តជាដើម ក៏ដូច្នោះដែរ បានសម្រេចគុណជាត មានសាវកបារមីញាណជាដើម ។ ក៏ទេវតានិងមនុស្សទាំងឡាយ ប្រមាណមិនបានអាស្រ័យព្រះពុទ្ធហើយ ក៏បានសម្រេចនូវអាសវក្ខយញ្ញាណ ហើយចូលទៅកាន់ព្រហ្មលោកត្រកូល ៨ ម៉ឺន ញ៉ាំងចិត្តឱ្យជ្រះថ្លា ក្នុងព្រះសារីបុត្តត្ថេរហើយ ឧបត្ថម្ភព្រះថេរៈដោយបច្ច័យ ៤ បានកើតហើយក្នុងឋានសួគ៌មួយទៀត ត្រកូលទាំង ៨ ម៉ឺន ញ៉ាំងចិត្តឱ្យជ្រះថ្លាហើយ ក្នុងព្រះមហាសាវកទាំងពួង មានព្រះមហាមោគ្គល្លាន និងព្រះមហាកស្សបៈជាដើម ក៏យ៉ាងដូច្នេះដែរ ។

# រឿងគ្រូសុនេត្រ

ក្នុងអតីតកាល ព្រះពោធិសត្វមានព្រះនាមថា សុនេត្រ ជាសាស្ដានៃគណៈ ធ្វើលទ្ធិដូចជាកំពង់ជាទីចុះកាន់សុគតិ ជាអ្នកប្រាកចាកសេចក្ដីតម្រេកក្នុងកាមទាំងឡាយ ដោយអំណាចនៃវិក្ខម្ភនបហានៈ ដែលព្រះសាស្ដា ទ្រង់ត្រាស់សំដៅយកក្នុងសត្តសុរិយសូត្រ ក្នុងសត្តកនិបាត អង្គុត្តរនិកាយថា "ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង គ្រូសុនេត្រ បានអប់រំចិត្តប្រកបដោយមេត្តារហូត ៧ ឆ្នាំ លុះបានអប់រំមេត្តាចិត្តអស់ ៧ ឆ្នាំហើយ ទើបមិនបានមកកាន់លោកនេះម្ដងទៀត រហូត ៧ សំវដ្ដវិវដ្ដកប្ប ម្នាលភិក្ខុទាំងឡាយ បានឮថា កាលបើលោកវិនាស គ្រូសុនេត្រនោះជាអ្នកចូលទៅដល់ព្រហ្មលោក ជាន់អាភស្សរៈកាលបើលោកចម្រើនរមែងចូលទៅកាន់វិមានព្រហ្មដែលស្ងាត់សូន្យ" ។

បណ្ដាបទទាំងនោះ ពីរបទថា **មេត្តចិត្តំ ភាវេត្វា** គឺអប់រំចិត្តដែលប្រកបព្រមដោយមេត្តា ដែលប្រកបដោយតិកឈាន និងចតុក្កឈាន ធ្វើឱ្យប្រណីតហើយ ។ ក៏ក្នុងបទទាំង ២ នេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សមាធិដោយស័ព្ទគឺចិត្តជាប្រធាន

ព្រោះហេតុនោះ ទើបមានសេចក្តីថា "លុះញ៉ាំងមេត្តាសមាធិ គឺមេត្តាព្រហ្មវិហារឱ្យកើតហើយនិងឱ្យចម្រើនឡើងហើយ" ។

ពីរបទថា **សត្ត សំវដ្ដវិវដ្ដកប្បេ** គឺអស់មហាកប្ប ៧ ។ សូម្បីកប្បដែលតាំងនៅក្នុងផ្លូវវិនាស និងកប្បដែលតាំងនៅក្នុងផ្លូវចម្រើន ក៏ព្រះមានព្រះភាគទ្រង់ប្រកាន់យកហើយ ដោយសំវដ្ដនិងវិវដ្ដស័ព្ទនុ៎ះឯង ។ ពីរបទថា **ឥមំ លោកំ** គឺកាន់តាមលោក ។ បទថា **សំវដ្ដមានេ សុទំ** មានសេចក្តី ថាកាលបើលោកវិនាស គឺត្រូវភ្លើងឆេះ បានដល់វិនាសសាបសូន្យ ។ ឯពាក្យថា **សុទំ** គ្រាន់តែនិបាត ។ បទថា **លោកេ** គឺកាលបើកប្ប ។ បទថា **អាភស្សរូបគោ** គឺគ្រូសុនេត្រចូលទៅកាន់ព្រហ្មលោកជាន់អាភស្សរៈនោះ ។ ព្រះមានព្រះភាគទ្រង់សំដែងកប្បដែលវិនាសព្រោះភ្លើងដោយពាក្យនោះ ។ បទថា **វិវដ្ដមានេ** គឺតាំងនៅបានដល់កើតមាន ។ បទថា **សុញ្ញំ** គឺឈ្មោះថា ស្ងាត់សូន្យ ព្រោះមិនមានសត្វណាមួយកើត ក្នុងព្រហ្មលោកនោះ អធិប្បាយថា "វិមានព្រហ្មពោលគឺ ភូមិនៃបឋមឈាន ឯណាកើតហើយខាងដើម គ្រូសុនេត្រ រមែងកើតឡើង គឺចូលដល់វិមានព្រហ្មដោយអំណាចចាប់បដិសន្ធិ" ។

បានឮថា ក្នុងកាលណោះ ព្រះពោធិសត្វសូម្បីជាអ្នកបាននូវសមាបត្តិ ៨ ជាប្រក្រតីយ៉ាងដូច្នោះក៏ដោយ ក៏នៅតែត្រួតមើលប្រយោជន៍សុខដល់សត្វ ។ និងការបំពេញបារមីរបស់ខ្លួនញ៉ាំងសេចក្តីត្រេកអរឱ្យកើតឡើងហើយ ក្នុងភូមិនៃឈានទាំងពីរយ៉ាងនោះឯង បានអន្ទោលទៅមកដោយអំណាចនៃមេត្តាព្រហ្មវិហារ ។ ក៏គ្រូសុនេត្រមានសាវ័កជាច្រើនរយនាក់ ។ ពួកសាវ័កទាំងអស់នោះ បានស្តាប់ទេសនារបស់ព្រះពោធិសត្វនោះហើយ ក៏ស្ថិតនៅក្នុងឱវាទនៃពោធិសត្វនោះ ហើយ ជាអ្នកមានសុគតិជាទីប្រព្រឹត្តទៅព្ធដ៏ខាងមុខ ។ ក៏បណ្តាសាវ័កទាំងនោះ សាវ័កពួកខ្លះបានទៅដល់ព្រហ្មលោក សាវ័កពួកខ្លះបានចូលដល់កាមាវចរសួគ៌ ៦ ជាន់ សាវ័កពួកខ្លះបានចូលទៅដល់ភាពជាខត្តិយមហាសាល ព្រាហ្មណ៍មហាសាល និងគហបតីមហាសាលដូច្នេះ ។

បណ្ឌិតទាំងឡាយរមែងមិនញ៉ាំងខ្លួន និងជនអ្នកធ្វើតាមពាក្យរបស់ខ្លួនឱ្យវិនាស ដោយប្រការដូច្នោះឯង ។

បុគ្គលណាមិនសេពគប់នូវពួកបុគ្គលពាល បុគ្គលនោះ

ឈ្មោះថា សេពគប់នូវពួកបណ្ឌិត បុគ្គលណាសេពគប់នូវពួកបណ្ឌិត បុគ្គលនោះឈ្មោះថា មិនសេពគប់នូវពួកបុគ្គលពាល ព្រោះហេតុណា ព្រោះហេតុនោះ ពាក្យទាំងពីរយ៉ាងនោះដោយសេចក្ដីក៏ជាពាក្យជាមួយគ្នានោះឯង ជាពាក្យជាមួយគ្នាក៏ពិតមែនហើយ ទោះបីជាដូច្នោះក៏ដោយ បណ្ដាពាក្យទាំងពីរយ៉ាងនោះ ពាក្យនេះថា "ការមិនសេពនូវជនពាលទាំងឡាយ ១" ដូច្នេះ សូម្បីក្នុងគាថាទី ១ នោះ គប្បីជ្រាបថា "ព្រះដ៏មានព្រះភាគត្រាស់ទុកហើយ ដើម្បីឱ្យដឹងច្បាស់ សូម្បីនូវសេចក្ដីដែលផ្ទុយពីគ្នានេះថា ការសេពគប់នូវបុគ្គលពាលទាំងឡាយ មិនមែនជាមង្គល" ដូច្នេះ ពាក្យនេះថា "ការសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១" ដូច្នេះគប្បីជ្រាបថា "ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុកហើយ ដើម្បីឱ្យដឹងច្បាស់ សូម្បីនូវសេចក្ដីដែលផ្ទុយពីគ្នានេះថា ការមិនសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ មិនមែនជាមង្គលដូច្នេះ ប្រៀបដូចជាបុរសដែលឆ្លាតក្នុងផ្លូវ កាលបង្ហាញប្រាប់នូវផ្លូវ បានបង្ហាញប្រាប់នូវផ្លូវដែលមិនគួរកាន់យកជាមុនសិន ហើយទើបបង្ហាញប្រាប់នូវផ្លូវ ដែលគួរកាន់យកជាខាងក្រោយយ៉ាងដូច្នេះថា "ចូរអ្នកលះបង់បោលនូវផ្លូវខាងឆ្វេង ចូរកាន់យកនូវផ្លូវខាងស្ដាំ"

ដូច្នេះ បុគ្គលណាលះបង់នូវផ្លូវខាងឆ្វេង បុគ្គលនោះ ឈ្មោះថា កាន់យកនូវផ្លូវខាងស្តាំបុគ្គលនោះឈ្មោះលះបង់ចោលនូវផ្លូវខាងឆ្វេង ព្រោះហេតុណា ព្រោះហេតុនោះ សូម្បីពាក្យទាំងពីរយ៉ាងនោះ ដោយសេចក្តីគឺជាពាក្យតែមួយនោះឯង ជាពាក្យតែមួយក៏ពិតមែន ហើយទោះបីជាយ៉ាងដូច្នោះក៏ដោយ បណ្តាពាក្យទាំងពីរយ៉ាងនោះ ពាក្យថា"ចូរអ្នកលះបង់ចោលនូវផ្លូវខាងឆ្វេង" ដូច្នេះ គប្បីជ្រាបថា "បុរសនោះពោលហើយ ដើម្បីឱ្យដឹងជាក់ច្បាស់ សូម្បីនូវសេចក្តីដែលផ្ទុយគ្នានេះថា ចូរអ្នកកុំលះបង់ចោលនូវផ្លូវខាងស្តាំ" ដូច្នេះ ពាក្យនេះថា "ចូរអ្នកកាន់យកនូវផ្លូវខាងស្តាំ" ដូច្នេះ គប្បីជ្រាបថា "បុរសនោះពោលហើយ ដើម្បីឱ្យដឹងជាក់ច្បាស់ សូម្បីនូវសេចក្តីដែលផ្ទុយគ្នានេះថា ចូរអ្នកកុំកាន់នូវផ្លូវខាងឆ្វេងឡើយយ៉ាងដូច្នោះឯង ក៏ព្រោះធ្វើអត្ថាធិប្បាយយ៉ាងដូច្នេះ ទើបព្រះដ៏មានព្រះភាគមិនទ្រង់ត្រាស់នូវការសេពគប់នូវបណ្ឌិតទុកជាមុន" (តែ)ទ្រង់ត្រាស់ការមិនសេពគប់នូវបុគ្គលពាលទុកជាមុន ក៏ប្រសិនបើព្រះអង្គគប្បីត្រាស់នូវការសេពគប់នូវបណ្ឌិតទុកជាមុន សេចក្តីនៃពាលសព្ទ គឺវេនេយ្យសត្វក៏រមែងមិនយល់ជាក់ច្បាស់បានឡើយ ព្រោះទ្រង់ត្រាស់នូវបណ្ឌិត ជាមុន

កាលបើអត្ថនៃពាលស័ព្ទនោះ គឺ វិនេយ្យសត្វមិនបានដឹងជាក់ច្បាស់ហើយ ចំណែកឯការសេពគប់នូវបុគ្គលពាលក៏វិនេយ្យសត្វរមែងមិនដឹងជាក់ច្បាស់ដូចគ្នាផងដែរ ។ ក៏ព្រោះព្រះដ៏មានព្រះភាគទ្រង់ ប្រាថ្នាដើម្បីឱ្យវិនេយ្យសត្វបានដឹងច្បាស់នូវការសេពគប់នូវបុគ្គលពាលជាមុន ដូច្នោះ ទើបព្រះអង្គទ្រង់ត្រាស់ ការមិនសេពគប់បុគ្គលពាលនោះឯងទុកជាមុន ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា "ការមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១" ដូច្នេះ ចំណែកការសេពគប់បុគ្គលពាល ក៏ឈ្មោះថា រមែងឱ្យវិនេយ្យសត្វដឹងជាក់ច្បាស់ផងដែរ ព្រោះព្រះដ៏មានព្រះភាគបៀបដូចជាបុរសដែលឆ្លាតក្នុងផ្លូវ ហេតុដូច្នោះ ព្រះអង្គទ្រង់ញ៉ាំងឱ្យវិនេយ្យសត្វដឹងច្បាស់នូវការសេពគបបុគ្គលពាល ពោលគឺការមិនសេពគប់បណ្ឌិតដែលមិនគួរកាន់យក ប្រៀបដូចជាផ្លូវខាងឆ្វេងជាមុនហើយ ទើបទ្រង់ញ៉ាំងឱ្យវិនេយ្យសត្វបានដឹងច្បាស់នូវការមិនសេពគប់នូវបុគ្គលពាល ពោលគឺការសេពគប់នូវបណ្ឌិតដែលគួរកាន់យក ប្រៀបដូចជាផ្លូវខាងស្តាំព្ធដ៏ខាងក្រោយ ។

## សេពគប់នូវបុគ្គលពាលមិនមែនជាមង្គល

មែនពិត សូម្បីការសេពគប់រកនូវបុគ្គលពាល ក៏ឈ្មោះថាមិនមែនជាមង្គល ព្រោះជាហេតុនៃសេចក្ដីវិនាស ព្រោះហេតុនោះទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់នៅក្នុង**បរាភវសូត្រ** បិដកលេខ ៥៤, ទំព័រ ៣៧ ថា ៖

អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ
អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។

បុគ្គលមានពួកអសប្បុរស ជាទីស្រឡាញ់ មិនធ្វើសេចក្ដីស្រឡាញ់ចំពោះពួកសប្បុរស ពេញចិត្តចំពោះធម៌របស់ពួកសប្បុរស នោះជាប្រធាននៃសេចក្ដីវិនាស ។

បណ្ដាបទទាំងឡាយនោះ បទថា អសន្តស្ស មានសេចក្ដីថា ពួកអសប្បុរស គឺមនុស្សមិនល្អទាំងឡាយ មានគ្រូទាំង ៦ នាក់ជាដើម រមែងជាទីស្រឡាញ់របស់បុគ្គលនោះ ។

បាទគាថា ថា សន្តេ ន កុរុតេ បិយំ មានសេចក្ដីថា បុគ្គលនោះរមែងមិនធ្វើនូវអសប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម ឱ្យជាទីស្រឡាញ់របស់ខ្លួនឡើយ ។

ក៏ក្នុងបាទគាថានេះ ព្រះមានព្រះភាគទ្រង់ធ្វើការខុសផ្សេងគ្នានៃវចនៈថា សន្តេ បិយំ ដោយអំណាចវេនេយ្យសត្វ ។

ទិដ្ឋិ ៦២ និងអកុសលកម្មបថ១០ ឈ្មោះថា **ធម៌របស់អសប្បុរស** បុគ្គលនោះរមែងចូលចិត្ត គឺស្រឡាញ់ បានដល់សេពគប់នូវធម៌របស់អសប្បុរសនោះ ។

បទថា តំ មានសេចក្តីថា កម្ម ៣ យ៉ាងគឺ ភាពជាអ្នកមានអសប្បុរសដែលជាទីស្រឡាញ់ ១ ភាពជាអ្នកមានសប្បុរសមិនជាទីស្រឡាញ់ ១ ការស្រឡាញ់ពេញចិត្តធម៌របស់អសប្បុរស ១ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាប្រធានរបស់បុគ្គលអ្នកវិនាស គឺជាហេតុនៃសេចក្តីវិនាសរបស់បុគ្គលអ្នកវិនាស គឺ អ្នកដែលកំពុងតែវិនាស មែនពិតបុគ្គលដែលប្រកបព្រមដោយកម្មទាំង ៣ ប្រការនោះ រមែងវិនាស គឺរមែងសាបសូន្យ បានដល់ រមែងមិនបាន សម្រេចនូវសេចក្តីចំរើនទាំងក្នុងលោកនេះ ទាំងក្នុងលោកខាងមុខដោយពិតប្រាកដ ព្រោះហេតុនោះ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ជាប្រធាននៃបុគ្គលវិនាសដូច្នេះឯង ។

## អានិសង្សការមិនសេពគប់បុគ្គលពាល

១- ធ្វើឱ្យមិនធ្លាក់ខ្លួនទៅកាន់ផ្លូវខុស

២- ធ្វើឱ្យអាចរក្សាសេចក្ដីល្អទុកបាន

៣- ធ្វើឱ្យអាចសាងសេចក្ដីល្អថ្មីបន្ថែមឡើងទៀតបាន

៤- ធ្វើឱ្យមិនត្រូវបុគ្គលពាលធ្វើបាប

៥- ធ្វើឱ្យមិនមានការតិះដៀល មិនមានការដាក់ទោស

៦- ធ្វើឱ្យមិនមានការសម្លឹងអាក្រក់ បានទទួលការទុកចិត្តអំពីមនុស្សទូទៅ

៧- ធ្វើឱ្យមានការចម្រើនទៅមុខជានិច្ច

៨- ធ្វើឱ្យមាននូវសេចក្ដីសុខទាំងខ្លួនឯង ទាំងនៅក្នុងក្រុមគ្រួសារ នឹងប្រទេសជាតិ

៩- ជាការកាត់មិនឱ្យមានពូជពាល រាតត្បាតទៅទៀត ព្រោះគ្មានមនុស្សគាំទ្រទំនុកបម្រុងជាដើម ។

៦. *វេលាណាបាបនៅមិនទាន់ឱ្យផល បុគ្គលពាលមានសេចក្ដីសម្គាល់បាបថា មានរសផ្អែមដូចទឹកឃ្មុំ តែបាបឱ្យផលកាលណា បុគ្គលពាលរមែងចូលដល់ទុក្ខកាលនោះ ។*

ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ

សង្សារវដ្តវែងឆ្ងាយ សម្រាប់បុគ្គលពាលទាំងឡាយដែលមិនដឹងនូវព្រះសទ្ធម្ម ។

សុករំ សាធុនា សាធុ សាធុ បាបេន ទុក្ករំ

បាបំ បាបេន សុករំ បាបមរិយេហិ ទុក្ករំ ។

- អំពើល្អមនុស្សល្អធ្វើបានដោយងាយ,
- អំពើល្អមនុស្សអាក្រក់ធ្វើបានដោយកម្រ,
- អំពីអាក្រក់មនុស្សអាក្រក់ធ្វើបានដោយងាយ,
- អំពើអាក្រក់ពួកព្រះអរិយបុគ្គលធ្វើបានដោយកម្រ ។

អសេវនា ច ពាលានំ ឯតម្មង្គលមុត្តមំ

**☝..កិរិយាមិនសេពគប់បុគ្គលពាលទាំងឡាយ**

**នេះជាមង្គលដ៏ឧត្តមៗ**

# មង្គលកថា មង្គលទី ១ ចប់

## គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

-គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស.២៥៥៧
-អដ្ឋកថាពន្យល់សេចក្តីនៃគម្ពីរព្រះត្រៃបិដក.ស.២៥២២
-មង្គលត្ថទីបនីភាគ ១ របស់ព្រះមហាឃិន នឿន ព.ស.២៥៣៨
-គម្ពីរឃ្លាំងបរិយត្តិភាគ ១-២ ព.ស. ២៥៥៧
-គម្ពីរធម្មាវលី របស់ភិក្ខុធម្មវរាចារ្យ
-មង្គលជីវិត របស់ព្រះភិក្ខុ វជិប្បញ្ញោ គូ សុភាព ព.ស.២៥៥៥
-មិត្តល្អ របស់ព្រះភិក្ខុ សុវណ្ណជោតោ ភួង សុវណ្ណ ព.ស.២៥៥៥
-សង្គាលកសូត្ររបស់ព្រះភិក្ខុវជិរប្បញ្ញោ សាន សុជា ព.ស.២៥៥២
-វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ព.ស. ២៥១១
-ព្រមទាំងឯកសាមួយចំនួនទៀត។

# ថ្ងៃល្អនៃជីវិត

*នៅក្នុងបិដកលេខ ៤១ ទំព័រ ៤៧៥ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ជាមួយនឹងភិក្ខុថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណាប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាព្រឹក វេលាថ្ងៃ វេលាល្ងាច សត្វទាំងនោះឈ្មោះថា មានវេលាព្រឹត្តដ៏ល្អ វេលាថ្ងៃដ៏ល្អ វេលាល្ងាចដ៏ល្អ។ សមដូចព្រះគាថាថា៖*

**សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ**
**សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ។**

*ថ្ងៃណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ថ្ងៃនោះឈ្មោះថា នក្ខត្តបឫក្សល្អ មង្គលល្អ ថ្ងៃភ្លឺស្វាងល្អ ថ្ងៃនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជាហើយ)ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះឈ្មោះថា ជាគ្រឿងបូជាល្អ។*